# អភិធម្មបិដក





៨៥

# ABHIDHAMMA PITAKA

# ព្រះ

# ត្រៃបិដកបាលី

# និង

# សេចក្តីប្រែជាភាសាខ្មែរ

# អភធម្មបិដក

# កថាវត្ថុ ទុតយភាគ

# ៨៥



ផ្សព្វផ្សាយដោយសម្តេចព្រះអភិសិរីសុគន្ធាមហាសង្ឃរាជាធិបតី បួរ គ្រី
សម្តេចព្រះមហាសង្ឃរាជនៃគណៈធម្មយុត្តិកនិកាយ
នៃព្រះរាជាណាចក្រកម្ពុជា

*ព. ស. ២៥៥៣*

# ABHIDHAMMAPIṬAKA

## KATHĀVATTHU

## DUTIYABHĀGA

# 85

សម្តេចព្រះអភិសិរីសុគន្ធាមហាសង្ឃរាជាធិបតី បួរ គ្រី
សម្តេចព្រះមហាសង្ឃរាជ នៃគណៈធម្មយុត្តិកនិកាយ នៃព្រះរាជាណាចក្រកម្ពុជា

# និយមវចនៈ

ព្រះត្រៃបិដកត្រូវបានបង្កើតឡើង ប្រមាណ៥០០ឆ្នាំប្លាយ ក្រោយអំពីការរំលត់ព្រះខន្ធចូលកាន់ ព្រះបរមនិព្វានរបស់សម្តេចព្រះសម្មាសម្ពុទ្ធព្រះបរមគ្រូជាអម្ចាស់នៃយើងគ្រប់គ្នា ។ គ្រប់ប្រទេស អ្នកកាន់ព្រះពុទ្ធសាសនា និងប្រទេសខ្លះមួយចំនួនមិនមែនអ្នកកាន់ព្រះពុទ្ធសាសនា គ្រប់អង្គការ ពុទ្ធិកសមាគម និងតាមបណ្ណាល័យជាតិធំ ៗ តែងតែបានទទួលយកមកតម្កល់ទុកធ្វើជាគ្រឹះ ដើម្បីធ្វើការស្រាវជ្រាវសិក្សាស្វែងយល់ តាមអ្វីដែលហៅថាព្រះពុទ្ធវាចា (ពុទ្ធធម៌) ។ កាលដើមឡើយគេនាំគ្នា កត់ត្រាលើស្លឹករឹត ព្រមទាំងសរសេរចារឹកលើផែនថ្ម និងលើផែនលោហៈក៏មាន លុះចំណេរតមក ក៏បាននាំគ្នាបោះពុម្ពលើក្រដាសចងក្រងជាសៀវភៅ (គម្ពីរ) រហូតបច្ចុប្បន្ននេះ បច្ចេកវិជ្ជាកាន់តែ ចម្រើនឡើង គេបានវាយបញ្ចូលក្នុងកុំព្យូទ័រ តែទោះបីជាបច្ចេកទេសម៉ាស៊ីនចម្រើនឡើងយ៉ាងណា ក៏នៅមិនអាចបោះបង់សៀវភៅចោលបានឡើយ ដូច្នេះហើយទើបយើងខ្ញុំបានខិតខំធ្វើឲ្យកើតមាន ឡើងនូវក្រុមអក្សរព្រះត្រៃបិដក ដើម្បីជួយធ្វើឲ្យអក្ខរៈខ្លះដែលរលុបមិនអាចអានច្បាស់បាន ឲ្យមាន ការច្បាស់តាមតួអក្ខរៈឡើងវិញ ។

ដោយសទ្ធាជ្រះថ្លាដ៏មុតមាំដែលមានចំពោះព្រះពុទ្ធសាសនា ហើយក៏ជាកាតព្វកិច្ចមួយដ៏ធំក្នុងតួនាទីជាពុទ្ធបរិស័ទ ដែលបានប្រគល់កាយថ្វាយជីវិត អ្នកធ្វើដំណើរតាមស្នាមព្រះបាទសម្តេចព្រះពុទ្ធអង្គ រួមកម្លាំងទ្រទ្រង់ បានធ្វើការលះបង់កម្លាំងកាយ វាចា ចិត្ត ទ្រព្យធនផ្ទាល់ ព្រមទាំងបបួលពុទ្ធបរិស័ទ ញាតិមិត្តជិតឆ្ងាយ ក្នុងនិងក្រៅប្រទេសធ្វើឡើង ដើម្បីជាពុទ្ធបូជា ធម្មបូជា សង្ឃបូជា ។

សូមសេចក្តីឧស្សាហ៍ក្នុងការជាកុសលនេះ សម្រេចប្រយោជន៍ជូនដល់ព្រះពុទ្ធសាសនាជូនដល់ពុទ្ធបរិស័ទ សូមបានប្រកបតែនឹងសេចក្តីសុខចម្រើនរុងរឿង ក្នុងលោកនេះផង និងលោកដទៃខាងមុខទៀតផង ជាភិយ្យោភាពតរៀងទៅ ។

វត្តបទុមជ. ថ្ងៃទី ០៨ ខែមិថុនា ឆ្នាំ ២០០៩

បួរ-គ្រី

VATT Botum Dhammavutt Sangkat Chatumuk Khan Daun Penh P.Penh

ទំព័រទទេ

# សេចក្តីណែនាំក្នុងការអាន

១) *ប្រសិនបើលោកអ្នកអាន បានឃើញពាក្យទាំងឡាយណា ដែលមានសញ្ញាលេខបូកនៅពីខាងក្រោម ហើយបន្ទាប់មកបានឃើញព្យញ្ជនៈមួយតួទៀតនៅខាងចុងពាក្យនោះ សូមមេត្តាកត់សម្គាល់ថា ព្យញ្ជនៈដែលនៅខាងចុងនោះ គឺជាជើងរបស់ព្យញ្ជនៈដែលមានសញ្ញាលេខបូកនៅពីខាងក្រោម ដោយកំហុសបច្ចេកទេសកុំព្យូទ័រ ។*

*ឧទាហរណ៍*

*-ពាក្យខ្មែរ:* **សម̟ល** *ក្នុងពាក្យនេះ ព្យញ្ជនៈ* **ល** *គឺជាជើងរបស់ព្យញ្ជនៈ* **ម** *ដូច្នេះពាក្យនេះគឺ* **សម្ល** *។*

*-ពាក្យបាលី:* **តស̟ស** *គឺ* **តស្ស** *។*

២) *ចំពោះពាក្យខ្មែរ យើងសម្រេចយកតាមវចនានុក្រមខ្មែរ របស់សម្តេចព្រះសង្ឃរាជជោតញ្ញាណោ* (**ជួន-ណាត**) *ជាគោល ។ ប៉ុន្តែបើពាក្យទាំងឡាយណា ដែលអាចសរសេរតាមបែបបុរាណក៏ត្រឹមត្រូវដែរនោះ យើងខ្ញុំសូមរក្សានូវពាក្យទាំងនោះទុកដដែល ។*

៣) *ចំពោះ* **សន្លឹកច្រាប់ពាក្យខុស-ត្រូវ** *ដែលមាននៅផ្នែកខាងចុងនៃព្រះត្រៃបិដកច្បាប់ដើម ក្រុមយើងខ្ញុំសូមមិនដាក់ទៀតទេ ព្រោះក្រុមការងារយើងបានកែតម្រូវតាមនោះរួចរាល់ហើយ ។*

# អភិធម្មបិដក

## កថាវត្ថុ ទុតិយភាគ

៨៤

ព. ស. ២៥០៩

# អភិធម្មបិដកេ

# កថាវត្ថុស្ស ទុតិយោ ភាគោ

## បរូបហារកថា

[១] អត្ថិ អរហតោ អសុចិសុក្កវិសដ្ឋីតិ ។ អាមន្តា ។ អត្ថិ អរហតោ រាគោ កាមរាគោ កាមរាគបរិយុដ្ឋានំ កាមរាគសញ្ញោជនំ កាមោឃោ កាមយោគោ កាមច្ឆន្ទនីវរណន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[២] នត្ថិ អរហតោ រាគោ កាមរាគោ កាមរាគបរិយុដ្ឋានំ កាមរាគសញ្ញោជនំ កាមោឃោ កាមយោគោ កាមច្ឆន្ទនីវរណន្តិ ។ អាមន្តា ។ ហញ្ចិ នត្ថិ អរហតោ រាគោ កាមរាគោ កាមរាគបរិយុដ្ឋានំ កាមរាគសញ្ញោជនំ កាមោឃោ កាមយោគោ កាមច្ឆន្ទនីវរណំ នោ វត រេ វត្តព្វេ អត្ថិ អរហតោ អសុចិសុក្កវិសដ្ឋីតិ ។

[៣] អត្ថិ បុថុជ្ជនស្ស អសុចិសុក្កវិសដ្ឋិ អត្ថិ តស្ស រាគោ កាមរាគោ កាមរាគបរិយុដ្ឋានំ កាមរាគសញ្ញោជនំ កាមោឃោ កាមយោគោ កាមច្ឆន្ទនីវរណន្តិ ។ អាមន្តា ។ អត្ថិ អរហតោ អសុចិសុក្កវិសដ្ឋិ អត្ថិ តស្ស រាគោ កាមរាគោ កាមរាគបរិយុដ្ឋានំ ។ បេ ។ កាមច្ឆន្ទនីវរណន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។

# អភិធម្មបិដក
# កថាវត្ថុ ទុតិយភាគ
# បរូបហារកថា

[១] (សកវាទីសួរថា) ការបញ្ចេញទឹកសុក្កៈ មិនស្អាត របស់ព្រះអរហន្ត មានដែរឬ ។ (បរវាទី ឆ្លើយថា) អើ ។ រាគៈ កាមរាគៈ បរិយុដ្ឋានៈ គឺ កាមរាគៈ សញ្ញោជនៈ គឺ កាមរាគៈ កាមោឃៈ កាមយោគៈ កាមច្ឆន្ទនីវរណៈ របស់ព្រះអរហន្ត មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[២] រាគៈ កាមរាគៈ បរិយុដ្ឋានៈ គឺ កាមរាគៈ សញ្ញោជនៈ គឺ កាមរាគៈ កាមោឃៈ កាមយោគៈ កាមច្ឆន្ទនីវរណៈ របស់ព្រះអរហន្ត មិនមានទេឬ ។ អើ ។ បើ រាគៈ កាមរាគៈ បរិយុដ្ឋានៈ គឺ កាមរាគៈ សញ្ញោជនៈ គឺ កាមរាគៈ កាមោឃៈ កាមយោគៈ កាមច្ឆន្ទនីវរណៈ របស់ព្រះអរហន្ត មិនមានទេ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា ការបញ្ចេញទឹកសុក្កៈ មិនស្អាត របស់ព្រះអរហន្ត មានទេ ។

[៣] ការបញ្ចេញទឹកសុក្កៈ មិនស្អាត របស់បុថុជ្ជន មាន រាគៈ កាមរាគៈ បរិយុដ្ឋានៈ គឺ កាមរាគៈ សញ្ញោជនៈ គឺ កាមរាគៈ កាមោឃៈ កាមយោគៈ កាមច្ឆន្ទនីវរណៈ របស់បុថុជ្ជននោះ មានដែរឬ ។ អើ ។ ការបញ្ចេញទឹកសុក្កៈ មិនស្អាត របស់ព្រះអរហន្ត មាន រាគៈ កាមរាគៈ បរិយុដ្ឋានៈ គឺ កាមរាគៈ ។ បេ ។ កាមច្ឆន្ទនីវរណៈ របស់ព្រះអរហន្តនោះ មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[៤] អត្ថិ អរហតោ អសុចិសុក្កវិសដ្ឋិ ឯត្ថិ តស្ស រាគោ កាមរាគោ កាមរាគបរិយុដ្ឋានំ ។ បេ ។ កាមច្ឆន្ទ-នីវរណន្តិ ។ អាមន្តា ។ អត្ថិ បុថុជ្ជនស្ស អសុចិសុក្កវិ-សដ្ឋិ ឯត្ថិ តស្ស រាគោ កាមរាគោ កាមរាគបរិយុដ្ឋា-នំ ។ បេ ។ កាមច្ឆន្ទនីវរណន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[៥] អត្ថិ អរហតោ អសុចិសុក្កវិសដ្ឋីតិ ។ អាមន្តា ។ កេនដ្ឋេនាតិ ។ ហន្ទ ហិ មារកាយិកា ទេវតា អរហតោ អសុចិសុក្កវិសដ្ឋឹ ឧបសំហរន្តីតិ ។

[៦] មារកាយិកា ទេវតា អរហតោ អសុចិសុក្ក-វិសដ្ឋឹ ឧបសំហរន្តីតិ ។ អាមន្តា ។ អត្ថិ មារកាយិកានំ ទេវតានំ អសុចិសុក្កវិសដ្ឋីតិ ។ ន ហេវំ វតព្វេ ។ បេ ។

[៧] ឯត្ថិ មារកាយិកានំ ទេវតានំ អសុចិសុក្ក-វិសដ្ឋីតិ ។ អាមន្តា ។ ហញ្ចិ ឯត្ថិ មារកាយិកានំ ទេវ-តានំ អសុចិសុក្កវិសដ្ឋិ នោ វត រេ វត្តព្វេ មារកាយិកា ទេវតា អរហតោ អសុចិសុក្កវិសដ្ឋឹ ឧបសំហរន្តីតិ ។

[៨] មារកាយិកា ទេវតា អរហតោ អសុចិសុក្ក-វិសដ្ឋឹ ឧបសំហរន្តីតិ ។ អាមន្តា ។ មារកាយិកា ទេវតា

[៤] ការបញ្ចេញទឹកសុក្កៈ មិនស្អាត របស់ព្រះអរហន្ត មាន រាគៈ កាមរាគៈ បរិយុដ្ឋានៈ គឺ កាមរាគៈ ។ បេ ។ កាមច្ឆន្ទនីវរណៈ របស់ព្រះអរហន្តនោះ មិនមានទេឬ ។ អើ ។ ការបញ្ចេញទឹកសុក្កៈ មិនស្អាត របស់បុថុជ្ជន មាន រាគៈ កាមរាគៈ បរិយុដ្ឋានៈ គឺ កាមរាគៈ ។ បេ ។ កាមច្ឆន្ទនីវរណៈ របស់បុថុជ្ជននោះ មិនមានទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[៥] ការបញ្ចេញទឹកសុក្កៈ មិនស្អាត របស់ព្រះអរហន្ត មានដែរឬ ។ អើ ។ (ការបញ្ចេញ ទឹកសុក្កៈ មិនស្អាត របស់ព្រះអរហន្ត) មានដោយអត្ថដូចម្តេច ។ ទំនងជាទេវតា ជាពួកនៃមារ នាំយកការបញ្ចេញទឹកសុក្កៈ មិនស្អាត របស់ព្រះអរហន្ត ។

[៦] ទេវតា ជាពួកនៃមារ នាំយកការបញ្ចេញទឹកសុក្កៈ មិនស្អាត របស់ព្រះអរហន្តឬ ។ អើ ។ ការបញ្ចេញទឹកសុក្កៈ មិនស្អាត របស់ទេវតាជាពួកនៃមារ មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[៧] ការបញ្ចេញទឹកសុក្កៈ មិនស្អាត របស់ទេវតា ជាពួកនៃមារ មិនមានទេឬ ។ អើ ។ បើការបញ្ចេញទឹកសុក្កៈ មិនស្អាត របស់ទេវតាជាពួកនៃមារ មិនមានទេ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរនិយាយថា ទេវតាជាពួកនៃមារ នាំយកការបញ្ចេញទឹកសុក្កៈ មិនស្អាត របស់ព្រះអរហន្តទេ ។

[៨] ទេវតា ជាពួកនៃមារ នាំយកការបញ្ចេញទឹកសុក្កៈ មិនស្អាត របស់ព្រះអរហន្តឬ ។ អើ ។ ទេវតា ជាពួកនៃមារ នាំយកការបញ្ចេញ

៣

បរូបហារកថា

អត្តនោ អសុចិសុក្កវិសដ្ឋឹ ឧបសំហរន្តិ អញ្ញសំ អសុចិសុក្កវិសដ្ឋឹ ឧបសំហរន្តិ តស្ស អសុចិសុក្កវិសដ្ឋឹ ឧបសំហរន្តីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[៩] មារកាយិកា ទេវតា ទេវ អត្តនោ ន អញ្ញសំ ន តស្ស អសុចិសុក្កវិសដ្ឋឹ ឧបសំហរន្តីតិ ។ អាមន្តា ។ ហញ្ចិ មារកាយិកា ទេវតា ទេវ អត្តនោ ន អញ្ញសំ ន តស្ស អសុចិសុក្កវិសដ្ឋឹ ឧបសំហរន្តិ នោ វត រេ វត្តព្វេ មារកាយិកា ទេវតា អរហតោ អសុចិសុក្កវិសដ្ឋឹ ឧបសំហរន្តីតិ ។

[១០] មារកាយិកា ទេវតា អរហតោ អសុចិសុក្កវិសដ្ឋឹ ឧបសំហរន្តីតិ ។ អាមន្តា ។ លោមកូបេហិ ឧបសំហរន្តីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[១១] មារកាយិកា ទេវតា អរហតោ អសុចិសុក្កវិសដ្ឋឹ ឧបសំហរន្តីតិ ។ អាមន្តា ។ កឹការណាតិ ។ ហន្ទ ហិ វិមតឹ គាហយិស្សាមាតិ ។ អត្ថិ អរហតោ វិមតីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[១២] អត្ថិ អរហតោ វិមតីតិ ។ អាមន្តា ។ អត្ថិ អរហតោ សត្ថរិ វិមតិ ធម្មេ វិមតិ សង្ឃេ វិមតិ

ទឹកសុក្កៈ មិនស្អាត របស់ខ្លួន នាំយកការបញ្ចេញទឹកសុក្កៈ មិនស្អាត របស់ពួកជនដទៃ នាំយកការបញ្ចេញទឹកសុក្កៈ មិនស្អាត របស់ព្រះអរហន្តនោះឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[៩] ទេវតា ជាពួកនៃមារ មិននាំយកការបញ្ចេញទឹកសុក្កៈ មិនស្អាត របស់ខ្លួន មិននាំយកទឹកសុក្កៈ របស់អ្នកដទៃ មិននាំយកទឹកសុក្កៈ របស់ព្រះអរហន្តនោះទេឬ ។ អើ ។ បើទេវតា ជាពួកនៃមារ មិននាំយកការបញ្ចេញទឹកសុក្កៈ មិនស្អាត របស់ខ្លួន មិននាំយកទឹកសុក្កៈ របស់ពួកជនដទៃ មិននាំយកទឹកសុក្កៈ របស់ព្រះអរហន្តនោះ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា ទេវតា ជាពួកនៃមារ នាំយកការបញ្ចេញទឹកសុក្កៈ មិនស្អាត របស់ព្រះអរហន្តទេ ។

[១០] ទេវតា ជាពួកនៃមារ នាំយកការបញ្ចេញទឹកសុក្កៈ មិនស្អាត របស់ព្រះអរហន្តឬ ។ អើ ។ ទេវតា ជាពួកនៃមារ នាំយកតាមរណ្តៅនៃរោមឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[១១] ទេវតា ជាពួកនៃមារ នាំយកការបញ្ចេញទឹកសុក្កៈ មិនស្អាត របស់ព្រះអរហន្តឬ ។ អើ ។ ព្រោះហេតុអ្វី ។ ព្រោះទេវតា (មានគំនិតថា) យើងនឹងញុំាំងអ្នកដទៃឲ្យកាន់យកមតិខុស ។ ព្រះអរហន្ត មានមតិខុសដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[១២] មតិខុស របស់ព្រះអរហន្ត មានដែរឬ ។ អើ ។ មតិខុស របស់ព្រះអរហន្ត ក្នុងព្រះសាស្តា មតិខុសក្នុងព្រះធម៌ មតិខុសក្នុងព្រះសង្ឃ

សិក្ខាយ វិមតិ បុព្វន្តេ វិមតិ អបរន្តេ វិមតិ បុព្វន្តាបរន្តេ វិមតិ ឥទប្បច្ចយតាបដិច្ចសមុប្បន្នេសុ ធម្មេសុ វិមតីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[១៣] នត្ថិ អរហតោ សត្ថរិ វិមតិ ធម្មេ វិមតិ សង្ឃេ វិមតិ សិក្ខាយ វិមតិ បុព្វន្តេ វិមតិ អបរន្តេ វិមតិ បុព្វន្តាបរន្តេ វិមតិ ឥទប្បច្ចយតាបដិច្ចសមុប្បន្នេសុ ធម្មេសុ វិមតីតិ ។ អាមន្តា ។ ហញ្ចិ នត្ថិ អរហតោ សត្ថរិ វិមតិ ។ បេ ។ ឥទប្បច្ចយតាបដិច្ចសមុប្បន្នេសុ ធម្មេសុ វិមតិ នោ វត រេ វត្តព្វេ អត្ថិ អរហតោ វិមតីតិ ។

[១៤] អត្ថិ បុថុជ្ជនស្ស វិមតិ អត្ថិ តស្ស សត្ថរិ វិមតិ ។ បេ ។ ឥទប្បច្ចយតាបដិច្ចសមុប្បន្នេសុ ធម្មេសុ វិមតីតិ ។ អាមន្តា ។ អត្ថិ អរហតោ វិមតិ អត្ថិ តស្ស សត្ថរិ វិមតិ ។ បេ ។ ឥទប្បច្ចយតាបដិច្ចសមុប្បន្នេសុ ធម្មេសុ វិមតីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

មតិខុសក្នុងសិក្ខា មតិខុសក្នុងចំណែកខាងដើម មតិខុសក្នុងចំណែកខាងចុង មតិខុសក្នុងចំណែកខាងដើមនិងខាងចុង មតិខុសក្នុងធម៌ដែលកើតឡើង ព្រោះអាស្រ័យហេតុ ព្រោះធម៌នេះជាបច្ច័យ មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[១៣] មតិខុស របស់ព្រះអរហន្ត មិនមានក្នុងព្រះសាស្តា មិនមានមតិខុសក្នុងព្រះធម៌ មិនមានមតិខុសក្នុងព្រះសង្ឃ មិនមានមតិខុសក្នុងសិក្ខា មិនមានមតិខុសក្នុងចំណែកខាងដើម មិនមានមតិខុសក្នុងចំ-ណែកខាងចុង មិនមានមតិខុសក្នុងចំណែកខាងដើមនិងខាងចុង មិនមានមតិខុសក្នុងព្រះធម៌ដែលកើតឡើង ព្រោះអាស្រ័យហេតុ ព្រោះធម៌នេះជាបច្ច័យទេឬ ។ អើ ។ បើមតិខុស របស់ព្រះអរហន្ត មិនមានក្នុងព្រះសាស្តា ។ បេ ។ មិនមានមតិខុសក្នុងព្រះធម៌ដែលកើតឡើង ព្រោះអាស្រ័យហេតុ ព្រោះធម៌នេះជាបច្ច័យ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា មតិខុស របស់ព្រះអរហន្ត មានទេ ។

[១៤] មតិខុស របស់បុថុជ្ជន មាន មតិខុស របស់បុថុជ្ជននោះក្នុងព្រះសាស្តា ។ បេ ។ មតិខុសក្នុងធម៌ដែលកើតឡើង ព្រោះអាស្រ័យហេតុ ព្រោះធម៌នេះជាបច្ច័យ មានដែរឬ ។ អើ ។ មតិខុស របស់ព្រះអរហន្ត មាន មតិខុស របស់ព្រះអរហន្តនោះ ក្នុងព្រះសាស្តា ។ បេ ។ មតិខុសក្នុងធម៌ដែលកើតឡើង ព្រោះអាស្រ័យហេតុ ព្រោះធម៌នេះជាបច្ច័យ មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

៤

បរូបហារកថា

[១៥] អត្ថិ អរហតោ វិមតិ ឯត្ថិ តស្ស សត្ថរិ វិមតិ ។ បេ ។ ឥទប្បច្ចយតាបដិច្ចសមុប្បន្នេសុ ធម្មេសុ វិមតីតិ ។ អាមន្តា ។ អត្ថិ បុថុជ្ជនស្ស វិមតិ ឯត្ថិ តស្ស សត្ថរិ វិមតិ ។ បេ ។ ឥទប្បច្ចយតាបដិច្ចសមុប្បន្នេសុ ធម្មេសុ វិមតីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[១៦] អត្ថិ អរហតោ អសុចិសុក្កវិសដ្ឋីតិ ។ អាមន្តា ។ អរហតោ អសុចិសុក្កវិសដ្ឋិ កិស្ស និស្សន្ទោតិ ។ អសិតបីតខាយិតសាយិតស្ស និស្សន្ទោតិ ។ អរហតោ អសុចិសុក្កវិសដ្ឋិ អសិតបីតខាយិតសាយិតស្ស និស្សន្ទោតិ ។ អាមន្តា ។ យេ កេចិ អសន្តិ បិវន្តិ ខាយន្តិ សាយន្តិ សព្វេសញ្ញេវ អត្ថិ អសុចិសុក្កវិសដ្ឋីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[១៧] យេ កេចិ អសន្តិ បិវន្តិ ខាទន្តិ សាយន្តិ សព្វេសញ្ញេវ អត្ថិ អសុចិសុក្កវិសដ្ឋីតិ ។ អាមន្តា ។ ទារកា អសន្តិ បិវន្តិ ខាទន្តិ សាយន្តិ អត្ថិ ទារកានំ អសុចិសុក្កវិសដ្ឋីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[១៥] មតិខុស របស់ព្រះអរហន្ត មាន មតិខុស របស់ព្រះអរហន្ត នោះ មិនមានក្នុងព្រះសាស្តា ។ បេ ។ មិនមានមតិខុសក្នុងធម៌ដែលកើតឡើង ព្រោះអាស្រ័យហេតុ ព្រោះធម៌នេះជាបច្ច័យឬ ។ អើ ។ មតិខុស របស់បុថុជ្ជន មាន មតិខុស របស់បុថុជ្ជននោះ មិនមានក្នុងព្រះសាស្តា ។ បេ ។ មិនមានមតិខុសក្នុងធម៌ដែលកើតឡើង ព្រោះអាស្រ័យហេតុ ព្រោះធម៌នេះជាបច្ច័យឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[១៦] ការបញ្ចេញទឹកសុក្កៈ មិនស្អាត របស់ព្រះអរហន្ត មាន ដែរឬ ។ អើ ។ ការបញ្ចេញទឹកសុក្កៈ មិនស្អាត របស់ព្រះអរហន្ត ជាអានិសង្ស នៃរបស់អ្វី ។ ការបញ្ចេញទឹកសុក្កៈ របស់ព្រះអរហន្ត ជាអានិសង្ស នៃបាយដែលស៊ី ទឹកដែលផឹក វត្ថុដែលទំពាស៊ី រស ដែលលិទ្ធភ្លក្ស ។ ការបញ្ចេញទឹកសុក្កៈ មិនស្អាត របស់ព្រះអរហន្ត ជាអានិសង្ស នៃបាយដែលស៊ី ទឹកដែលផឹក វត្ថុដែលទំពាស៊ី និងរស ដែលលិទ្ធភ្លក្សដែរឬ ។ អើ ។ ពួកជនណាមួយ ស៊ី ផឹក ទំពាស៊ី លិទ្ធភ្លក្ស ការបញ្ចេញទឹកសុក្កៈ មិនស្អាត របស់ជនទាំងអស់នោះ មាន ដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[១៧] ពួកជនណាមួយ ស៊ី ផឹក ទំពាស៊ី លិទ្ធភ្លក្ស ការបញ្ចេញទឹកសុក្កៈ មិនស្អាត របស់ជនទាំងអស់នោះ មានដែរឬ ។ អើ ។ ពួកទារក ស៊ី ផឹក ទំពាស៊ី លិទ្ធភ្លក្ស ការបញ្ចេញទឹកសុក្កៈ មិនស្អាត របស់ទារក មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[១៨] បណ្ឌកា អសន្តិ បិវន្តិ ខាទន្តិ សាយន្តិ អត្ថិ បណ្ឌកានំ អសុចិសុក្កវិសដ្ឋីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[១៩] ទេវា អសន្តិ បិវន្តិ ខាទន្តិ សាយន្តិ អត្ថិ ទេវតានំ អសុចិសុក្កវិសដ្ឋីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[២០] អរហតោ អសុចិសុក្កវិសដ្ឋិ អសិតបីតខាយិតសាយិតស្ស និស្សន្ទោតិ ។ អាមន្តា ។ អត្ថិ តស្ស អាសយោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[២១] អរហតោ ឧច្ចារបស្សាវោ អសិតបីតខាយិតសាយិតស្ស និស្សន្ទោ អត្ថិ តស្ស អាសយោតិ ។ អាមន្តា ។ អរហតោ អសុចិសុក្កវិសដ្ឋិ អសិតបីតខាយិតសាយិតស្ស និស្សន្ទោ អត្ថិ តស្ស អាសយោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[២២] អរហតោ អសុចិសុក្កវិសដ្ឋិ អសិតបីតខាយិតសាយិតស្ស និស្សន្ទោ នត្ថិ តស្ស អាសយោតិ ។ អាមន្តា ។ អរហតោ ឧច្ចារបស្សាវោ អសិតបីត-

[១៨] ពួកបណ្ឌកៈ (មនុស្សខ្ទើយ) ស៊ី ផឹក ទំពាស៊ី លិទ្ធភ្លក្ស ការបញ្ចេញទឹកសុក្កៈ មិនស្អាត របស់ពួកបណ្ឌកៈ មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[១៩] ពួកទេវតាស៊ី ផឹក ទំពាស៊ី លិទ្ធភ្លក្ស ការបញ្ចេញទឹកសុក្កៈមិនស្អាត របស់ពួកទេវតា មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[២០] ការបញ្ចេញទឹកសុក្កៈ មិនស្អាត របស់ព្រះអរហន្ត ជាអានិសង្ស នៃបាយដែលស៊ី ទឹកដែលផឹក វត្ថុដែលទំពាស៊ី រសដែលលិទ្ធភ្លក្សឬ ។ អើ ។ ទីនៅនៃទឹកសុក្កៈ របស់ព្រះអរហន្តនោះ មានដែរឬ ។ អ្នកមិនគួរនិយាយយ៉ាងនេះទេ ។ បេ ។

[២១] ឧច្ចារៈនិងបស្សាវៈរបស់ព្រះអរហន្ត ជាអានិសង្ស នៃបាយដែលស៊ី ទឹកដែលផឹក វត្ថុដែលទំពាស៊ី រសដែលលិទ្ធភ្លក្ស ទីនៅនៃទឹកសុក្កៈ របស់ព្រះអរហន្តនោះ មានដែរឬ ។ អើ ។ ការបញ្ចេញទឹកសុក្កៈ មិនស្អាត របស់ព្រះអរហន្ត ជាអានិសង្ស នៃបាយដែលស៊ី ទឹកដែលផឹក វត្ថុដែលទំពាស៊ី រសដែលលិទ្ធភ្លក្ស ទីនៅនៃទឹកសុក្កៈ របស់ព្រះអរហន្តនោះ មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[២២] ការបញ្ចេញទឹកសុក្កៈ មិនស្អាត របស់ព្រះអរហន្ត ជាអានិសង្ស នៃបាយដែលស៊ី ទឹកដែលផឹក វត្ថុដែលទំពាស៊ី រសដែលលិទ្ធភ្លក្ស ទីនៅនៃទឹកសុក្កៈ របស់ព្រះអរហន្តនោះ មិនមានទេឬ ។ អើ ។ ឧច្ចារៈនិងបស្សាវៈ របស់ព្រះអរហន្ត ជាអានិសង្ស នៃបាយដែលស៊ី ទឹកដែលផឹក

ខាយិតសាយិតស្ស និស្សគ្គោ នត្ថិ តស្ស អាសយោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[២៣] អត្ថិ អរហតោ អសុចិសុក្កវិសដ្ឋីតិ ។ អាមន្តា ។ អរហា មេថុនំ ធម្មំ បដិសេវេយ្យ មេថុនំ ធម្មំ ឧប្បាទេយ្យ បុត្តសម្ពាធសយនំ អជ្ឈាវសេយ្យ កាសិកចន្ទនំ បច្ចនុភវេយ្យ មាលាគន្ធវិលេបនំ ធារេយ្យ ជាតរូបរជតំ សាទិយេយ្យាតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[២៤] អត្ថិ បុថុជ្ជនស្ស អសុចិសុក្កវិសដ្ឋិ បុថុ-ជ្ជនោ មេថុនំ ធម្មំ បដិសេវេយ្យ មេថុនំ ធម្មំ ឧប្បាទេយ្យ ។ បេ ។ ជាតរូបរជតំ សាទិយេយ្យាតិ ។ អាមន្តា ។ អត្ថិ អរហតោ អសុចិសុក្កវិសដ្ឋិ អរហា មេថុនំ ធម្មំ បដិសេវេយ្យ មេថុនំ ធម្មំ ឧប្បាទេយ្យ ។ បេ ។ ជាតរូប-រជតំ សាទិយេយ្យាតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[២៥] អត្ថិ អរហតោ អសុចិសុក្កវិសដ្ឋិ ន ច អរហា មេថុនំ ធម្មំ បដិសេវេយ្យ មេថុនំ ធម្មំ ឧប្បា-ទេយ្យ ។ បេ ។ ជាតរូបរជតំ សាទិយេយ្យាតិ ។ អាមន្តា ។ អត្ថិ បុថុជ្ជនស្ស អសុចិសុក្កវិសដ្ឋិ ន ច បុថុជ្ជនោ មេថុនំ ធម្មំ បដិសេវេយ្យ មេថុនំ ធម្មំ ឧប្បាទេយ្យ បុត្តសម្ពាធសយនំ

វត្ថុដែលទំពាស៊ី រសដែលលិទ្ធភ្លក្ស ទីនៅនៃទឹកសុក្កៈ របស់ព្រះអរហន្ត នោះ មិនមានទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[២៣] ការបញ្ចេញទឹកសុក្កៈ មិនស្អាត របស់ព្រះអរហន្ត មានដែរឬ ។ អើ ។ ព្រះអរហន្ត គប្បីសេពមេថុនធម្ម គប្បីញុំាងមេថុនធម្មឲ្យកើតឡើង គប្បីនៅគ្រប់គ្រងនូវទីដេកដ៏ចង្អៀតដោយកូន គប្បីប្រដាប់នូវខ្លឹមចន្ទន៍ក្នុងដែនកាសិកៈ គប្បីទ្រទ្រង់ នូវកម្រងផ្កា គ្រឿងក្រអូប គ្រឿងលាប គប្បីត្រេកអរចំពោះមាសនិងប្រាក់ ដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[២៤] ការបញ្ចេញទឹកសុក្កៈ មិនស្អាត របស់បុថុជ្ជនមាន បុថុជ្ជនគប្បីសេពមេថុនធម្ម គប្បីញុំាងមេថុនធម្មឲ្យកើតឡើង ។ បេ ។ គប្បីត្រេកអរចំពោះមាសនិងប្រាក់ ដែរឬ ។ អើ ។ ការបញ្ចេញទឹកសុក្កៈ មិនស្អាត របស់ព្រះអរហន្ត មាន ព្រះអរហន្ត គប្បីសេពមេថុនធម្ម គប្បីញុំាងមេថុនធម្មឲ្យកើតឡើង ។ បេ ។ គប្បីត្រេកអរចំពោះមាសនិងប្រាក់ ដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[២៥] ការបញ្ចេញទឹកសុក្កៈ មិនស្អាត របស់ព្រះអរហន្ត មាន តែព្រះអរហន្ត មិនសេពមេថុនធម្ម មិនញុំាងមេថុនធម្មឲ្យកើតឡើងទេ ។ បេ ។ មិនត្រេកអរចំពោះមាសនិងប្រាក់ ទេឬ ។ អើ ។ ការបញ្ចេញទឹកសុក្កៈ មិនស្អាត របស់បុថុជ្ជន មាន តែបុថុជ្ជន មិនសេពមេថុនធម្ម មិនញុំាងមេថុនធម្មឲ្យកើតឡើង មិនគប្បីអាស្រ័យនូវទីដេកដ៏ចង្អៀតដោយកូន

អញ្ញាវសេយ្យ កាសិកាចន្ទនំ បច្ចនុភវេយ្យ មាលា-គន្ធវិលេបនំ ធារេយ្យ ជាតរូបរជតំ សាទិយេយ្យា-តិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[២៦] អត្ថិ អរហតោ អសុចិសុក្កវិសដ្ឋីតិ ។ អាមន្តា ។ នត្ថិ អរហតោ រាគោ បហីនោ ឧច្ឆិន្នមូលោ តាលាវត្ថុកតោ អនភាវង្កតោ អាយតឹ អនុប្បាទធម្មោ-តិ ។ អាមន្តា ។ ហញ្ចិ អរហតោ រាគោ បហីនោ ឧច្ឆិន្នមូលោ តាលាវត្ថុកតោ អនភាវង្កតោ អាយតឹ អនុប្បាទធម្មោ នោ វត រេ វត្តព្វេ អត្ថិ អរហតោ អសុចិសុក្កវិសដ្ឋីតិ ។

[២៧] អត្ថិ អរហតោ អសុចិសុក្កវិសដ្ឋីតិ ។ អាមន្តា ។ នត្ថិ អរហតោ ទោសោ បហីនោ ។ បេ ។ មោហោ បហីនោ មានោ បហីនោ ទិដ្ឋិ បហីនា វិចិកិច្ឆា បហីនា ថីនំ បហីនំ ឧទ្ធច្ចំ បហីនំ អហិរិកំ បហីនំ ។ បេ ។ អនោត្តប្បំ បហីនំ ឧច្ឆិន្នមូលំ តាលា-វត្ថុកតំ អនភាវង្កតំ អាយតឹ អនុប្បាទធម្មន្តិ ។ អាមន្តា ។ ហញ្ចិ អរហតោ អនោត្តប្បំ បហីនំ ឧច្ឆិន្នមូលំ តាលាវត្ថុ-កតំ អនភាវង្កតំ អាយតឹ អនុប្បាទធម្មំ នោ វត រេ វត្តព្វេ

មិនប្រដាប់ នូវខ្លឹមចន្ទន៍ក្នុងដែនកាសិកៈ មិនទ្រទ្រង់ នូវកម្រងផ្កា គ្រឿងក្រអូប គ្រឿងលាប មិនត្រេកអរចំពោះមាសនិងប្រាក់ទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[២៦] ការបញ្ចេញទឹកសុក្កៈ មិនស្អាត របស់ព្រះអរហន្ត មានដែរឬ ។ អើ ។ ក្រែងព្រះអរហន្ត លះបង់រាគៈ ផ្តាច់ផ្តិលឫសគល់ ធ្វើឲ្យសល់តែទីនៅដូចជាទីនៅនៃដើមត្នោត ធ្វើមិនឲ្យមានបែបភាព ឲ្យជាធម៌លែងកើតតទៅទៀតឬ ។ អើ ។ បើព្រះអរហន្ត លះបង់រាគៈ ផ្តាច់ផ្តិលឫសគល់ ធ្វើឲ្យសល់តែទីនៅដូចជាទីនៅនៃដើមត្នោត ធ្វើមិនឲ្យមានបែបភាព ឲ្យជាធម៌លែងកើត តទៅទៀតហើយ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា ការបញ្ចេញទឹកសុក្កៈ មិនស្អាត របស់ព្រះអរហន្ត មានទេ ។

[២៧] ការបញ្ចេញទឹកសុក្កៈ មិនស្អាត របស់ព្រះអរហន្ត មានដែរឬ ។ អើ ។ ក្រែងព្រះអរហន្ត លះទោសៈ ។ បេ ។ លះមោហៈ លះមានះ លះទិដ្ឋិ លះវិចិកិច្ឆា លះថីនៈ លះឧទ្ធច្ចៈ លះអហិរិកៈ ។ បេ ។ លះអនោត្តប្បៈ ផ្តាច់ផ្តិលឫសគល់ ធ្វើឲ្យសល់តែទីនៅដូចជាទីនៅនៃដើមត្នោត ធ្វើមិនឲ្យមានបែបភាព ឲ្យជាធម៌លែងកើត តទៅទៀតឬ ។ អើ ។ បើព្រះអរហន្ត លះអនោត្តប្បៈ ផ្តាច់ផ្តិលឫសគល់ ធ្វើឲ្យសល់តែទីនៅដូចជាទីនៅនៃដើមត្នោត ធ្វើមិនឲ្យមានបែបភាព ឲ្យជាធម៌លែងកើត តទៅទៀតហើយ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា

៩

បរូបហារកថា

អត្ថិ អរហតោ អសុចិសុក្កវិសដ្ឋីតិ ។

[២៨] អត្ថិ អរហតោ អសុចិសុក្កវិសដ្ឋីតិ ។ អាមន្តា ។ ននុ អរហតោ រាគប្បហានាយ មគ្គោ ភាវិតោតិ ។ អាមន្តា ។ ហញ្ចិ អរហតោ រាគប្បហានាយ មគ្គោ ភាវិតោ នោ វត រេ វត្តព្វេ អត្ថិ អរហតោ អសុចិសុក្កវិសដ្ឋីតិ ។

[២៩] អត្ថិ អរហតោ អសុចិសុក្កវិសដ្ឋីតិ ។ អាមន្តា ។ ននុ អរហតោ រាគប្បហានាយ សតិប្បដ្ឋានា ភាវិតា ។ បេ ។ សម្មប្បធានា ភាវិតា ឥទ្ធិបាទា ភាវិតា ឥន្ទ្រិយា ភាវិតា ពលា ភាវិតា ។ បេ ។ ពោជ្ឈង្គា ភាវិតាតិ ។ អាមន្តា ។ ហញ្ចិ អរហតោ រាគប្បហានាយ ពោជ្ឈង្គា ភាវិតា នោ វត រេ វត្តព្វេ អត្ថិ អរហតោ អសុចិសុក្កវិសដ្ឋីតិ ។

[៣០] អត្ថិ អរហតោ អសុចិសុក្កវិសដ្ឋីតិ ។ អាមន្តា ។ ននុ អរហតោ ទោសប្បហានាយ ។ បេ ។ មោហប្បហានាយ ។ បេ ។ អនោត្តប្បប្បហានាយ មគ្គោ ភាវិតោ ។ បេ ។ ពោជ្ឈង្គា ភាវិតាតិ ។ អាមន្តា ។ ហញ្ចិ អរហតោ អនោត្តប្បប្បហានាយ ពោជ្ឈង្គា ភាវិតា

ការបញ្ចេញទឹកសុក្កៈ មិនស្អាត របស់ព្រះអរហន្ត មានទេ ។

[២៨] ការបញ្ចេញទឹកសុក្កៈ មិនស្អាត របស់ព្រះអរហន្ត មានដែរឬ ។ អើ ។ ក្រែងព្រះអរហន្ត ចម្រើនមគ្គ ដើម្បីលះរាគៈឬ ។ អើ ។ បើព្រះអរហន្ត ចម្រើនមគ្គ ដើម្បីលះរាគៈ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា ការបញ្ចេញទឹកសុក្កៈ មិនស្អាត របស់ព្រះអរហន្ត មានទេ ។

[២៩] ការបញ្ចេញទឹកសុក្កៈ មិនស្អាត របស់ព្រះអរហន្ត មានដែរឬ ។ អើ ។ ក្រែងព្រះអរហន្ត ចម្រើនសតិប្បដ្ឋាន ដើម្បីលះរាគៈ ។ បេ ។ ចម្រើនសម្មប្បធាន ចម្រើនឥទ្ធិបាទ ចម្រើនឥន្ទ្រិយ ចម្រើនពលៈ ។ បេ ។ ចម្រើនពោជ្ឈង្គៈ ដើម្បីលះរាគៈឬ ។ អើ ។ បើព្រះអរហន្ត ចម្រើនពោជ្ឈង្គៈ ដើម្បីលះរាគៈ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា ការបញ្ចេញទឹកសុក្កៈ មិនស្អាត របស់ព្រះអរហន្ត មានទេ ។

[៣០] ការបញ្ចេញទឹកសុក្កៈ មិនស្អាត របស់ព្រះអរហន្ត មានដែរឬ ។ អើ ។ ក្រែងព្រះអរហន្ត ចម្រើនមគ្គ ដើម្បីលះទោសៈ ។ បេ ។ ដើម្បីលះមោហៈ ។ បេ ។ ចម្រើនមគ្គ ដើម្បីលះអនោត្តប្បៈ ។ បេ ។ ចម្រើនពោជ្ឈង្គៈឬ ។ អើ ។ បើព្រះអរហន្ត ចម្រើនពោជ្ឈង្គៈ ដើម្បីលះអនោត្តប្បៈ

ជោ វត រេ វត្តព្វេ អត្ថិ អរហតោ អសុចិសុក្កវិសដ្ឋីតិ ។

[៣១] អត្ថិ អរហតោ អសុចិសុក្កវិសដ្ឋីតិ ។ អាមន្តា ។ ននុ អរហា វីតរាគោ វីតទោសោ វីតមោហោ កតករណីយោ ឱហិតភារោ អនុប្បត្តសទត្ថោ បរិក្ខីណភវសញ្ញោជនោ សម្មទញ្ញាវិមុត្តោ ឧក្ខិត្តបលិឃោ សង្កិណ្ណបរិខោ អព្ពុឡ្ហេសិកោ និរគ្គឡោ អរិយោ បន្នទ្ធជោ បន្នភារោ វិសញ្ញុត្តោ សុវិជិតវិជយោ ទុក្ខំ តស្ស បរិញ្ញាតំ សមុទយោ បហីនោ និរោធោ សច្ឆិកតោ មគ្គោ ភាវិតោ អភិញ្ញេយ្យំ អភិញ្ញាតំ បរិញ្ញេយ្យំ បរិញ្ញាតំ បហាតព្វំ បហីនំ ភាវេតព្វំ ភាវិតំ សច្ឆិកាតព្វំ សច្ឆិកតន្តិ ។ អាមន្តា ។ ហញ្ចិ អរហា វីតរាគោ វីតទោសោ វីតមោហោ កតករណីយោ ។ បេ ។ សច្ឆិកាតព្វំ សច្ឆិកតំ ជោ វត រេ វត្តព្វេ អត្ថិ អរហតោ អសុចិសុក្កវិសដ្ឋីតិ ។

[៣២] អត្ថិ អរហតោ អសុចិសុក្កវិសដ្ឋីតិ ។

ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា ការបញ្ចេញទឹកសុក្កៈ មិនស្អាត របស់ព្រះអរហន្ត មានទេ ។

[៣១] ការបញ្ចេញទឹកសុក្កៈ មិនស្អាត របស់ព្រះអរហន្ត មានឬ ។ អើ ។ ក្រែងព្រះអរហន្ត ប្រាសចាករាគៈ ប្រាសចាកទោសៈ ប្រាសចាកមោហៈ មានករណីយកិច្ចធ្វើហើយ មានភារៈដាក់ចុះហើយ មានប្រយោជន៍របស់ខ្លួនដល់ហើយ មានសញ្ញោជនៈក្នុងភពអស់ហើយ មានចិត្តផុតស្រឡះហើយ ព្រោះដឹងដោយប្រពៃ មានសន្ទះបើកឡើងហើយ មានគូទម្លាយហើយ មានសសរខឿនដកឡើងហើយ មិនមានគន្លឹះទ្វារ ជាអរិយបុគ្គល មានទង់ដាក់ចុះហើយ មានភារៈដាក់ចុះហើយ មិនប្រកបដោយកិលេស មានជម្នះឈ្នះល្អហើយ ព្រះអរហន្តនោះ កំណត់ដឹងនូវទុក្ខ លះនូវសមុទ័យ ធ្វើឲ្យជាក់ច្បាស់នូវនិរោធ ចម្រើនមគ្គ ត្រាស់ដឹងនូវអភិញ្ញេយ្យកិច្ច កំណត់ដឹងនូវបរិញ្ញេយ្យកិច្ច លះនូវបហាតព្វកិច្ច ចម្រើននូវភាវេតព្វកិច្ច ធ្វើឲ្យជាក់ច្បាស់នូវសច្ឆិកាតព្វ-កិច្ចឬ ។ អើ ។ បើព្រះអរហន្ត ប្រាសចាករាគៈ ប្រាសចាកទោសៈ ប្រាសចាកមោហៈ មានករណីយកិច្ចធ្វើហើយ ។ បេ ។ ធ្វើឲ្យជាក់ច្បាស់នូវសច្ឆិកាតព្វកិច្ច ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា ការបញ្ចេញទឹកសុក្កៈ មិនស្អាត របស់ព្រះអរហន្ត មានទេ ។

[៣២] ការបញ្ចេញទឹកសុក្កៈ មិនស្អាត របស់ព្រះអរហន្ត មាន

សុទ្ធកុសលស្ស អព្យាកតោ អត្ថិ អសុចិសុក្កាវិសដ្ឋិ បរិវារកុសលស្ស អព្យាកតោ ឥត្ថិ អសុចិសុក្កា-វិសដ្ឋីតិ ។ សុទ្ធកុសលស្ស អព្យាកតោ អត្ថិ អសុចិ-សុក្កាវិសដ្ឋីតិ ។ អាមន្តា ។ បរិវារកុសលស្ស អព្យា-កតោ អត្ថិ អសុចិសុក្កាវិសដ្ឋីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[៣៣] បរិវារកុសលស្ស អព្យាកតោ ឥត្ថិ អសុចិ-សុក្កាវិសដ្ឋីតិ ។ អាមន្តា ។ សុទ្ធកុសលស្ស អព្យាកតោ ឥត្ថិ អសុចិសុក្កាវិសដ្ឋីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[៣៤] សុទ្ធកុសលស្ស អព្យាកតោ រាគោ បហីនោ អត្ថិ តស្ស អសុចិសុក្កាវិសដ្ឋីតិ ។ អាមន្តា ។ បរិវារកុសលស្ស អព្យាកតោ រាគោ បហីនោ អត្ថិ តស្ស អសុចិសុក្កាវិសដ្ឋីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[៣៥] សុទ្ធកុសលស្ស អព្យាកតោ ទោសោ បហីនោ

ឬ ។ ការបញ្ចេញទឹកសុក្កៈ មិនស្អាត របស់ព្រះអរហន្ត អ្នកឈ្លាសក្នុងធម៌របស់ខ្លួន[១] មាន ការបញ្ចេញទឹកសុក្កៈ មិនស្អាត របស់ព្រះអរហន្ត អ្នកឈ្លាសក្នុងធម៌ដទៃ[២] មិនមានទេ ។ ការបញ្ចេញទឹកសុក្កៈ មិនស្អាត របស់ព្រះអរហន្ត អ្នកឈ្លាសក្នុងធម៌របស់ខ្លួន មានឬ ។ អើ ។ ការបញ្ចេញទឹកសុក្កៈ មិនស្អាត របស់ព្រះអរហន្ត អ្នកឈ្លាសក្នុងធម៌ដទៃ មានឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[៣៣] ការបញ្ចេញទឹកសុក្កៈ មិនស្អាត របស់ព្រះអរហន្ត អ្នកឈ្លាសក្នុងធម៌ដទៃ មិនមានទេឬ ។ អើ ។ ការបញ្ចេញទឹកសុក្កៈ មិនស្អាត របស់ព្រះអរហន្ត អ្នកឈ្លាសក្នុងធម៌របស់ខ្លួន មិនមានទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[៣៤] ព្រះអរហន្ត អ្នកឈ្លាសក្នុងធម៌របស់ខ្លួន លះរាគៈហើយ ការបញ្ចេញទឹកសុក្កៈ មិនស្អាត របស់ព្រះអរហន្តនោះ មានឬ ។ អើ ។ ព្រះអរហន្ត អ្នកឈ្លាសក្នុងធម៌ដទៃ លះរាគៈហើយ ការបញ្ចេញទឹកសុក្កៈ មិនស្អាត របស់ព្រះអរហន្តនោះ មានឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[៣៥] ព្រះអរហន្ត អ្នកឈ្លាសក្នុងធម៌របស់ខ្លួន លះទោសៈហើយ

១ ធម៌របស់ខ្លួន បានដល់អរហត្តធម៌ ។ ២ ធម៌ដទៃ បានដល់សមាបត្តិ ៨ ។ អដ្ឋកថា ។

មោហោ បហីនោ ។ បេ ។ អនោត្តប្បំ បហីនំ អត្ថិ តស្ស អសុចិសុក្កវិសដ្ឋីតិ ។ អាមន្តា ។ បរជនកុសលស្ស អរហតោ អនោត្តប្បំ បហីនំ អត្ថិ តស្ស អសុចិសុក្កវិសដ្ឋីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[៣៦] សជនកុសលស្ស អរហតោ រាគប្បហានាយ មគ្គោ ភាវិតោ ។ បេ ។ ពោជ្ឈង្គា ភាវិតា ។ បេ ។ ទោសប្បហានាយ ។ បេ ។ មោហប្បហានាយ ។ បេ ។ អនោត្តប្បប្បហានាយ មគ្គោ ភាវិតោ ។ បេ ។ ពោជ្ឈង្គា ភាវិតា អត្ថិ តស្ស អសុចិសុក្កវិសដ្ឋីតិ ។ អាមន្តា ។ បរជនកុសលស្ស អរហតោ អនោត្តប្បប្បហានាយ ពោជ្ឈង្គា ភាវិតា អត្ថិ តស្ស អសុចិសុក្កវិសដ្ឋីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[៣៧] សជនកុសលោ អរហា វីតរាគោ វីតទោសោ ។ បេ ។ សច្ឆិកាតព្វំ សច្ឆិកតំ អត្ថិ តស្ស អសុចិសុក្កវិសដ្ឋីតិ ។ អាមន្តា ។ បរជនកុសលោ អរហា វីតរាគោ វីតទោសោ ។ បេ ។ សច្ឆិកាតព្វំ សច្ឆិកតំ អត្ថិ តស្ស អសុចិសុក្កវិសដ្ឋីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

លះមោហៈហើយ ។ បេ ។ លះអនោត្តប្បៈហើយ ការបញ្ចេញទឹកសុក្កៈ មិនស្អាត របស់ព្រះអរហន្តនោះ មានឬ ។ អើ ។ ព្រះអរហន្ត អ្នកឈ្លាសក្នុងធម៌ដទៃ លះអនោត្តប្បៈហើយ ការបញ្ចេញទឹកសុក្កៈ មិនស្អាត របស់ព្រះអរហន្តនោះ មានឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[៣៦] ព្រះអរហន្ត អ្នកឈ្លាសក្នុងធម៌របស់ខ្លួន ចម្រើនមគ្គ ដើម្បីលះរាគៈ ។ បេ ។ ចម្រើនពោជ្ឈង្គៈ ។ បេ ។ ដើម្បីលះទោសៈ ។ បេ ។ ដើម្បីលះមោហៈ ។ បេ ។ ចម្រើនមគ្គ ដើម្បីលះអនោត្តប្បៈ ។ បេ ។ ចម្រើនពោជ្ឈង្គៈ ការបញ្ចេញទឹកសុក្កៈ មិនស្អាត របស់ព្រះអរហន្តនោះ មានដែរឬ ។ អើ ។ ព្រះអរហន្ត អ្នកឈ្លាសក្នុងធម៌ដទៃ ចម្រើនពោជ្ឈង្គៈ ដើម្បីលះអនោត្តប្បៈ ការបញ្ចេញទឹកសុក្កៈ មិនស្អាត របស់ព្រះអរហន្តនោះ មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[៣៧] ព្រះអរហន្ត អ្នកឈ្លាសក្នុងធម៌របស់ខ្លួន ប្រាសចាករាគៈ ប្រាសចាកទោសៈ ។ បេ ។ សច្ឆិកាតព្វកិច្ច លោកធ្វើឲ្យជាក់ច្បាស់ហើយ ការបញ្ចេញទឹកសុក្កៈ មិនស្អាត របស់ព្រះអរហន្តនោះ មានដែរឬ ។ អើ ។ ព្រះអរហន្ត អ្នកឈ្លាសក្នុងធម៌ដទៃ ប្រាសចាករាគៈ ប្រាសចាកទោសៈ ។ បេ ។ សច្ឆិកាតព្វកិច្ច លោកធ្វើឲ្យជាក់ច្បាស់ហើយ ការបញ្ចេញទឹកសុក្កៈ មិនស្អាត របស់ព្រះអរហន្តនោះ មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

១៣

បរូបបហារកថា

[៣៨] បរជម្មកុសលស្ស អរហតោ ភកោ បហីដោ ជត្តិ តស្ស អសុចិសុក្កាវិសជ្ជីតិ ។ អាមន្តា ។ សជម្ម-កុសលស្ស អរហតោ ភកោ បហីដោ ជត្តិ តស្ស អសុចិសុក្កាវិសជ្ជីតិ ។ ជ ហេវំ វត្តព្វេ ។ បេ ។

[៣៩] បរជម្មកុសលស្ស អរហតោ ដោសោ បហីដោ មោហោ បហីដោ ។ បេ ។ អជោត្តប្បំ បហីជំ ជត្តិ តស្ស អសុចិសុក្កាវិសជ្ជីតិ ។ អាមន្តា ។ សជម្ម-កុសលស្ស អរហតោ អជោត្តប្បំ បហីជំ ជត្តិ តស្ស អសុចិសុក្កាវិសជ្ជីតិ ។ ជ ហេវំ វត្តព្វេ ។ បេ ។

[៤០] បរជម្មកុសលស្ស អរហតោ ភគប្បហាជា-យ មគ្គោ ភាវិតោ ។ បេ ។ ពោជ្ឈង្គា ភាវិតា ។ បេ ។ ដោសប្បហាជាយ ។ បេ ។ មោហប្បហាជាយ ។ បេ ។ អជោត្តប្បប្បហាជាយ មគ្គោ ភាវិតោ ។ បេ ។ ពោជ្ឈង្គា ភាវិតា ជត្តិ តស្ស អសុចិសុក្កាវិសជ្ជីតិ ។ អាមន្តា ។ សជម្មកុសលស្ស អរហតោ អជោត្តប្បប្បហាជាយ ពោជ្ឈង្គា ភាវិតា ជត្តិ តស្ស អសុចិសុក្កាវិសជ្ជីតិ ។ ជ ហេវំ វត្តព្វេ ។ បេ ។

បរូបហារកថា

[៣៨] ព្រះអរហន្ត អ្នកឈ្លាសក្នុងធម៌ដទៃ បានលះរាគៈហើយ ការបញ្ចេញទឹកសុក្កៈ មិនស្អាត របស់ព្រះអរហន្ត មិនមានទេឬ ។ អើ ។ ព្រះអរហន្ត អ្នកឈ្លាសក្នុងធម៌របស់ខ្លួន បានលះរាគៈហើយ ការបញ្ចេញទឹកសុក្កៈ មិនស្អាត របស់ព្រះអរហន្តនោះ មិនមានទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[៣៩] ព្រះអរហន្ត អ្នកឈ្លាសក្នុងធម៌ដទៃ បានលះទោសៈហើយ លះមោហៈហើយ ។ បេ ។ លះអនោត្តប្បៈហើយ ការបញ្ចេញទឹកសុក្កៈមិនស្អាត របស់ព្រះអរហន្តនោះ មិនមានទេឬ ។ អើ ។ ព្រះអរហន្ត អ្នកឈ្លាសក្នុងធម៌របស់ខ្លួន បានលះអនោត្តប្បៈហើយ ការបញ្ចេញទឹកសុក្កៈ មិនស្អាត របស់ព្រះអរហន្តនោះ មិនមានទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[៤០] ព្រះអរហន្ត អ្នកឈ្លាសក្នុងធម៌ដទៃ ចម្រើនមគ្គ ដើម្បីលះរាគៈ ។ បេ ។ ចម្រើនពោជ្ឈង្គៈ ។ បេ ។ ដើម្បីលះទោសៈ ។ បេ ។ ដើម្បីលះមោហៈ ។ បេ ។ ចម្រើនមគ្គ ដើម្បីលះអនោត្តប្បៈ ។ បេ ។ ចម្រើនពោជ្ឈង្គៈ ការបញ្ចេញទឹកសុក្កៈ មិនស្អាត របស់ព្រះអរហន្តនោះ មិនមានទេឬ ។ អើ ។ ព្រះអរហន្ត អ្នកឈ្លាសក្នុងធម៌របស់ខ្លួន ចម្រើនពោជ្ឈង្គៈ ដើម្បីលះអនោត្តប្បៈ ការបញ្ចេញទឹកសុក្កៈ មិនស្អាត របស់ព្រះអរហន្តនោះ មិនមានទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[៤១] បរជម្មកុសលោ អរហា វីតរាគោ វីតទោសោ វីតមោហោ ។ បេ ។ សច្ឆិកាតព្វំ សច្ឆិកតំ នត្ថិ តស្ស អសុចិសុក្កវិស្សដ្ឋីតិ ។ អាមន្តា ។ សជម្ម-កុសលោ អរហា វីតរាគោ វីតទោសោ វីតមោហោ ។ បេ ។ សច្ឆិកាតព្វំ សច្ឆិកតំ នត្ថិ តស្ស អសុចិ-សុក្កវិសដ្ឋីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[៤២] អត្ថិ អរហតោ អសុចិសុក្កវិសដ្ឋីតិ ។ អាមន្តា ។ ននុ វុត្តំ ភគវតា យេ តេ ភិក្ខវេ ភិក្ខូ បុថុជ្ជនា សីលសម្បន្នា សតិសម្បជានា និទ្ទំ ឱក្កមន្តិ តេសំ អសុចិ ន មុច្ចតិ យេបិ តេ ភិក្ខវេ ពាហិរកា ឥសយោ កាមេសុ វីតរាគា តេសម្បិ អសុចិ ន មុច្ចតិ អដ្ឋានមេតំ ភិក្ខវេ អនវកាសោ យំ អរហតោ អសុចិ មុច្ចេយ្យាតិ អត្ថេវ សុត្តន្តោតិ ។ [១]តេន ហិ ន វត្តព្វំ អត្ថិ អរហតោ អសុចិសុក្កវិសដ្ឋីតិ ។

---

១ ឱ. ម. ឯត្ថន្តរេ អាមន្តាតិ ទិស្សតិ ។

[៤១] ព្រះអរហន្ត អ្នកឈ្លាសក្នុងធម៌ដទៃ ប្រាសចាករាគៈ ប្រាសចាកទោសៈ ប្រាសចាកមោហៈ ។ បេ ។ សច្ចិកាតព្វកិច្ច លោកធ្វើឲ្យជាក់ច្បាស់ហើយ ការបញ្ចេញទឹកសុក្កៈ មិនស្អាត របស់ព្រះអរហន្តនោះ មិនមានទេឬ ។ អើ ។ ព្រះអរហន្ត អ្នកឈ្លាសក្នុងធម៌របស់ខ្លួន ប្រាសចាករាគៈ ប្រាសចាកទោសៈ ប្រាសចាកមោហៈ ។ បេ ។ សច្ចិកាតព្វកិច្ច លោកធ្វើឲ្យជាក់ច្បាស់ហើយ ការបញ្ចេញទឹកសុក្កៈមិនស្អាត របស់ព្រះអរហន្តនោះ មិនមានទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[៤២] ការបញ្ចេញទឹកសុក្កៈ មិនស្អាត របស់ព្រះអរហន្ត មានដែរឬ ។ អើ ។ ក្រែងព្រះមានព្រះភាគត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ពួកភិក្ខុណា ជាបុថុជ្ជន បរិបូណ៌ដោយសីល មានសតិនិងសម្បជញ្ញៈ ចុះសិប់កាន់កិរិយាដេកលក់ អសុចិរបស់ភិក្ខុទាំងនោះ មិនឃ្លាតចេញទេ ម្នាលភិក្ខុទាំងឡាយ ពួកឥសី ជាខាងក្រៅ ណា ប្រាសចាករាគៈ ក្នុងកាមទាំងឡាយ អសុចិរបស់ឥសីទាំងនោះ មិនឃ្លាតចេញទេ អសុចិរបស់ព្រះអរហន្ត គប្បីឃ្លាតចេញ ដោយហេតុណា ម្នាលភិក្ខុទាំងឡាយ ហេតុនុ៎ះ រមែងមិនមាន មិនមែនជាឱកាសទេ ពាក្យដូច្នេះ មានក្នុងព្រះសូត្រឬ ។ ព្រោះហេតុនោះ អ្នកមិនគួរពោលថា ការបញ្ចេញទឹកសុក្កៈ មិនស្អាត របស់ព្រះអរហន្ត មានទេ ។

[៤៣] ន វត្តព្វំ អត្ថិ អរហតោ បរូបហារោតិ(១) ។ អាមន្តា ។ ននុ អរហតោ ចីវរបិណ្ឌបាតសេនាសនគិលានប្បច្ចយភេសជ្ជបរិក្ខារំ បរេ ឧបសំហរេយ្យុន្តិ ។ អាមន្តា ។ ហញ្ចិ អរហតោ ចីវរបិណ្ឌបាតសេនាសនគិលានប្បច្ចយភេសជ្ជបរិក្ខារំ បរេ ឧបសំហរេយ្យុំ តេន វត រេ វត្តព្វេ អត្ថិ អរហតោ បរូបហារោតិ(១) ។

[៤៤] អរហតោ ចីវរបិណ្ឌបាតសេនាសនគិលានប្បច្ចយភេសជ្ជបរិក្ខារំ បរេ ឧបសំហរេយ្យុន្តិ ។ អត្ថិ អរហតោ បរូបហារោតិ ។ អាមន្តា ។ អរហតោ សោតាបត្តិផលំ វា សកទាគាមិផលំ វា អនាគាមិផលំ វា អរហត្តំ វា បរេ ឧបសំហរេយ្យុន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។

បរូបហារកថា ។

# អញ្ញាណកថា

[៤៥] អត្ថិ អរហតោ អញ្ញាណន្តិ ។ អាមន្តា ។ អត្ថិ អរហតោ អវិជ្ជា អវិជ្ជោឃោ អវិជ្ជាយោគោ អវិជ្ជានុសយោ អវិជ្ជាបរិយុដ្ឋានំ អវិជ្ជាសញ្ញោជនំ អវិជ្ជានីវរណន្តិ ។

១ ឱ. អសុចិសុក្កវិសដ្ឋីតិ ទិស្សតិយេវ ។

[៤៣] អ្នកមិនគប្បីពោលថា ការញុំាងបុគ្គលដទៃឲ្យនាំមក របស់ព្រះអរហន្ត មានឬ ។ អើ ។ ក្រែងពួកជនដទៃ គប្បីនាំមក នូវចីវរ បិណ្ឌ-បាត សេនាសនៈ គិលានប្បច្ច័យ និងភេសជ្ជបរិក្ខារ ដើម្បីព្រះអរហន្តដែរ ឬ ។ អើ ។ បើពួកជនដទៃ គប្បីនាំមក នូវចីវរ បិណ្ឌបាត សេនាសនៈ គិលានប្បច្ច័យ និងភេសជ្ជបរិក្ខារ ដើម្បីព្រះអរហន្ត ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគប្បីពោលថា ការញុំាងបុគ្គលដទៃឲ្យនាំមក របស់ព្រះអរហន្ត មានដែរ ។

[៤៤] ពួកជនដទៃ គប្បីនាំមក នូវចីវរ បិណ្ឌបាត សេនាសនៈ គិលានប្បច្ច័យ និងភេសជ្ជបរិក្ខារ ដើម្បីព្រះអរហន្តដែរឬ ។ ការញុំាងបុគ្គលដទៃឲ្យនាំមក របស់ព្រះអរហន្ត មានដែរឬ ។ អើ ។ ពួកជនដទៃគប្បីនាំមក នូវសោតាបត្តិផលក្តី សកទាគាមិផលក្តី អនាគាមិផលក្តី អរហត្ត-ផលក្តី ដើម្បីព្រះអរហន្តឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

ចប់ បរូបហារកថា ។

# អញ្ញាណកថា

[៤៥] ការមិនដឹង របស់ព្រះអរហន្ត មានដែរឬ ។ អើ ។ អវិជ្ជា ឱឃៈគឺអវិជ្ជា យោគៈគឺអវិជ្ជា អនុស័យគឺអវិជ្ជា បរិយុដ្ឋានៈគឺអវិជ្ជា សញ្ញោជនៈគឺអវិជ្ជា នីវរណៈគឺអវិជ្ជា របស់ព្រះអរហន្ត មានដែរឬ ។

ន ហេវំ វត្តព្វេ ។ បេ ។

[៤៦] នត្ថិ អរហតោ អវិជ្ជា អវិជ្ជោឃោ អវិជ្ជាយោគោ អវិជ្ជានុសយោ អវិជ្ជាបរិយុដ្ឋានំ អវិជ្ជាសញ្ញោជនំ អវិជ្ជានីវរណន្តិ ។ អាមន្តា ។ ហញ្ចិ នត្ថិ អរហតោ អវិជ្ជា អវិជ្ជោឃោ អវិជ្ជាយោគោ អវិជ្ជានុសយោ អវិជ្ជាបរិយុដ្ឋានំ អវិជ្ជាសញ្ញោជនំ អវិជ្ជានីវរណំ នោ វត រេ វត្តព្វេ អត្ថិ អរហតោ អញ្ញាណន្តិ ។

[៤៧] អត្ថិ បុថុជ្ជនស្ស អញ្ញាណំ អត្ថិ តស្ស អវិជ្ជា អវិជ្ជោឃោ អវិជ្ជាយោគោ អវិជ្ជានុសយោ អវិជ្ជាបរិយុដ្ឋានំ អវិជ្ជាសញ្ញោជនំ អវិជ្ជានីវរណន្តិ ។ អាមន្តា ។ អត្ថិ អរហតោ អញ្ញាណំ អត្ថិ តស្ស អវិជ្ជា អវិជ្ជោឃោ អវិជ្ជាយោគោ អវិជ្ជានុសយោ អវិជ្ជាបរិយុដ្ឋានំ អវិជ្ជាសញ្ញោជនំ អវិជ្ជានីវរណន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[៤៨] អត្ថិ អរហតោ អញ្ញាណំ នត្ថិ តស្ស អវិជ្ជា អវិជ្ជោឃោ អវិជ្ជាយោគោ អវិជ្ជានុសយោ អវិជ្ជាបរិយុដ្ឋានំ អវិជ្ជាសញ្ញោជនំ អវិជ្ជានីវរណន្តិ ។

អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[៤៦] អវិជ្ជា ឱឃៈគឺអវិជ្ជា យោគៈគឺអវិជ្ជា អនុស័យគឺអវិជ្ជា បរិយុដ្ឋានៈគឺអវិជ្ជា សញ្ញោជនៈគឺអវិជ្ជា នីវរណៈគឺអវិជ្ជា របស់ព្រះអរហន្ត មិនមានទេឬ ។ អើ ។ បើអវិជ្ជា ឱឃៈគឺអវិជ្ជា យោគៈគឺអវិជ្ជា អនុស័យគឺអវិជ្ជា បរិយុដ្ឋានៈគឺអវិជ្ជា សញ្ញោជនៈគឺអវិជ្ជា នីវរណៈគឺអវិជ្ជា របស់ព្រះអរហន្ត មិនមានទេ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា ការមិនដឹង របស់ព្រះអរហន្ត មានទេ ។

[៤៧] ការមិនដឹង របស់បុថុជ្ជន មាន អវិជ្ជា ឱឃៈគឺអវិជ្ជា យោគៈគឺអវិជ្ជា អនុស័យគឺអវិជ្ជា បរិយុដ្ឋានៈគឺអវិជ្ជា សញ្ញោជនៈគឺអវិជ្ជា នីវរណៈគឺអវិជ្ជា របស់បុថុជ្ជននោះ មានដែរឬ ។ អើ ។ ការមិនដឹង របស់ព្រះអរហន្ត មាន អវិជ្ជា ឱឃៈគឺអវិជ្ជា យោគៈគឺអវិជ្ជា អនុស័យគឺអវិជ្ជា បរិយុដ្ឋានៈគឺអវិជ្ជា សញ្ញោជនៈគឺអវិជ្ជា នីវរណៈគឺអវិជ្ជា របស់ព្រះអរហន្ត មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[៤៨] ការមិនដឹង របស់ព្រះអរហន្ត មាន អវិជ្ជា ឱឃៈគឺអវិជ្ជា យោគៈគឺអវិជ្ជា អនុស័យគឺអវិជ្ជា បរិយុដ្ឋានៈគឺអវិជ្ជា សញ្ញោជនៈគឺអវិជ្ជា នីវរណៈគឺអវិជ្ជា របស់ព្រះអរហន្តនោះ មិនមានទេឬ ។

អាមន្តា ។ អត្ថិ បុថុជ្ជនស្ស អញ្ញាណំ នត្ថិ តស្ស អវិជ្ជា អវិជ្ជោឃោ អវិជ្ជាយោគោ អវិជ្ជានុសយោ អវិជ្ជាបរិយុដ្ឋានំ អវិជ្ជាសញ្ញោជនំ អវិជ្ជានីវរណន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[៤៩] អត្ថិ អរហតោ អញ្ញាណន្តិ ។ អាមន្តា ។ អរហា អញ្ញាណបកតោ បាណំ ហនេយ្យ អទិន្នំ អាទិយេយ្យ មុសា ភណេយ្យ បិសុណំ ភណេយ្យ ផរុសំ ភណេយ្យ សម្ផំ បលបេយ្យ សន្ធឹ ឆិន្ទេយ្យ និល្លោបំ ហរេយ្យ ឯកាគារិកំ ករេយ្យ បរិបន្ថេ តិដ្ឋេយ្យ បរទារំ គច្ឆេយ្យ គាមឃាតំ ករេយ្យ និគមឃាតំ ករេយ្យាតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[៥០] អត្ថិ បុថុជ្ជនស្ស អញ្ញាណំ បុថុជ្ជនោ អញ្ញាណបកតោ បាណំ ហនេយ្យ អទិន្នំ អាទិ-យេយ្យ ។ បេ ។ គាមឃាតំ ករេយ្យ និគមឃាតំ ករេយ្យាតិ ។ អាមន្តា ។ អត្ថិ អរហតោ អញ្ញាណំ អរហា អញ្ញាណបកតោ បាណំ ហនេយ្យ អទិន្នំ អាទិយេយ្យ ។ បេ ។ គាមឃាតំ ករេយ្យ និគមឃាតំ ករេយ្យាតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

អើ ។ ការមិនដឹង របស់បុថុជ្ជន មាន អវិជ្ជា ឱឃៈគឺអវិជ្ជា យោគៈគឺអវិជ្ជា អនុស័យគឺអវិជ្ជា បរិយុដ្ឋានៈគឺអវិជ្ជា សញ្ញោជនៈគឺអវិជ្ជា នីវរណៈគឺអវិជ្ជា របស់បុថុជ្ជននោះ មិនមានទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[៤៩] ការមិនដឹង របស់ព្រះអរហន្ត មានដែរឬ ។ អើ ។ ព្រះអរហន្ត ដែលការមិនដឹងគ្របសង្កត់ គប្បីសម្លាប់សត្វ គប្បីកាន់យកទ្រព្យដែលគេមិនឲ្យ គប្បីពោលពាក្យកុហក គប្បីពោលពាក្យញុះញង់ គប្បីពោលពាក្យអាក្រក់ គប្បីពោលពាក្យឥតប្រយោជន៍ គប្បីកាត់ទី-ត គប្បីពួនចាំឆក់ គប្បីប្លន់តែផ្ទះមួយ គប្បីឈរស្កាត់ត្រង់ផ្លូវ គប្បីគប់រកប្រពន្ធបុគ្គលដទៃ គប្បីសម្លាប់អ្នកស្រុក គប្បីសម្លាប់អ្នកនិគមឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[៥០] ការមិនដឹង របស់បុថុជ្ជន មាន បុថុជ្ជន ដែលការមិនដឹងគ្របសង្កត់ គប្បីសម្លាប់សត្វ គប្បីកាន់យកទ្រព្យដែលគេមិនឲ្យ ។ បេ ។ គប្បីសម្លាប់អ្នកស្រុក គប្បីសម្លាប់អ្នកនិគមឬ ។ អើ ។ ការមិនដឹង របស់ព្រះអរហន្ត មាន ព្រះអរហន្ត ដែលការមិនដឹងគ្របសង្កត់ គប្បីសម្លាប់សត្វ គប្បីកាន់យកទ្រព្យដែលគេមិនឲ្យ ។ បេ ។ គប្បីសម្លាប់អ្នកស្រុក គប្បីសម្លាប់អ្នកនិគមឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ។ បេ ។

[៤១] អត្ថិ អរហតោ អញ្ញាណំ ន ច អរហា អញ្ញាណបកតោ ចាណំ ហនេយ្យ អទិន្នំ អាទិយេយ្យ ។ បេ ។ គាមឃាតំ ករេយ្យ និគមឃាតំ ករេយ្យាតិ ។ អាមន្តា ។ អត្ថិ បុថុជ្ជនស្ស អញ្ញាណំ ន ច បុថុជ្ជនោ អញ្ញាណបកតោ ចាណំ ហនេយ្យ អទិន្នំ អាទិយេយ្យ ។ បេ ។ គាមឃាតំ ករេយ្យ និគមឃាតំ ករេយ្យា-តិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[៤២] អត្ថិ អរហតោ អញ្ញាណន្តិ ។ អាមន្តា ។ អត្ថិ អរហតោ សត្ថរិ អញ្ញាណំ ធម្មេ អញ្ញាណំ សង្ឃេ អញ្ញាណំ សិក្ខាយ អញ្ញាណំ បុព្វន្តេ អញ្ញាណំ អបរន្តេ អញ្ញាណំ បុព្វន្តាបរន្តេ អញ្ញាណំ ឥទប្បច្ច-យតាបដិច្ចសមុប្បន្នេសុ ធម្មេសុ អញ្ញាណន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[៤៣] នត្ថិ អរហតោ សត្ថរិ អញ្ញាណំ ធម្មេ អញ្ញាណំ សង្ឃេ អញ្ញាណំ សិក្ខាយ អញ្ញាណំ បុព្វន្តេ អញ្ញាណំ អបរន្តេ អញ្ញាណំ បុព្វន្តាបរន្តេ អញ្ញាណំ ឥទប្បច្ចយតាបដិច្ចសមុប្បន្នេសុ ធម្មេសុ អញ្ញាណន្តិ ។ អាមន្តា ។ ហញ្ចិ នត្ថិ អរហតោ

[៥១] ការមិនដឹង របស់ព្រះអរហន្ត មាន ប៉ុន្តែព្រះអរហន្ត ដែលការមិនដឹងគ្របសង្កត់ មិនគប្បីសម្លាប់សត្វ មិនគប្បីកាន់យកទ្រព្យ ដែលគេមិនឲ្យ ។ បេ ។ មិនគប្បីសម្លាប់អ្នកស្រុក មិនគប្បីសម្លាប់អ្នកនិគម ទេឬ ។ អើ ។ ការមិនដឹង របស់បុថុជ្ជន មាន ប៉ុន្តែបុថុជ្ជន ដែលការមិន ដឹងគ្របសង្កត់ មិនគប្បីសម្លាប់សត្វ មិនគប្បីកាន់យកទ្រព្យដែលគេមិន ឲ្យ ។ បេ ។ មិនគប្បីសម្លាប់អ្នកស្រុក មិនគប្បីសម្លាប់អ្នកនិគមទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[៥២] ការមិនដឹង របស់ព្រះអរហន្ត មានដែរឬ ។ អើ ។ ការមិន ដឹង របស់ព្រះអរហន្ត ក្នុងព្រះសាស្ដា មិនដឹងក្នុងព្រះធម៌ មិនដឹងក្នុង ព្រះសង្ឃ មិនដឹងក្នុងសិក្ខា មិនដឹងក្នុងចំណែកខាងដើម មិនដឹងក្នុង ចំណែកខាងចុង មិនដឹងក្នុងចំណែកខាងដើមនិងចំណែកខាងចុង មិនដឹង ក្នុងពួកធម៌ដែលកើតឡើង ព្រោះអាស្រ័យហេតុ ព្រោះធម៌នេះជាបច្ច័យ មានឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[៥៣] ការមិនដឹង របស់ព្រះអរហន្ត ក្នុងព្រះសាស្ដា ការមិនដឹង ក្នុងព្រះធម៌ មិនដឹងក្នុងព្រះសង្ឃ មិនដឹងក្នុងសិក្ខា មិនដឹងក្នុងចំណែកខាង ដើម មិនដឹងក្នុងចំណែកខាងចុង មិនដឹងក្នុងចំណែកខាងដើមនិងចំណែក ខាងចុង មិនដឹងក្នុងពួកធម៌ដែលកើតឡើង ព្រោះអាស្រ័យហេតុ ព្រោះ ធម៌នេះជាបច្ច័យ មិនមានទេឬ ។ អើ ។ បើការមិនដឹង របស់ព្រះអរហន្ត

អញ្ញាណកថា

សត្ថរិ អញ្ញាណំ ធម្មេ អញ្ញាណំ សង្ឃេ អញ្ញាណំ ។ បេ ។ ឥទប្បច្ចយតាបដិច្ចសមុប្បន្នេសុ ធម្មេសុ អញ្ញាណំ នោ វត រេ វត្តព្វេ អត្ថិ អរហតោ អញ្ញាណន្តិ ។

[៤៨] អត្ថិ បុថុជ្ជនស្ស អញ្ញាណំ អត្ថិ តស្ស សត្ថរិ អញ្ញាណំ ធម្មេ អញ្ញាណំ សង្ឃេ អញ្ញាណំ ។ បេ ។ ឥទប្បច្ចយតាបដិច្ចសមុប្បន្នេសុ ធម្មេសុ អញ្ញាណន្តិ ។ អាមន្តា ។ អត្ថិ អរហតោ អញ្ញាណំ អត្ថិ តស្ស សត្ថរិ អញ្ញាណំ ធម្មេ អញ្ញាណំ សង្ឃេ អញ្ញាណំ ។ បេ ។ ឥទប្បច្ចយតាបដិច្ចសមុប្បន្នេសុ ធម្មេសុ អញ្ញាណន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[៤៩] អត្ថិ អរហតោ អញ្ញាណំ នត្ថិ តស្ស សត្ថរិ អញ្ញាណំ ធម្មេ អញ្ញាណំ សង្ឃេ អញ្ញាណំ ។ បេ ។ ឥទប្បច្ចយតាបដិច្ចសមុប្បន្នេសុ ធម្មេសុ អញ្ញាណន្តិ ។ អាមន្តា ។ អត្ថិ បុថុជ្ជនស្ស អញ្ញាណំ នត្ថិ តស្ស សត្ថរិ អញ្ញាណំ ធម្មេ អញ្ញាណំ សង្ឃេ អញ្ញាណំ ។ បេ ។ ឥទប្បច្ចយតាបដិច្ចសមុប្បន្នេសុ ធមេសុ អញ្ញាណន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។

ក្នុងព្រះសាស្តា មិនដឹងក្នុងព្រះធម៌ មិនដឹងក្នុងព្រះសង្ឃ ។ បេ ។ មិនដឹងក្នុងពួកធម៌ដែលកើតឡើង ព្រោះអាស្រ័យហេតុ ព្រោះធម៌នេះជាបច្ច័យ មិនមានទេ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា ការមិនដឹង របស់ព្រះអរហន្ត មានទេ ។

[៥៤] ការមិនដឹង របស់បុថុជ្ជន មាន ការមិនដឹង របស់បុថុជ្ជននោះ ក្នុងព្រះសាស្តា មិនដឹងក្នុងព្រះធម៌ មិនដឹងក្នុងព្រះសង្ឃ ។ បេ ។ មិនដឹងក្នុងពួកធម៌ដែលកើតឡើង ព្រោះអាស្រ័យហេតុ ព្រោះធម៌នេះជាបច្ច័យ មានដែរឬ ។ អើ ។ ការមិនដឹង របស់ព្រះអរហន្ត មាន ការមិនដឹង របស់ព្រះអរហន្តនោះ ក្នុងព្រះសាស្តា មិនដឹងក្នុងព្រះធម៌ មិនដឹងក្នុងព្រះសង្ឃ ។ បេ ។ មិនដឹងក្នុងពួកធម៌ដែលកើតឡើង ព្រោះអាស្រ័យហេតុ ព្រោះធម៌នេះជាបច្ច័យ មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[៥៥] ការមិនដឹង របស់ព្រះអរហន្ត មាន ការមិនដឹង របស់ព្រះអរហន្តនោះ ក្នុងព្រះសាស្តា មិនដឹងក្នុងព្រះធម៌ មិនដឹងក្នុងព្រះសង្ឃ ។ បេ ។ មិនដឹងក្នុងពួកធម៌ដែលកើតឡើង ព្រោះអាស្រ័យហេតុ ព្រោះធម៌នេះជាបច្ច័យ មិនមានទេឬ ។ អើ ។ ការមិនដឹង របស់បុថុជ្ជន មាន ការមិនដឹង របស់បុថុជ្ជននោះ ក្នុងព្រះសាស្តា មិនដឹងក្នុងព្រះធម៌ មិនដឹងក្នុងព្រះសង្ឃ ។ បេ ។ មិនដឹងក្នុងពួកធម៌ដែលកើតឡើង ព្រោះអាស្រ័យហេតុ ព្រោះធម៌នេះជាបច្ច័យ មិនមានទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[៥៦] អត្ថិ អរហតោ អញ្ញាណន្តិ ។ អាមន្តា ។ ននុ អរហតោ រាគោ បហីនោ ឧច្ឆិន្នមូលោ តាលាវត្ថុកតោ អនភាវង្កតោ អាយតឹ អនុប្បាទធម្មោតិ ។ អាមន្តា ។ ហញ្ចិ អរហតោ រាគោ បហីនោ ឧច្ឆិន្នមូលោ តាលាវត្ថុកតោ អនភាវង្កតោ អាយតឹ អនុប្បាទធម្មោ នោ វត រេ វត្តព្វេ អត្ថិ អរហតោ អញ្ញាណន្តិ ។ បេ ។ ននុ អរហតោ ទោសោ បហីនោ ។ បេ ។ មោហោ បហីនោ ។ បេ ។ អនោត្តប្បំ បហីនំ ឧច្ឆិន្នមូលំ តាលាវត្ថុកតំ អនភាវង្កតំ អាយតឹ អនុប្បាទធម្មន្តិ ។ អាមន្តា ។ ហញ្ចិ អរហតោ អនោត្តប្បំ បហីនំ ឧច្ឆិន្នមូលំ តាលាវត្ថុកតំ អនភាវង្កតំ អនុប្បាទធម្មំ នោ វត រេ វត្តព្វេ អត្ថិ អរហតោ អញ្ញាណន្តិ ។

[៥៧] អត្ថិ អរហតោ អញ្ញាណន្តិ ។ អាមន្តា ។ ននុ អរហតោ រាគប្បហានាយ មគ្គោ ភាវិតោ ។ បេ ។ ពោជ្ឈង្គា ភាវិតាតិ ។ អាមន្តា ។ ហញ្ចិ អរហតោ រាគប្បហានាយ ពោជ្ឈង្គា ភាវិតា នោ វត រេ វត្តព្វេ អត្ថិ អរហតោ អញ្ញាណន្តិ ។

[៥៨] អត្ថិ អរហតោ អញ្ញាណន្តិ ។ អាមន្តា ។

[៩៦] ការមិនដឹង របស់ព្រះអរហន្ត មានដែរឬ ។ អើ ។ ក្រែង ព្រះអរហន្ត លះរាគៈ ផ្តាច់ផ្តិលឫសគល់ ធ្វើឲ្យសល់តែទីនៅដូចជាទីនៅ នៃដើមត្នោត ធ្វើមិនឲ្យមានបែបភាព ឲ្យជាធម៌លែងកើតតទៅទៀតឬ ។ អើ ។ បើព្រះអរហន្ត លះរាគៈ ផ្តាច់ផ្តិលឫសគល់ ធ្វើឲ្យសល់តែទីនៅ ដូចជាទីនៅនៃដើមត្នោត ធ្វើមិនឲ្យមានបែបភាព ឲ្យជាធម៌លែងកើតតទៅ ទៀត ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា ការមិនដឹង របស់ព្រះអរហន្ត មានទេ ។ បេ ។ ក្រែងព្រះអរហន្ត លះទោសៈ ។ បេ ។ លះមោហៈ ។ បេ ។ លះអនោត្តប្បៈ ផ្តាច់ផ្តិលឫសគល់ ធ្វើឲ្យសល់តែទីនៅដូចជាទីនៅនៃដើម ត្នោត ធ្វើមិនឲ្យមានបែបភាព ឲ្យជាធម៌លែងកើតតទៅទៀតឬ ។ អើ ។ បើព្រះអរហន្ត លះអនោត្តប្បៈ ផ្តាច់ផ្តិលឫសគល់ ធ្វើឲ្យសល់តែទីនៅ ដូចជាទីនៅនៃដើមត្នោត ធ្វើមិនឲ្យមានបែបភាព ឲ្យជាធម៌លែងកើតត ទៅទៀត ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា ការមិនដឹង របស់ព្រះ អរហន្ត មានទេ ។

[៩៧] ការមិនដឹង របស់ព្រះអរហន្ត មានដែរឬ ។ អើ ។ ក្រែង ព្រះអរហន្ត ចម្រើនមគ្គ ដើម្បីលះរាគៈ ។ បេ ។ ចម្រើនពោជ្ឈង្គៈឬ ។ អើ ។ បើព្រះអរហន្ត ចម្រើនពោជ្ឈង្គៈ ដើម្បីលះរាគៈ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា ការមិនដឹង របស់ព្រះអរហន្ត មានទេ ។

[៩៨] ការមិនដឹង របស់ព្រះអរហន្ត មានដែរឬ ។ អើ ។

ឆន្ទុ អរហតោ ទោសប្បហានាយ ។ បេ ។ អនោត្ត-
ប្បប្បហានាយ មគ្គោ ភាវិតោ ។ បេ ។ ពោជ្ឈង្គា
ភាវិតាតិ ។ អាមន្តា ។ ហញ្ចិ អរហតោ អនោត្តប្ប-
ប្បហានាយ ពោជ្ឈង្គា ភាវិតា នោ វត រេ វត្តព្វេ
អត្ថិ អរហតោ អញ្ញាណន្តិ ។

[៥៩] អត្ថិ អរហតោ អញ្ញាណន្តិ ។ អាមន្តា ។
ឆន្ទុ អរហា វីតរាគោ វីតទោសោ វីតមោហោ ។ បេ ។
សច្ឆិកាតព្វំ សច្ឆិកតន្តិ ។ អាមន្តា ។ ហញ្ចិ អរហា
វីតរាគោ ។ បេ ។ សច្ឆិកាតព្វំ សច្ឆិកតំ នោ វត
រេ វត្តព្វេ អត្ថិ អរហតោ អញ្ញាណន្តិ ។

[៦០] អត្ថិ អរហតោ អញ្ញាណន្តិ ។ សជម្ម-
កុសលស្ស អរហតោ អត្ថិ អញ្ញាណំ បរជម្មកុស-
លស្ស អរហតោ ឆត្ថិ អញ្ញាណន្តិ ។ សជម្មកុស-
លស្ស អរហតោ អត្ថិ អញ្ញាណន្តិ ។ អាមន្តា ។
បរជម្មកុសលស្ស អរហតោ អត្ថិ អញ្ញាណន្តិ ។
ឆ ហេវំ វត្តព្វេ ។ បេ ។

ក្រែងព្រះអរហន្ត ចម្រើនមគ្គ ដើម្បីលះទោសៈ ។ បេ ។ ចម្រើនមគ្គ ដើម្បីលះអនោត្តប្បៈ ។ បេ ។ ចម្រើនពោជ្ឈង្គៈឬ ។ អើ ។ បើព្រះអរហន្ត ចម្រើនពោជ្ឈង្គៈ ដើម្បីលះអនោត្តប្បៈ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា ការមិនដឹង របស់ព្រះអរហន្ត មានទេ ។

[៥៩] ការមិនដឹង របស់ព្រះអរហន្ត មានដែរឬ ។ អើ ។ ក្រែងព្រះអរហន្ត ប្រាសចាករាគៈ ប្រាសចាកទោសៈ ប្រាសចាកមោហៈ ។ បេ ។ សច្ឆិកាតព្វកិច្ច (កិច្ចដែលគួរធ្វើឲ្យជាក់ច្បាស់) លោកធ្វើឲ្យជាក់ច្បាស់ហើយឬ ។ អើ ។ បើព្រះអរហន្ត ប្រាសចាករាគៈ ។ បេ ។ សច្ឆិកាតព្វកិច្ច លោកធ្វើឲ្យជាក់ច្បាស់ហើយ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា ការមិនដឹង របស់ព្រះអរហន្ត មានទេ ។

[៦០] ការមិនដឹង របស់ព្រះអរហន្ត មានដែរឬ ។ ការមិនដឹង របស់ព្រះអរហន្ត អ្នកឈ្លាសក្នុងធម៌របស់ខ្លួន មាន ការមិនដឹង របស់ព្រះអរហន្ត អ្នកឈ្លាសក្នុងធម៌ដទៃ មិនមានទេ ។ ការមិនដឹង របស់ព្រះអរហន្ត អ្នកឈ្លាសក្នុងធម៌របស់ខ្លួន មានដែរឬ ។ អើ ។ ការមិនដឹង របស់ព្រះអរហន្ត អ្នកឈ្លាសក្នុងធម៌ដទៃ មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[៦១] បរជម្មកុសលស្ស អរហតោ ឧត្ថិ អញ្ញា-ណាន្តិ ។ អាមន្តា ។ សជម្មកុសលស្ស អរហតោ ឧត្ថិ អញ្ញាណាន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[៦២] សជម្មកុសលស្ស អរហតោ រាគោ ប-ហីនោ អត្ថិ តស្ស អញ្ញាណាន្តិ ។ អាមន្តា ។ បរ-ជម្មកុសលស្ស អរហតោ រាគោ បហីនោ អត្ថិ តស្ស អញ្ញាណាន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[៦៣] សជម្មកុសលស្ស អរហតោ ទោសោ បហីនោ មោហោ បហីនោ ។ បេ ។ អនោត្តប្បំ ប-ហីនំ អត្ថិ តស្ស អញ្ញាណាន្តិ ។ អាមន្តា ។ បរ-ជម្មកុសលស្ស អរហតោ អនោត្តប្បំ បហីនំ អត្ថិ តស្ស អញ្ញាណាន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[៦៤] សជម្មកុសលស្ស អរហតោ រាគប្បហា-នាយ មគ្គោ ភាវិតោ ។ បេ ។ ពោជ្ឈង្គា ភាវិតា អត្ថិ តស្ស អញ្ញាណាន្តិ ។ អាមន្តា ។ បរជម្មកុស-លស្ស អរហតោ រាគប្បហានាយ(១) ពោជ្ឈង្គា ភាវិតា អត្ថិ តស្ស អញ្ញាណាន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។

១ ឱ. ឥតោ បរំ មគ្គោ ភាវិតោ ។ បេ ។ ឥតិ បាឋោ ទិស្សតិ ។

[៦១] ការមិនដឹង របស់ព្រះអរហន្ត អ្នកឈ្លាសក្នុងធម៌ដទៃ មិនមានទេឬ ។ អើ ។ ការមិនដឹង របស់ព្រះអរហន្ត អ្នកឈ្លាសក្នុងធម៌របស់ខ្លួន មិនមានទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[៦២] ព្រះអរហន្ត អ្នកឈ្លាសក្នុងធម៌របស់ខ្លួន លះរាគៈ ការមិនដឹង របស់ព្រះអរហន្តនោះ មានដែរឬ ។ អើ ។ ព្រះអរហន្ត អ្នកឈ្លាសក្នុងធម៌ដទៃ លះរាគៈ ការមិនដឹង របស់ព្រះអរហន្តនោះ មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[៦៣] ព្រះអរហន្ត អ្នកឈ្លាសក្នុងធម៌របស់ខ្លួន លះទោសៈ លះមោហៈ ។ បេ ។ លះអនោត្តប្បៈ ការមិនដឹង របស់ព្រះអរហន្តនោះ មានដែរឬ ។ អើ ។ ព្រះអរហន្ត អ្នកឈ្លាសក្នុងធម៌ដទៃ លះអនោ-ត្តប្បៈ ការមិនដឹង របស់ព្រះអរហន្តនោះ មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[៦៤] ព្រះអរហន្ត អ្នកឈ្លាសក្នុងធម៌របស់ខ្លួន ចម្រើនមគ្គដើម្បីលះរាគៈ ។ បេ ។ ចម្រើនពោជ្ឈង្គៈ ការមិនដឹង របស់ព្រះអរហន្តនោះ មានដែរឬ ។ អើ ។ ព្រះអរហន្ត អ្នកឈ្លាសក្នុងធម៌ដទៃ ចម្រើនពោជ្ឈង្គៈ ដើម្បីលះរាគៈ ការមិនដឹង របស់ព្រះអរហន្តនោះ មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

អញ្ញាណកថា

[៦៥] សជម្មកុសលស្ស អរហតោ ពោសប្ប-
ហាជាយ ។ បេ ។ អជោត្តប្បប្បហាជាយ មគ្គោ
ភាវិតោ ។ បេ ។ ពោជ្ឈង្គា ភាវិតា អត្ថិ តស្ស
អញ្ញាណន្តិ ។ អាមន្តា ។ បរជម្មកុសលស្ស អរ-
ហតោ អជោត្តប្បប្បហាជាយ ពោជ្ឈង្គា ភាវិតា អត្ថិ
តស្ស អញ្ញាណន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[៦៦] សជម្មកុសលោ អរហា វីតរាគោ វីតទោ-
សោ វីតមោហោ ។ បេ ។ សច្ឆិកាតព្វំ សច្ឆិកតំ
អត្ថិ តស្ស អញ្ញាណន្តិ ។ អាមន្តា ។ បរជម្មកុសលោ
អរហា វីតរាគោ ។ បេ ។ សច្ឆិកាតព្វំ សច្ឆិកតំ អត្ថិ
តស្ស អញ្ញាណន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[៦៧] បរជម្មកុសលស្ស អរហតោ រាគោ បហីជោ
ជត្ថិ តស្ស អញ្ញាណន្តិ ។ អាមន្តា ។ សជម្មកុសលស្ស
អរហតោ រាគោ បហីជោ ជត្ថិ តស្ស អញ្ញាណន្តិ ។

អញ្ញាណកថា

[៦៥] ព្រះអរហន្ត អ្នកឈ្លាសក្នុងធម៌របស់ខ្លួន ចម្រើនមគ្គ ដើម្បីលះទោសៈ ។ បេ ។ ចម្រើនមគ្គ ដើម្បីលះអនោត្តប្បៈ ។ បេ ។ ចម្រើនពោជ្ឈង្គៈ ការមិនដឹង របស់ព្រះអរហន្តនោះ មានដែរឬ ។ អើ ។ ព្រះអរហន្ត អ្នកឈ្លាសក្នុងធម៌ដទៃ ចម្រើនពោជ្ឈង្គៈ ដើម្បីលះអនោត្តប្បៈ ការមិនដឹង របស់ព្រះអរហន្តនោះ មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[៦៦] ព្រះអរហន្ត អ្នកឈ្លាសក្នុងធម៌របស់ខ្លួន ប្រាសចាករាគៈ ប្រាសចាកទោសៈ ប្រាសចាកមោហៈ ។ បេ ។ សច្ឆិកាតព្វកិច្ច លោកធ្វើឲ្យជាក់ច្បាស់ហើយ ការមិនដឹង របស់ព្រះអរហន្តនោះ មានដែរឬ ។ អើ ។ ព្រះអរហន្ត អ្នកឈ្លាសក្នុងធម៌ដទៃ ប្រាសចាករាគៈ ។ បេ ។ សច្ឆិកាតព្វកិច្ច លោកធ្វើឲ្យជាក់ច្បាស់ហើយ ការមិនដឹង របស់ព្រះអរហន្តនោះ មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[៦៧] ព្រះអរហន្ត អ្នកឈ្លាសក្នុងធម៌ដទៃ លះរាគៈ ការមិនដឹង របស់ព្រះអរហន្តនោះ មិនមានទេឬ ។ អើ ។ ព្រះអរហន្ត អ្នកឈ្លាសក្នុងធម៌របស់ខ្លួន លះរាគៈ ការមិនដឹង របស់ព្រះអរហន្តនោះ មិនមានទេឬ ។

ន ហេវំ វត្តព្វេ ។ បេ ។

[៦៨] បរជម្មកុសលស្ស អរហតោ ទោសោ បហីនោ ។ បេ ។ អនោត្តប្បំ បហីនំ នត្ថិ តស្ស អញ្ញាណន្តិ ។ អាមន្តា ។ សជម្មកុសលស្ស អរហតោ[១] អនោត្តប្បំ បហីនំ នត្ថិ តស្ស អញ្ញាណន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[៦៩] បរជម្មកុសលស្ស អរហតោ រាគប្បហានាយ មគ្គោ ភាវិតោ ។ បេ ។ ពោជ្ឈង្គា ភាវិតា ។ បេ ។ អនោត្តប្បប្បហានាយ មគ្គោ ភាវិតោ ។ បេ ។ ពោជ្ឈង្គា ភាវិតា នត្ថិ តស្ស អញ្ញាណន្តិ ។ អាមន្តា ។ សជម្មកុសលស្ស អរហតោ អនោត្តប្បប្បហានាយ ពោជ្ឈង្គា ភាវិតា នត្ថិ តស្ស អញ្ញាណន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[៧០] បរជម្មកុសលោ អរហា វីតរាគោ វីតទោសោ វីតមោហោ ។ បេ ។ សច្ឆិកាតព្វំ សច្ឆិកតំ នត្ថិ តស្ស អញ្ញាណន្តិ ។ អាមន្តា ។ សជម្មកុសលោ អរហា វីតរាគោ ។ បេ ។ សច្ឆិកាតព្វំ សច្ឆិកតំ

១ ឱ. បោត្ថកេ ឯត្តន្តរេ ទោសោ បហីនោ ។ បេ ។ ឥតិ លិខិតំ ។

អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[៦៨] ព្រះអរហន្ត អ្នកឈ្លាសក្នុងធម៌ដទៃ លះរាគៈ ។ បេ ។ លះអនោត្តប្បៈ ការមិនដឹង របស់ព្រះអរហន្តនោះ មិនមានទេឬ ។ អើ ។ ព្រះអរហន្ត អ្នកឈ្លាសក្នុងធម៌របស់ខ្លួន លះអនោត្តប្បៈ ការមិនដឹង របស់ព្រះអរហន្តនោះ មិនមានទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[៦៩] ព្រះអរហន្ត អ្នកឈ្លាសក្នុងធម៌ដទៃ ចម្រើនមគ្គ ដើម្បីលះរាគៈ ។ បេ ។ ចម្រើនពោជ្ឈង្គៈ ។ បេ ។ ចម្រើនមគ្គ ដើម្បីលះអនោត្តប្បៈ ។ បេ ។ ចម្រើនពោជ្ឈង្គៈ ការមិនដឹង របស់ព្រះអរហន្តនោះ មិនមានទេឬ ។ អើ ។ ព្រះអរហន្ត អ្នកឈ្លាសក្នុងធម៌របស់ខ្លួន ចម្រើនពោជ្ឈង្គៈ ដើម្បីលះអនោត្តប្បៈ ការមិនដឹង របស់ព្រះអរហន្តនោះ មិនមានទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[៧០] ព្រះអរហន្ត អ្នកឈ្លាសក្នុងធម៌ដទៃ ប្រាសចាករាគៈ ប្រាសចាកទោសៈ ប្រាសចាកមោហៈ ។ បេ ។ សច្ឆិកាតព្វកិច្ច លោកធ្វើឲ្យជាក់ច្បាស់ហើយ ការមិនដឹង របស់ព្រះអរហន្តនោះ មិនមានទេឬ ។ អើ ។ ព្រះអរហន្ត អ្នកឈ្លាសក្នុងធម៌របស់ខ្លួន ប្រាសចាករាគៈ ។ បេ ។ សច្ឆិកាតព្វកិច្ច លោកធ្វើឲ្យជាក់ច្បាស់ហើយ ការមិនដឹង របស់ព្រះអរហន្តនោះ

នត្ថិ តស្ស អញ្ញាណន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[៧១] អត្ថិ អរហតោ អញ្ញាណន្តិ ។ អាមន្តា ។ ននុ វុត្តំ ភគវតា ជានត្វាហំ ភិក្ខវេ បស្សតោ អាស-វានំ ខយំ វទាមិ នោ អជានតោ នោ អបស្សតោ កិញ្ច ភិក្ខវេ ជានតោ កឹ បស្សតោ អាសវានំ ខយោ ហោតិ ឥតិ រូបំ ឥតិ រូបស្ស សមុទយោ ឥតិ រូបស្ស អត្ថង្គមោ ឥតិ វេទនា ។ បេ ។ ឥតិ សញ្ញា ។ បេ ។ ឥតិ សង្ខារា ។ បេ ។ ឥតិ វិញ្ញាណំ ឥតិ វិញ្ញា-ណស្ស សមុទយោ ឥតិ វិញ្ញាណស្ស អត្ថង្គមោតិ ឯវំ ខោ ភិក្ខវេ ជានតោ ឯវំ បស្សតោ អាសវានំ ខយោ ហោតីតិ អត្ថេវ សុត្តន្តោតិ ។ អាមន្តា ។ តេន ហិ ន វត្តព្វំ អត្ថិ អរហតោ អញ្ញាណន្តិ ។

[៧២] អត្ថិ អរហតោ អញ្ញាណន្តិ ។ អាមន្តា ។ ននុ វុត្តំ ភគវតា ជានត្វាហំ ភិក្ខវេ បស្សតោ

មិនមានទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[៧១] ការមិនដឹង របស់ព្រះអរហន្ត មានដែរឬ ។ អើ ។ ក្រែងព្រះមានព្រះភាគត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគត ពោលនូវការអស់ទៅនៃអាសវៈ របស់បុគ្គល កាលដឹង កាលឃើញ មិនពោលនូវការអស់ទៅ នៃអាសវៈ របស់បុគ្គល កាលមិនដឹង មិនពោលនូវការអស់ទៅនៃអាសវៈ របស់បុគ្គល កាលមិនឃើញទេ ម្នាលភិក្ខុទាំងឡាយ ការអស់ទៅនៃអាសវៈ របស់បុគ្គល កាលដឹងដូចម្តេច កាលឃើញដូចម្តេច (ការអស់ទៅនៃអាសវៈ របស់បុគ្គល កាលដឹង កាលឃើញយ៉ាងនេះថា) រូប ដូច្នេះ ការកើតឡើងនៃរូប ដូច្នេះ សេចក្តីវិនាសទៅនៃរូប ដូច្នេះ វេទនា ដូច្នេះ ។ បេ ។ សញ្ញាដូច្នេះ ។ បេ ។ សង្ខារទាំងឡាយ ដូច្នេះ ។ បេ ។ វិញ្ញាណ ដូច្នេះ ការកើតឡើងនៃវិញ្ញាណ ដូច្នេះ ការវិនាសទៅនៃវិញ្ញាណ ដូច្នេះ ម្នាលភិក្ខុទាំងឡាយ ការអស់ទៅនៃអាសវៈ របស់បុគ្គល កាលដឹងយ៉ាងនេះ កាលឃើញយ៉ាងនេះ ដូច្នេះឯង ពាក្យដូច្នេះមានក្នុងព្រះសូត្រឬ ។ អើ ។ បើដូច្នោះ អ្នកមិនគួរពោលថា ការមិនដឹង របស់ព្រះអរហន្ត មានទេ ។

[៧២] ការមិនដឹង របស់ព្រះអរហន្ត មានដែរឬ ។ អើ ។ ក្រែងព្រះមានព្រះភាគត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគត ពោលនូវការអស់ទៅ នៃអាសវៈ របស់បុគ្គល កាលដឹង កាលឃើញ

អាសវានំ ខយំ វទាមិ នោ អជានតោ នោ អបស្សតោ
កិញ្ច ភិក្ខវេ ជានតោ កឹ បស្សតោ អាសវានំ
ខយោ ហោតិ ឥទំ ទុក្ខន្តិ ភិក្ខវេ ជានតោ បស្ស-
តោ អាសវានំ ខយោ ហោតិ អយំ ទុក្ខសមុទយោតិ
ជានតោ បស្សតោ អាសវានំ ខយោ ហោតិ អយំ
ទុក្ខនិរោធោតិ ជានតោ បស្សតោ អាសវានំ ខយោ
ហោតិ អយំ ទុក្ខនិរោធគាមិនីបដិបទាតិ ជានតោ
បស្សតោ អាសវានំ ខយោ ហោតិ ឯវំ ខោ ភិក្ខវេ
ជានតោ ឯវំ បស្សតោ អាសវានំ ខយោ ហោតីតិ
អត្ថេវ សុត្តន្តោតិ ។ អាមន្តា ។ តេន ហិ ន វត្តព្វំ
អត្ថិ អរហតោ អញ្ញាណន្តិ ។

[៧៣] អត្ថិ អរហតោ អញ្ញាណន្តិ ។ អាមន្តា ។
ននុ វុត្តំ ភគវតា សព្វំ ភិក្ខវេ អនភិជានំ អបរិជានំ
អវិរាជយំ អប្បជហំ អភព្វោ ទុក្ខក្ខយាយ សព្វញ្ច
ខោ ភិក្ខវេ អភិជានំ បរិជានំ វិរាជយំ បជហំ ភព្វោ
ទុក្ខក្ខយាយាតិ អត្ថេវ សុត្តន្តោតិ ។ អាមន្តា ។

មិនពោលនូវការអស់ទៅនៃអាសវៈ របស់បុគ្គល កាលមិនដឹង មិនពោល នូវការអស់ទៅនៃអាសវៈ របស់បុគ្គល កាលមិនឃើញទេ ម្នាលភិក្ខុទាំងឡាយ ការអស់ទៅនៃអាសវៈ របស់បុគ្គល កាលដឹងដូចម្តេច កាលឃើញដូចម្តេច ម្នាលភិក្ខុទាំងឡាយ ការអស់ទៅនៃអាសវៈ របស់បុគ្គល កាលដឹង កាលឃើញថា នេះជាទុក្ខ ការអស់ទៅនៃអាសវៈ របស់បុគ្គល កាលដឹង កាលឃើញថា នេះជាទុក្ខសមុទ័យ ការអស់ទៅនៃអាសវៈ របស់បុគ្គល កាលដឹង កាលឃើញថា នេះជាទុក្ខនិរោធ ការអស់ទៅនៃអាសវៈ របស់បុគ្គល កាលដឹង កាលឃើញថា នេះជាទុក្ខនិរោធគាមិនីបដិបទា ម្នាលភិក្ខុទាំងឡាយ ការអស់ទៅនៃអាសវៈ របស់បុគ្គល កាលដឹងយ៉ាងនេះ កាលឃើញយ៉ាងនេះឯង ពាក្យដូច្នេះ មានក្នុងព្រះសូត្របុ ។ អើ ។ បើដូច្នោះ អ្នកមិនគួរពោលថា ការមិនដឹង របស់ព្រះអរហន្ត មានទេ ។

[៧៣] ការមិនដឹង របស់ព្រះអរហន្ត មានដែរឬ ។ អើ ។ ក្រែងព្រះមានព្រះភាគ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ បុគ្គល កាលមិនដឹងច្បាស់ មិនកំណត់ដឹង មិនបន្ទោបង់ មិនលះបង់ នូវធម៌ទាំងពួង មិនគួរដើម្បីអស់ទៅនៃទុក្ខ ម្នាលភិក្ខុទាំងឡាយ បុគ្គល កាលដឹងច្បាស់ កំណត់ដឹង បន្ទោបង់ លះបង់ នូវធម៌ទាំងពួង គួរដើម្បីអស់ទៅនៃទុក្ខ ពាក្យដូច្នេះ មានក្នុងព្រះសូត្របុ ។ អើ ។

អញ្ញាណកថា

តេន ហិ ន វត្តព្វំ អត្ថិ អរហតោ អញ្ញាណន្តិ ។

[៧៤] អត្ថិ អរហតោ អញ្ញាណន្តិ ។ អាមន្តា ។ ននុ វុត្តំ ភគវតា

សហាវស្ស ទស្សនសម្បទាយ
តយស្សុ ធម្មា ជហិតា ភវន្តិ
សក្កាយទិដ្ឋិ វិចិកិច្ឆិតញ្ច
សីលព្វតំ វាបិ យទត្ថិ កិញ្ចិ
ចតូហបាយេហិ ច វិប្បមុត្តោ
ឆ ចាភិឋានានិ អភព្វោ កាតុន្តិ

អត្ថេវ សុត្តន្តោតិ ។ អាមន្តា ។ តេន ហិ ន វត្តព្វំ អត្ថិ អរហតោ អញ្ញាណន្តិ ។

[៧៥] អត្ថិ អរហតោ អញ្ញាណន្តិ ។ អាមន្តា ។ ននុ វុត្តំ ភគវតា យស្មឹ ភិក្ខវេ សមយេ អរិយសាវកស្ស វិរជំ វីតមលំ ធម្មចក្ខុំ ឧទបាទិ យំ កិញ្ចិ សមុទយធម្មំ សព្វន្តំ និរោធធម្មន្តិ

បើដូច្នោះ អ្នកមិនគួរពោលថា ការមិនដឹង របស់ព្រះអរហន្ត មាន ទេ ។

[៧៤] ការមិនដឹង របស់ព្រះអរហន្ត មានឬ ។ អើ ។ ក្រែង ព្រះមានព្រះភាគ ទ្រង់ត្រាស់ថា

ធម៌ ៣ យ៉ាងគឺ សក្កាយទិដ្ឋិ វិចិកិច្ឆា និងសីលព្វតបរាមាសៈ ណាមួយ ដែលព្រះសោតាបន្នបុគ្គលនោះ បានលះបង់ហើយ ជាមួយនឹងទស្សនសម្ប័ទ គឺ សោតាបត្តិមគ្គ ម្យ៉ាងទៀត សោតាបន្នបុគ្គល បានរួចស្រឡះ ចាកអបាយទាំង ៤ ហើយ មិនគួរធ្វើនូវឋានៈដ៏អាក្រក់ ៦ យ៉ាងគឺ អនន្តរិយកម្ម ៥ និង កិរិយាផ្លាកចិត្តទៅកាន់សាសនាដទៃ

ពាក្យដូច្នេះ មានក្នុងព្រះសូត្រឬ ។ អើ ។ បើដូច្នោះ អ្នកមិនគួរពោល ថា ការមិនដឹង របស់ព្រះអរហន្ត មានទេ ។

[៧៥] ការមិនដឹង របស់ព្រះអរហន្ត មានឬ ។ អើ ។ ក្រែងព្រះមាន ព្រះភាគទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ក្នុងសម័យណា អរិយសាវ័ក មានធម្មចក្ខុ ប្រាសចាកធូលី ប្រាសចាកមន្ទិល កើតឡើងថា ធម្មជាតណា មួយ កើតឡើងជាធម្មតា ធម្មជាតទាំងអស់នោះ តែងរលត់ទៅជាធម្មតា

សហ ទស្សនុប្បាទា ភិក្ខវេ អរិយសាវកស្ស តីណិ សញ្ញោជនានិ បហីយន្តិ សក្កាយទិដ្ឋិ វិចិកិច្ឆា សី-លព្វតបរាមាសោតិ អត្ថេវ សុត្តន្តោតិ ។ អាមន្តា ។ តេន ហិ ន វត្តព្វំ អត្ថិ អរហតោ អញ្ញាណន្តិ ។

[៧៦] ន វត្តព្វំ អត្ថិ អរហតោ អញ្ញាណន្តិ ។ អាមន្តា ។ ននុ អរហា ឥត្ថីបុរិសានំ នាមគោត្តំ ន ជានេយ្យ មគ្គាមគ្គំ ន ជានេយ្យ តិណកដ្ឋវនប្បតីនំ នាមំ ន ជានេយ្យាតិ ។ អាមន្តា ។ ហញ្ចិ អរហា ឥត្ថីបុរិសានំ នាមគោត្តំ ន ជានេយ្យ មគ្គាមគ្គំ ន ជា-នេយ្យ តិណកដ្ឋវនប្បតីនំ នាមំ ន ជានេយ្យ តេន វត រេ វត្តព្វេ អត្ថិ អរហតោ អញ្ញាណន្តិ ។ អរហា ឥត្ថីបុរិសានំ នាមគោត្តំ ន ជានេយ្យ មគ្គាមគ្គំ ន ជានេយ្យ តិណកដ្ឋវនប្បតីនំ នាមំ ន ជានេយ្យាតិ អត្ថិ អរហតោ អញ្ញាណន្តិ ។ អាមន្តា ។ អរហា សោតាបត្តិផលំ វា សកទាគាមិផលំ វា អនាគាមិ-ផលំ វា អរហត្តំ វា ន ជានេយ្យាតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

អញ្ញាណកថា ។

ម្នាលភិក្ខុទាំងឡាយ (ក្នុងសម័យនោះ) អរិយសាវ័ក លះបង់នូវសញ្ញោជនៈ ៣ យ៉ាងគឺ សក្កាយទិដ្ឋិ វិចិកិច្ឆា សីលព្វតបរាមាសៈ ជាមួយនឹងការកើតឡើងនៃទស្សនៈគឺសោតាបត្តិមគ្គ ពាក្យដូច្នេះ មានក្នុងព្រះសូត្រឬ ។ អើ ។ បើដូច្នោះ អ្នកមិនគួរពោលថា ការមិនដឹង របស់ព្រះអរហន្ត មានទេ ។

[៧៦] អ្នកមិនគប្បីពោលថា ការមិនដឹង របស់ព្រះអរហន្ត មានឬ ។ អើ ។ ក្រែងព្រះអរហន្ត មិនគប្បីដឹងនូវនាមនិងគោត្ត របស់ស្ត្រីនិងបុរស មិនគប្បីដឹងនូវផ្លូវនិងមិនមែនផ្លូវ មិនគប្បីដឹងនូវឈ្មោះនៃស្មៅ ឈើតូចនិងឈើធំឬ ។ អើ ។ បើព្រះអរហន្ត មិនគប្បីដឹងនូវនាមនិងគោត្ត របស់ស្ត្រីនិងបុរស មិនគប្បីដឹងនូវផ្លូវនិងមិនមែនផ្លូវ មិនគប្បីដឹងនូវឈ្មោះ នៃស្មៅ ឈើតូចនិងឈើធំ ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគប្បីពោលថា ការមិនដឹង របស់ព្រះអរហន្ត មាន ។ ព្រះអរហន្ត មិនគប្បីដឹងនូវនាមនិងគោត្ត នៃស្ត្រីនិងបុរស មិនគប្បីដឹងនូវផ្លូវនិងមិនមែនផ្លូវ មិនគប្បីដឹងនូវឈ្មោះ នៃស្មៅ ឈើតូច និងឈើធំ ព្រោះហេតុនោះ ការមិនដឹង របស់ព្រះអរហន្ត មានឬ ។ អើ ។ ព្រះអរហន្ត មិនគប្បីដឹង នូវសោតាបត្តិផលក្តី នូវសកទាគាមិផលក្តី នូវអនាគាមិផលក្តី នូវអរហត្តផលក្តី ទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

ចប់ អញ្ញាណកថា ។

២៩

# កង្ខាកថា

[៧៧] អត្ថិ អរហតោ កង្ខាតិ ។ អាមន្តា ។ អត្ថិ អរហតោ វិចិកិច្ឆា វិចិកិច្ឆាបរិយុដ្ឋានំ វិចិកិច្ឆាសញ្ញោជនំ វិចិកិច្ឆានីវរណន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[៧៨] នត្ថិ អរហតោ វិចិកិច្ឆា វិចិកិច្ឆាបរិយុដ្ឋានំ វិចិកិច្ឆាសញ្ញោជនំ វិចិកិច្ឆានីវរណន្តិ ។ អាមន្តា ។ ហញ្ចិ នត្ថិ អរហតោ វិចិកិច្ឆា វិចិកិច្ឆាបរិយុដ្ឋានំ វិចិកិច្ឆាសញ្ញោជនំ វិចិកិច្ឆានីវរណំ នោ ច វត រេ វត្តព្វេ អត្ថិ អរហតោ កង្ខាតិ ។

[៧៩] អត្ថិ បុថុជ្ជនស្ស កង្ខា អត្ថិ តស្ស វិចិកិច្ឆា វិចិកិច្ឆាបរិយុដ្ឋានំ វិចិកិច្ឆាសញ្ញោជនំ វិចិកិច្ឆានីវរណន្តិ ។ អាមន្តា ។ អត្ថិ អរហតោ កង្ខា អត្ថិ តស្ស វិចិកិច្ឆា វិចិកិច្ឆាបរិយុដ្ឋានំ វិចិកិច្ឆាសញ្ញោជនំ វិចិកិច្ឆានីវរណន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[១៧៣] វាចា របស់បុគ្គលចូលកាន់បឋមជ្ឈាន រលត់ហើយ ពាក្យដូច្នេះ មានក្នុងព្រះសូត្រ ព្រោះហេតុនោះ វចីភេទ របស់បុគ្គលចូលកាន់បឋមជ្ឈាននោះ មានដែរឬ ។ អើ ។ បីតិ របស់បុគ្គលចូលកាន់តតិយជ្ឈាន រលត់ហើយ ។ បេ ។ អស្សាសបស្សាសៈ របស់បុគ្គលចូលកាន់ចតុត្ថជ្ឈាន រលត់ហើយ រូបសញ្ញា របស់បុគ្គលចូលកាន់អាកាសានញ្ចាយតនជ្ឈាន រលត់ហើយ អាកាសានញ្ចាយតនសញ្ញា របស់បុគ្គលចូលកាន់វិញ្ញាណញ្ចាយតនជ្ឈាន រលត់ហើយ វិញ្ញាណញ្ចាយតនសញ្ញា របស់បុគ្គលចូលកាន់អាកិញ្ចញ្ញាយតនជ្ឈាន រលត់ហើយ ។ បេ ។ អាកិញ្ចញ្ញាយតនសញ្ញា របស់បុគ្គលចូលកាន់នេវសញ្ញានាសញ្ញាយតនជ្ឈាន រលត់ហើយ សញ្ញានិងវេទនា របស់បុគ្គលចូលកាន់សញ្ញាវេទយិតនិរោធសមាបត្តិ រលត់ហើយ ពាក្យដូច្នេះ មាន

សុត្តន្តោតិ អត្ថិ តស្ស សញ្ញា ច វេទនា ចាតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[១៧៤] ន វត្តព្វំ សមាបន្នស្ស អត្ថិ វចីភេទោតិ ។ អាមន្តា ។ ននុ បឋមស្ស ឈានស្ស សទ្ទោ កណ្ដកោ វុត្តោ ភគវតាតិ ។ អាមន្តា ។ ហញ្ចិ បឋមស្ស ឈានស្ស សទ្ទោ កណ្ដកោ វុត្តោ ភគវតា តេន វត វេ វត្តព្វេ សមាបន្នស្ស អត្ថិ វចីភេទោតិ ។

[១៧៥] បឋមស្ស ឈានស្ស សទ្ទោ កណ្ដកោ វុត្តោ ភគវតាតិ សមាបន្នស្ស អត្ថិ វចីភេទោតិ ។ អាមន្តា ។ ទុតិយស្ស ឈានស្ស វិតក្កវិចារា កណ្ដកោ វុត្តា ភគវតា ។ បេ ។ តតិយស្ស ឈានស្ស បីតិ កណ្ដកោ វុត្តា ភគវតា ចតុត្ថស្ស ឈានស្ស អស្សាសបស្សាសា កណ្ដកោ វុត្តា ភគវតា អាកាសានញ្ចាយតនំ សមាបន្នស្ស រូបសញ្ញា កណ្ដកោ វុត្តា ភគវតា វិញ្ញាណញ្ចាយតនំ សមាបន្នស្ស អាកាសានញ្ចាយតនសញ្ញា កណ្ដកោ វុត្តា ភគវតា អាកិញ្ចញ្ញាយតនំ សមាបន្នស្ស វិញ្ញាណញ្ចាយតនសញ្ញា

ក្នុងព្រះសូត្រ ព្រោះហេតុនោះ សញ្ញានិងវេទនា របស់បុគ្គលចូលកាន់តតិយជ្ឈានជាដើមនោះ មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[១៧៤] បុគ្គលមិនគួរនិយាយថា វចីភេទ របស់បុគ្គលចូលកាន់សមាបត្តិ មានទេឬ ។ អើ ។ ក្រែងព្រះមានព្រះភាគត្រាស់ថា សំឡេង ជាសត្រូវដល់បឋមជ្ឈានឬ ។ អើ ។ បើព្រះមានព្រះភាគត្រាស់ថា សំឡេង ជាសត្រូវដល់បឋមជ្ឈានហើយ ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគួរពោលថា វចីភេទ របស់បុគ្គលចូលកាន់សមាបត្តិ មាន ។

[១៧៥] ព្រះមានព្រះភាគត្រាស់ថា សំឡេង ជាសត្រូវដល់បឋមជ្ឈាន ព្រោះហេតុនោះ វចីភេទ របស់បុគ្គលចូលកាន់សមាបត្តិ មានដែរឬ ។ អើ ។ ព្រះមានព្រះភាគត្រាស់ថា វិតក្កៈវិចារៈ ជាសត្រូវដល់ទុតិយជ្ឈាន ។ បេ ។ ព្រះមានព្រះភាគត្រាស់ថា បីតិ ជាសត្រូវដល់តតិយជ្ឈាន ព្រះមានព្រះភាគត្រាស់ថា អស្សាសប្បស្សាសៈ ជាសត្រូវដល់ចតុត្ថជ្ឈាន ព្រះមានព្រះភាគត្រាស់ថា រូបសញ្ញា ជាសត្រូវដល់បុគ្គលចូលកាន់អាកាសានញ្ចាយតនជ្ឈាន ព្រះមានព្រះភាគត្រាស់ថា អាកាសានញ្ចាយតនសញ្ញា ជាសត្រូវដល់បុគ្គលចូលកាន់វិញ្ញាណញ្ចាយតនជ្ឈាន ព្រះមានព្រះភាគត្រាស់ថា វិញ្ញាណញ្ចាយតនសញ្ញា ជា

កណ្ហកោ វុត្តា ភគវតា នេវសញ្ញានាសញ្ញាយតនំ សមាបន្នស្ស អាកិញ្ចញ្ញាយតនសញ្ញា កណ្ហកោ វុត្តោ ភគវតា ។ បេ ។ សញ្ញាវេទយិតនិរោធំ សមាបន្នស្ស សញ្ញា ច វេទនា ច កណ្ហកោ វុត្តោ ភគវតា អត្ថិ តស្ស សញ្ញា ច វេទនា ចាតិ ។ ន ហេវំ វត្តព្វំ ។ បេ ។

[១៧៦] ន វត្តព្វំ សមាបន្នស្ស អត្ថិ វចីភេទោតិ ។ អាមន្តា ។ ននុ វុត្តំ ភគវតា សិខិស្ស អានន្ទ ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស អភិភូ នាម សាវកោ ព្រហ្មលោកេ ឋិតោ សហស្សីលោកធាតុំ សរេន វិញ្ញាបេសិ

អារព្ភថ និក្ខមថ យុញ្ជថ ពុទ្ធសាសនេ
ធុនាថ មច្ចុនោ សេនំ នឡាគារំវ កុញ្ជរោ
យោ ឥមស្មឹ ធម្មវិនយេ អប្បមត្តោ វិហេស្សតិ[១]
បហាយ ជាតិសំសារំ ទុក្ខស្សន្តំ ករិស្សតីតិ

អត្ថេវ សុត្តន្តោតិ ។ អាមន្តា ។ តេន ហិ សមាបន្នស្ស អត្ថិ វចីភេទោតិ ។

វចីភេទកថា ។

---
១ ម. វិហរិស្សតិ ។

សត្រូវដល់បុគ្គលចូលកាន់អាកិញ្ចញ្ញាយតនជ្ឈាន ព្រះមានព្រះភាគត្រាស់ថា អាកិញ្ចញ្ញាយតនសញ្ញា ជាសត្រូវដល់បុគ្គលចូលកាន់នេវសញ្ញានាសញ្ញាយតនជ្ឈាន ។ បេ ។ ព្រះមានព្រះភាគត្រាស់ថា សញ្ញានិងវេទនា ជាសត្រូវដល់បុគ្គលចូលកាន់សញ្ញាវេទយិតនិរោធ ចុះសញ្ញានិងវេទនា របស់បុគ្គលចូលកាន់ទុតិយជ្ឈានជាដើមនោះ មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[១៧៦] បុគ្គលមិនគួរនិយាយថា វចីភេទ របស់បុគ្គលចូលកាន់សមាបត្តិ មានដែរឬ ។ អើ ។ ក្រែងព្រះមានព្រះភាគទ្រង់ត្រាស់ថា ម្នាលអានន្ទ សាវ័កឈ្មោះអភិភូ របស់ព្រះអរហន្តសម្មាសម្ពុទ្ធមានព្រះភាគ ទ្រង់ព្រះនាមសិខី ឋិតនៅក្នុងព្រហ្មលោក ហើយញុំាងពាន់នៃលោកធាតុឲ្យដឹងច្បាស់ ដោយសំឡេងថា

អ្នកទាំងឡាយ ចូរប្រុងប្រៀប ឈានទៅ ប្រកប ក្នុងពុទ្ធសាសនា ចូរកម្ចាត់បង់ នូវសេនានៃមច្ចុ ដូចជាដំរីកម្ចាត់បង់ នូវផ្ទះជាវិការៈនៃដើមបបុស បុគ្គលណា ជាអ្នកមិនប្រមាទ នៅក្នុងធម៌វិន័យនេះ បុគ្គលនោះ នឹងលះ នូវជាតិសំសារៈ ធ្វើនូវទីបំផុត នៃសេចក្តីទុក្ខបាន

ពាក្យដូច្នេះ មានក្នុងព្រះសូត្រឬ ។ អើ ។ បើដូច្នោះ វចីភេទ របស់បុគ្គលចូលកាន់សមាបត្តិ មាន ។

ចប់ វចីភេទកថា ។

# ទុក្ខាហារកថា

[១៧៧] ទុក្ខាហារេ មគ្គង្គំ មគ្គបរិយាបន្នន្តិ ។ អាមន្តា ។ យេ កេចិ ទុក្ខន្តិ វាចំ ភាសន្តិ សព្វេ តេ មគ្គំ ភាវេន្តីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[១៧៨] យេ កេចិ ទុក្ខន្តិ វាចំ ភាសន្តិ សព្វេ តេ មគ្គំ ភាវេន្តីតិ ។ អាមន្តា ។ ពាលបុថុជ្ជនា ទុក្ខន្តិ វាចំ ភាសន្តិ ពាលបុថុជ្ជនា មគ្គំ ភាវេន្តីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ មាតុឃាតកោ ។ បេ ។ បិតុឃាតកោ អរហន្តឃាតកោ រុហិរុប្បាទកោ[១] ។ បេ ។ សង្ឃភេទកោ ទុក្ខន្តិ វាចំ ភាសតិ សង្ឃភេទកោ មគ្គំ ភាវេតីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

ទុក្ខាហារកថា ។

# ចិត្តដ្ឋិតិកថា

[១៧៩] ឯកំ ចិត្តំ ទិវសំ តិដ្ឋតីតិ ។ អាមន្តា ។ ឧបឌ្ឍទិវសោ ឧប្បាទក្ខណោ ឧបឌ្ឍទិវសោ វយក្ខណោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

---
១ ម. លោហិតុប្បាទកោ ។

# ទុក្ខាហារកថា

[១៧៧] ការនាំមកនូវញាណ (ការដឹង) ក្នុងទុក្ខ ជាអង្គនៃមគ្គ ដែលរាប់បញ្ចូលក្នុងមគ្គឬ ។ អើ ។ ពួកជនណាមួយ ពោលវាចាថា ទុក្ខ ជនទាំងអស់នោះ តែងចម្រើននូវមគ្គឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[១៧៨] ពួកជនណាមួយ ពោលវាចាថា ទុក្ខ ជនទាំងអស់នោះ តែងចម្រើននូវមគ្គឬ ។ អើ ។ ពួកពាលបុថុជ្ជន ពោលវាចាថា ទុក្ខ ពួកពាលបុថុជ្ជន តែងចម្រើននូវមគ្គឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ ជនអ្នកសម្លាប់មាតា ។ បេ ។ ជនអ្នកសម្លាប់បិតា ជនអ្នកសម្លាប់ព្រះអរហន្ត ជនអ្នកធ្វើព្រះលោហិតឲ្យពុះពោរឡើង ។ បេ ។ ជនអ្នកបំបែកសង្ឃ ពោលវាចាថា ទុក្ខ ជនអ្នកបំបែកសង្ឃ តែងចម្រើននូវមគ្គដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

ចប់ ទុក្ខាហារកថា ។

# ចិត្តដ្ឋិតិកថា

[១៧៩] ចិត្តមួយ ឋិតនៅអស់មួយថ្ងៃឬ ។ អើ ។ កន្លះថ្ងៃជាឧប្បាទក្ខណៈ កន្លះថ្ងៃ ជាវយក្ខណៈឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

## ចិត្តដ្ឋិតិកថា

[១៨០] ឯកំ ចិត្តំ ទ្វេ ទិវសេ តិដ្ឋតីតិ ។ អាមន្តា ។ ទិវសោ ឧប្បាទក្ខណោ ទិវសោ វយក្ខណោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[១៨១] ឯកំ ចិត្តំ ចត្តារោ ទិវសេ តិដ្ឋតិ ។ បេ ។ អដ្ឋ ទិវសេ តិដ្ឋតិ ទស ទិវសេ តិដ្ឋតិ វីសតិ ទិវសេ តិដ្ឋតិ មាសំ តិដ្ឋតិ ទ្វេ មាសេ តិដ្ឋតិ ចត្តារោ មាសេ តិដ្ឋតិ អដ្ឋ មាសេ តិដ្ឋតិ ទស មាសេ តិដ្ឋតិ សំវច្ឆរំ តិដ្ឋតិ ទ្វេ វស្សានិ តិដ្ឋតិ ចត្តារិ វស្សានិ តិដ្ឋតិ អដ្ឋ វស្សានិ តិដ្ឋតិ ទស វស្សានិ តិដ្ឋតិ វីសតិ វស្សានិ តិដ្ឋតិ តឹស វស្សានិ តិដ្ឋតិ ចត្តាឡីស វស្សានិ តិដ្ឋតិ បញ្ញាស វស្សានិ តិដ្ឋតិ វស្សសតំ តិដ្ឋតិ ទ្វេ វស្សសតានិ តិដ្ឋតិ ចត្តារិ វស្សសតានិ តិដ្ឋតិ បញ្ច វស្សសតានិ តិដ្ឋតិ វស្សសហស្សំ តិដ្ឋតិ ទ្វេ វស្សសហស្សានិ តិដ្ឋតិ ចត្តារិ វស្សសហស្សានិ តិដ្ឋតិ អដ្ឋ វស្សសហស្សានិ តិដ្ឋតិ សោឡស វស្សសហស្សានិ តិដ្ឋតិ កប្បំ តិដ្ឋតិ ទ្វេ កប្បេ តិដ្ឋតិ ចត្តារោ កប្បេ តិដ្ឋតិ អដ្ឋ កប្បេ តិដ្ឋតិ

ចិត្តដ្ឋិតិកថា

[១៨០] ចិត្តមួយ ឋិតនៅអស់ពីរថ្ងៃឬ ។ អើ ។ មួយថ្ងៃ ជាឧប្បាទក្ខណៈ មួយថ្ងៃ ជាវយក្ខណៈឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[១៨១] ចិត្តមួយ ឋិតនៅអស់៤ថ្ងៃ ។ បេ ។ ឋិតនៅអស់៨ថ្ងៃ ឋិតនៅអស់ ១០ ថ្ងៃ ឋិតនៅអស់ ២០ ថ្ងៃ ឋិតនៅអស់ ១ ខែ ឋិតនៅអស់ ២ ខែ ឋិតនៅអស់ ៤ ខែ ឋិតនៅអស់ ៨ ខែ ឋិតនៅអស់ ១០ ខែ ឋិតនៅអស់ ១ ឆ្នាំ ឋិតនៅអស់ ២ ឆ្នាំ ឋិតនៅអស់ ៤ ឆ្នាំ ឋិតនៅអស់ ៨ ឆ្នាំ ឋិតនៅអស់ ១០ ឆ្នាំ ឋិតនៅអស់ ២០ ឆ្នាំ ឋិតនៅអស់ ៣០ ឆ្នាំ ឋិតនៅអស់ ៤០ ឆ្នាំ ឋិតនៅអស់ ៥០ ឆ្នាំ ឋិតនៅអស់ ១០០ ឆ្នាំ ឋិតនៅអស់ ២០០ ឆ្នាំ ឋិតនៅអស់ ៤០០ ឆ្នាំ ឋិតនៅអស់ ៥០០ ឆ្នាំ ឋិតនៅអស់ ១.០០០ ឆ្នាំ ឋិតនៅអស់ ២.០០០ ឆ្នាំ ឋិតនៅអស់ ៤.០០០ ឆ្នាំ ឋិតនៅអស់ ៨.០០០ ឆ្នាំ ឋិតនៅអស់ ១៦.០០០ ឆ្នាំ ឋិតនៅអស់ ១ កប្ប ឋិតនៅអស់ ២ កប្ប ឋិតនៅអស់ ៤ កប្ប ឋិតនៅអស់ ៨ កប្ប

សោឡស កប្បេ តិដ្ឋតិ ពត្តឹស កប្បេ តិដ្ឋតិ ចតុ-ស្សដ្ឋី កប្បេ តិដ្ឋតិ បញ្ច កប្បសតានិ តិដ្ឋតិ កប្ប-សហស្សំ តិដ្ឋតិ ទ្វេ កប្បសហស្សានិ តិដ្ឋតិ ចត្តារិ កប្បសហស្សានិ តិដ្ឋតិ អដ្ឋ កប្បសហស្សានិ តិដ្ឋតិ សោឡស កប្បសហស្សានិ តិដ្ឋតិ វីសតិ កប្បស-ហស្សានិ តិដ្ឋតិ ចត្តាឡីស កប្បសហស្សានិ តិដ្ឋតិ សដ្ឋី កប្បសហស្សានិ តិដ្ឋតិ ។ បេ ។ ចតុរាសីតិ កប្បសហស្សានិ តិដ្ឋតីតិ ។ អាមន្តា ។ ទ្វេ ចត្តា-ឡីស កប្បសហស្សានិ ឧប្បាទក្ខណោ ទ្វេ ចត្តា-ឡីស កប្បសហស្សានិ វយក្ខណោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[១៨២] ឯកំ ចិត្តំ ទិវសំ តិដ្ឋតីតិ ។ អា-មន្តា ។ អត្ថញ្ញេ ធម្មា ឯកាហំ ពហុម្បិ ឧប្បជ្ជិត្វា និរុជ្ឈន្តីតិ ។ អាមន្តា ។ តេ ធម្មា ចិត្តេន លហុប-រិវត្តាតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[១៨៣] តេ ធម្មា ចិត្តេន លហុបរិវត្តាតិ ។ អាមន្តា ។ ននុ វុត្តំ ភគវតា នាហំ ភិក្ខវេ អញ្ញំ ឯកំ ធម្មម្បិ សមនុបស្សាមិ យំ ឯវំ លហុបរិវត្តំ

បិតនៅអស់ ១៦ កប្ប បិតនៅអស់ ៣២ កប្ប បិតនៅអស់ ៦៤ កប្ប បិតនៅអស់ ៥ រយកប្ប បិតនៅអស់ ១ ពាន់កប្ប បិតនៅអស់ ២ ពាន់កប្ប បិតនៅអស់ ៤ ពាន់កប្ប បិតនៅអស់ ៨ ពាន់កប្ប បិតនៅអស់ ១៦ ពាន់កប្ប បិតនៅអស់ ២០ ពាន់កប្ប បិតនៅអស់ ៤០ ពាន់កប្ប បិតនៅអស់ ៦០ ពាន់កប្ប ។ បេ ។ បិតនៅអស់ ៨៤ ពាន់កប្បឬ ។ អើ ។ ៤២ ពាន់កប្ប ជាឧប្បាទក្ខណៈ ៤២ ពាន់កប្ប ជាវយក្ខណៈឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[១៨២] ចិត្តមួយ បិតនៅអស់ ១ ថ្ងៃឬ ។ អើ ។ ពួកធម៌ដទៃ ដែលកើតឡើងអស់ ១ ថ្ងៃ ឬច្រើនថ្ងៃ ហើយរលត់ទៅវិញ មានដែរឬ ។ អើ ។ ធម៌ទាំងនោះ ប្រព្រឹត្តទៅរហ័ស ដោយចិត្តដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[១៨៣] ធម៌ទាំងនោះ ប្រព្រឹត្តទៅរហ័ស ដោយចិត្តដែរឬ ។ អើ ។ ក្រែងព្រះមានព្រះភាគត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតពិចារណារកមិនឃើញ នូវធម៌ដទៃ សូម្បីតែមួយ ដែលប្រព្រឹត្តទៅរហ័ស

យថយិទំ ភិក្ខវេ ចិត្តំ យាវញ្ចិទំ ភិក្ខវេ ឧបមាបិ ន សុករា យាវ លហុបរិវត្តំ ចិត្តន្តិ អត្ថេវ សុត្តន្តោតិ ។ អាមន្តា ។ តេន ហិ ន វត្តព្វំ តេ ធម្មា ចិត្តេន លហុបរិវត្តាតិ ។

[១៨៤] តេ ធម្មា ចិត្តេន លហុបរិវត្តាតិ ។ អាមន្តា ។ ននុ វុត្តំ ភគវតា សេយ្យថាបិ ភិក្ខវេ មក្កដោ អរញ្ញេ បវនេ ចរមានោ សាខំ គណ្ហាតិ តំ មុញ្ចិត្វា អញ្ញំ គណ្ហាតិ តំ មុញ្ចិត្វា អញ្ញំ គណ្ហាតិ ឯវមេវ ខោ ភិក្ខវេ យទិទំ វុច្ចតិ ចិត្តំ ឥតិបិ មនោ ឥតិបិ វិញ្ញាណំ ឥតិបិ តំ រត្តិយា ច ទិវសស្ស ច អញ្ញទេវ ឧប្បជ្ជតិ អញ្ញំ និរុជ្ឈតីតិ អត្ថេវ សុត្តន្តោតិ ។ អាមន្តា ។ តេន ហិ ន វត្តព្វំ តេ ធម្មា ចិត្តេន លហុបរិវត្តាតិ ។

[១៨៥] ឯកំ ចិត្តំ ទិវសំ តិដ្ឋតីតិ ។ អាមន្តា ។ ចក្ខុវិញ្ញាណំ ទិវសំ តិដ្ឋតីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ សោតវិញ្ញាណំ ។ បេ ។ ឃានវិញ្ញាណំ ជិវ្ហាវិញ្ញាណំ កាយវិញ្ញាណំ អកុសលំ ចិត្តំ រាគសហគតំ ទោសសហគតំ មោហសហគតំ

យ៉ាងនេះ ដូចជាចិត្តនេះទេ ម្នាលភិក្ខុទាំងឡាយ ចិត្តនេះ ប្រព្រឹត្តទៅរហ័ស មិនងាយបុគ្គលនឹងធ្វើសេចក្តីប្រៀបបានឡើយ ពាក្យដូច្នេះ មានក្នុងព្រះសូត្រឬ ។ អើ ។ ព្រោះហេតុនោះ អ្នកមិនគួរពោលថា ធម៌ទាំងនោះ ប្រព្រឹត្តទៅរហ័ស ដោយចិត្តទេ ។

[១៨៤] ធម៌ទាំងនោះ ប្រព្រឹត្តទៅរហ័ស ដោយចិត្តឬ ។ អើ ។ ក្រែងព្រះមានព្រះភាគត្រាស់ថា ម្នាលភិក្ខុទាំងឡាយ សត្វស្វា ត្រាច់ទៅក្នុងព្រៃតូច ព្រៃធំ ចាប់កាន់មែកឈើ លែងមែកឈើនោះ ហើយចាប់មែកដទៃ លែងមែកនោះហើយ ចាប់មែកដទៃ យ៉ាងណាមិញ ម្នាលភិក្ខុទាំងឡាយ ធម្មជាតណា ហៅថាចិត្តដូច្នេះក្តី ហៅថាមនោដូច្នេះក្តី ហៅថាវិញ្ញាណដូច្នេះក្តី ធម្មជាតនោះ ជាធម្មជាតដទៃមែនពិត កើតឡើងក្នុងវេលាយប់ផង ក្នុងវេលាថ្ងៃផង ធម្មជាតដទៃរលត់ទៅវិញផង ពាក្យដូច្នេះ មានក្នុងព្រះសូត្រឬ ។ អើ ។ ព្រោះហេតុនោះ អ្នកមិនគួរពោលថា ធម៌ទាំងនោះ ប្រព្រឹត្តទៅរហ័ស ដោយចិត្តទេ ។

[១៨៥] ចិត្តមួយ ឋិតនៅអស់ ១ ថ្ងៃឬ ។ អើ ។ ចក្ខុវិញ្ញាណឋិតនៅអស់ ១ ថ្ងៃដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ សោតវិញ្ញាណ ។ បេ ។ ឃានវិញ្ញាណ ជិវ្ហាវិញ្ញាណ កាយវិញ្ញាណ អកុសលចិត្ត ចិត្តដែលប្រកបដោយរាគៈ ប្រកបដោយទោសៈ ប្រកបដោយមោហៈ

មានសហគតំ ទិដ្ឋិសហគតំ វិចិកិច្ឆាសហគតំ ថីនសហគតំ ឧទ្ធច្ចសហគតំ អហិរិកសហគតំ អនោត្តប្បសហគតំ ចិត្តំ និរុសំ តិដ្ឋតីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[១៨៦] ឯកំ ចិត្តំ និរុសំ តិដ្ឋតីតិ ។ អាមន្តា ។ យេនេវ ចិត្តេន ចក្ខុនា រូបំ បស្សតិ តេនេវ ចិត្តេន សោតេន សទ្ទំ សុណាតិ ។ បេ ។ ឃានេន គន្ធំ ឃាយតិ ជិវ្ហាយ រសំ សាយតិ កាយេន ផោដ្ឋព្វំ ផុសតិ ។ បេ ។ មនសា ធម្មំ វិជានាតិ ។ បេ ។ យេនេវ ចិត្តេន មនសា ធម្មំ វិជានាតិ តេនេវ ចិត្តេន ចក្ខុនា រូបំ បស្សតិ ។ បេ ។ សោតេន សទ្ទំ សុណាតិ ឃានេន គន្ធំ ឃាយតិ ជិវ្ហាយ រសំ សាយតិ ។ បេ ។ កាយេន ផោដ្ឋព្វំ ផុសតីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[១៨៧] ឯកំ ចិត្តំ និរុសំ តិដ្ឋតីតិ ។ អាមន្តា ។ យេនេវ ចិត្តេន អភិក្កមតិ តេនេវ ចិត្តេន បដិក្កមតិ យេនេវ ចិត្តេន បដិក្កមតិ តេនេវ ចិត្តេន អភិក្កមតិ យេនេវ ចិត្តេន អាលោកេតិ តេនេវ ចិត្តេន វិលោកេតិ យេនេវ ចិត្តេន វិលោកេតិ តេនេវ ចិត្តេន អាលោកេតិ យេនេវ ចិត្តេន សម្មិញ្ជេតិ

ប្រកបដោយមានះ ប្រកបដោយទិដ្ឋិ ប្រកបដោយវិចិកិច្ឆា ប្រកបដោយថីនៈ ប្រកបដោយឧទ្ធច្ចៈ ប្រកបដោយអហិរិកៈ ប្រកបដោយអនោត្តប្បៈ ឋិតនៅអស់ ១ ថ្ងៃដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[១៨៦] ចិត្តមួយ ឋិតនៅអស់ ១ ថ្ងៃឬ ។ អើ ។ បុគ្គលឃើញរូបដោយភ្នែក ដោយចិត្តណា ក៏ឮសំឡេងដោយត្រចៀក ដោយចិត្តនោះដែរ ។ បេ ។ ធុំក្លិនដោយច្រមុះ លិទ្ធភ្លក្សរសដោយអណ្តាត ពាល់ត្រូវផ្សព្វដោយកាយ ។ បេ ។ ដឹងច្បាស់ធម្មារម្មណ៍ដោយចិត្ត ។ បេ ។ បុគ្គលដឹងច្បាស់ធម្មារម្មណ៍ដោយចិត្ត ដោយចិត្តណា ក៏ឃើញរូបដោយភ្នែក ដោយចិត្តនោះដែរ ។ បេ ។ ឮសំឡេងដោយត្រចៀក ធុំក្លិនដោយច្រមុះ លិទ្ធភ្លក្សរសដោយអណ្តាត ។ បេ ។ ពាល់ត្រូវផ្សព្វដោយកាយ (ដោយចិត្តនោះ) ដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[១៨៧] ចិត្តមួយ ឋិតនៅអស់ ១ ថ្ងៃឬ ។ អើ ។ បុគ្គល ឈានទៅមុខដោយចិត្តណា ឈានបែរមកក្រោយ ដោយចិត្តនោះដែរ ឈានបែរមកក្រោយ ដោយចិត្តណា ឈានទៅមុខ ដោយចិត្តនោះដែរ មើលទៅមុខដោយចិត្តណា មើលចំហៀង ដោយចិត្តនោះដែរ មើលចំហៀង ដោយចិត្តណា មើលទៅមុខ ដោយចិត្តនោះដែរ បត់អវយវៈចូល ដោយចិត្តណា

តេនេវ ចិត្តេន បសាវេតិ យេនេវ ចិត្តេន បសាវេតិ តេនេវ ចិត្តេន សម្មិញ្ជេតីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[១៨៨] អាកាសានញ្ចាយតនូបគានំ ទេវានំ ឯកំ ចិត្តំ យាវតាយុកំ តិដ្ឋតីតិ ។ អាមន្តា ។ មនុស្សានំ ឯកំ ចិត្តំ យាវតាយុកំ តិដ្ឋតីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[១៨៩] អាកាសានញ្ចាយតនូបគានំ ទេវានំ ឯកំ ចិត្តំ យាវតាយុកំ តិដ្ឋតីតិ ។ អាមន្តា ។ ចាតុម្មហារាជិកានំ ទេវានំ ។ បេ ។ តាវត្តឹសានំ ទេវានំ . . . យាមានំ ទេវានំ . . . តុសិតានំ ទេវានំ . . . និម្មានរតីនំ ទេវានំ . . . បរនិម្មិតវសវត្តីនំ ទេវានំ . . . ព្រហ្មបារិសជ្ជានំ ទេវានំ . . . ព្រហ្មបុរោហិតានំ ទេវានំ . . . មហាព្រហ្មានំ ទេវានំ . . . បរិត្តាភានំ ទេវានំ . . . អប្បមាណាភានំ ទេវានំ . . . អាភស្សរានំ ទេវានំ . . . បរិត្តសុភានំ ទេវានំ . . .

លាអវយវៈចេញ ដោយចិត្តនោះដែរ លាអវយវៈចេញ ដោយចិត្តណា បត់អវយវៈចូល ដោយចិត្តនោះដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[១៨៨] ចិត្តមួយ របស់ពួកទេវតា ដែលចូលទៅកើតក្នុងជាន់អាកាសានញ្ចាយតនៈ ឋិតនៅដរាបដល់អស់អាយុដែរឬ ។ អើ ។ ចិត្តមួយ របស់មនុស្សទាំងឡាយ ឋិតនៅដរាបដល់អស់អាយុដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[១៨៩] ចិត្តមួយ របស់ពួកទេវតា ដែលចូលទៅកើតក្នុងជាន់អាកាសានញ្ចាយតនៈ ឋិតនៅដរាបដល់អស់អាយុដែរឬ ។ អើ ។ ចិត្តមួយ របស់ពួកទេវតាដែលឋិតនៅក្នុងឋានចាតុម្មហារាជិកា ។ បេ ។ របស់ពួកទេវតា ដែលឋិតនៅក្នុងឋានតាវត្តិង្ស . . . ពួកទេវតា ដែលឋិតនៅក្នុងឋានយាមៈ . . . ពួកទេវតា ដែលឋិតនៅក្នុងឋានតុសិត . . . ពួកទេវតា ដែលឋិតនៅក្នុងឋាននិម្មានរតី . . . ពួកទេវតា ដែលឋិតនៅក្នុងឋានបរនិម្មិតវសវត្តី . . . ពួកទេវតា ដែលឋិតនៅក្នុងឋានព្រហ្មបារិសជ្ជា . . . ពួកទេវតា ដែលឋិតនៅក្នុងឋានព្រហ្មបុរោហិតា . . . ពួកទេវតា ដែលឋិតនៅក្នុងឋានមហាព្រហ្ម . . . ពួកទេវតា ដែលឋិតនៅក្នុងឋានបរិត្តាភា . . . ពួកទេវតា ដែលឋិតនៅក្នុងឋានអប្បមាណាភា . . . ពួកទេវតា ដែលឋិតនៅក្នុងឋានអាភស្សរៈ . . . ពួកទេវតា ដែលឋិតនៅក្នុងឋានបរិត្តសុភា . . .

អប្បមាណាសុភានំ ទេវានំ . . . សុភកិណ្ហានំ ទេវានំ . . . វេហប្ផលានំ ទេវានំ . . . អវិហានំ ទេវានំ . . . អតប្បានំ ទេវានំ . . . សុទស្សានំ ទេវានំ . . . សុទស្សីនំ ទេវានំ ។ បេ ។ អកនិដ្ឋានំ ទេវានំ ឯកំ ចិត្តំ យាវតាយុកំ តិដ្ឋតីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[១៩០] អាកាសានញ្ចាយតនូបកានំ ទេវានំ វីសតិ កប្បសហស្សានិ អាយុប្បមាណំ អាកាសានញ្ចាយតនូបកានំ ទេវានំ ឯកំ ចិត្តំ វីសតិ កប្បសហស្សានិ តិដ្ឋតីតិ ។ អាមន្តា ។ មនុស្សានំ វស្សសតំ អាយុប្បមាណំ មនុស្សានំ ឯកំ ចិត្តំ វស្សសតំ តិដ្ឋតីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[១៩១] អាកាសានញ្ចាយតនូបកានំ ទេវានំ វីសតិ កប្បសហស្សានិ អាយុប្បមាណំ អាកាសានញ្ចាយតនូបកានំ ទេវានំ ឯកំ ចិត្តំ វីសតិ កប្បសហស្សានិ តិដ្ឋតីតិ ។ អាមន្តា ។ ចាតុម្មហារាជិកានំ ទេវានំ បញ្ច វស្សសតានិ អាយុប្បមាណំ

ពួកទេវតា ដែលឋិតនៅក្នុងឋានអប្បមាណសុភា ... ពួកទេវតា ដែលឋិតនៅក្នុងឋានសុភកិណ្ហា ... ពួកទេវតា ដែលឋិតនៅក្នុងឋានវេហប្ផលា ... ពួកទេវតា ដែលឋិតនៅក្នុងឋានអវិហា ... ពួកទេវតា ដែលឋិតនៅក្នុងឋានអតប្បា ... ពួកទេវតា ដែលឋិតនៅក្នុងឋានសុទស្សា ... ពួកទេវតា ដែលឋិតនៅក្នុងឋានសុទស្សី ។ បេ ។ ពួកទេវតា ដែលឋិតនៅក្នុងឋានអកនិដ្ឋ ឋិតនៅដរាបដល់អស់អាយុដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[១៩០] ២០ ពាន់កប្ប ជាប្រមាណនៃអាយុ របស់ពួកទេវតា ដែលចូលទៅកើតក្នុងជាន់អាកាសានញ្ចាយតនៈ ចិត្តមួយ របស់ពួកទេវតា ដែលចូលទៅកើតក្នុងជាន់អាកាសានញ្ចាយតនៈ (នោះ) ឋិតនៅអស់ ២០ ពាន់កប្បដែរឬ ។ អើ ។ មួយរយឆ្នាំ ជាប្រមាណនៃអាយុ របស់មនុស្សទាំងឡាយ ចិត្តមួយ របស់ពួកមនុស្ស ឋិតនៅអស់មួយរយឆ្នាំដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[១៩១] ២០ ពាន់កប្ប ជាប្រមាណនៃអាយុ របស់ពួកទេវតា ដែលចូលទៅកើតក្នុងជាន់អាកាសានញ្ចាយតនៈ ចិត្តមួយ របស់ពួកទេវតា ដែលចូលទៅកើតក្នុងជាន់អាកាសានញ្ចាយតនៈ ឋិតនៅអស់ ២០ ពាន់កប្បដែរឬ ។ អើ ។ ប្រាំរយឆ្នាំ ជាប្រមាណនៃអាយុ របស់ពួកទេវតា

ចាតុម្មហារាជិកានំ ទេវានំ ឯកំ ចិត្តំ បញ្ច វស្សសតានិ តិដ្ឋតិ ។ បេ ។ វស្សសហស្សំ តិដ្ឋតិ ទ្វេ វស្សសហស្សានិ តិដ្ឋតិ ចត្តារិ វស្សសហស្សានិ តិដ្ឋតិ អដ្ឋ វស្សសហស្សានិ តិដ្ឋតិ សោឡស វស្សសហស្សានិ តិដ្ឋតិ កប្បស្ស តតិយភាគំ តិដ្ឋតិ ឧបឌ្ឍកប្បំ តិដ្ឋតិ ឯកំ កប្បំ តិដ្ឋតិ ទ្វេ កប្បេ តិដ្ឋតិ ចត្តារោ កប្បេ តិដ្ឋតិ អដ្ឋ កប្បេ តិដ្ឋតិ សោឡស កប្បេ តិដ្ឋតិ ពត្តឹស កប្បេ តិដ្ឋតិ ចតុសដ្ឋី កប្បេ តិដ្ឋតិ បញ្ច កប្បសតានិ តិដ្ឋតិ កប្បសហស្សំ តិដ្ឋតិ ទ្វេ កប្បសហស្សានិ តិដ្ឋតិ ចត្តារិ កប្បសហស្សានិ តិដ្ឋតិ អដ្ឋ កប្បសហស្សានិ តិដ្ឋតិ ។ បេ ។ អកនិដ្ឋានំ ទេវានំ សោឡស កប្បសហស្សានិ អាយុប្បមាណំ អកនិដ្ឋានំ ទេវានំ ឯកំ ចិត្តំ សោឡស កប្បសហស្សានិ តិដ្ឋតីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[១៩២] អាកាសានញ្ចាយតនូបគានំ ទេវានំ ចិត្តំ មុហុត្តំ មុហុត្តំ ឧប្បជ្ជតិ មុហុត្តំ មុហុត្តំ និរុជ្ឈតីតិ ។ អាមន្តា ។ អាកាសានញ្ចាយតនូបគានំ ទេវានំ មុហុត្តំ មុហុត្តំ ចវន្តិ មុហុត្តំ មុហុត្តំ ឧប្បជ្ជន្តីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

ដែលឋិតនៅក្នុងជាន់ចាតុម្មហារាជិកា ចិត្តមួយ របស់ពួកទេវតាក្នុងឋាន ចាតុម្មហារាជិកា (នោះ) ឋិតនៅអស់ប្រាំរយឆ្នាំដែរឬ ។ បេ ។ ឋិតនៅអស់ ១ ពាន់ឆ្នាំ ឋិតនៅអស់ ២ ពាន់ឆ្នាំ ឋិតនៅអស់ ៤ ពាន់ឆ្នាំ ឋិតនៅអស់ ៨ ពាន់ឆ្នាំ ឋិតនៅអស់ ១៦ ពាន់ឆ្នាំ ឋិតនៅអស់ភាគជាគម្រប់បីនៃកប្ប ឋិតនៅអស់កន្លះកប្ប ឋិតនៅអស់ ១ កប្ប ឋិតនៅអស់ ២ កប្ប ឋិតនៅអស់ ៤ កប្ប ឋិតនៅអស់ ៨ កប្ប ឋិតនៅអស់ ១៦ កប្ប ឋិតនៅអស់ ៣២ កប្ប ឋិតនៅអស់ ៦៤ កប្ប ឋិតនៅអស់ប្រាំរយកប្ប ឋិតនៅអស់ ១ ពាន់កប្ប ឋិតនៅអស់ ២ ពាន់កប្ប ឋិតនៅអស់ ៤ ពាន់កប្ប ឋិតនៅអស់ ៨ ពាន់កប្ប ។ បេ ។ ១៦ ពាន់កប្ប ជាប្រមាណនៃអាយុ របស់ទេវតាក្នុងឋានអកនិដ្ឋ ចិត្តមួយ របស់ពួកទេវតាដែលឋិតនៅក្នុងឋានអកនិដ្ឋ ឋិតនៅអស់ ១៦ ពាន់កប្បដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[១៩២] ចិត្ត របស់ពួកទេវតាដែលចូលទៅកើតក្នុងជាន់អាកាសានញ្ចាយតនៈ កើតឡើងមួយស្របក់ៗ រលត់ទៅមួយស្របក់ៗឬ ។ អើ ។ ពួកទេវតា ដែលចូលទៅកើតក្នុងជាន់អាកាសានញ្ចាយតនៈ ច្យុតមួយស្របក់ ៗ កើតឡើងមួយស្របក់ ៗ ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[១៩៣] អាកាសានញ្ចាយតនូបគានំ ទេវានំ ឯកំ ចិត្តំ យាវតាយុកំ តិដ្ឋតីតិ ។ អាមន្តា ។ អាកាសានញ្ចាយតនូបគា ទេវា យេនេវ ចិត្តេន ឧប្បជ្ជន្តិ តេនេវ ចិត្តេន ចវន្តីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

ចិត្តដ្ឋិតិកថា ។

# កុក្កុឡកថា

[១៩៤] សព្វេ សង្ខារា អនោធឹកត្វា កុក្កុឡាតិ ។ អាមន្តា ។ ននុ អត្ថិ សុខា វេទនា កាយិកំ សុខំ ចេតសិកំ សុខំ ទិព្វំ សុខំ មានុសកំ សុខំ លាភសុខំ សក្ការសុខំ យានសុខំ សយនសុខំ ឥស្សរិយសុខំ អាធិបច្ចសុខំ គិហិសុខំ សាមញ្ញសុខំ សាសវំ សុខំ អនាសវំ សុខំ ឧបធិសុខំ និរុបធិសុខំ សាមិសំ សុខំ និរាមិសំ សុខំ សប្បីតិកំ សុខំ និប្បីតិកំ សុខំ ឈានសុខំ វិមុត្តិសុខំ កាមសុខំ នេក្ខម្មសុខំ បវិវេកសុខំ ឧបសមសុខំ សម្ពោធសុខន្តិ ។ អាមន្តា ។ ហញ្ចិ អត្ថិ សុខា វេទនា ។ បេ ។

[១៩៣] ចិត្តមួយ របស់ពួកទេវតា ដែលចូលទៅកើតក្នុងជាន់អាកាសានញ្ចាយតនៈ ឋិតនៅដរាបដល់អស់អាយុឬ ។ អើ ។ ពួកទេវតាដែលចូលទៅកើតក្នុងជាន់អាកាសានញ្ចាយតនៈ កើតឡើងដោយចិត្តណា ច្យុតទៅវិញដោយចិត្តនោះឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

ចប់ ចិត្តដ្ឋិតិកថា ។

# កុក្កុឡកថា

[១៩៤] សង្ខារទាំងពួង ដូចជាផេះក្តៅ ធ្វើមិនឲ្យមានព្រំដែនឬ ។ អើ ។ វេទនា ជាសុខ គឺសុខប្រព្រឹត្តទៅក្នុងកាយ សុខប្រព្រឹត្តទៅក្នុងចិត្ត សុខជាទិព្វ សុខជារបស់មនុស្ស សុខដោយលាភ សុខដោយសក្ការៈ សុខដោយយាន សុខដោយដំណេក សុខដោយភាពនៃខ្លួនជាធំ សុខដោយភាពនៃខ្លួនជាអធិបតី សុខរបស់គ្រហស្ថ សុខរបស់សមណៈ សុខប្រកបដោយអាសវៈ សុខមិនមានអាសវៈ សុខប្រកបដោយឧបធិក្កិលេស សុខមិនមានឧបធិក្កិលេស សុខប្រកបដោយអាមិសៈ សុខមិនមានអាមិសៈ សុខប្រកបដោយបីតិ សុខមិនមានបីតិ សុខដោយឈាន សុខដោយវិមុត្តិ សុខក្នុងកាម សុខដោយការចេញចាកកាម សុខដោយការស្ងប់ស្ងាត់ សុខដោយការរម្ងាប់ សុខដោយការត្រាស់ដឹង ក្រែងមានដែរឬ ។ អើ ។ បើវេទនា ជាសុខ ។ បេ ។

សម្ពោធសុខំ នោ វត វេ វត្តព្វេ សព្វេ សង្ខារា អនោ-
ធីកត្វា កុក្កុឡាតិ ។

[១៩៥] សព្វេ សង្ខារា អនោធីកត្វា កុក្កុឡា-
តិ ។ អាមន្តា ។ សព្វេ សង្ខារា ទុក្ខា វេទនា កា-
យិកំ ទុក្ខំ ចេតសិកំ ទុក្ខំ សោកបរិទេវទុក្ខទោ-
មនស្សុបាយាសាតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[១៩៦] ន វត្តព្វំ សព្វេ សង្ខារា អនោធីកត្វា
កុក្កុឡាតិ ។ អាមន្តា ។ ននុ វុត្តំ ភគវតា សព្វំ
ភិក្ខវេ អាទិត្តំ កិញ្ច ភិក្ខវេ សព្វំ អាទិត្តំ ចក្ខុំ ភិក្ខ-
វេ អាទិត្តំ រូបា អាទិត្តា ចក្ខុវិញ្ញាណំ អាទិត្តំ ចក្ខុ-
សម្ផស្សោ អាទិត្តោ យម្បិទំ ចក្ខុសម្ផស្សប្បច្ចយា
ឧប្បជ្ជតិ វេទយិតំ សុខំ វា ទុក្ខំ វា អទុក្ខមសុខំ វា
តម្បិ អាទិត្តំ កេន អាទិត្តំ អាទិត្តំ រាគគ្គិនា ទោ-
សគ្គិនា មោហគ្គិនា អាទិត្តំ ជាតិយា ជរាមរណេន[១]
សោកេហិ បរិទេវេហិ ទុក្ខេហិ ទោមនស្សេហិ ឧ-
បាយាសេហិ អាទិត្តន្តិ វទាមិ សោតំ អាទិត្តំ សទ្ទា
អាទិត្តា ។ បេ ។ ឃានំ អាទិត្តំ គន្ធា អាទិត្តា ។ បេ ។

១ ម. ជរាយ មរណេន ។

កុក្កុឡកថា

*សុខកើតអំពីការត្រាស់ដឹង មាន ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា សង្ខារទាំងពួង ដូចជាផេះក្តៅ ធ្វើមិនឲ្យមានព្រំដែនទេ ។*

*[១៩៥] សង្ខារទាំងពួង ដូចជាផេះក្តៅ ធ្វើមិនឲ្យមានព្រំដែនឬ ។ អើ ។ សង្ខារទាំងពួង មានវេទនាជាទុក្ខ គឺទុក្ខប្រព្រឹត្តទៅក្នុងកាយ ទុក្ខប្រព្រឹត្តទៅក្នុងចិត្ត សេចក្តីសោក ខ្សឹកខ្សួល ទុក្ខ ទោមនស្ស សេចក្តីសង្រេងសង្រៃ ដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។*

*[១៩៦] បុគ្គលមិនគួរនិយាយថា សង្ខារទាំងពួង ដូចជាផេះក្តៅ ធ្វើមិនឲ្យមានព្រំដែនទេឬ ។ អើ ។ ក្រែងព្រះមានព្រះភាគត្រាស់ថា ម្នាលភិក្ខុទាំងឡាយ វត្ថុទាំងអស់ជារបស់ក្តៅ ម្នាលភិក្ខុទាំងឡាយ វត្ថុទាំងអស់ គឺអ្វី ជារបស់ក្តៅ ម្នាលភិក្ខុទាំងឡាយ ភ្នែកជារបស់ក្តៅ រូបជារបស់ក្តៅ ចក្ខុវិញ្ញាណជារបស់ក្តៅ ចក្ខុសម្ផស្សជារបស់ក្តៅ ធម្មជាតណា ដែលទទួលអារម្មណ៍ ជាសុខក្តី ជាទុក្ខក្តី មិនមែនជាទុក្ខមិនមែនជាសុខក្តី កើតឡើងព្រោះចក្ខុសម្ផស្សជាបច្ច័យ ធម្មជាតនោះជារបស់ក្តៅ ចុះក្តៅដោយអ្វី ក្តៅដោយភ្លើងគឺរាគៈ ក្តៅដោយភ្លើងគឺទោសៈ ក្តៅដោយភ្លើងគឺមោហៈ ក្តៅដោយជាតិ ជរា មរណៈ សោកៈ បរិទេវៈ ទុក្ខ ទោមនស្ស ឧបាយាសៈ តថាគតពោលថា ក្តៅ ត្រចៀកជារបស់ក្តៅ សំឡេងជារបស់ក្តៅ ។ បេ ។ ច្រមុះជារបស់ក្តៅ ក្លិនជារបស់ក្តៅ ។ បេ ។*

ជិវ្ហា អាទិត្តា រសា អាទិត្តា ។ បេ ។ កាយោ អាទិត្តោ ផោដ្ឋព្វា អាទិត្តា ។ បេ ។ មនោ អាទិត្តោ ធម្មា អាទិត្តា មនោវិញ្ញាណំ អាទិត្តំ មនោសម្ផស្សោ អាទិត្តោ យម្បិទំ មនោសម្ផស្សប្បច្ចយា ឧប្បជ្ជតិ វេទយិតំ សុខំ វា ទុក្ខំ វា អទុក្ខមសុខំ វា តម្បិ អាទិត្តំ កេន អាទិត្តំ អាទិត្តំ រាគគ្គិនា ទោសគ្គិនា មោហគ្គិនា អាទិត្តំ ជាតិយា ជរាមរណេន សោកេហិ បរិទេវេហិ ទុក្ខេហិ ទោមនស្សេហិ ឧបាយាសេហិ អាទិត្តន្តិ វទាមីតិ អត្ថេវ សុត្តន្តោតិ ។ អាមន្តា ។ តេន ហិ សព្វេ សង្ខារា អនោធិកត្វា កុក្កុឡាតិ ។

[១៩៧] សព្វេ សង្ខារា អនោធិកត្វា កុក្កុឡាតិ ។ អាមន្តា ។ ននុ វុត្តំ ភគវតា បញ្ចិមេ ភិក្ខវេ កាមគុណា កតមេ បញ្ច ចក្ខុវិញ្ញេយ្យា រូបា ឥដ្ឋា កន្តា មនាបា បិយរូបា កាមូបសញ្ហិតា រជនិយា សោតវិញ្ញេយ្យា សទ្ទា ។ បេ ។ ឃានវិញ្ញេយ្យា គន្ធា ។ បេ ។ ជិវ្ហាវិញ្ញេយ្យា រសា ។ បេ ។ កាយវិញ្ញេយ្យា ផោដ្ឋព្វា ឥដ្ឋា កន្តា មនាបា បិយរូបា កាមូបសញ្ហិតា រជនិយា ឥមេ ខោ ភិក្ខវេ បញ្ច កាមគុណាតិ

អណ្តាតជារបស់ក្តៅ រសជារបស់ក្តៅ ។ បេ ។ កាយជារបស់ក្តៅ ផោដ្ឋព្វៈជារបស់ក្តៅ ។ បេ ។ ចិត្តជារបស់ក្តៅ ធម្មារម្មណ៍ជារបស់ក្តៅ មនោ-វិញ្ញាណជារបស់ក្តៅ មនោសម្ផស្សជារបស់ក្តៅ ធម្មជាតណា ដែលទទួលអារម្មណ៍ ជាសុខក្តី ជាទុក្ខក្តី មិនមែនជាទុក្ខមិនមែនជាសុខក្តី កើតឡើងព្រោះមនោសម្ផស្សជាបច្ច័យ ធម្មជាតនោះ ជារបស់ក្តៅ ចុះក្តៅដោយអ្វី ក្តៅដោយភ្លើងគឺរាគៈ ក្តៅដោយភ្លើងគឺទោសៈ ក្តៅដោយភ្លើងគឺមោហៈ ក្តៅដោយជាតិ ជរា មរណៈ សោកៈ បរិទេវៈ ទុក្ខ ទោមនស្ស ឧបាយា-សៈ តថាគត ពោលថា ក្តៅ ពាក្យដូច្នេះ មានក្នុងព្រះសូត្រឬ ។ អើ ។ ព្រោះហេតុនោះ សង្ខារទាំងពួង ដូចជាផេះក្តៅ ធ្វើមិនឲ្យមានព្រំដែន ។

[១៩៧] សង្ខារទាំងពួង ដូចជាផេះក្តៅ ធ្វើមិនឲ្យមានព្រំដែនឬ ។ អើ ។ ក្រែងព្រះមានព្រះភាគត្រាស់ថា ម្នាលភិក្ខុទាំងឡាយ កាម-គុណនេះ មាន ៥ យ៉ាង កាមគុណទាំង ៥ តើដូចម្តេចខ្លះ គឺរូបដែលគប្បីដឹងដោយភ្នែក ជាទីប្រាថ្នា ជាទីត្រេកអរ ជាទីពេញចិត្ត ជាទីស្រ-ឡាញ់ ប្រកបដោយកាម ជាតម្រេក ១ សំឡេងដែលគប្បីដឹងដោយត្រ-ចៀក ១ ។ បេ ។ ក្លិនដែលគប្បីដឹងដោយច្រមុះ ១ ។ បេ ។ រសដែលគប្បីដឹងដោយអណ្តាត ១ ។ បេ ។ ផ្សព្វដែលគប្បីដឹងដោយកាយ ជាទីប្រាថ្នា ជាទីត្រេកអរ ជាទីពេញចិត្ត ជាទីស្រឡាញ់ ប្រកបដោយកាម ជាតម្រេក ១ ម្នាលភិក្ខុទាំងឡាយ កាមគុណ មាន ៥ យ៉ាងនេះឯង

អត្ថេវ សុត្តន្តោតិ ។ អាមន្តា ។ តេន ហិ ន វត្តព្វំ សព្វេ សង្ខារា អនោធិកត្វា កុក្កុឡាតិ ។

[១៩៨] ន វត្តព្វំ សព្វេ សង្ខារា អនោធិកត្វា កុក្កុឡាតិ ។ អាមន្តា ។ ននុ វុត្តំ ភគវតា លាភា វោ ភិក្ខវេ សុលទ្ធំ វោ ភិក្ខវេ ខណោ វោ បដិវិទ្ធោ ព្រហ្មចរិយវាសាយ ទិដ្ឋា មយា ភិក្ខវេ ឆផស្សាយតនិកា នាម និរយា តត្ថ យំ កិញ្ចិ ចក្ខុនា រូបំ បស្សតិ អនិដ្ឋរូបញ្ញេវ បស្សតិ នោ ឥដ្ឋរូបំ អកន្តរូបញ្ញេវ បស្សតិ នោ កន្តរូបំ អមនាបរូបញ្ញេវ បស្សតិ នោ មនាបរូបំ យំ កិញ្ចិ សោតេន សទ្ទំ សុណាតិ ។ បេ ។ ឃានេន គន្ធំ ឃាយតិ ។ បេ ។ ជិវ្ហាយ រសំ សាយតិ ។ បេ ។ កាយេន ផោដ្ឋព្វំ ផុសតិ ។ បេ ។ មនសា ធម្មំ វិជានាតិ អនិដ្ឋរូបញ្ញេវ វិជានាតិ នោ ឥដ្ឋរូបំ អកន្តរូបញ្ញេវ វិជានាតិ នោ កន្តរូបំ អមនាបរូបញ្ញេវ វិជានាតិ នោ មនាបរូបន្តិ អត្ថេវ សុត្តន្តោតិ ។ អាមន្តា ។ តេន ហិ[១] សព្វេ សង្ខារា អនោធិកត្វា កុក្កុឡាតិ ។

១ ម. ឯត្តន្តរេ (ន វត្តព្វន្តិ) បាឋោ ទិស្សតិ ។

ពាក្យដូច្នេះ មានក្នុងព្រះសូត្របុ ។ អើ ។ ព្រោះហេតុនោះ អ្នកមិនគួរពោលថា សង្ខារទាំងពួង ដូចជាផេះក្តៅ ធ្វើមិនឲ្យមានព្រំដែនទេ ។

[១៩៨] បុគ្គលមិនគួរពោលថា សង្ខារទាំងពួង ដូចជាផេះក្តៅ ធ្វើមិនឲ្យមានព្រំដែនឬ ។ អើ ។ ក្រែងព្រះមានព្រះភាគត្រាស់ថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ ពេញហៅមានលាភ អត្តភាពនៃមនុស្ស អ្នកទាំងឡាយពេញជាបានល្អហើយ ម្នាលភិក្ខុទាំងឡាយ ខណៈ អ្នកទាំងឡាយបានចាក់ធ្លុះហើយ ដើម្បីប្រព្រឹត្តព្រហ្មចរិយៈ ម្នាលភិក្ខុទាំងឡាយ នរក ឈ្មោះឆផស្សាយតនិកៈ តថាគតបានឃើញហើយ បណ្តាធម៌ទាំងនោះ បុគ្គល ឃើញរូបណាមួយដោយភ្នែក តែងឃើញរូបមិនជាទីប្រាថ្នា តែម្យ៉ាង មិនឃើញរូបជាទីប្រាថ្នា តែងឃើញរូបមិនជាទីត្រេកអរ មិនឃើញរូបជាទីត្រេកអរ តែងឃើញរូបមិនជាទីគាប់ចិត្ត មិនឃើញរូបជាទីគាប់ចិត្ត បុគ្គល ឮសំឡេងណាមួយដោយត្រចៀក ។ បេ ។ ធុំក្លិនដោយច្រមុះ ។ បេ ។ លិទ្ធភ្លក្សរសដោយអណ្តាត ។ បេ ។ ពាល់ត្រូវផ្សព្វដោយកាយ ។ បេ ។ ដឹងច្បាស់ធម្មារម្មណ៍ដោយចិត្ត តែងដឹងច្បាស់នូវរូបមិនជាទីប្រាថ្នា មិនដឹងច្បាស់នូវរូបជាទីប្រាថ្នា តែងដឹងច្បាស់នូវរូបមិនជាទីត្រេកអរ មិនដឹងច្បាស់នូវរូបជាទីត្រេកអរ តែងដឹងច្បាស់នូវរូបមិនជាទីពេញចិត្ត មិនដឹងច្បាស់នូវរូបជាទីពេញចិត្ត ពាក្យដូច្នេះ មានក្នុងព្រះសូត្របុ ។ អើ ។ ព្រោះហេតុនោះ សង្ខារទាំងពួង ដូចជាផេះក្តៅ ធ្វើមិនឲ្យមានព្រំដែន ។

[១៩៩] សព្វេ សង្ខារា អនោធឹកត្វា ទុក្ខាតិ ។ អាមន្តា ។ ននុ វុត្តំ ភគវតា លាភា វោ ភិក្ខវេ សុលទ្ធំ វោ ភិក្ខវេ ខណោ វោ បដិវិទ្ធោ ព្រហ្មចរិយវាសាយ ទិដ្ឋា មយា ភិក្ខវេ ឆផស្សាយតនិកា នាម សគ្គា តត្ថ យំ កិញ្ចិ ចក្ខុនា រូបំ បស្សតិ ឥដ្ឋរូបញ្ញេវ បស្សតិ នោ អនិដ្ឋរូបំ កន្តរូបញ្ញេវ បស្សតិ នោ អកន្តរូបំ មនាបរូបញ្ញេវ បស្សតិ នោ អមនាបរូបំ យំ កិញ្ចិ សោតេន សទ្ទំ សុណាតិ ។ បេ ។ ឃានេន គន្ធំ ឃាយតិ ។ បេ ។ ជិវ្ហាយ រសំ សាយតិ ។ បេ ។ កាយេន ផោដ្ឋព្វំ ផុសតិ ។ បេ ។ មនសា ធម្មំ វិជានាតិ ឥដ្ឋរូបញ្ញេវ វិជានាតិ នោ អនិដ្ឋរូបំ កន្តរូបញ្ញេវ វិជានាតិ នោ អកន្តរូបំ មនាបរូបញ្ញេវ វិជានាតិ នោ អមនាបរូបន្តិ អត្ថេវ សុត្តន្តោតិ ។ អាមន្តា ។ តេន ហិ ន វត្តព្វំ សព្វេ សង្ខារា អនោធឹកត្វា ទុក្ខាតិ ។

[១៩៩] សង្ខារទាំងពួង ដូចជាផេះក្ដៅ ធ្វើមិនឲ្យមានព្រំដែនឬ ។ អើ ។ ក្រែងព្រះមានព្រះភាគត្រាស់ថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ ពេញហៅមានលាភ អត្តភាពនៃមនុស្ស អ្នកទាំងឡាយពេញជាបានល្អហើយ ម្នាលភិក្ខុទាំងឡាយ ខណៈ អ្នកទាំងឡាយបានចាក់ដុះហើយ ដើម្បីប្រព្រឹត្តព្រហ្មចរិយៈ ម្នាលភិក្ខុទាំងឡាយ ឋានសួគ៌ ឈ្មោះផស្សាយតនិកៈ តថាគតបានឃើញហើយ បណ្ដាធម៌ទាំងនោះ បុគ្គលឃើញរូបណាមួយដោយភ្នែក តែងឃើញរូបជាទីប្រាថ្នា មិនឃើញរូបមិនជាទីប្រាថ្នា តែងឃើញរូបជាទីត្រេកអរ មិនឃើញរូបមិនជាទីត្រេកអរ តែងឃើញរូបជាទីពេញចិត្ត មិនឃើញរូបមិនជាទីពេញចិត្ត ឮសំឡេងណាមួយដោយត្រចៀក ។ បេ ។ ធុំក្លិនដោយច្រមុះ ។ បេ ។ លិទ្ធភ្លក្សរសដោយអណ្ដាត ។ បេ ។ ពាល់ត្រូវផ្សព្វដោយកាយ ។ បេ ។ ដឹងច្បាស់ធម្មារម្មណ៍ដោយចិត្ត តែងដឹងច្បាស់នូវរូបជាទីប្រាថ្នា មិនដឹងច្បាស់នូវរូបមិនជាទីប្រាថ្នា តែងដឹងច្បាស់នូវរូបជាទីត្រេកអរ មិនដឹងច្បាស់នូវរូបមិនជាទីត្រេកអរ តែងដឹងច្បាស់នូវរូបជាទីពេញចិត្ត មិនដឹងច្បាស់នូវរូបមិនជាទីពេញចិត្ត ពាក្យដូច្នេះ មានក្នុងព្រះសូត្រឬ ។ អើ ។ ព្រោះហេតុនោះ អ្នកមិនគួរពោលថា សង្ខារទាំងពួង ដូចជាផេះក្ដៅ ធ្វើមិនឲ្យមានព្រំដែនទេ ។

៧៧

កុក្កុឡកថា

[២០០] ន វត្តព្វំ សព្វេ សង្ខារា អនោធឹកត្វា កុក្កុឡាតិ ។ អាមន្តា ។ ននុ យទនិច្ចំ តំ ទុក្ខំ វុត្តំ ភគវតា សព្វេ សង្ខារា អនិច្ចាតិ ។ អាមន្តា ។ ហញ្ចិ យទនិច្ចំ តំ ទុក្ខំ វុត្តំ ភគវតា សព្វេ សង្ខារា អនិច្ចា តេន វត រេ វត្តព្វេ សព្វេ សង្ខារា អនោធឹកត្វា កុក្កុឡាតិ ។

[២០១] សព្វេ សង្ខារា អនោធឹកត្វា កុក្កុឡាតិ ។ អាមន្តា ។ ទានំ អនិដ្ឋផលំ អកន្តផលំ អមនុញ្ញផលំ សេចនកផលំ ទុក្ខុទ្រយំ ទុក្ខវិបាកន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។ សីលំ ។ បេ ។ ឧបោសថោ ។ បេ ។ ភាវនា ។ បេ ។ ព្រហ្មចរិយំ អនិដ្ឋផលំ អកន្តផលំ អមនុញ្ញផលំ សេចនកផលំ ទុក្ខុទ្រយំ ទុក្ខវិបាកន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។ ននុ ទានំ ឥដ្ឋផលំ កន្តផលំ មនុញ្ញផលំ អសេចនកផលំ សុខុទ្រយំ សុខវិបាកន្តិ ។ អាមន្តា ។ ហញ្ចិ ទានំ ឥដ្ឋផលំ កន្តផលំ មនុញ្ញផលំ អសេចនកផលំ សុខុទ្រយំ សុខវិបាកំ នោ វត រេ វត្តព្វេ សព្វេ សង្ខារា

កុក្កុឡកថា

[២០០] បុគ្គលមិនគួរនិយាយថា សង្ខារទាំងពួង ដូចជាផេះក្តៅ ធ្វើមិនឲ្យមានព្រំដែនឬ ។ អើ ។ ក្រែងព្រះមានព្រះភាគត្រាស់ថា របស់ណា មិនទៀង របស់នោះ ជាទុក្ខ ចុះសង្ខារទាំងពួង មិនទៀងឬ ។ អើ ។ បើព្រះមានព្រះភាគត្រាស់ថា របស់ណា មិនទៀង របស់នោះ ជាទុក្ខ សង្ខារទាំងពួង មិនទៀង ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកមិនគួរពោលថា សង្ខារទាំងពួង ដូចជាផេះក្តៅ ធ្វើមិនឲ្យមានព្រំដែនទេ ។

[២០១] សង្ខារទាំងពួង ដូចជាផេះក្តៅ ធ្វើមិនឲ្យមានព្រំដែនឬ ។ អើ ។ ទាន មានផលមិនជាទីប្រាថ្នា មានផលមិនជាទីត្រេកអរ មានផលមិនជាទីគាប់ចិត្ត មានផលប្រឡូកប្រឡំ មានទុក្ខជាកម្រៃ មានវិបាកជាទុក្ខឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ សីល ។ បេ ។ ឧបោសថ ។ បេ ។ ភាវនា ។ បេ ។ ព្រហ្មចរិយៈ មានផលមិនជាទីប្រាថ្នា មានផលមិនជាទីត្រេកអរ មានផលមិនជាទីគាប់ចិត្ត មានផលប្រឡូកប្រឡំ មានទុក្ខជាកម្រៃ មានវិបាកជាទុក្ខឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ ក្រែងទាន មានផលជាទីប្រាថ្នា មានផលជាទីត្រេកអរ មានផលជាទីគាប់ចិត្ត មានផលមិនប្រឡូកប្រឡំ មានសុខជាកម្រៃ មានវិបាកជាសុខឬ ។ អើ ។ បើទាន មានផលជាទីប្រាថ្នា មានផលជាទីត្រេកអរ មានផលជាទីគាប់ចិត្ត មានផលមិនប្រឡូកប្រឡំ មានសុខជាកម្រៃ មានវិបាកជាសុខហើយ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា សង្ខារទាំងពួង

អនោជីកត្វា កុក្កុច្ចាតិ ។ ននុ សីលំ ។ បេ ។ ឧបោសថោ ។ បេ ។ ភាវនា ។ បេ ។ ព្រហ្មចរិយំ ឥដ្ឋផលំ កន្តផលំ មនុញ្ញផលំ អសេចនកផលំ សុខុទ្រយំ សុខវិបាកន្តិ ។ អាមន្តា ។ ហញ្ចិ ព្រហ្មចរិយំ ឥដ្ឋផលំ កន្តផលំ មនុញ្ញផលំ អសេចនកផលំ សុខុទ្រយំ សុខវិបាកំ នោ វត រេ វត្តព្វេ សព្វេ សង្ខារា អនោជីកត្វា កុក្កុច្ចាតិ ។

[២០២] សព្វេ សង្ខារា អនោជីកត្វា កុក្កុច្ចាតិ ។ អាមន្តា ។ ននុ វុត្តំ ភគវតា

សុខោ វិវេកោ តុដ្ឋស្ស សុតធម្មស្ស បស្សតោ
អព្យាបជ្ឈំ សុខំ លោកេ បាណភូតេសុ សញ្ញមោ
សុខា វិរាគតា លោកេ កាមានំ សមតិក្កមោ
អស្មិមានស្ស យោ វិនយោ ឯតំ វេ បរមំ សុខំ
តំ សុខេន សុខំ បត្តំ អច្ចន្តំ សុខមេវ តំ

ដូចជាផេះក្តៅ ធ្វើមិនឲ្យមានព្រំដែនទេ ។ ក្រែងសីល ។ បេ ។ ឧបោ-សថ ។ បេ ។ ភាវនា ។ បេ ។ ព្រហ្មចរិយៈ មានផលជាទីប្រាថ្នា មានផលជាទីត្រេកអរ មានផលជាទីគាប់ចិត្ត មានផលមិនប្រឡូកប្រឡំ មានសុខជាកម្រៃ មានវិបាកជាសុខឬ ។ អើ ។ បើព្រហ្មចរិយៈ មានផលជាទីប្រាថ្នា មានផលជាទីត្រេកអរ មានផលជាទីគាប់ចិត្ត មានផលមិនប្រឡូកប្រឡំ មានសុខជាកម្រៃ មានវិបាកជាសុខ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា សង្ខារទាំងពួង ដូចជាផេះក្តៅ ធ្វើមិនឲ្យមានព្រំដែនទេ ។

[២០២] សង្ខារទាំងពួង ដូចជាផេះក្តៅ ធ្វើមិនឲ្យមានព្រំដែនឬ ។ អើ ។ ក្រែងព្រះមានព្រះភាគ ទ្រង់ត្រាស់ថា

វិវេក របស់បុគ្គល អ្នកត្រេកអរ ជាអ្នកមានធម៌បានស្តាប់
ហើយ ឃើញ (ធម៌) រមែងនាំមកនូវសេចក្តីសុខ ការមិន
បៀតបៀន គឺការសង្រួម ក្នុងសត្វទាំងឡាយ នាំមកនូវ
សេចក្តីសុខ ក្នុងលោក ភាវៈប្រាសចាករាគៈ គឺកិរិយា
កន្លង នូវកាមទាំងឡាយ នាំមក នូវសេចក្តីសុខក្នុងលោក
ការបន្ទោបង់ នូវអស្មិមានះ ណា នេះឯង ជាសេចក្តីសុខ
ដ៏ក្រៃលែង សេចក្តីសុខនោះ បុគ្គល បានដល់ហើយ
ដោយងាយ សេចក្តីសុខនោះឯង មានទីបំផុតដ៏ក្រៃលែង

អនុបុញ្ញាភិសមយកថា

តិស្សោ វិជ្ជា អនុប្បត្តា ឯតំ វេ បរមំ សុខន្តិ អត្ថេវ សុត្តន្តោតិ ។ អាមន្តា ។ តេន ហិ ន វត្តព្វំ សព្វេ សង្ខារា អនោធិកត្វា កុក្កុឡាតិ ។

កុក្កុឡកថា ។

# អនុបុញ្ញាភិសមយកថា

[២០៣] អនុបុព្វាភិសមយោតិ ។ អាមន្តា ។ អនុបុព្វេន សោតាបត្តិមគ្គំ ភាវេតីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ អនុបុព្វេន សោតាបត្តិមគ្គំ ភាវេតី-តិ ។ អាមន្តា ។ អនុបុព្វេន សោតាបត្តិផលំ សច្ឆិ-ករោតីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[២០៤] អនុបុព្វាភិសមយោតិ ។ អាមន្តា ។ អនុបុព្វេន សកទាគាមិមគ្គំ ភាវេតីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ អនុបុព្វេន សកទាគាមិមគ្គំ ភាវេតី-តិ ។ អាមន្តា ។ អនុបុព្វេន សកទាគាមិផលំ សច្ឆិ-ករោតីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[២០៥] អនុបុព្វាភិសមយោតិ ។ អាមន្តា ។ អនុ-បុព្វេន អនាគាមិមគ្គំ ភាវេតីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

*វិជ្ជា ៣ ដែលគេបានដល់ហើយ នេះ ជាសេចក្តីសុខដ៏ក្រៃលែង ពាក្យដូច្នេះ មានក្នុងព្រះសូត្រឬ ។ អើ ។ ព្រោះហេតុនោះ អ្នកមិនគួរពោលថា សង្ខារទាំងពួង ដូចជាផេះក្តៅ ធ្វើមិនឲ្យមានព្រំដែនទេ ។*

ចប់ កុក្កុឡកថា ។

# អនុបុព្វាភិសមយកថា

[២០៣] *ការត្រាស់ដឹងជាលំដាប់ មានដែរឬ ។ អើ ។ បុគ្គល ចម្រើនសោតាបត្តិមគ្គ តាមលំដាប់ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ បុគ្គល ចម្រើនសោតាបត្តិមគ្គ តាមលំដាប់ឬ ។ អើ ។ បុគ្គល ធ្វើឲ្យជាក់ច្បាស់ នូវសោតាបត្តិផល តាមលំដាប់ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។*

[២០៤] *ការត្រាស់ដឹងជាលំដាប់ មានឬ ។ អើ ។ បុគ្គល ចម្រើនសកទាគាមិមគ្គ តាមលំដាប់ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ បុគ្គលចម្រើនសកទាគាមិមគ្គ តាមលំដាប់ឬ ។ អើ ។ បុគ្គល ធ្វើឲ្យជាក់ច្បាស់ នូវសកទាគាមិផល តាមលំដាប់ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។*

[២០៥] *ការត្រាស់ដឹងជាលំដាប់ មានឬ ។ អើ ។ បុគ្គលចម្រើនអនាគាមិមគ្គ តាមលំដាប់ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។*

អនុបុព្វេន អនាគាមិមគ្គំ ភាវេតីតិ ។ អាមន្តា ។ អនុបុព្វេន អនាគាមិផលំ សច្ឆិករោតីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[២០៦] អនុបុព្វាភិសមយោតិ ។ អាមន្តា ។ អនុបុព្វេន អរហត្តមគ្គំ ភាវេតីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ អនុបុព្វេន អរហត្តមគ្គំ ភាវេតីតិ ។ អាមន្តា ។ អនុបុព្វេន អរហត្តផលំ សច្ឆិករោតីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[២០៧] សោតាបត្តិផលសច្ឆិកិរិយាយ បដិបន្នោ បុគ្គលោ ទុក្ខទស្សនេន កឹ ជហាតីតិ ។ សក្កាយទិដ្ឋឹ វិចិកិច្ឆំ សីលព្វតបរាមាសំ តទេកដ្ឋេ ច កិលេសេ ចតុព្ភាគំ ជហាតីតិ ។ ចតុព្ភាគំ សោតាបន្នោ ចតុព្ភាគំ ន សោតាបន្នោ ចតុព្ភាគំ សោតាបត្តិផលប្បត្តោ បដិលទ្ធោ អធិគតោ សច្ឆិកតោ ឧបសម្បជ្ជ វិហរតិ កាយេន ផុសិត្វា វិហរតិ ចតុព្ភាគំ ន កាយេន ផុសិត្វា វិហរតិ ចតុព្ភាគំ សត្តក្ខត្តុំ បរមោ កោលំកោលោ ឯកពីជី ពុទ្ធេ អវេច្ចប្បសាទេន សមន្នាគតោ ធម្មេ ។ បេ ។ សង្ឃេ ។ បេ ។

បុគ្គលចម្រើនអនាគាមិមគ្គ តាមលំដាប់ឬ ។ អើ ។ បុគ្គលធ្វើឲ្យជាក់ច្បាស់ នូវអនាគាមិផល តាមលំដាប់ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[២០៦] ការត្រាស់ដឹងជាលំដាប់ មានឬ ។ អើ ។ បុគ្គលចម្រើនអរហត្តមគ្គ តាមលំដាប់ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ បុគ្គល ចម្រើនអរហត្តមគ្គ តាមលំដាប់ឬ ។ អើ ។ បុគ្គល ធ្វើឲ្យជាក់ច្បាស់ នូវអរហត្តផល តាមលំដាប់ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[២០៧] បុគ្គល ប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់ នូវសោតាបត្តិផល ដោយការឃើញទុក្ខសច្ច តើលះបង់អ្វី ។ បុគ្គល លះសក្កាយទិដ្ឋិ វិចិកិច្ឆា សីលព្វតបរាមាសៈ និងពួកកិលេស ដែលដូចគ្នានឹងធម៌ទាំងនោះ ជាចតុព្ភាគ (មានចំណែកជា ៤) ។ សោតាបន្នបុគ្គល ជាចតុព្ភាគ មិនមែនសោតាបន្នបុគ្គល ជាចតុព្ភាគ បុគ្គលដល់សោតាបត្តិផល បានចំពោះ ត្រាស់ដឹង ធ្វើឲ្យជាក់ច្បាស់ សម្រេច ពាល់ត្រូវដោយនាមកាយ ជាចតុព្ភាគ មិនពាល់ត្រូវដោយនាមកាយ ជាចតុព្ភាគ សត្តក្ខត្តុំបរមបុគ្គល កោលំកោលបុគ្គល ឯកពីជិបុគ្គល ប្រកបដោយសេចក្ដីជ្រះថ្លាមិនញាប់ញ័រ ក្នុងព្រះពុទ្ធ ក្នុងព្រះធម៌ ។ បេ ។ ក្នុងព្រះសង្ឃ ។ បេ ។

អនុបុព្វាភិសមយកថា

អរិយកន្តេហិ សីលេហិ សមន្នាគតោ ចតុត្ថកំ ន អរិយកន្តេហិ សីលេហិ សមន្នាគតោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ សមុទយទស្សនេន ។ បេ ។ និរោធទស្សនេន ។ បេ ។ មគ្គទស្សនេន កាំ ជហាតីតិ ។ សក្កាយទិដ្ឋឹ វិចិកិច្ឆំ សីលព្វតបរាមាសំ តទេកដ្ឋេ ច កិលេសេ ចតុត្ថកំ ជហាតីតិ ។ ចតុត្ថកំ សោតាបន្នោ ចតុត្ថកំ ន សោតាបន្នោ ចតុត្ថកំ សោតាបត្តិផលប្បត្តោ បដិលទ្ធោ អធិគតោ សច្ឆិកតោ ឧបសម្បជ្ជ វិហរតិ កាយេន ផុសិត្វា វិហរតិ ចតុត្ថកំ ន កាយេន ផុសិត្វា វិហរតិ ចតុត្ថកំ សត្តក្ខត្តុំបរមោ កោលំកោលោ ឯកពីជី ពុទ្ធេ អវេច្ចប្បសាទេន សមន្នាគតោ ធម្មេ ។ បេ ។ សង្ឃេ ។ បេ ។ អរិយកន្តេហិ សីលេហិ សមន្នាគតោ ចតុត្ថកំ ន អរិយកន្តេហិ សីលេហិ សមន្នាគតោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

ប្រកបដោយសីលជាទីត្រេកអររបស់អរិយៈទាំងឡាយ ជាចតុក្កាគ មិនប្រកបដោយសីលជាទីត្រេកអររបស់អរិយៈទាំងឡាយ ជាចតុក្កាគ មាន ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ ដោយការឃើញសមុទយ-សច្ច ។ បេ ។ ដោយការឃើញនិរោធសច្ច ។ បេ ។ ដោយការឃើញមគ្គសច្ច តើលះបង់អ្វី ។ បុគ្គល លះសក្កាយទិដ្ឋិ វិចិកិច្ឆា សីលព្វត-បរាមាសៈ និងពួកកិលេសដែលដូចគ្នានឹងធម៌ទាំងនោះ ជាចតុក្កាគ ។ សោតាបន្នបុគ្គល ជាចតុក្កាគ មិនមែនសោតាបន្នបុគ្គល ជាចតុក្កាគ បុគ្គលដល់សោតាបត្តិផល បានចំពោះ ត្រាស់ដឹង ធ្វើឲ្យជាក់ច្បាស់ សម្រេច ពាល់ត្រូវដោយនាមកាយ ជាចតុក្កាគ មិនពាល់ត្រូវដោយនាមកាយ ជាចតុក្កាគ សត្តក្ខត្តុំបរមបុគ្គល កោលំកោលបុគ្គល ឯកពីជិ-បុគ្គល ប្រកបដោយសេចក្តីជ្រះថ្លាមិនញាប់ញ័រ ក្នុងព្រះពុទ្ធ ក្នុងព្រះធម៌ ។ បេ ។ ក្នុងព្រះសង្ឃ ។ បេ ។ ប្រកបដោយសីលជាទីត្រេកអររបស់អរិយៈទាំងឡាយ ជាចតុក្កាគ មិនប្រកបដោយសីលជាទីត្រេកអររបស់អរិយៈទាំងឡាយ ជាចតុក្កាគឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[២០៨] សកទាគាមិផលសច្ឆិកិរិយាយ បដិបន្នោ បុគ្គលោ ទុក្ខទស្សនេន កាំ ជហាតីតិ ។ ឱឡារិកំ កាមរាគំ ឱឡារិកំ ព្យាបាទំ តទេកដ្ឋេ ច កិលេសេ ចតុត្ថាគំ ជហាតីតិ ។ ចតុត្ថាគំ សកទាគាមី ចតុត្ថាគំ ន សកទាគាមី ចតុត្ថាគំ សកទាគាមិផលប្បត្តោ បដិលទ្ធោ អធិគតោ សច្ឆិកតោ ឧបសម្បជ្ជ វិហរតិ កាយេន ផុសិត្វា វិហរតិ ចតុត្ថាគំ ន កាយេន ផុសិត្វា វិហរតីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ សមុទយទស្សនេន ។ បេ ។ និរោធទស្សនេន ។ បេ ។ មគ្គទស្សនេន កាំ ជហាតីតិ ។ ឱឡារិកំ កាមរាគំ ឱឡារិកំ ព្យាបាទំ តទេកដ្ឋេ ច កិលេសេ ចតុត្ថាគំ ជហាតីតិ ។ ចតុត្ថាគំ សកទាគាមី ចតុត្ថាគំ ន សកទាគាមី ចតុត្ថាគំ សកទាគាមិផលប្បត្តោ បដិលទ្ធោ អធិគតោ សច្ឆិកតោ ឧបសម្បជ្ជ វិហរតិ កាយេន ផុសិត្វា វិហរតិ ចតុត្ថាគំ ន កាយេន ផុសិត្វា វិហរតីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[២០៨] បុគ្គល ប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់ នូវសកទាគាមិផល ដោយការឃើញទុក្ខសច្ច តើលះបង់អ្វី ។ បុគ្គល លះកាមរាគគ្រោតគ្រាត ព្យាបាទគ្រោតគ្រាត និងពួកកិលេសដែលដូចគ្នានឹងធម៌ទាំងនោះ ជាចតុព្ភាគ ។ សកទាគាមិបុគ្គល ជាចតុព្ភាគ មិនមែនសកទាគាមិបុគ្គល ជាចតុព្ភាគ បុគ្គល ដល់នូវសកទាគាមិផល បានចំពោះ ត្រាស់ដឹង ធ្វើឲ្យជាក់ច្បាស់ សម្រេច ពាល់ត្រូវដោយនាមកាយ ជាចតុព្ភាគ មិនពាល់ត្រូវដោយនាមកាយ ជាចតុព្ភាគដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ ដោយការឃើញសមុទយសច្ច ។ បេ ។ ដោយការឃើញនិរោធសច្ច ។ បេ ។ ដោយការឃើញមគ្គសច្ច តើលះបង់អ្វី ។ បុគ្គល លះកាមរាគគ្រោតគ្រាត ព្យាបាទគ្រោតគ្រាត និងពួកកិលេសដែលដូចគ្នានឹងធម៌ទាំងនោះ ជាចតុព្ភាគ ។ សកទាគាមិបុគ្គល ជាចតុព្ភាគ មិនមែនសកទាគាមិបុគ្គល ជាចតុព្ភាគ បុគ្គល ដល់នូវសកទាគាមិផល បានចំពោះ ត្រាស់ដឹង ធ្វើឲ្យជាក់ច្បាស់ សម្រេច ពាល់ត្រូវដោយនាមកាយ ជាចតុព្ភាគ មិនពាល់ត្រូវដោយនាមកាយ ជាចតុព្ភាគឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

៨៣

អនុបុព្វាភិសមយកថា

[២០៩] អនាគាមិផលសច្ឆិកិរិយាយ បដិបន្នោ
បុគ្គលោ ទុក្ខទស្សនេន កឹ ជហាតីតិ ។ អណុស-
ហគតំ កាមរាគំ អណុសហគតំ ព្យាបាទំ តទេកដ្ឋេ
ច កិលេសេ ចតុក្កតំ ជហាតីតិ ។ ចតុក្កតំ អនា-
គាមី ចតុក្កតំ ន អនាគាមី ចតុក្កតំ អនាគាមិផ-
លប្បត្តោ បដិលទ្ធោ អធិគតោ សច្ឆិកតោ ឧបសម្បជ្ជ
វិហរតិ កាយេន ផុសិត្វា វិហរតិ ចតុក្កតំ ន កា-
យេន ផុសិត្វា វិហរតិ ចតុក្កតំ អន្តរាបរិនិព្វាយី ។ បេ ។
ឧបហច្ចបរិនិព្វាយី ។ បេ ។ អសង្ខារបរិនិព្វាយី ។ បេ ។
សសង្ខារបរិនិព្វាយី ។ បេ ។ ឧទ្ធំសោតោ អកនិដ្ឋគាមី
ចតុក្កតំ ន ឧទ្ធំសោតោ ន អកនិដ្ឋគាមីតិ ។ ន
ហេវំ វត្តព្វេ ។ បេ ។ សមុទយទស្សនេន ។ បេ ។ និរោ-
ធទស្សនេន ។ បេ ។ មគ្គទស្សនេន កឹ ជហាតី-
តិ ។ អណុសហគតំ កាមរាគំ អណុសហគតំ ព្យា-
បាទំ តទេកដ្ឋេ ច កិលេសេ ចតុក្កតំ ជហាតីតិ ។
ចតុក្កតំ អនាគាមី ចតុក្កតំ ន អនាគាមី ចតុក្កតំ
អនាគាមិផលប្បត្តោ បដិលទ្ធោ អធិគតោ សច្ឆិកតោ
ឧបសម្បជ្ជ វិហរតិ កាយេន ផុសិត្វា វិហរតិ ចតុក្កតំ

អនុបុញ្ញាភិសមយកថា

[២០៩] បុគ្គល ប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់ នូវអនាគាមិ-ផល ដោយការឃើញទុក្ខសច្ច តើលះបង់អ្វី ។ បុគ្គល លះកាមរាគស្រាលស្តើង ព្យាបាទស្រាលស្តើង និងពួកកិលេសដែលដូចគ្នានឹងធម៌ទាំងនោះ ជាចតុក្កាគ ។ អនាគាមិបុគ្គល ជាចតុក្កាគ មិនមែនអនាគា-មិបុគ្គល ជាចតុក្កាគ បុគ្គល ដល់នូវអនាគាមិផល បានចំពោះ ត្រាស់ដឹង ធ្វើឲ្យជាក់ច្បាស់ សម្រេច ពាល់ត្រូវដោយនាមកាយ ជាចតុក្កាគ មិនពាល់ត្រូវដោយនាមកាយ ជាចតុក្កាគ អន្តរាបរិនិព្វាយិបុគ្គល ។ បេ ។ ឧបហច្ចបរិនិព្វាយិបុគ្គល ។ បេ ។ អសង្ខារបរិនិព្វាយិបុគ្គល ។ បេ ។ សសង្ខារបរិនិព្វាយិបុគ្គល ។ បេ ។ ឧទ្ធំសោតៈ អកនិដ្ឋគាមិបុគ្គល ជាចតុក្កាគ មិនមែនឧទ្ធំសោតៈ មិនមែនអកនិដ្ឋគាមិបុគ្គល ជាចតុក្កាគ ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ ដោយការឃើញសមុ-ទយសច្ច ។ បេ ។ ដោយការឃើញនិរោធសច្ច ។ បេ ។ ដោយការឃើញមគ្គសច្ច តើលះបង់អ្វី ។ បុគ្គល លះកាមរាគស្រាលស្តើង ព្យាបាទស្រាលស្តើង និងពួកកិលេសដែលដូចគ្នានឹងពួកធម៌ទាំងនោះ ជាចតុក្កាគ ។ អនាគាមិបុគ្គល ជាចតុក្កាគ មិនមែនអនាគាមិបុគ្គល ជាចតុក្កាគ បុគ្គល ដល់នូវអនាគាមិផល បានចំពោះ ត្រាស់ដឹង ធ្វើឲ្យជាក់ច្បាស់ សម្រេច ពាល់ត្រូវដោយនាមកាយ ជាចតុក្កាគ

ន កាយេន ផុសិត្វា វិហរតិ ចតុត្ថកំ អន្តរាបរិ-និព្វាយី ។ បេ ។ ឧបហច្ចបរិនិព្វាយី ។ បេ ។ អសង្ខា-របរិនិព្វាយី ។ បេ ។ សសង្ខារបរិនិព្វាយី ។ ឧទ្ធំសោតោ អកនិដ្ឋគាមី ចតុត្ថកំ ន ឧទ្ធំសោតោ ន អកនិដ្ឋ-គាមីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[២១០] អរហត្តសច្ឆិកិរិយាយ បដិបន្នោ បុគ្គ-លោ ទុក្ខូនស្សនេន កឹ ជហាតីតិ ។ រូបរាគំ អរូប-រាគំ មានំ ឧទ្ធច្ចំ អវិជ្ជំ តទេកដ្ឋេ ច កិលេសេ ចតុត្ថកំ ជហាតីតិ ។ ចតុត្ថកំ អរហា ចតុត្ថកំ ន អរហា ចតុត្ថកំ អរហត្តប្បត្តោ បដិលទ្ធោ អធិគតោ សច្ឆិកតោ ឧបសម្បជ្ជ វិហរតិ កាយេន ផុសិត្វា វិហរតិ ចតុត្ថកំ ន កាយេន ផុសិត្វា វិហរតិ ចតុត្ថកំ វីតរាគោ វីតទោសោ វីតមោហោ កតករណីយោ ឱហិតភារោ អនុប្បត្តសទត្ថោ បរិក្ខីណភវសញ្ញោជ-នោ សម្មទញ្ញា វិមុត្តោ ឧក្ខិត្តបលិឃោ សង្កិណ្ណបរិខោ អព្ពុឡ្ហេសិកោ និរគ្គឡោ អរិយោ បន្នទ្ធជោ បន្នភារោ

មិនពាល់ត្រូវដោយនាមកាយ ជាចតុក្កាគ អន្តរាបរិនិព្វាយិបុគ្គល ។ បេ ។ ឧបហច្ចបរិនិព្វាយិបុគ្គល ។ បេ ។ អសង្ខារបរិនិព្វាយិបុគ្គល ។ បេ ។ សសង្ខារបរិនិព្វាយិបុគ្គល ។ បេ ។ ឧទ្ធំសោតៈ អកនិដ្ឋគាមិបុគ្គល ជាចតុក្កាគ មិនមែនឧទ្ធំសោតៈ មិនមែនអកនិដ្ឋគាមិបុគ្គល ជាចតុក្កាគឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[២១០] បុគ្គល ប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់ នូវអរហត្ត ដោយការឃើញទុក្ខសច្ច តើលះបង់អ្វី ។ បុគ្គល លះរូបរាគៈ អរូបរាគៈ មានះ ឧទ្ធច្ចៈ អវិជ្ជា និងពួកកិលេសដែលដូចគ្នានឹងពួកធម៌ទាំងនោះ ជាចតុក្កាគ ។ ព្រះអរហន្ត ជាចតុក្កាគ មិនមែនព្រះអរហន្ត ជាចតុក្កាគ បុគ្គល ដល់នូវអរហត្ត បានចំពោះ ត្រាស់ដឹង ធ្វើឲ្យជាក់ច្បាស់ សម្រេច ពាស់ត្រូវដោយនាមកាយ ជាចតុក្កាគ មិនពាល់ត្រូវដោយនាមកាយ ជាចតុក្កាគ ប្រាសចាករាគៈ ប្រាសចាកទោសៈ ប្រាសចាកមោហៈ មានសោឡសកិច្ចធ្វើរួចហើយ មានភារៈដាក់ចុះហើយ មានប្រយោជន៍ជារបស់ខ្លួនដល់ហើយដោយលំដាប់ មានសញ្ញោជនៈក្នុងភពអស់ហើយ មានចិត្តរួចស្រឡះហើយ ព្រោះដឹងដោយប្រពៃ មានទ្វារដើងគុលគឺអវិជ្ជាលើកឡើងហើយ មានគូ (ស្នាមភ្ញោះ) ទម្លាយហើយ មានសសរខឿនដកចោលហើយ មិនមានសន្ទះទ្វារចេញចាកសត្រូវ មានទង់ដាក់ចុះហើយ មានភារៈដាក់ចុះហើយ

វិសញ្ញុត្តោ សុវិជិតវិជយោ ទុក្ខន្តស្ស បរិញ្ញាតំ សមុ-
ទយោ បហីនោ និរោធោ សច្ឆិកតោ មគ្គោ ភាវិ-
តោ អភិញ្ញេយ្យំ អភិញ្ញាតំ បរិញ្ញេយ្យំ បរិញ្ញាតំ
បហាតព្វំ បហីនំ ភាវេតព្វំ ភាវិតំ ។ បេ ។ សច្ឆិ-
កាតព្វំ សច្ឆិកតំ ចតុក្កំ សច្ឆិកាតព្វំ ន សច្ឆិ-
កតន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។ សមុទយទស្ស-
នេន ។ បេ ។ និរោធទស្សនេន ។ បេ ។ មគ្គទស្ស-
នេន កឹ ជហាតីតិ ។ រូបរាគំ អរូបរាគំ មានំ ឧទ្ធច្ចំ
អវិជ្ជំ តទេកដ្ឋេ ច កិលេសេ ចតុក្កំ ជហាតីតិ ។
ចតុក្កំ អរហា ចតុក្កំ ន អរហា ចតុក្កំ អរ-
ហត្តប្បត្តោ បដិលទ្ធោ អធិគតោ សច្ឆិកតោ ឧប-
សម្បជ្ជ វិហរតិ កាយេន ផុសិត្វា វិហរតិ ចតុក្កំ
ន កាយេន ផុសិត្វា វិហរតិ ចតុក្កំ វីតរាគោ
វីតទោសោ វីតមោហោ កតករណីយោ ឱហិតភារោ

អនុបុញ្ញាភិសមយកថា

ប្រាសចាកធម៌ជាគ្រឿងប្រកប មានជម្នះឈ្នះដោយប្រពៃ ទុក្ខសច្ច បុគ្គលនោះ ក៏បានកំណត់ដឹងហើយ សមុទយសច្ច (ហេតុដែលនាំឲ្យកើតទុក្ខ) ក៏បានលះបង់ហើយ និរោធសច្ច (ធម៌ជាទីរំលត់ទុក្ខ) បានធ្វើឲ្យជាក់ច្បាស់ហើយ មគ្គសច្ច ក៏បានចម្រើនហើយ ធម្មជាតដែលគួរត្រាស់ដឹង ក៏បានត្រាស់ដឹងហើយ ធម្មជាតដែលគួរកំណត់ដឹង ក៏បានកំណត់ដឹងហើយ ធម្មជាតដែលគួរលះ ក៏បានលះហើយ ធម្មជាតដែលគួរចម្រើន ក៏បានចម្រើនហើយ ។ បេ ។ ធម្មជាតដែលគួរធ្វើឲ្យជាក់ច្បាស់ បុគ្គលនោះ ក៏បានធ្វើឲ្យជាក់ច្បាស់ហើយ ជាចតុក្កាគ ធម្មជាតដែលគួរធ្វើឲ្យជាក់ច្បាស់ បុគ្គលនោះមិនបានធ្វើឲ្យជាក់ច្បាស់ហើយ ជាចតុក្កាគ មានឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ ដោយការឃើញសមុទយសច្ច ។ បេ ។ ដោយការឃើញនិរោធសច្ច ។ បេ ។ ដោយការឃើញមគ្គសច្ច តើលះបង់អ្វី ។ បុគ្គល លះរូបរាគៈ អរូបរាគៈ មានះ ឧទ្ធច្ចៈ អវិជ្ជា និងពួកកិលេសដែលដូចគ្នានឹងធម៌ទាំងនោះ ជាចតុក្កាគ ។ អរហន្ត ជាចតុក្កាគ មិនមែនអរហន្ត ជាចតុក្កាគ បុគ្គល ដល់នូវអរហត្ត បានចំពោះ ត្រាស់ដឹង ធ្វើឲ្យជាក់ច្បាស់ សម្រេច ពាល់ត្រូវដោយនាមកាយ ជាចតុក្កាគ មិនពាល់ត្រូវដោយនាមកាយ ជាចតុក្កាគ ប្រាសចាករាគៈ ប្រាសចាកទោសៈ ប្រាសចាកមោហៈ មានសោឡសកិច្ចធ្វើហើយ មានភារៈដាក់ចុះហើយ

អនុប្បត្តសទត្ថោ បរិក្ខីណភវសញ្ញោជនោ សម្មទញ្ញា វិមុត្តោ ឧក្ខិត្តបលិឃោ សង្កិណ្ណបរិខោ អព្ពុឡ្ហេសិកោ និរគ្គឡោ អរិយោ បន្នទ្ធជោ បន្នភារោ វិសញ្ញុត្តោ សុវិជិតវិជយោ ទុក្ខន្តស្ស បរិញ្ញាតំ សមុទយោ បហី-នោ និរោធោ សច្ឆិកតោ មគ្គោ ភាវិតោ អភិញ្ញេយ្យំ អភិញ្ញាតំ បរិញ្ញេយ្យំ បរិញ្ញាតំ បហាតព្វំ បហីនំ ភាវេតព្វំ ភាវិតំ ។ បេ ។ សច្ឆិកាតព្វំ សច្ឆិកតំ ច-តុព្ភកំ សច្ឆិកាតព្វំ ន សច្ឆិកតន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[២១១] សោតាបត្តិផលសច្ឆិកិរិយាយ បដិបន្នោ បុគ្គលោ ទុក្ខំ ទក្ខន្តោ បដិបន្នកោតិ វត្តព្វោតិ ។ អាមន្តា ។ ទុក្ខេ ទិដ្ឋេ ផលេ ឋិតោតិ វត្តព្វោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ សមុទយំ ទក្ខន្តោ ។ បេ ។

មានប្រយោជន៍ជារបស់ខ្លួនដល់ហើយដោយលំដាប់ មានសញ្ញោជនៈក្នុងភពអស់រលីងហើយ មានចិត្តរួចស្រឡះហើយ ព្រោះដឹងដោយប្រពៃ មានទ្វារដើងគុលគឺអវិជ្ជាលើកឡើងហើយ មានគូទម្លាយហើយ មានសសរខឿនដកចោលហើយ មិនមានសន្ទះទ្វារ ចេញចាកសត្រូវ មានទង់ដាក់ចុះហើយ មានភារៈដាក់ចុះហើយ ប្រាសចាកធម៌ជាគ្រឿងប្រកប មានជម្នះឈ្នះហើយដោយប្រពៃ ទុក្ខសច្ច បុគ្គលនោះបានកំណត់ដឹងហើយ សមុទយសច្ច ក៏បានលះបង់ហើយ និរោធសច្ច ក៏បានធ្វើឲ្យជាក់ច្បាស់ហើយ មគ្គសច្ច ក៏បានចម្រើនហើយ ធម្មជាតដែលគួរត្រាស់ដឹង ក៏បានត្រាស់ដឹងហើយ ធម្មជាតដែលគួរកំណត់ដឹង ក៏បានកំណត់ដឹងហើយ ធម្មជាតដែលគួរលះ ក៏បានលះហើយ ធម្មជាតដែលគួរចម្រើន ក៏បានចម្រើនហើយ ។ បេ ។ ធម្មជាតដែលគួរធ្វើឲ្យជាក់ច្បាស់ បុគ្គលនោះបានធ្វើឲ្យជាក់ច្បាស់ហើយ ជាចតុក្កាគ ធម្មជាតដែលគួរធ្វើឲ្យជាក់ច្បាស់ បុគ្គលនោះមិនបានធ្វើឲ្យជាក់ច្បាស់ហើយ ជាចតុក្កាគ មានឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[២១១] បុគ្គល ប្រតិបត្តិដើម្បីធ្វើឲ្យជាក់ច្បាស់ នូវសោតាបត្តិផល ឃើញទុក្ខ គួរនិយាយថា ជាអ្នកប្រតិបត្តិបានឬ ។ អើ ។ កាលបើទុក្ខដែលបុគ្គលបានឃើញហើយគួរនិយាយថា ជាអ្នកឋិតនៅក្នុងផលបានឬ ។ អ្នកមិនគួពោលយ៉ាងនេះទេ ។ បេ ។ បុគ្គលឃើញ សមុទយៈ ។ បេ ។

និរោធំ ឧក្ខន្តោ បដិបន្នកោតិ វត្តព្វោតិ ។ អា-មន្តា ។ និរោធេ ទិដ្ឋេ ផលេ ឋិតោតិ វត្តព្វោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[២១២] សោតាបត្តិផលសច្ឆិកិរិយាយ បដិ-បន្នោ បុគ្គលោ មគ្គំ ឧក្ខន្តោ បដិបន្នកោតិ វត្តព្វោ មគ្គេ ទិដ្ឋេ ផលេ ឋិតោតិ វត្តព្វោតិ ។ អាមន្តា ។ ទុក្ខំ ឧក្ខន្តោ បដិបន្នកោតិ វត្តព្វោ ទុក្ខេ ទិដ្ឋេ ផលេ ឋិតោតិ វត្តព្វោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ មគ្គំ ឧក្ខន្តោ បដិបន្នកោតិ វត្តព្វោ មគ្គេ ទិដ្ឋេ ផលេ ឋិតោតិ វត្តព្វោតិ ។ អាមន្តា ។ សមុទយំ ឧក្ខន្តោ ។ បេ ។ និរោធំ ឧក្ខន្តោ បដិបន្នកោតិ វត្តព្វោ និរោធេ ទិដ្ឋេ ផលេ ឋិតោតិ វត្តព្វោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[២១៣] សោតាបត្តិផលសច្ឆិកិរិយាយ បដិ-បន្នោ បុគ្គលោ ទុក្ខំ ឧក្ខន្តោ បដិបន្នកោតិ វត្តព្វោ ទុក្ខេ ទិដ្ឋេ ន វត្តព្វំ ផលេ ឋិតោតិ វត្តព្វោតិ ។ អាមន្តា ។ មគ្គំ ឧក្ខន្តោ បដិបន្នកោតិ វត្តព្វោ

ឃើញនិរោធ គួរនិយាយថា ជាអ្នកប្រតិបត្តិបានឬ ។ អើ ។ កាលបើនិរោធ បុគ្គលនោះបានឃើញហើយ គួរនិយាយថា ជាអ្នកឋិតនៅក្នុងផលបានឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[២១២] បុគ្គល ប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់ នូវសោតាបត្តិផល ឃើញមគ្គ គួរនិយាយថា ជាអ្នកប្រតិបត្តិ ចុះកាលបើមគ្គ បុគ្គលនោះបានឃើញហើយ គួរនិយាយថា ជាអ្នកឋិតនៅក្នុងផលបានឬ ។ អើ ។ បុគ្គលឃើញទុក្ខ គួរនិយាយថា ជាអ្នកប្រតិបត្តិ ចុះកាលបើទុក្ខ បុគ្គលបានឃើញហើយ គួរនិយាយថា ជាអ្នកឋិតនៅក្នុងផលបានឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ បុគ្គលឃើញមគ្គ គួរនិយាយថា ជាអ្នកប្រតិបត្តិ ចុះកាលបើមគ្គ បុគ្គលនោះបានឃើញហើយ គួរនិយាយថា ជាអ្នកឋិតនៅក្នុងផលបានឬ ។ អើ ។ បុគ្គលឃើញសមុទយៈ ។ បេ ។ ឃើញនិរោធ គួរនិយាយថា ជាអ្នកប្រតិបត្តិ ចុះកាលបើនិរោធ បុគ្គលនោះបានឃើញហើយ គួរនិយាយថា ជាអ្នកឋិតនៅក្នុងផលបានឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[២១៣] បុគ្គល ប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់ នូវសោតាបត្តិផល ឃើញទុក្ខ គួរនិយាយថា ជាអ្នកប្រតិបត្តិ កាលបើទុក្ខ បុគ្គលនោះបានឃើញហើយ គេមិនគួរពោលថា គួរនិយាយថា ជាអ្នកឋិតនៅក្នុងផលទេឬ ។ អើ ។ បុគ្គលឃើញមគ្គ គួរនិយាយថា ជាអ្នកប្រតិបត្តិ

មគ្គេ ទិដ្ឋេ ន វត្តព្វំ ផលេ ឋិតោតិ វត្តព្វោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ សមុទយំ ទក្ខន្តោ ។ បេ ។ និរោធំ ទក្ខន្តោ បដិបន្នកោតិ វត្តព្វោ និរោធេ ទិដ្ឋេ ន វត្តព្វំ ផលេ ឋិតោតិ វត្តព្វោតិ ។ អាមន្តា ។ មគ្គំ ទក្ខន្តោ បដិបន្នកោតិ វត្តព្វោ មគ្គេ ទិដ្ឋេ ន វត្តព្វំ ផលេ ឋិតោតិ វត្តព្វោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[២១៤] សោតាបត្តិផលសច្ឆិកិរិយាយ បដិបន្នោ បុគ្គលោ ទុក្ខំ ទក្ខន្តោ បដិបន្នកោតិ វត្តព្វោ ទុក្ខេ ទិដ្ឋេ ន វត្តព្វំ ផលេ ឋិតោតិ វត្តព្វោតិ ។ អាមន្តា ។ និវត្តិយំ(១) ទុក្ខទស្សនន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។ សមុទយំ ទក្ខន្តោ ។ បេ ។ និរោធំ ទក្ខន្តោ បដិបន្នកោតិ វត្តព្វោ និរោធេ ទិដ្ឋេ ន វត្តព្វំ ផលេ ឋិតោតិ វត្តព្វោតិ ។ អាមន្តា ។ និវត្តិយំ និរោធទស្សនន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។

---

១ ម. និទត្តិយំ ។

កាលបើមគ្គ បុគ្គលនោះបានឃើញហើយ គេមិនគួរពោលថា គួរនិយាយថា ជាអ្នកឋិតនៅក្នុងផលទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ បុគ្គល ឃើញសមុទយៈ ។ បេ ។ ឃើញនិរោធៈ គួរនិយាយថា ជាអ្នកប្រតិបត្តិ កាលបើនិរោធ បុគ្គលនោះបានឃើញហើយ គេមិនគួរពោលថា គួរនិយាយថា ជាអ្នកឋិតនៅក្នុងផលទេឬ ។ អើ ។ បុគ្គលឃើញមគ្គ គួរនិយាយថា ជាអ្នកប្រតិបត្តិ កាលបើមគ្គ បុគ្គលនោះបានឃើញហើយ គេមិនគួរពោលថា គួរនិយាយថា ជាអ្នកឋិតនៅក្នុងផលបានទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[២១៤] បុគ្គល ប្រតិបត្តិដើម្បីធ្វើឲ្យជាក់ច្បាស់ នូវសោតាបត្តិ-ផល ឃើញទុក្ខ គួរនិយាយថា ជាអ្នកប្រតិបត្តិ កាលបើទុក្ខ បុគ្គលនោះបានឃើញហើយ គេមិនគួរពោលថា គួរនិយាយថា ជាអ្នកឋិតនៅក្នុងផលបានទេឬ ។ អើ ។ ការឃើញទុក្ខ ជាការឥតប្រយោជន៍ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ បុគ្គល ឃើញសមុទយៈ ។ បេ ។ ឃើញនិរោធ គួរនិយាយថា ជាអ្នកប្រតិបត្តិ កាលបើនិរោធ បុគ្គលនោះបានឃើញហើយ គេមិនគួរពោលថា គួរនិយាយថា ជាអ្នកឋិតនៅក្នុងផលបានទេឬ ។ អើ ។ ការឃើញនិរោធ ជាការឥតប្រ-យោជន៍ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

៨៩

## អនុបុព្វាភិសមយកថា

[២១៥] ទុក្ខេ ទិដ្ឋេ ចត្តារិ សច្ចានិ ទិដ្ឋានិ ហោន្តីតិ ។ អាមន្តា ។ ទុក្ខសច្ចំ ចត្តារិ សច្ចានីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[២១៦] រូបក្ខន្ធេ អនិច្ចតោ ទិដ្ឋេ បញ្ចក្ខន្ធា អនិច្ចតោ ទិដ្ឋា ហោន្តីតិ ។ អាមន្តា ។ រូបក្ខន្ធោ បញ្ចក្ខន្ធាតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[២១៧] ចក្ខាយតនេ អនិច្ចតោ ទិដ្ឋេ ទ្វាទសាយតនានិ អនិច្ចតោ ទិដ្ឋានិ ហោន្តីតិ ។ អាមន្តា ។ ចក្ខាយតនំ ទ្វាទសាយតនានីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[២១៨] ចក្ខុធាតុយា អនិច្ចតោ ទិដ្ឋាយ អដ្ឋារស ធាតុយោ អនិច្ចតោ ទិដ្ឋា ហោន្តីតិ ។ អាមន្តា ។ ចក្ខុធាតុ អដ្ឋារស ធាតុយោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[២១៩] ចក្ខុន្ទ្រិយេ អនិច្ចតោ ទិដ្ឋេ ពាវីសតិន្ទ្រិយានិ អនិច្ចតោ ទិដ្ឋានិ ហោន្តីតិ ។ អាមន្តា ។ ចក្ខុន្ទ្រិយំ ពាវីសតិន្ទ្រិយានីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

អនុបុញ្ញាភិសមយកថា

[២១៥] កាលបើទុក្ខ បុគ្គលបានឃើញហើយ សច្ចៈ ៤ ឈ្មោះថាបានឃើញហើយឬ ។ អើ ។ ទុក្ខសច្ច ឈ្មោះថាសច្ចៈ ៤ ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[២១៦] កាលបើរូបក្ខន្ធ បុគ្គលបានឃើញហើយ ដោយសេចក្ដីថាមិនទៀង បញ្ចក្ខន្ធ ឈ្មោះថាបានឃើញហើយ ដោយសេចក្ដីថាមិនទៀងឬ ។ អើ ។ រូបក្ខន្ធ ឈ្មោះថាបញ្ចក្ខន្ធឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[២១៧] កាលបើចក្ខាយតនៈ បុគ្គលឃើញហើយ ដោយសេចក្ដីថា មិនទៀង អាយតនៈ ១២ ឈ្មោះថាបុគ្គលឃើញហើយ ដោយសេចក្ដីថា មិនទៀងឬ ។ អើ ។ ចក្ខាយតនៈ ឈ្មោះថាអាយតនៈ ១២ ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[២១៨] កាលបើចក្ខុធាតុ បុគ្គលបានឃើញហើយ ដោយសេចក្ដីថាមិនទៀង ធាតុទាំង១៨ ឈ្មោះថាបានឃើញហើយ ដោយសេចក្ដីថាមិនទៀងឬ ។ អើ ។ ចក្ខុធាតុ ឈ្មោះថាធាតុ ១៨ ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[២១៩] កាលបើចក្ខុន្ទ្រិយ បុគ្គលបានឃើញហើយ ដោយសេចក្ដីថា មិនទៀង ឥន្ទ្រិយទាំង២២ ឈ្មោះថាបានឃើញហើយ ដោយសេចក្ដីថា មិនទៀងឬ ។ អើ ។ ចក្ខុន្ទ្រិយ ឈ្មោះថាឥន្ទ្រិយ ២២ ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[២២០] ចតូហិ ញាណេហិ សោតាបត្តិផលំ សច្ឆិ-
ករោតីតិ ។ អាមន្តា ។ ចត្តារិ សោតាបត្តិផលានីតិ ។
ន ហេវំ វត្តព្វេ ។ បេ ។ អដ្ឋហិ ញាណេហិ សោតា-
បត្តិផលំ សច្ឆិករោតីតិ ។ អាមន្តា ។ អដ្ឋ សោតា-
បត្តិផលានីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ ទ្វាទស-
ហិ ញាណេហិ សោតាបត្តិផលំ សច្ឆិករោតីតិ ។
អាមន្តា ។ ទ្វាទស សោតាបត្តិផលានីតិ ។ ន ហេវំ
វត្តព្វេ ។ បេ ។ ចតុច្ចត្តាឡីសាយ ញាណេហិ សោ-
តាបត្តិផលំ សច្ឆិករោតីតិ ។ អាមន្តា ។ ចតុច្ចត្តា-
ឡីស សោតាបត្តិផលានីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។
សត្តសត្តតិយា ញាណេហិ សោតាបត្តិផលំ សច្ឆិក-
រោតីតិ ។ អាមន្តា ។ សត្តសត្តតិ សោតាបត្តិផលានី-
តិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[២២១] ន វត្តព្វំ អនុបុព្វាភិសមយោតិ ។ អាមន្តា ។
ននុ វុត្តំ ភគវតា សេយ្យថាបិ ភិក្ខវេ មហាសមុទ្ទោ
អនុបុព្វនិន្នោ អនុបុព្វចោណោ អនុបុព្វបព្ភារោ ន អា-
យតកេនេវ បបាតោ ឯវមេវ ខោ ភិក្ខវេ ឥមស្មឹ ធម្ម-
វិនយេ អនុបុព្វសិក្ខា អនុបុព្វកិរិយា អនុបុព្វបដិបទា

[២២០] បុគ្គល ធ្វើឲ្យជាក់ច្បាស់ នូវសោតាបត្តិផល ដោយញាណទាំង ៤ ឬ ។ អើ ។ សោតាបត្តិផល មាន ៤ ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ បុគ្គលធ្វើឲ្យជាក់ច្បាស់ នូវសោតាបត្តិ-ផល ដោយញាណទាំង ៨ ឬ ។ អើ ។ សោតាបត្តិផល មាន ៨ ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ បុគ្គលធ្វើឲ្យជាក់ច្បាស់ នូវសោតាបត្តិផល ដោយញាណទាំង ១២ ឬ ។ អើ ។ សោតាបត្តិ-ផល មាន ១២ ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ បុគ្គលធ្វើឲ្យជាក់ច្បាស់ នូវសោតាបត្តិផល ដោយញាណទាំង ៤៤ ឬ ។ អើ ។ សោតាបត្តិផល មាន ៤៤ ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ បុគ្គលធ្វើឲ្យជាក់ច្បាស់ នូវសោតាបត្តិផល ដោយញាណទាំង ៧៧ ឬ ។ អើ ។ សោតាបត្តិផល មាន ៧៧ ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[២២១] បុគ្គលមិនគួរនិយាយថា ការត្រាស់ដឹងជាលំដាប់ មានទេឬ ។ អើ ។ ក្រែងព្រះមានព្រះភាគ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ មហាសមុទ្រ ទាបទៅដោយលំដាប់ ជ្រាលទៅដោយលំដាប់ ទេរទៅដោយលំដាប់ មិនមែនចោតជ្រៅស្រឡូង ដូចជាអណ្តូងទេ យ៉ាងណាមិញ ម្នាលភិក្ខុទាំងឡាយ ក្នុងធម្មវិន័យនេះ មានការសិក្សាជាលំដាប់ មានកិច្ចដែលត្រូវធ្វើដោយលំដាប់ មានសេចក្តីប្រតិបត្តិ ដោយលំដាប់

ន អាយតកេនេវ អញ្ញាបដិវេធោតិ អត្ថេវ សុត្តន្តោតិ ។ អាមន្តា ។ តេន ហិ អនុបុព្វាភិសមយោតិ ។

[២២២] ន វត្តព្វំ អនុបុព្វាភិសមយោតិ ។ អាមន្តា ។ ននុ វុត្តំ ភគវតា

អនុបុព្វេន មេធាវី ថោកំ ថោកំ ខណេ ខណេ
កម្មារោ រជតស្សេវ និទ្ធមេ មលមត្តនោតិ

អត្ថេវ សុត្តន្តោតិ ។ អាមន្តា ។ តេន ហិ អនុបុព្វាភិសមយោតិ ។

[២២៣] ន វត្តព្វំ អនុបុព្វាភិសមយោតិ ។ អាមន្តា ។ ននុ អាយស្មា គវម្បតិត្ថេរោ ភិក្ខូ ឯតទវោច សម្មុខា មេតំ អាវុសោ ភគវតោ សុតំ សម្មុខា បដិគ្គហិតំ យោ ភិក្ខវេ ទុក្ខំ បស្សតិ ទុក្ខសមុទយម្បិ សោ បស្សតិ ទុក្ខនិរោធម្បិ បស្សតិ ទុក្ខនិរោធគាមិនីបដិបទម្បិ បស្សតិ យោ ទុក្ខសមុទយំ បស្សតិ ទុក្ខម្បិ សោ បស្សតិ ទុក្ខនិរោធម្បិ បស្សតិ ទុក្ខនិរោធគាមិនីបដិបទម្បិ បស្សតិ យោ ទុក្ខនិរោធំ បស្សតិ ទុក្ខម្បិ សោ បស្សតិ

មិនមែនបានត្រាស់ដឹងព្រះអរហត្តផលតែម្តងទេ ក៏យ៉ាងនោះឯង ពាក្យដូច្នេះ មានក្នុងព្រះសូត្រឬ ។ អើ ។ ព្រោះហេតុនោះ ការត្រាស់ដឹងជាលំដាប់ មាន ។

[២២២] បុគ្គលមិនគួរនិយាយថា ការត្រាស់ដឹងជាលំដាប់ មានទេឬ ។ អើ ។ ក្រែងព្រះមានព្រះភាគ ទ្រង់ត្រាស់ថា

អ្នកមានប្រាជ្ញា គប្បីកម្ចាត់បង់ នូវមន្ទិលរបស់ខ្លួន បន្តិច
ម្តង ៗ ក្នុងមួយខណៈ ៗ ដោយលំដាប់ ដូចជាជាងមាស
ដែលកម្ចាត់បង់ នូវមន្ទិលនៃរជតវត្ថុ ដូច្នោះដែរ

ពាក្យដូច្នេះ មានក្នុងព្រះសូត្រឬ ។ អើ ។ ព្រោះហេតុនោះ ការត្រាស់ដឹងជាលំដាប់ មាន ។

[២២៣] បុគ្គលមិនគួរនិយាយថា ការត្រាស់ដឹងជាលំដាប់ មានទេឬ ។ អើ ។ ក្រែងព្រះគវម្បតិត្ថេរមានអាយុ បានពោលដូច្នេះ នឹងភិក្ខុទាំងឡាយហើយថា ម្នាលលោកមានអាយុទាំងឡាយ ពាក្យនេះ ខ្ញុំបានស្តាប់ក្នុងទីចំពោះព្រះភក្ត្រ បានទទួលក្នុងទីចំពោះព្រះភក្ត្រ នៃព្រះមានព្រះភាគថា ម្នាលភិក្ខុទាំងឡាយ បុគ្គលណា ឃើញទុក្ខ បុគ្គលនោះ ឈ្មោះថាឃើញទុក្ខសមុទយៈផង ឃើញទុក្ខនិរោធផង ឃើញទុក្ខនិរោធ-គាមិនីបដិបទាផង បុគ្គលណា ឃើញទុក្ខសមុទយៈ បុគ្គលនោះ ឈ្មោះថាឃើញទុក្ខផង ឃើញទុក្ខនិរោធផង ឃើញទុក្ខនិរោធគាមិនីបដិបទាផង បុគ្គលណា ឃើញទុក្ខនិរោធ បុគ្គលនោះ ឈ្មោះថាឃើញទុក្ខផង

ទុក្ខសមុទយម្បិ បស្សតិ ទុក្ខនិរោធគាមិនីបដិបទម្បិ បស្សតិ យោ ទុក្ខនិរោធគាមិនីបដិបទម្បិ បស្សតិ ទុក្ខម្បិ សោ បស្សតិ ទុក្ខសមុទយម្បិ បស្សតិ ទុក្ខនិរោធម្បិ បស្សតីតិ អត្ថេវ សុត្តន្តោតិ ។ អាមន្តា ។ តេន ហិ ន វត្តព្វំ អនុបុព្វាភិសមយោតិ ។

[២២៤] អនុបុព្វាភិសមយោតិ ។ អាមន្តា ។ ននុ វុត្តំ ភគវតា សហាវស្ស ទស្សនសម្បទាយ ។ បេ ។ ឆ ចាភិឋានានិ អភព្វោ កាតុន្តិ អត្ថេវ សុត្តន្តោតិ ។ អាមន្តា ។ តេន ហិ ន វត្តព្វំ អនុបុព្វាភិសមយោតិ ។

[២២៥] អនុបុព្វាភិសមយោតិ ។ អាមន្តា ។ ននុ វុត្តំ ភគវតា យស្មឹ ភិក្ខវេ សមយេ អរិយសាវកស្ស វិរជំ វីតមលំ ធម្មចក្ខុំ ឧទបាទិ យំ កិញ្ចិ សមុទយធម្មំ សព្វន្តំ និរោធធម្មន្តិ សហ ទស្សនុប្បាទា ភិក្ខវេ អរិយសាវកស្ស តីណិ សញ្ញោជនានិ បហីយន្តិ សក្កាយទិដ្ឋិ វិចិកិច្ឆា សីលព្វតបរាមាសោតិ

ឃើញទុក្ខសមុទយៈផង ឃើញទុក្ខនិរោធគាមិនីបដិបទាផង បុគ្គលណា ឃើញទុក្ខនិរោធគាមិនីបដិបទា បុគ្គលនោះ ឈ្មោះថាឃើញទុក្ខផង ឃើញទុក្ខសមុទយៈផង ឃើញទុក្ខនិរោធផង ពាក្យដូច្នេះ មានក្នុងព្រះសូត្របុ ។ អើ ។ ព្រោះហេតុនោះ បុគ្គលមិនគួរនិយាយថា ការត្រាស់ដឹងជាលំដាប់ មានទេ ។

[២២៨] ការត្រាស់ដឹងជាលំដាប់ មានឬ ។ អើ ។ ក្រែងព្រះមានព្រះភាគ ទ្រង់ត្រាស់ថា ជាមួយនឹងទស្សនសម្បទា (គឺសោ-តាបត្តិមគ្គ) ។ បេ ។ សោតាបន្នបុគ្គល មិនគួរធ្វើនូវហេតុជាទីតាំងនៃសេចក្តីអាក្រក់ទាំង ៦ ពាក្យដូច្នេះ មានក្នុងព្រះសូត្របុ ។ អើ ។ ព្រោះហេតុនោះ បុគ្គលមិនគួរនិយាយថា ការត្រាស់ដឹងជាលំដាប់ មានទេ ។

[២២៩] ការត្រាស់ដឹងជាលំដាប់ មានឬ ។ អើ ។ ក្រែងព្រះមានព្រះភាគ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ សម័យណា ធម្មចក្ខុ ដែលមានធូលីទៅប្រាសហើយ មានមន្ទិលទៅប្រាសហើយ របស់អរិយសាវ័ក កើតឡើងថា ធម្មជាតណាមួយ មានការកើតឡើងជាធម្មតា ធម្មជាតទាំងអស់នោះ មានការរលត់ទៅវិញជាធម្មតា ម្នាលភិក្ខុទាំងឡាយ សម័យនោះ សញ្ញោជនៈ ៣ យ៉ាងគឺ សក្កាយទិដ្ឋិ ១ វិចិកិច្ឆា ១ សីលព្វតបរាមាសៈ ១ ឈ្មោះថាអរិយសាវ័កបានលះបង់

អត្ថេវ សុត្តន្តោតិ ។ អាមន្តា ។ តេន ហិ ន វត្តព្វំ អនុបុព្វាភិសមយោតិ ។

អនុបុព្វាភិសមយកថា ។

# វោហារកថា

[២២៦] ពុទ្ធស្ស ភគវតោ វោហារោ លោកុត្តរោតិ ។ អាមន្តា ។ លោកុត្តរេ សោតេ បដិហញ្ញតិ នោ លោកិយេ លោកុត្តរេន វិញ្ញាណេន បដិវិជានន្តិ នោ លោកិយេន សាវកា បដិវិជានន្តិ នោ បុថុជ្ជនាតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[២២៧] ននុ ពុទ្ធស្ស ភគវតោ វោហារោ លោកិយេ សោតេ បដិហញ្ញតីតិ ។ អាមន្តា ។ ហញ្ចិ ពុទ្ធស្ស ភគវតោ វោហារោ លោកិយេ សោតេ បដិហញ្ញតិ នោ វត វេ វត្តព្វេ ពុទ្ធស្ស ភគវតោ វោហារោ លោកុត្តរោតិ ។

[២២៨] ននុ ពុទ្ធស្ស ភគវតោ វោហារំ លោកិយេន វិញ្ញាណេន បដិវិជានន្តីតិ ។ អាមន្តា ។ ហញ្ចិ ពុទ្ធស្ស ភគវតោ វោហារំ លោកិយេន វិញ្ញាណេន

ជាមួយនឹងការកើតឡើងនៃទស្សនសម្បទា ពាក្យដូច្នេះ មានក្នុងព្រះសូត្រ ឬ ។ អើ ។ ព្រោះហេតុនោះ បុគ្គលមិនគួរនិយាយថា ការត្រាស់ដឹងជាលំដាប់ មានទេ ។

ចប់ អនុបុព្វាភិសមយកថា ។

# វោហារកថា

[២២៦] វោហារ របស់ព្រះពុទ្ធមានព្រះភាគ ជាលោកុត្តរៈឬ ។ អើ ។ វោហារ របស់ព្រះពុទ្ធមានព្រះភាគ ប៉ះទង្គិចត្រចៀកជាលោកុត្តរៈ មិនប៉ះទង្គិចត្រចៀកជាលោកិយៈ ជនទាំងឡាយ ដឹងច្បាស់ដោយវិញ្ញាណជាលោកុត្តរៈ មិនដឹងច្បាស់ ដោយវិញ្ញាណជាលោកិយៈ សាវ័កទាំងឡាយ ដឹងច្បាស់ បុថុជ្ជនទាំងឡាយ មិនដឹងច្បាស់ទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[២២៧] ក្រែងវោហារ របស់ព្រះពុទ្ធមានព្រះភាគ ប៉ះទង្គិចត្រចៀកជាលោកិយៈឬ ។ អើ ។ បើវោហារ របស់ព្រះពុទ្ធមានព្រះភាគ ប៉ះទង្គិចត្រចៀកជាលោកិយៈដែរ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា វោហារ របស់ព្រះពុទ្ធមានព្រះភាគ ជាលោកុត្តរៈទេ ។

[២២៨] ក្រែងពួកសាវ័ក ដឹងច្បាស់ នូវវោហារ របស់ព្រះពុទ្ធមានព្រះភាគ ដោយវិញ្ញាណជាលោកិយៈឬ ។ អើ ។ បើពួកសាវ័ក ដឹងច្បាស់ នូវវោហារ របស់ព្រះពុទ្ធមានព្រះភាគ ដោយវិញ្ញាណជាលោកិយៈដែរ

បដិវិជានន្តិ នោ វត រេ វត្តព្វេ ពុទ្ធស្ស ភគវតោ វោហារោ លោកុត្តរោតិ ។

[២២៩] ននុ ពុទ្ធស្ស ភគវតោ វោហារំ បុថុជ្ជនា បដិវិជានន្តីតិ ។ អាមន្តា ។ ហញ្ចិ ពុទ្ធស្ស ភគវតោ វោហារំ បុថុជ្ជនា បដិវិជានន្តិ នោ វត រេ វត្តព្វេ ពុទ្ធស្ស ភគវតោ វោហារោ លោកុត្តរោតិ ។

[២៣០] ពុទ្ធស្ស ភគវតោ វោហារោ លោកុត្តរោតិ ។ អាមន្តា ។ មគ្គោ ផលំ និព្វានំ សោតាបត្តិមគ្គោ សោតាបត្តិផលំ សកទាគាមិមគ្គោ សកទាគាមិផលំ អនាគាមិមគ្គោ អនាគាមិផលំ អរហត្តមគ្គោ អរហត្តផលំ សតិប្បដ្ឋានំ សម្មប្បធានំ ឥទ្ធិបាទោ ឥន្ទ្រិយំ ពលំ ពោជ្ឈង្គោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[២៣១] ពុទ្ធស្ស ភគវតោ វោហារោ លោកុត្តរោតិ ។ អាមន្តា ។ អត្ថិ កោចិ ពុទ្ធស្ស ភគវតោ វោហារំ សុណាតីតិ ។ អាមន្តា ។ លោកុត្តរោ ធម្មោ សោតវិញ្ញេយ្យោ សោតស្មឹ បដិហញ្ញតិ សោតស្ស អាបាថំ អាគច្ឆតីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា វោហារ របស់ព្រះពុទ្ធមានព្រះភាគ ជាលោកុត្តរៈទេ ។

[២២៩] ក្រែងពួកបុថុជ្ជន ដឹងច្បាស់ នូវវោហារ របស់ព្រះពុទ្ធមានព្រះភាគឬ ។ អើ ។ បើពួកបុថុជ្ជន ដឹងច្បាស់ នូវវោហារ របស់ព្រះពុទ្ធមានព្រះភាគដែរ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា វោហារ របស់ព្រះពុទ្ធមានព្រះភាគ ជាលោកុត្តរៈទេ ។

[២៣០] វោហារ របស់ព្រះពុទ្ធមានព្រះភាគ ជាលោកុត្តរៈឬ ។ អើ ។ ចុះមគ្គ ផល និព្វាន សោតាបត្តិមគ្គ សោតាបត្តិផល សកទាគាមិមគ្គ សកទាគាមិផល អនាគាមិមគ្គ អនាគាមិផល អរហត្តមគ្គ អរហត្តផល សតិប្បដ្ឋាន សម្មប្បធាន ឥទ្ធិបាទ ឥន្ទ្រិយ ពលៈ ពោជ្ឈង្គៈ (ជាលោកុត្តរៈ) ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[២៣១] វោហារ របស់ព្រះពុទ្ធមានព្រះភាគ ជាលោកុត្តរៈឬ ។ អើ ។ សាវ័កពួកខ្លះ ស្តាប់វោហាររបស់ព្រះពុទ្ធមានព្រះភាគ មានឬ ។ អើ ។ លោកុត្តរធម៌ បុគ្គលគប្បីដឹងដោយត្រចៀក ប៉ះទង្គិចត្រចៀក មកកាន់វង្វង់នៃត្រចៀកឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[២៣២] ននុ លោកុត្តរោ ធម្មោ ន សោតវិញ្ញេយ្យោ ន សោតស្មឹ បដិហញ្ញតិ ន សោតស្ស អាបាថំ អាគច្ឆតីតិ ។ អាមន្តា ។ ហញ្ចិ លោកុត្តរោ ធម្មោ ន សោតវិញ្ញេយ្យោ ន សោតស្មឹ បដិហញ្ញតិ ន សោតស្ស អាបាថំ អាគច្ឆតិ នោ ច វត រេ វត្តព្វេ ពុទ្ធស្ស ភគវតោ វោហារោ លោកុត្តរោតិ ។

[២៣៣] ពុទ្ធស្ស ភគវតោ វោហារោ លោកុត្តរោតិ ។ អាមន្តា ។ អត្ថិ កោចិ ពុទ្ធស្ស ភគវតោ វោហារេ រជ្ជេយ្យុន្តិ ។ អាមន្តា ។ លោកុត្តរោ ធម្មោ រាគដ្ឋានិយោ រជនិយោ កាមនិយោ មទនិយោ ពន្ធនិយោ មុច្ឆនិយោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[២៣៤] ននុ លោកុត្តរោ ធម្មោ ន រាគដ្ឋានិយោ ន រជនិយោ ន កាមនិយោ ន មទនិយោ ន ពន្ធនិយោ ន មុច្ឆនិយោតិ ។ អាមន្តា ។ ហញ្ចិ លោកុត្តរោ ធម្មោ ន រាគដ្ឋានិយោ ន រជនិយោ ន កាមនិយោ ន មទនិយោ ន ពន្ធនិយោ ន មុច្ឆនិយោ នោ ច វត រេ វត្តព្វេ ពុទ្ធស្ស ភគវតោ វោហារោ លោកុត្តរោតិ ។

វោហារកថា

[២៣២] ក្រែងលោកុត្តរធម៌ បុគ្គលមិនគប្បីដឹងដោយត្រចៀក មិនប៉ះទង្គិចត្រចៀក មិនមកកាន់វង្វង់នៃត្រចៀកទេឬ ។ អើ ។ បើលោកុត្តរធម៌ បុគ្គលមិនគប្បីដឹងដោយត្រចៀក មិនប៉ះទង្គិចត្រចៀក មិនមកកាន់វង្វង់នៃត្រចៀកទេ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា វោហារ របស់ព្រះពុទ្ធមានព្រះភាគ ជាលោកុត្តរៈទេ ។

[២៣៣] វោហារ របស់ព្រះពុទ្ធមានព្រះភាគ ជាលោកុត្តរៈឬ ។ អើ ។ សាវ័កពួកខ្លះ ត្រេកអរ នឹងវោហាររបស់ព្រះពុទ្ធមានព្រះភាគ មានឬ ។ អើ ។ លោកុត្តរធម៌ ជាទីតាំងនៃរាគៈ ជាទីត្រេកអរ ជាទីប្រាថ្នា ជាទីស្រវឹង ជាទីចង ជាទីជ្រប់ចុះឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[២៣៤] ក្រែងលោកុត្តរធម៌ មិនមែនជាទីតាំងនៃរាគៈ មិនជាទីត្រេកអរ មិនជាទីប្រាថ្នា មិនជាទីស្រវឹង មិនជាទីចង មិនជាទីជ្រប់ចុះទេឬ ។ អើ ។ បើលោកុត្តរធម៌ មិនជាទីតាំងនៃរាគៈ មិនជាទីត្រេកអរ មិនជាទីប្រាថ្នា មិនជាទីស្រវឹង មិនជាទីចង មិនជាទីជ្រប់ចុះទេ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា វោហារ របស់ព្រះពុទ្ធមានព្រះភាគ ជាលោកុត្តរៈទេ ។

[២៣៥] ពុទ្ធស្ស ភគវតោ វោហារោ លោកុត្ត-
រោតិ ។ អាមន្តា ។ អត្ថិ កេចិ ពុទ្ធស្ស ភគវតោ
វោហារំ[១] ទុស្សេយ្យុន្តិ ។ អាមន្តា ។ លោកុត្តរោ
ធម្មោ ទោសដ្ឋានិយោ កោបដ្ឋានិយោ បដិឃដ្ឋានិ-
យោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[២៣៦] ននុ លោកុត្តរោ ធម្មោ ន ទោសដ្ឋា-
និយោ ន កោបដ្ឋានិយោ ន បដិឃដ្ឋានិយោតិ ។
អាមន្តា ។ ហញ្ចិ លោកុត្តរោ ធម្មោ ន ទោសដ្ឋា-
និយោ ន កោបដ្ឋានិយោ ន បដិឃដ្ឋានិយោ នោ
វត រេ វត្តព្វេ ពុទ្ធស្ស ភគវតោ វោហារោ លោកុត្ត-
រោតិ ។

[២៣៧] ពុទ្ធស្ស ភគវតោ វោហារោ លោកុត្ត-
រោតិ ។ អាមន្តា ។ អត្ថិ កេចិ ពុទ្ធស្ស ភគវតោ
វោហារេ មុយ្ហេយ្យុន្តិ ។ អាមន្តា ។ លោកុត្តរោ
ធម្មោ មោហដ្ឋានិយោ អញ្ញាណករណោ អចក្ខុក-
រណោ បញ្ញានិរោធិកោ វិឃាតបក្ខិកោ អនិព្វាន-
សំវត្តនិកោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

---

១ ម. វោហារេតិ ទិស្សតិ ។

[២៣៥] វោហារ របស់ព្រះពុទ្ធមានព្រះភាគ ជាលោកុត្តរៈ ឬ ។ អើ ។ សាវកពួកខ្លះ ប្រទូស្ត នឹងវោហារ របស់ព្រះពុទ្ធមានព្រះភាគ មានឬ ។ អើ ។ លោកុត្តរធម៌ ជាទីតាំងនៃសេចក្តីប្រទូស្ត ជាទីតាំងនៃសេចក្តីក្រោធ ជាទីតាំងនៃសេចក្តីថ្នាំងថ្នាក់ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[២៣៦] ក្រែងលោកុត្តរធម៌ មិនមែនជាទីតាំងនៃសេចក្តីប្រទូស្ត មិនមែនជាទីតាំងនៃសេចក្តីក្រោធ មិនមែនជាទីតាំងនៃសេចក្តីថ្នាំងថ្នាក់ទេឬ ។ អើ ។ បើលោកុត្តរធម៌ មិនមែនជាទីតាំងនៃសេចក្តីប្រទូស្ត មិនមែនជាទីតាំងនៃសេចក្តីក្រោធ មិនមែនជាទីតាំងនៃសេចក្តីថ្នាំងថ្នាក់ទេ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា វោហារ របស់ព្រះពុទ្ធមានព្រះភាគ ជាលោកុត្តរៈទេ ។

[២៣៧] វោហារ របស់ព្រះពុទ្ធមានព្រះភាគ ជាលោកុត្តរៈឬ ។ អើ ។ សាវកពួកខ្លះ វង្វេង ក្នុងវោហាររបស់ព្រះពុទ្ធមានព្រះភាគឬ ។ អើ ។ លោកុត្តរធម៌ ជាទីតាំងនៃសេចក្តីវង្វេង ធ្វើមិនឲ្យមានញាណ ធ្វើមិនឲ្យមានចក្ខុ ប្រកបដោយការរលត់ទៅនៃបញ្ញា ជាពួកនៃសេចក្តីចង្អៀតចង្អល់ មិនប្រព្រឹត្តទៅដើម្បីព្រះនិព្វានទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

៩៧

## វោហារកថា

[២៣៨] ននុ លោកុត្តរោ ធម្មោ ន មោហដ្ឋានិយោ ន អញ្ញាណករណោ ន អចក្ខុករណោ បញ្ញាវុឌ្ឍិកោ អវិឃាតបក្ខិកោ និព្វានសំវត្តនិកោតិ ។ អាមន្តា ។ ហញ្ចិ លោកុត្តរោ ធម្មោ ន មោហដ្ឋានិយោ ន អញ្ញាណករណោ ន អចក្ខុករណោ បញ្ញាវុឌ្ឍិកោ អវិឃាតបក្ខិកោ និព្វានសំវត្តនិកោ នោ វត រេ វត្តព្វេ ពុទ្ធស្ស ភគវតោ វោហារោ លោកុត្តរោតិ ។

[២៣៩] ពុទ្ធស្ស ភគវតោ វោហារោ លោកុត្តរោតិ ។ អាមន្តា ។ យេ កេចិ ពុទ្ធស្ស ភគវតោ វោហារំ សុណន្តិ សព្វេ តេ មគ្គំ ភាវេន្តីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[២៤០] យេ កេចិ ពុទ្ធស្ស ភគវតោ វោហារំ សុណន្តិ សព្វេ តេ មគ្គំ ភាវេន្តីតិ ។ អាមន្តា ។ ពាលបុថុជ្ជនា ពុទ្ធស្ស ភគវតោ វោហារំ សុណន្តិ ពាលបុថុជ្ជនា មគ្គំ ភាវេន្តីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ មាតុឃាតកោ ។ បេ ។ បិតុឃាតកោ . . . អរហន្តឃាតកោ . . . រុហិរុប្បាទកោ ។ បេ ។ សង្ឃភេទកោ

វោហារកថា

[២៣៨] ក្រែងលោកុត្តរធម៌ មិនមែនជាទីតាំងនៃសេចក្តីវង្វេង មិនមែនធ្វើមិនឲ្យមានញាណ មិនមែនធ្វើមិនឲ្យមានចក្ខុ ប្រកបដោយការចម្រើននៃបញ្ញា មិនមែនជាពួកនៃសេចក្តីចង្អៀតចង្អល់ ប្រព្រឹត្តទៅដើម្បីព្រះនិព្វានឬ ។ អើ ។ បើលោកុត្តរធម៌ មិនមែនជាទីតាំងនៃសេចក្តីវង្វេង មិនមែនធ្វើមិនឲ្យមានញាណ មិនមែនធ្វើមិនឲ្យមានចក្ខុ ប្រកបដោយការចម្រើននៃបញ្ញា មិនមែនជាពួកនៃសេចក្តីចង្អៀតចង្អល់ ប្រព្រឹត្តទៅដើម្បីព្រះនិព្វាន ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា វោហាររបស់ព្រះពុទ្ធមានព្រះភាគ ជាលោកុត្តរៈទេ ។

[២៣៩] វោហារ របស់ព្រះពុទ្ធមានព្រះភាគ ជាលោកុត្តរៈឬ ។ អើ ។ ពួកសាវ័កណាមួយ ស្តាប់វោហាររបស់ព្រះពុទ្ធមានព្រះភាគ សាវ័កទាំងអស់នោះ ចម្រើនមគ្គឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[២៤០] ពួកសាវ័កណាមួយ ស្តាប់វោហាររបស់ព្រះពុទ្ធមានព្រះភាគ សាវ័កទាំងអស់នោះ ចម្រើនមគ្គឬ ។ អើ ។ ពួកពាលបុថុជ្ជន ស្តាប់វោហារ របស់ព្រះពុទ្ធមានព្រះភាគ ពួកពាលបុថុជ្ជន ចម្រើនមគ្គឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ បុគ្គលអ្នកសម្លាប់មាតា ។ បេ ។ បុគ្គលអ្នកសម្លាប់បិតា . . . បុគ្គលអ្នកសម្លាប់ព្រះអរហន្ត . . . បុគ្គលអ្នកធ្វើព្រះលោហិតឲ្យពុះពោរ ។ បេ ។ បុគ្គលអ្នកបំបែកសង្ឃ

ពុទ្ធស្ស ភគវតោ វោហារំ សុណាតិ សង្ឃភេទកោ មគ្គំ ភាវេតីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[២៤១] លព្ភា សោវណ្ណមយាយ លដ្ឋិយា ធញ្ញ-បុញ្ជោបិ សុវណ្ណបុញ្ជោបិ អាចិក្ខិតុន្តិ ។ អាមន្តា ។ ឯវមេវ ភគវា លោកុត្តរេន វោហារេន លោកិយម្បិ លោកុត្តរម្បិ ធម្មំ វោហរតីតិ ។

[២៤២] លព្ភា ឯលណ្ឌិយាយ លដ្ឋិយា ធញ្ញ-បុញ្ជោបិ សុវណ្ណបុញ្ជោបិ អាចិក្ខិតុន្តិ ។ អាមន្តា ។ ឯវមេវ ភគវា លោកិយេន វោហារេន លោកិយម្បិ លោកុត្តរម្បិ ធម្មំ វោហរតីតិ ។

[២៤៣] ពុទ្ធស្ស ភគវតោ វោហារោ លោកិ-យំ វោហរន្តស្ស លោកិយោ ហោតិ លោកុត្តរំ វោហរន្តស្ស លោកុត្តរោ ហោតីតិ ។ អាមន្តា ។ លោកិយំ វោហរន្តស្ស សោ លោកិយេ សោតេ បដិហញ្ញតិ លោកុត្តរំ វោហរន្តស្ស លោកុត្តរេ សោ-តេ បដិហញ្ញតិ លោកិយំ វោហរន្តស្ស លោកិ-យេន វិញ្ញាណេន បដិវិជានន្តិ លោកុត្តរំ វោហ-រន្តស្ស លោកុត្តរេន វិញ្ញាណេន បដិវិជានន្តិ

ស្តាប់វោហាររបស់ព្រះពុទ្ធមានព្រះភាគ បុគ្គលអ្នកបំបែកសង្ឃ ចម្រើនមគ្គឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[២៤១] គំនរស្រូវក្តី គំនរមាសក្តី បុគ្គលអាចដើម្បីប្រាប់ថា ជាកូនឆ្នោតជាវិការៈនៃមាសឬ ។ អើ ។ ព្រះមានព្រះភាគ ទ្រង់ពោលនូវធម៌ជាលោកិយៈក្តី ជាលោកុត្តរៈក្តី ដោយវោហារជាលោកុត្តរៈ យ៉ាងនេះឯង ។

[២៤២] គំនរស្រូវក្តី គំនរមាសក្តី បុគ្គលអាចដើម្បីប្រាប់ថា ជាកូនឆ្នោត មានសណ្ឋានដូចដើមល្ហុងខ្វៃឬ ។ អើ ។ ព្រះមានព្រះភាគ ទ្រង់ពោល នូវធម៌ជាលោកិយៈក្តី ជាលោកុត្តរៈក្តី ដោយវោហារជាលោកិយៈ យ៉ាងនេះឯង ។

[២៤៣] វោហារ ដែលព្រះពុទ្ធមានព្រះភាគ កាលពោលថា ជាលោកិយៈ ក៏ជាលោកិយៈមែន កាលពោលថា ជាលោកុត្តរៈ ក៏ជាលោកុត្តរៈមែនឬ ។ អើ ។ កាលព្រះពុទ្ធមានព្រះភាគ ពោលជាលោកិយៈ វោហារនោះ ប៉ះទង្គិចត្រចៀកជាលោកិយៈ កាលពោលជាលោកុត្តរៈ ប៉ះទង្គិចត្រចៀកជាលោកុត្តរៈ កាលពោលជាលោកិយៈ ពួកសាវ័ក រមែងដឹងច្បាស់ ដោយវិញ្ញាណជាលោកិយៈ កាលពោលជាលោកុត្តរៈ ពួកសាវ័ក រមែងដឹងច្បាស់ ដោយវិញ្ញាណជាលោកុត្តរៈ

លោកិយំ វោហារន្តស្ស បុថុជ្ជនា បដិវិជានន្តិ លោ-
កុត្តរំ វោហារន្តស្ស សាវកា បដិវិជានន្តីតិ ។ ន
ហេវំ វត្តព្វេ ។ បេ ។

[២៤៤] ន វត្តព្វំ ពុទ្ធស្ស ភគវតោ វោហារោ
លោកិយំ វោហារន្តស្ស លោកិយោ ហោតិ លោ-
កុត្តរំ វោហារន្តស្ស លោកុត្តរោ ហោតីតិ ។ អា-
មន្តា ។ ននុ ភគវា លោកិយម្បិ លោកុត្តរម្បិ ធម្មំ
វោហរតីតិ ។ អាមន្តា ។ ហញ្ចិ ភគវា លោកិ-
យម្បិ លោកុត្តរម្បិ ធម្មំ វោហរតិ តេន វត រេ វត្តព្វេ
ពុទ្ធស្ស ភគវតោ វោហារោ លោកិយំ វោហារន្តស្ស
លោកិយោ ហោតិ លោកុត្តរំ វោហារន្តស្ស លោ-
កុត្តរោ ហោតីតិ ។

[២៤៥] ពុទ្ធស្ស ភគវតោ វោហារោ លោកិ-
យំ វោហារន្តស្ស លោកិយោ ហោតិ លោកុត្តរំ វោ-
ហារន្តស្ស លោកុត្តរោ ហោតីតិ ។ អាមន្តា ។ មគ្គំ
វោហារន្តស្ស មគ្គោ ហោតិ អមគ្គំ វោហារន្តស្ស អ-
មគ្គោ ហោតិ ផលំ វោហារន្តស្ស ផលំ ហោតិ

កាលពោលជាលោកិយៈ ពួកបុថុជ្ជន រមែងដឹងច្បាស់ កាលពោលជាលោកុត្តរៈ ពួកសាវ័ក រមែងដឹងច្បាស់ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[២៤៤] បុគ្គលមិនគួរនិយាយថា វោហារ ដែលព្រះពុទ្ធមានព្រះភាគ កាលពោលជាលោកិយៈ ក៏ជាលោកិយៈមែន កាលពោលជាលោកុត្តរៈ ក៏ជាលោកុត្តរៈមែនឬ ។ អើ ។ ក្រែងព្រះមានព្រះភាគ ទ្រង់ពោល នូវធម៌ជាលោកិយៈផង ជាលោកុត្តរៈផងឬ ។ អើ ។ បើព្រះមានព្រះភាគ ទ្រង់ពោល នូវធម៌ជាលោកិយៈផង ជាលោកុត្តរៈផង ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគួរពោលថា វោហារ កាលព្រះពុទ្ធមានព្រះភាគ ពោលជាលោកិយៈ ក៏ជាលោកិយៈមែន កាលពោលជាលោកុត្តរៈ ក៏ជាលោកុត្តរៈមែន ។

[២៤៥] វោហារ កាលព្រះពុទ្ធមានព្រះភាគ ពោលជាលោកិយៈ ក៏ជាលោកិយៈមែន កាលពោលជាលោកុត្តរៈ ក៏ជាលោកុត្តរៈមែនឬ ។ អើ ។ ព្រះមានព្រះភាគ កាលពោលថាមគ្គ ក៏ជាមគ្គមែន កាលពោលថាមិនមែនមគ្គ ក៏មិនមែនមគ្គមែន កាលពោលថាផល ក៏ជាផលមែន

អផលំ វោហារន្តស្ស អផលំ ហោតិ និព្វានំ វោហារន្តស្ស និព្វានំ ហោតិ អនិព្វានំ វោហារន្តស្ស អនិព្វានំ ហោតិ សង្ខតំ វោហារន្តស្ស សង្ខតំ ហោតិ អសង្ខតំ វោហា-រន្តស្ស អសង្ខតំ ហោតិ រូបំ វោហារន្តស្ស រូបំ ហោ-តិ អរូបំ វោហារន្តស្ស អរូបំ ហោតិ វេទនំ វោហារន្ត-ស្ស វេទនា ហោតិ អវេទនំ វោហារន្តស្ស អវេទនា ហោតិ សញ្ញំ វោហារន្តស្ស សញ្ញា ហោតិ អសញ្ញំ វោហារន្តស្ស អសញ្ញា ហោតិ សង្ខារេ វោហារន្តស្ស សង្ខារា ហោន្តិ អសង្ខារេ វោហារន្តស្ស អសង្ខារា ហោន្តិ វិញ្ញាណំ វោហារន្តស្ស វិញ្ញាណំ ហោតិ អ-វិញ្ញាណំ វោហារន្តស្ស អវិញ្ញាណំ ហោតីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

វោហារកថា ។

# និរោធកថា

[២៤៦] ទ្វេ និរោធាតិ ។ អាមន្តា ។ ទ្វេ ទុក្ខ-និរោធាតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ ទ្វេ ទុក្ខ-និរោធាតិ ។ អាមន្តា ។ ទ្វេ និរោធសច្ចានីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ ទ្វេ និរោធសច្ចានីតិ ។

*កាលពោលថាមិនមែនផល ក៏មិនមែនផលមែន កាលពោលថានិព្វាន ក៏ជានិព្វានមែន កាលពោលថាមិនមែននិព្វាន ក៏មិនមែននិព្វានមែន កាលពោលថាសង្ខតធម៌ ក៏ជាសង្ខតធម៌មែន កាលពោលថាអសង្ខតធម៌ ក៏ជាអសង្ខធម៌មែន កាលពោលថារូប ក៏ជារូបមែន កាលពោលថាមិនមែនរូប ក៏មិនមែនរូបមែន កាលពោលថាវេទនា ក៏ជាវេទនាមែន កាលពោលថាមិនមែនវេទនា ក៏មិនមែនវេទនាមែន កាលពោលថាសញ្ញា ក៏ជាសញ្ញាមែន កាលពោលថាមិនមែនសញ្ញា ក៏មិនមែនសញ្ញាមែន កាលពោលថាពួកសង្ខារ ក៏ជាពួកសង្ខារមែន កាលពោលថាមិនមែនពួកសង្ខារ ក៏មិនមែនពួកសង្ខារមែន កាលពោលថាវិញ្ញាណ ក៏ជាវិញ្ញាណមែន កាលពោលថាមិនមែនវិញ្ញាណ ក៏មិនមែនវិញ្ញាណមែនឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។*

ចប់ វោហារកថា ។

# និរោធកថា

[២៨៦] *និរោធ មានពីរឬ ។ អើ ។ ទុក្ខនិរោធ មានពីរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ ទុក្ខនិរោធ មានពីរឬ ។ អើ ។ និរោធសច្ច មានពីរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ និរោធសច្ច មានពីរឬ ។*

អាមន្តា ។ ទ្វេ ទុក្ខសច្ចានីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ ទ្វេ និរោធសច្ចានីតិ ។ អាមន្តា ។ ទ្វេ សមុទយ-សច្ចានីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ ទ្វេ និរោធ-សច្ចានីតិ ។ អាមន្តា ។ ទ្វេ មគ្គសច្ចានីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ ទ្វេ និរោធសច្ចានីតិ ។ អាមន្តា ។ ទ្វេ តាណានិ ។ បេ ។ ទ្វេ លេណានិ ទ្វេ សរណា-និ ទ្វេ បរាយណានិ ទ្វេ អច្ចុតានិ ទ្វេ អមតានិ ។ បេ ។ ទ្វេ និព្វានានីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ ទ្វេ និព្វានា-នីតិ ។ អាមន្តា ។ អត្ថិ ទ្វិន្នំ និព្វានានំ ឧច្ចនីចតា ហីនប្បណីតតា ឧក្កំសាវកំសោ សីមា វា ភេទោ វា រាជី វា អន្តរិកា វាតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[២៤៧] ទ្វេ និរោធាតិ ។ អាមន្តា ។ ននុ អប្ប-ដិសង្ខានិរុទ្ធេ សង្ខារេ បដិសង្ខា និរោធេន្តីតិ ។ អា-មន្តា ។ ហញ្ចិ អប្បដិសង្ខានិរុទ្ធេ សង្ខារេ បដិសង្ខា និរោធេន្តិ តេន វត រេ វត្តព្វេ ទ្វេ និរោធាតិ ។

[២៤៨] ន វត្តព្វំ ទ្វេ និរោធាតិ ។ អាមន្តា ។ ននុ អប្បដិសង្ខានិរុទ្ធា សង្ខារា

អើ ។ ទុក្ខសច្ច មានពីរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ និរោធសច្ច មានពីរឬ ។ អើ ។ សមុទយសច្ច មានពីរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ និរោធសច្ច មានពីរឬ ។ អើ ។ មគ្គសច្ច មានពីរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ និរោធសច្ច មានពីរឬ ។ អើ ។ ការទីពឹង មានពីរ ។ បេ ។ ការជ្រកកោន មានពីរ ការរលឹក មានពីរ ការប្រព្រឹត្តទៅក្នុងខាងមុខ មានពីរ ការមិនច្យុត មានពីរ ការមិនស្លាប់ មានពីរ ។ បេ ។ និព្វាន មានពីរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ និព្វាន មានពីរឬ ។ អើ ។ ភាពខ្ពស់និងទាប ភាពថោកទាបនិងឧត្តមឧក្រិដ្ឋនិងឱនថយ ដែន ឬ ការបែកធ្លាយ ការប្រេះធា ឬ ចន្លោះ របស់និព្វានទាំងពីរ មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[២៤៧] និរោធ មានពីរឬ ។ អើ ។ ក្រែងថាកាលបើសង្ខាររលត់ ព្រោះមិនបានពិចារណា បញ្ញាជាគ្រឿងពិចារណាទាំងឡាយ រលត់ដែរឬ ។ អើ ។ បើសង្ខារ រលត់ព្រោះមិនបានពិចារណា បញ្ញាជាគ្រឿងពិចារណាទាំងឡាយ ក៏រលត់ទៅ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា និរោធ មានពីរទេ ។

[២៤៨] បុគ្គលមិនគួរនិយាយថា និរោធ មានពីរឬ ។ អើ ។ ក្រែងសង្ខារទាំងឡាយ រលត់ទៅព្រោះមិនបានពិចារណា

អច្ចន្តភគ្គា បដិសង្ខានិរុទ្ធាបិ សង្ខារា អច្ចន្តភគ្គាតិ ។ អាមន្តា ។ ហញ្ចិ អប្បដិសង្ខានិរុទ្ធាបិ សង្ខារា អច្ចន្ត-ភគ្គា បដិសង្ខានិរុទ្ធាបិ សង្ខារា អច្ចន្តភគ្គា តេន វត រេ វត្តព្វេ ទ្វេ និរោធាតិ ។

[២៤៩] ទ្វេ និរោធាតិ ។ អាមន្តា ។ បដិសង្ខា-និរុទ្ធាបិ សង្ខារា អរិយមគ្គំ អាគម្ម និរុទ្ធាតិ ។ អា-មន្តា ។ អប្បដិសង្ខានិរុទ្ធា សង្ខារា អរិយមគ្គំ អាគម្ម និរុទ្ធាតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[២៥០] ទ្វេ និរោធាតិ ។ អាមន្តា ។ បដិសង្ខា-និរុទ្ធា សង្ខារា ន បុន ឧប្បជ្ជន្តីតិ ។ អាមន្តា ។ អប្បដិសង្ខានិរុទ្ធា សង្ខារា ន បុន ឧប្បជ្ជន្តីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ តេន ហិ ន វត្តព្វំ ទ្វេ និរោ-ធាតិ ។

និរោធកថា ។

ទុតិយោ វគ្គោ ។

មានការបាក់បែកក្នុងទីបំផុត ចុះសង្ខារទាំងឡាយ រលត់ទៅព្រោះបានពិចា-រណា មានការបាក់បែកក្នុងទីបំផុតដែរឬ ។ អើ ។ បើ សង្ខារទាំងឡាយ រលត់ទៅព្រោះមិនបានពិចារណាក្តី មានការបាក់បែកក្នុងទីបំផុត សង្ខារទាំងឡាយ រលត់ទៅព្រោះបានពិចារណាក្តី មានការបាក់បែកក្នុងទីបំផុត (ដូចគ្នា) ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគួរពោលថា និរោធ មានពីរ ។

[២៤៩] និរោធ មានពីរឬ ។ អើ ។ សង្ខារទាំងឡាយ រលត់ទៅព្រោះបានពិចារណា រលត់ទៅ ព្រោះអាស្រ័យអរិយមគ្គឬ ។ អើ ។ សង្ខារទាំងឡាយ រលត់ទៅព្រោះមិនបានពិចារណា រលត់ទៅ ព្រោះអាស្រ័យអរិយមគ្គឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[២៥០] និរោធ មានពីរឬ ។ អើ ។ សង្ខារទាំងឡាយ រលត់ទៅព្រោះបានពិចារណា រមែងមិនកើតទៀតទេឬ ។ អើ ។ សង្ខារទាំងឡាយ រលត់ទៅព្រោះមិនបានពិចារណា រមែងមិនកើតទៀតទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ ព្រោះហេតុនោះ បុគ្គលមិនគួរនិយាយថា និរោធ មានពីរទេ ។

ចប់ និរោធកថា ។

ចប់ ទុតិយវគ្គ ។

១០៣

ពលកថា

## តស្ស ឧទ្ទានំ

បរូបហារោ អញ្ញាណំ   កង្ខា បរវិតារណា
វចីភេទោ ទុក្ខាហារោ   ឋិតិ កុក្កុឡា សង្ខារា[១]
ឯកោ អភិសមយោ ឯកោ
វោហារោ ឯកោ និរោធោតិ[២] ។

---

# ពលកថា

[២៨១] តថាគតពលំ សាវកសាធារណន្តិ ។ អាមន្តា ។ តថាគតពលំ សាវកពលំ សាវកពលំ តថាគតពលន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[២៨២] តថាគតពលំ សាវកសាធារណន្តិ ។ អាមន្តា ។ តញ្ញេវ តថាគតពលំ តំ សាវកពលំ តញ្ញេវ សាវកពលំ តំ តថាគតពលន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[២៨៣] តថាគតពលំ សាវកសាធារណន្តិ ។

---

១ ឥមស្មឹ ទុតិយវគ្គេ សង្ខារកថាតិ បាឋោ ន ហោតិ ។

២ ម. បរូបហារោ អញ្ញាណំ   កង្ខា បរវិតារណា
សង្ខាហារកថា មគ្គោ   ចិត្តដ្ឋិតិ ច កុក្កុឡា
ឯកាភិសមយោ ចេវ   វោហារោ ច និរោធកោតិ ទិស្សតិយេវ ។

# ឧទ្ទាននៃទុតិយវគ្គនោះ គឺ

*បរូបហារកថា ១ អញ្ញាណកថា ១ កង្ខាកថា ១ បរវិតារណាកថា ១ វចីភេទកថា ១ ទុក្ខាហារកថា ១ ចិត្តដ្ឋិតិកថា ១ កុក្កុឡកថា ១ សង្ខារកថា ១ អនុបុព្វាភិសមយកថា ១ វោហារកថា ១ និរោធកថា ១ ។*

---

# ពលកថា

[២៥១] *កម្លាំងរបស់ព្រះតថាគត ជាសាធារណៈដល់សាវ័កឬ ។ អើ ។ កម្លាំងរបស់ព្រះតថាគត ជាកម្លាំងរបស់សាវ័ក កម្លាំងរបស់សាវ័ក ជាកម្លាំងរបស់ព្រះតថាគតឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។*

[២៥២] *កម្លាំងរបស់ព្រះតថាគត ជាសាធារណៈដល់សាវ័កឬ ។ អើ ។ កម្លាំងរបស់ព្រះតថាគតនោះឯង ជាកម្លាំងរបស់សាវ័កនោះ កម្លាំងរបស់សាវ័កនោះឯង ជាកម្លាំងរបស់ព្រះតថាគតនោះឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។*

[២៥៣] *កម្លាំងរបស់ព្រះតថាគត ជាសាធារណៈដល់សាវ័កឬ ។*

អាមន្តា ។ យាទិសំ តថាគតពលំ តាទិសំ សាវកពលំ យាទិសំ សាវកពលំ តាទិសំ តថាគតពលន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[២៥៤] តថាគតពលំ សាវកសាធារណន្តិ ។ អាមន្តា ។ យាទិសោ តថាគតស្ស បុព្វយោគោ បុព្វចរិយា ធម្មក្ខានំ ធម្មទេសនា តាទិសោ សាវកស្ស បុព្វយោគោ បុព្វចរិយា ធម្មក្ខានំ ធម្មទេសនាតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[២៥៥] តថាគតពលំ សាវកសាធារណន្តិ ។ អាមន្តា ។ តថាគតោ ជិនោ សត្ថា សម្មាសម្ពុទ្ធោ សព្វញ្ញូ សព្វទស្សាវី ធម្មស្សាមី ធម្មប្បដិសរណោតិ ។ អាមន្តា ។ សាវកោ ជិនោ សត្ថា សម្មាសម្ពុទ្ធោ សព្វញ្ញូ សព្វទស្សាវី ធម្មស្សាមី ធម្មប្បដិសរណោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[២៥៦] តថាគតពលំ សាវកសាធារណន្តិ ។ អាមន្តា ។ តថាគតោ អនុប្បន្នស្ស មគ្គស្ស ឧប្បាទេតា អសញ្ជាតស្ស មគ្គស្ស សញ្ជនេតា[១]

---

១ ម. សញ្ជានេតា ។

អើ ។ កម្លាំងរបស់ព្រះតថាគត ដូចម្តេច កម្លាំងរបស់សាវ័ក ក៏ដូច្នោះ កម្លាំងរបស់សាវ័ក ដូចម្តេច កម្លាំងរបស់ព្រះតថាគត ក៏ដូច្នោះដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[២៥៤] កម្លាំងរបស់ព្រះតថាគត ជាសាធារណៈដល់សាវ័កដែរឬ ។ អើ ។ សេចក្តីព្យាយាមខាងដើម ការប្រព្រឹត្តខាងដើម ការពោលធម៌ កាលសម្តែងធម៌ របស់ព្រះតថាគត ដូចម្តេច សេចក្តីព្យាយាមខាងដើម ការប្រព្រឹត្តខាងដើម ការពោលធម៌ ការសម្តែងធម៌ របស់សាវ័ក ក៏ដូច្នោះដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[២៥៥] កម្លាំងរបស់ព្រះតថាគត ជាសាធារណៈដល់សាវ័កដែរឬ ។ អើ ។ ព្រះតថាគត ជាអ្នកឈ្នះ ជាគ្រូ ជាអ្នកត្រាស់ដឹងឯង ដឹងសព្វ ឃើញសព្វ ជាម្ចាស់ធម៌ មានធម៌ជាទីពឹងដែរឬ ។ អើ ។ សាវ័កជាអ្នកឈ្នះ ជាគ្រូ ជាអ្នកត្រាស់ដឹងឯង ដឹងសព្វ ឃើញសព្វ ជាម្ចាស់ធម៌ មានធម៌ជាទីពឹងដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[២៥៦] កម្លាំងរបស់ព្រះតថាគត ជាសាធារណៈដល់សាវ័កដែរឬ ។ អើ ។ ព្រះតថាគត ជាអ្នកញុំាងមគ្គដែលមិនទាន់កើតឲ្យកើតឡើង ជាអ្នកញុំាងមគ្គដែលមិនទាន់កើតព្រមឲ្យកើតព្រម ជាអ្នក

អនញ្ញាតស្ស មគ្គស្ស អញ្ញាតា មគ្គញ្ញូ មគ្គវិទូ មគ្គកោវិទោតិ ។ អាមន្តា ។ សាវកោ អនុប្បន្នស្ស មគ្គស្ស ឧប្បាទេតា អសញ្ជាតស្ស មគ្គស្ស សញ្ជ-នេតា អនញ្ញាតស្ស មគ្គស្ស អញ្ញាតា មគ្គញ្ញូ មគ្គវិទូ មគ្គកោវិទោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[២៥៧] ឥន្ទ្រិយបរោបរិយត្តំ យថាភូតំ ញាណំ តថាគតពលំ សាវកសាធារណន្តិ ។ អាមន្តា ។ សាវ-កោ សព្វញ្ញូ សព្វទស្សាវីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[២៥៨] សាវកោ ឋានាឋានំ ជានាតីតិ ។ អា-មន្តា ។ ហញ្ចិ សាវកោ ឋានាឋានំ ជានាតិ តេន វត រេ វត្តព្វេ ឋានាឋានំ យថាភូតំ ញាណំ តថាគ-តពលំ សាវកសាធារណន្តិ ។

[២៥៩] សាវកោ អតីតានាគតប្បច្ចុប្បន្នានំ កម្ម-សមាទានានំ ឋានសោ ហេតុសោ វិបាកំ ជានាតីតិ ។ អាមន្តា ។ ហញ្ចិ សាវកោ អតីតានាគតប្បច្ចុប្បន្នានំ កម្មសមាទានានំ ឋានសោ ហេតុសោ វិបាកំ ជានាតិ

ពោលនូវមគ្គដែលមិនទាន់ពោល ជាអ្នកជ្រាបនូវមគ្គ ដឹងច្បាស់នូវមគ្គ ឈ្លាសវៃក្នុងមគ្គដែរឬ ។ អើ ។ សាវ័ក ជាអ្នកញុំាងមគ្គដែលមិនទាន់កើតឲ្យកើតឡើង ជាអ្នកញុំាងមគ្គដែលមិនទាន់កើតព្រមឲ្យកើតព្រម ជាអ្នកពោលនូវមគ្គដែលមិនទាន់ពោល ជាអ្នកជ្រាបនូវមគ្គ ដឹងច្បាស់នូវមគ្គ ឈ្លាសវៃក្នុងមគ្គដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។

[២៥៧] កម្លាំងរបស់ព្រះតថាគត គឺការជ្រាបតាមពិត នូវឥន្ទ្រិយទន់និងចាស់ក្លា (នៃសត្វ) ជាសាធារណៈដល់សាវ័កដែរឬ ។ អើ ។ សាវ័ក ជាអ្នកដឹងសព្វ ឃើញសព្វដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[២៥៨] សាវ័ក ជ្រាបហេតុនិងមិនមែនហេតុដែរឬ ។ អើ ។ ប្រសិនបើ សាវ័ក ជ្រាបហេតុនិងមិនមែនហេតុដែរ ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគួរពោលថា កម្លាំងរបស់ព្រះតថាគត គឺការជ្រាបតាមពិត នូវហេតុនិងមិនមែនហេតុ ជាសាធារណៈដល់សាវ័កដែរ ។

[២៥៩] សាវ័ក ជ្រាបនូវផលរបស់កម្មសមាទានទាំងឡាយ ជាអតីតអនាគតនិងបច្ចុប្បន្ន ដោយឋានៈ ដោយហេតុដែរឬ ។ អើ ។ ប្រសិនបើ សាវ័ក ជ្រាបនូវផលរបស់កម្មសមាទានទាំងឡាយ ជាអតីតអនាគតនិងបច្ចុប្បន្ន ដោយឋានៈ ដោយហេតុដែរ ម្នាលអ្នកដ៏ចម្រើន

តេន វត រេ វត្តព្វេ អតីតានាគតប្បច្ចុប្បន្នានំ កម្ម-
សមាធានានំ ឋានសោ ហេតុសោ វិបាកំ យថាភូតំ
ញាណំ តថាគតពលំ សាវកសាធារណន្តិ ។

[២៦០] សាវកោ សព្វត្ថគាមិនីបដិបទំ ជានាតី-
តិ ។ អាមន្តា ។ ហញ្ចិ សាវកោ សព្វត្ថគាមិនីបដិ-
បទំ ជានាតិ តេន វត រេ វត្តព្វេ សព្វត្ថគាមិនីបដិ-
បទំ យថាភូតំ ញាណំ តថាគតពលំ សាវកសាធា-
រណន្តិ ។

[៦១] សាវកោ អនេកធាតុំ នានាធាតុំ
លោកំ ជានាតីតិ ។ អាមន្តា ។ ហញ្ចិ សាវកោ
អនេកធាតុំ នានាធាតុំ លោកំ ជានាតិ តេន វត
រេ វត្តព្វេ អនេកធាតុំ នានាធាតុំ លោកំ យថាភូតំ
ញាណំ តថាគតពលំ សាវកសាធារណន្តិ ។

[២៦២] សាវកោ សត្តានំ នានាធិមុត្តិកតំ
ជានាតីតិ ។ អាមន្តា ។ ហញ្ចិ សាវកោ សត្តានំ
នានាធិមុត្តិកតំ ជានាតិ តេន វត រេ វត្តព្វេ សត្តា-
នំ នានាធិមុត្តិកតំ យថាភូតំ ញាណំ តថាគតពលំ
សាវកសាធារណន្តិ ។

ព្រោះហេតុនោះ អ្នកគួរពោលថា កម្លាំងរបស់ព្រះតថាគត គឺការជ្រាបតាមពិត នូវផលរបស់កម្មសមាទានទាំងឡាយ ជាអតីតអនាគតនិងបច្ចុប្បន្ន ដោយឋានៈ ដោយហេតុ ជាសាធារណៈដល់សាវ័កដែរ ។

[២៦០] សាវ័ក ជ្រាបនូវបដិបទាជាដំណើរទៅរកប្រយោជន៍ទាំងអស់ដែរឬ ។ អើ ។ ប្រសិនបើ សាវ័ក ជ្រាបនូវបដិបទាជាដំណើរទៅរកប្រយោជន៍ទាំងអស់ដែរ ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគួរពោលថា កម្លាំងរបស់ព្រះតថាគត គឺការជ្រាបតាមពិត នូវបដិបទាជាដំណើរទៅរកប្រយោជន៍ទាំងអស់ ជាសាធារណៈដល់សាវ័កដែរ ។

[២៦១] សាវ័ក ជ្រាបនូវលោក ដែលមានធាតុច្រើន មានធាតុផ្សេងៗ ដែរឬ ។ អើ ។ ប្រសិនបើ សាវ័ក ជ្រាបនូវលោក ដែលមានធាតុច្រើន មានធាតុផ្សេងៗដែរ ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគួរពោលថា កម្លាំងរបស់ព្រះតថាគត គឺការជ្រាបតាមពិត នូវលោក ដែលមានធាតុច្រើន មានធាតុផ្សេងៗ ជាសាធារណៈដល់សាវ័កដែរ ។

[២៦២] សាវ័ក ជ្រាបនូវអធ្យាស្រ័យផ្សេងៗគ្នា របស់ពួកសត្វដែរឬ ។ អើ ។ ប្រសិនបើ សាវ័ក ជ្រាបនូវអធ្យាស្រ័យផ្សេងៗគ្នា របស់ពួកសត្វដែរ ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគួរពោលថា កម្លាំងរបស់ព្រះតថាគត គឺការជ្រាបតាមពិត នូវអធ្យាស្រ័យផ្សេងៗគ្នា របស់ពួកសត្វ ជាសាធារណៈដល់សាវ័កដែរ ។

[២៦៣] សាវកោ ឈានវិមោក្ខសមាធិសមាបត្តីនំ សង្កិលេសំ វោទានំ វុដ្ឋានំ ជានាតីតិ ។ អាមន្តា ។ ហញ្ចិ សាវកោ ឈានវិមោក្ខសមាធិសមាបត្តីនំ សង្កិលេសំ វោទានំ វុដ្ឋានំ ជានាតិ តេន វត រេ វត្តព្វេ ឈានវិមោក្ខសមាធិសមាបត្តីនំ សង្កិលេសំ វោទានំ វុដ្ឋានំ យថាភូតំ ញាណំ តថាគតពលំ សាវកសាធារណន្តិ ។

[២៦៤] សាវកោ បុព្វេនិវាសានុស្សតឹ ជានាតីតិ ។ អាមន្តា ។ ហញ្ចិ សាវកោ បុព្វេនិវាសានុស្សតឹ ជានាតិ តេន វត រេ វត្តព្វេ បុព្វេនិវាសានុស្សតឹ យថាភូតំ ញាណំ តថាគតពលំ សាវកសាធារណន្តិ ។

[២៦៥] សាវកោ សត្តានំ ចុតូបបាតំ ជានាតីតិ ។ អាមន្តា ។ ហញ្ចិ សាវកោ សត្តានំ ចុតូបបាតំ ជានាតិ តេន វត រេ វត្តព្វេ សត្តានំ ចុតូបបាតំ យថាភូតំ ញាណំ តថាគតពលំ សាវកសាធារណន្តិ ។

ពលកថា

[២៦៣] សាវ័ក ជ្រាប នូវការសៅហ្មង ការផូរផង់ និងការចេញ នៃឈាន វិមោក្ខ សមាធិ និងសមាបត្តិដែរឬ ។ អើ ។ ប្រសិនបើ សាវ័ក ជ្រាប នូវការសៅហ្មង ការផូរផង់ និងការចេញ នៃឈាន វិមោក្ខ សមាធិ និងសមាបត្តិដែរ ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគួរពោលថា កម្លាំងរបស់ព្រះតថាគត គឺការជ្រាបតាមពិត នូវការសៅហ្មង ការផូរផង់ និងការចេញ នៃឈាន វិមោក្ខ សមាធិ និងសមាបត្តិ ជាសាធារណៈដល់សាវ័កដែរ ។

[២៦៤] សាវ័ក ជ្រាប នូវការរឭកឃើញជាតិដែលធ្លាប់អាស្រ័យក្នុងកាលមុនដែរឬ ។ អើ ។ ប្រសិនបើ សាវ័ក ជ្រាប នូវការរឭកឃើញជាតិដែលធ្លាប់អាស្រ័យក្នុងកាលមុនដែរ ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគួរពោលថា កម្លាំងរបស់ព្រះតថាគត គឺការជ្រាបតាមពិត នូវការរឭកឃើញជាតិដែលធ្លាប់អាស្រ័យក្នុងកាលមុន ជាសាធារណៈដល់សាវ័កដែរ ។

[២៦៥] សាវ័ក ជ្រាប នូវចុតិនិងបដិសន្ធិ របស់ពួកសត្វដែរឬ ។ អើ ។ ប្រសិនបើ សាវ័ក ជ្រាប នូវចុតិនិងបដិសន្ធិ របស់ពួកសត្វដែរ ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគួរពោលថា កម្លាំងរបស់ព្រះតថាគត គឺការជ្រាបតាមពិត នូវចុតិនិងបដិសន្ធិ របស់ពួកសត្វ ជាសាធារណៈដល់សាវ័កដែរ ។

[២៦៦] ននុ តថាគតស្សាបិ អាសវា ខីណា សាវកស្សាបិ អាសវា ខីណាតិ ។ អាមន្តា ។ អត្ថិ កិញ្ចិ នានាករណំ តថាគតស្ស វា សាវកស្ស វា អាសវក្ខយេន វា អាសវក្ខយំ វិមុត្តិយា វា វិមុត្តីតិ ។ នត្ថិ ។ ហញ្ចិ នត្ថិ កិញ្ចិ នានាករណំ តថាគតស្ស វា សាវកស្ស វា អាសវក្ខយេន វា អាសវក្ខយំ វិមុត្តិយា វិមុត្តិ តេន វត រេ វត្តព្វេ អាសវានំ ខយេ យថាភូតំ ញាណំ តថាគតពលំ សាវកសាធារណន្តិ ។

[២៦៧] អាសវានំ ខយេ យថាភូតំ ញាណំ តថាគតពលំ សាវកសាធារណន្តិ ។ អាមន្តា ។ ឋានាឋានេ យថាភូតំ ញាណំ តថាគតពលំ សាវកសាធារណន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[២៦៨] អាសវានំ ខយេ យថាភូតំ ញាណំ តថាគតពលំ សាវកសាធារណន្តិ ។ អាមន្តា ។ សត្តានំ ចុតូបបាតេ យថាភូតំ ញាណំ តថាគតពលំ

[២៦៦] ក្រែងអាសវៈទាំងឡាយ របស់ព្រះតថាគតអស់ហើយ អាសវៈទាំងឡាយ របស់សាវ័ក អស់ហើយដែរឬ ។ អើ ។ ការអស់អាសវៈ ដោយការអស់អាសវៈក្តី ការផុតស្រឡះ ដោយការផុតស្រឡះក្តី របស់ព្រះតថាគតក្តី របស់សាវ័កក្តី ធ្វើឲ្យផ្សេងៗគ្នាបន្តិចបន្តួច មានដែរឬ ។ មិនមានទេ ។ ប្រសិនបើ ការអស់អាសវៈ ដោយការអស់អាសវៈក្តី ការផុតស្រឡះ ដោយការផុតស្រឡះក្តី របស់ព្រះតថាគតក្តី របស់សាវ័កក្តី ធ្វើឲ្យផ្សេងៗគ្នាបន្តិចបន្តួច មិនមានទេ ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគួរពោលថា កម្លាំងរបស់ព្រះតថាគត គឺការជ្រាបតាមពិត ក្នុងការអស់ទៅ នៃអាសវៈទាំងឡាយ ជាសាធារណៈដល់សាវ័កដែរ ។

[២៦៧] កម្លាំងរបស់ព្រះតថាគត គឺការជ្រាបតាមពិត ក្នុងការអស់ទៅ នៃអាសវៈទាំងឡាយ ជាសាធារណៈដល់សាវ័កដែរឬ ។ អើ ។ កម្លាំងរបស់ព្រះតថាគត គឺការជ្រាបតាមពិត ក្នុងហេតុនិងមិនមែនហេតុ ជាសាធារណៈដល់សាវ័កដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[២៦៨] កម្លាំងរបស់ព្រះតថាគត គឺការជ្រាបតាមពិត ក្នុងការអស់ទៅ នៃអាសវៈទាំងឡាយ ជាសាធារណៈដល់សាវ័កដែរឬ ។ អើ ។ កម្លាំងរបស់ព្រះតថាគត គឺការជ្រាបតាមពិត ក្នុងចុតិនិងបដិសន្ធិ របស់

សាវកសាធារណន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[២៦៩] ឋានាឋានេ យថាភូតំ ញាណំ តថាគតពលំ សាវកអសាធារណន្តិ ។ អាមន្តា ។ អាសវានំ ខយេ យថាភូតំ ញាណំ តថាគតពលំ សាវកអសាធារណន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[២៧០] សត្តានំ ចុតូបបាតេ យថាភូតំ ញាណំ តថាគតពលំ សាវកអសាធារណន្តិ ។ អាមន្តា ។ អាសវានំ ខយេ យថាភូតំ ញាណំ តថាគតពលំ សាវកអសាធារណន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[២៧១] ឥន្ទ្រិយបរោបរិយត្តំ យថាភូតំ ញាណំ តថាគតពលំ សាវកអសាធារណន្តិ ។ អាមន្តា ។ ឋានាឋានេ យថាភូតំ ញាណំ តថាគតពលំ សាវកអសាធារណន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[២៧២] ឥន្ទ្រិយបរោបរិយត្តំ យថាភូតំ ញាណំ តថាគតពលំ សាវកអសាធារណន្តិ ។ អាមន្តា ។

ពួកសត្វ ជាសាធារណៈដល់សាវ័កដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[២៦៩] កម្លាំងរបស់ព្រះតថាគត គឺការជ្រាបតាមពិត ក្នុងហេតុនិងមិនមែនហេតុ មិនសាធារណៈដល់សាវ័កទេឬ ។ អើ ។ កម្លាំងរបស់ព្រះតថាគត គឺការជ្រាបតាមពិត ក្នុងការអស់ទៅ នៃអាសវៈទាំង-ឡាយ មិនសាធារណៈដល់សាវ័កទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[២៧០] កម្លាំងរបស់ព្រះតថាគត គឺការជ្រាបតាមពិត ក្នុងចុតិនិងបដិសន្ធិ របស់ពួកសត្វ មិនសាធារណៈដល់សាវ័កទេឬ ។ អើ ។ កម្លាំងរបស់ព្រះតថាគត គឺការជ្រាបតាមពិត ក្នុងការអស់ទៅ នៃអាសវៈទាំងឡាយ មិនសាធារណៈដល់សាវ័កទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[២៧១] កម្លាំងរបស់ព្រះតថាគត គឺការជ្រាបតាមពិត នូវឥន្ទ្រិយទន់និងចាស់ក្លា មិនសាធារណៈដល់សាវ័កទេឬ ។ អើ ។ កម្លាំងរបស់ព្រះតថាគត គឺការជ្រាបតាមពិត ក្នុងហេតុនិងមិនមែនហេតុ មិនសាធា-រណៈដល់សាវ័កទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[២៧២] កម្លាំងរបស់ព្រះតថាគត គឺការជ្រាបតាមពិត នូវឥន្ទ្រិយទន់និងចាស់ក្លា មិនសាធារណៈដល់សាវ័កទេឬ ។ អើ ។

អាសវានំ ខយេ យថាភូតំ ញាណំ តថាគតពលំ សាវកអសាធារណន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[២៧៣] ឋានាឋានេ យថាភូតំ ញាណំ តថាគតពលំ សាវកសាធារណន្តិ ។ អាមន្តា ។ ឥន្ទ្រិយបរោបរិយត្តំ យថាភូតំ ញាណំ តថាគតពលំ សាវកសាធារណន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[២៧៤] អាសវានំ ខយេ យថាភូតំ ញាណំ តថាគតពលំ សាវកសាធារណន្តិ ។ អាមន្តា ។ ឥន្ទ្រិយបរោបរិយត្តំ យថាភូតំ ញាណំ តថាគតពលំ សាវកសាធារណន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។

ពលកថា ។

# អរិយន្តិកថា

[២៧៥] ឋានាឋានេ យថាភូតំ ញាណំ តថាគតពលំ អរិយន្តិ ។ អាមន្តា ។ មគ្គោ ផលំ និព្វានំ សោតាបត្តិមគ្គោ សោតាបត្តិផលំ សកទាគាមិមគ្គោ សកទាគាមិផលំ អនាគាមិមគ្គោ អនាគាមិផលំ អរហត្តមគ្គោ អរហត្តផលំ សតិប្បដ្ឋានំ សម្មប្បធានំ ឥទ្ធិបាទោ ឥន្ទ្រិយំ ពលំ ពោជ្ឈង្គោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

កម្លាំងរបស់ព្រះតថាគត គឺការជ្រាបតាមពិត ក្នុងការអស់ទៅ នៃអាសវៈទាំងឡាយ មិនសាធារណៈដល់សាវ័កទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[២៧៣] កម្លាំងរបស់ព្រះតថាគត គឺការជ្រាបតាមពិត ក្នុងហេតុនិងមិនមែនហេតុ ជាសាធារណៈដល់សាវ័កដែរឬ ។ អើ ។ កម្លាំងរបស់ព្រះតថាគត គឺការជ្រាបតាមពិត នូវឥន្ទ្រិយទន់និងចាស់ក្លា ជាសាធារណៈដល់សាវ័កដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[២៧៤] កម្លាំងរបស់ព្រះតថាគត គឺការជ្រាបតាមពិត ក្នុងការអស់ទៅ នៃអាសវៈទាំងឡាយ ជាសាធារណៈដល់សាវ័កដែរឬ ។ អើ ។ កម្លាំងរបស់ព្រះតថាគត គឺការជ្រាបតាមពិត នូវឥន្ទ្រិយទន់និងចាស់ក្លា ជាសាធារណៈដល់សាវ័កដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

ចប់ ពលកថា ។

# អរិយន្តិកថា

[២៧៥] កម្លាំងរបស់ព្រះតថាគត គឺការជ្រាបតាមពិត ក្នុងហេតុនិងមិនមែនហេតុ ជាអរិយៈដែរឬ ។ អើ ។ មគ្គ ផល និព្វាន សោតាបត្តិមគ្គ សោតាបត្តិផល សកទាគាមិមគ្គ សកទាគាមិផល អនាគាមិមគ្គ អនាគាមិផល អរហត្តមគ្គ អរហត្តផល សតិប្បដ្ឋាន សម្មប្បធាន ឥទ្ធិបាទ ឥន្ទ្រិយ ពលៈ ពោជ្ឈង្គៈ (ជាអរិយៈ) ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

អរិយន្តិកថា

[២៧៦] ហាដាហានេ យថាភូតំ ញាណំ តថាគតពលំ អរិយន្តិ ។ អាមន្តា ។ សុញ្ញតារម្មណាន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។ សុញ្ញតារម្មណាន្តិ ។ អាមន្តា ។ ហាដាហានញ្ច មនសិកាកោតិ សុញ្ញតញ្ច មនសិកាកោតីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ ហាដាហានញ្ច មនសិកាកោតិ សុញ្ញតញ្ច មនសិកាកោតីតិ ។ អាមន្តា ។ ទ្វិន្នំ ផស្សានំ ទ្វិន្នំ ចិត្តានំ សមោធានំ ហោតីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ ហាដាហានេ យថាភូតំ ញាណំ តថាគតពលំ អរិយន្តិ ។ អាមន្តា ។ អនិមិត្តារម្មណំ ។ បេ ។ អប្បណិហិតារម្មណាន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។ អប្បណិហិតារម្មណាន្តិ ។ អាមន្តា ។ ហាដាហានញ្ច មនសិកាកោតិ អប្បណិហិតញ្ច មនសិកាកោតីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ ហាដាហានញ្ច មនសិ កាកោតិ អប្បណិហិតញ្ច មនសិកាកោតីតិ ។ អាមន្តា ។ ទ្វិន្នំ ផស្សានំ ទ្វិន្នំ ចិត្តានំ សមោធានំ ហោតីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

អរិយន្តិកថា

[២៧៦] កម្លាំងរបស់ព្រះតថាគត គឺការជ្រាបតាមពិត ក្នុងហេតុនិងមិនមែនហេតុ ជាអរិយៈឬ ។ អើ ។ ជាសុញ្ញតារម្មណ៍ (មានសុញ្ញតនិព្វានជាអារម្មណ៍) ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ ជាសុញ្ញតារម្មណ៍ឬ ។ អើ ។ បុគ្គល ធ្វើទុកក្នុងចិត្ត នូវហេតុនិងមិនមែនហេតុផង ធ្វើទុកក្នុងចិត្ត នូវសុញ្ញតៈ (និព្វាន) ផងឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ បុគ្គល ធ្វើទុកក្នុងចិត្ត នូវហេតុនិងមិនមែនហេតុផង ធ្វើទុកក្នុងចិត្ត នូវសុញ្ញតៈ (និព្វាន) ផងឬ ។ អើ ។ (បើដូច្នោះ) ការប្រជុំចុះ នៃផស្សៈទាំង ២ នៃចិត្តទាំង ២ មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ កម្លាំងរបស់ព្រះតថាគត គឺការជ្រាបតាមពិត ក្នុងហេតុនិងមិនមែនហេតុ ជាអរិយៈឬ ។ អើ ។ ជាអនិមិត្តារម្មណ៍ (មានអនិមិត្តនិព្វានជាអារម្មណ៍) ។ បេ ។ ជាអប្បណិហិតារម្មណ៍ (មានអប្បណិហិតនិព្វានជាអារម្មណ៍)ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ ជាអប្បណិហិតារម្មណ៍ឬ ។ អើ ។ (បើដូច្នោះ) បុគ្គល ធ្វើទុកក្នុងចិត្ត នូវហេតុនិងមិនមែនហេតុផង ធ្វើទុកក្នុងចិត្ត នូវអប្បណិហិតៈ(និព្វាន) ផងឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ បុគ្គល ធ្វើទុកក្នុងចិត្ត នូវហេតុនិងមិនមែនហេតុផង ធ្វើទុកក្នុងចិត្ត នូវអប្បណិហិតៈ (និព្វាន) ផងឬ ។ អើ ។ (បើដូច្នោះ) ការប្រជុំចុះ នៃផស្សៈទាំង ២ នៃចិត្តទាំង ២ មានឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[២៧៧] សតិប្បដ្ឋានា អរិយា សុញ្ញតារម្មណា-តិ ។ អាមន្តា ។ ហានាហានេ យថាភូតំ ញាណំ តថា-គតពលំ អរិយំ សុញ្ញតារម្មណន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។ សតិប្បដ្ឋានា អរិយា អនិមិត្តារម្មណា ។ បេ ។ អប្បណិហិតារម្មណាតិ ។ អាមន្តា ។ ហានាហានេ យ-ថាភូតំ ញាណំ តថាគតពលំ អរិយំ អប្បណិហិតា-រម្មណន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[២៧៨] សម្មប្បធានា ឥទ្ធិបាទា ឥន្ទ្រិយា ព-លា ពោជ្ឈង្គា អរិយា សុញ្ញតារម្មណាតិ ។ អាមន្តា ។ ហានាហានេ យថាភូតំ ញាណំ តថាគតពលំ អរិយំ សុញ្ញតារម្មណន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។ ពោជ្ឈ-ង្គា អរិយា អនិមិត្តារម្មណា ។ បេ ។ អប្បណិហិតា-រម្មណាតិ ។ អាមន្តា ។ ហានាហានេ យថាភូតំ ញា-ណំ តថាគតពលំ អរិយំ អប្បណិហិតារម្មណន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[២៧៩] ហានាហានេ យថាភូតំ ញាណំ តថា-គតពលំ អរិយំ ន វត្តព្វំ សុញ្ញតារម្មណន្តិ ។

[២៧៧] សតិប្បដ្ឋាន ជាអរិយៈ ជាសុញ្ញតារម្មណ៍ឬ ។ អើ ។ កម្លាំងរបស់ព្រះតថាគត គឺការជ្រាបតាមពិត ក្នុងហេតុនិងមិនមែនហេតុ ជាអរិយៈ ជាសុញ្ញតារម្មណ៍ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ សតិប្បដ្ឋាន ជាអរិយៈ ជាអនិមិត្តារម្មណ៍ ។ បេ ។ ជាអប្បណិហិតារម្មណ៍ឬ ។ អើ ។ កម្លាំងរបស់ព្រះតថាគត គឺការជ្រាបតាមពិត ក្នុងហេតុនិងមិនមែនហេតុ ជាអរិយៈ ជាអប្បណិហិតារម្មណ៍ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[២៧៨] សម្មប្បធាន ឥទ្ធិបាទ ឥន្ទ្រិយ ពលៈ ពោជ្ឈង្គៈ ជាអរិយៈ ជាសុញ្ញតារម្មណ៍ឬ ។ អើ ។ កម្លាំងរបស់ព្រះតថាគត គឺការជ្រាបតាមពិត ក្នុងហេតុនិងមិនមែនហេតុ ជាអរិយៈ ជាសុញ្ញតារម្មណ៍ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ ពោជ្ឈង្គៈ ជាអរិយៈ ជាអនិមិត្តារម្មណ៍ ។ បេ ។ ជាអប្បណិហិតារម្មណ៍ឬ ។ អើ ។ កម្លាំងរបស់ព្រះតថាគត គឺការជ្រាបតាមពិត ក្នុងហេតុនិងមិនមែនហេតុ ជាអរិយៈ ជាអប្បណិហិតារម្មណ៍ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[២៧៩] កម្លាំងរបស់ព្រះតថាគត គឺការជ្រាបតាមពិត ក្នុងហេតុនិងមិនមែនហេតុ ជាអរិយៈ មិនគួរនិយាយថា ជាសុញ្ញតារម្មណ៍ទេឬ ។

អាមន្តា ។ សតិប្បដ្ឋានា អរិយា ន វត្តព្វា សុញ្ញតា-
រម្មណាតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ ហញ្ចិ ហេ
យថាភូតំ ញាណំ តថាគតពលំ អរិយំ ន វត្តព្វំ អនិ-
មិត្តារម្មណំ ។ បេ ។ អប្បណិហិតារម្មណន្តិ ។ អា-
មន្តា ។ សតិប្បដ្ឋានា អរិយា ន វត្តព្វា អប្បណិហិ-
តារម្មណាតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ ហញ្ចិ ហេ
យថាភូតំ ញាណំ តថាគតពលំ អរិយំ ន វត្តព្វំ
សុញ្ញតារម្មណំ ។ បេ ។ អនិមិត្តារម្មណំ ។ បេ ។
អប្បណិហិតារម្មណន្តិ ។ អាមន្តា ។ សម្មប្បធានា
។ បេ ។ ពោជ្ឈង្គា អរិយា ន វត្តព្វា អប្បណិហិតារម្ម-
ណាតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[២៨០] សត្តានំ ចុតូបបាតេ យថាភូតំ ញាណំ
តថាគតពលំ អរិយន្តិ ។ អាមន្តា ។ មគ្គោ ផលំ
និព្វានំ សោតាបត្តិមគ្គោ សោតាបត្តិផលំ ។ បេ ។
ពោជ្ឈង្គាតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[២៨១] សត្តានំ ចុតូបបាតេ យថាភូតំ ញាណំ
តថាគតពលំ អរិយន្តិ ។ អាមន្តា ។ សុញ្ញតារម្ម-
ណន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។ សុញ្ញតារម្មណន្តិ ។

*អើ ។ សតិប្បដ្ឋាន ជាអរិយៈ មិនគួរនិយាយថា ជាសុញ្ញតារម្មណ៍ទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ កម្លាំងរបស់ព្រះតថាគត គឺការជ្រាបតាមពិត ក្នុងហេតុនិងមិនមែនហេតុ ជាអរិយៈ មិនគួរនិយាយថា ជាអនិមិត្តារម្មណ៍ ។ បេ ។ ជាអប្បណិហិតារម្មណ៍ទេឬ ។ អើ ។ សតិប្បដ្ឋាន ជាអរិយៈ មិនគួរនិយាយថា ជាអប្បណិហិតារម្មណ៍ទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ កម្លាំងរបស់ព្រះតថាគត គឺការជ្រាបតាមពិត ក្នុងហេតុនិងមិនមែនហេតុ ជាអរិយៈ មិនគួរនិយាយថា ជាសុញ្ញតារម្មណ៍ ។ បេ ។ ជាអនិមិត្តារម្មណ៍ ។ បេ ។ ជាអប្បណិហិតារម្មណ៍ទេឬ ។ អើ ។ សម្មប្បធាន ។ បេ ។ ពោជ្ឈង្គៈ ជាអរិយៈ មិនគួរនិយាយថា ជាអប្បណិហិតារម្មណ៍ទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។*

[២៨០] *កម្លាំងរបស់ព្រះតថាគត គឺការជ្រាបតាមពិត ក្នុងចុតិនិងបដិសន្ធិ របស់ពួកសត្វ ជាអរិយៈឬ ។ អើ ។ មគ្គ ផល និព្វាន សោតាបត្តិមគ្គ សោតាបត្តិផល ។ បេ ។ ពោជ្ឈង្គៈ* (ជាអរិយៈ)*ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។*

[២៨១] *កម្លាំងរបស់ព្រះតថាគត គឺការជ្រាបតាមពិត ក្នុងចុតិនិងបដិសន្ធិ របស់ពួកសត្វ ជាអរិយៈឬ ។ អើ ។ ជាសុញ្ញតារម្មណ៍ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ជាសុញ្ញតារម្មណ៍ឬ ។*

អាមន្តា ។ សត្តានំ ចុតូបបាតញ្ច មនសិករោតិ សុញ្ញ-
តញ្ច មនសិករោតីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។
សត្តានំ ចុតូបបាតញ្ច មនសិករោតិ សុញ្ញតញ្ច មន-
សិករោតីតិ ។ អាមន្តា ។ ទ្វិន្នំ ផស្សានំ ទ្វិន្នំ ចិត្តា-
នំ សមោធានំ ហោតីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។
សត្តានំ ចុតូបបាតេ យថាភូតំ ញាណំ តថាគតពលំ
អរិយន្តិ ។ អាមន្តា ។ អនិមិត្តារម្មណំ ។ បេ ។ អប្ប-
ណិហិតារម្មណន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។ អប្បណិ-
ហិតារម្មណន្តិ ។ អាមន្តា ។ សត្តានំ ចុតូបបាតញ្ច
មនសិករោតិ អប្បណិហិតញ្ច មនសិករោតីតិ ។ ន
ហេវំ វត្តព្វេ ។ បេ ។ សត្តានំ ចុតូបបាតញ្ច មនសិក-
រោតិ អប្បណិហិតញ្ច មនសិករោតីតិ ។ អាមន្តា ។
ទ្វិន្នំ ផស្សានំ ទ្វិន្នំ ចិត្តានំ សមោធានំ ហោតីតិ ។
ន ហេវំ វត្តព្វេ ។ បេ ។

[២៨២] សតិប្បដ្ឋានា អរិយា សុញ្ញតារម្មណា
។ បេ ។ អនិមិត្តារម្មណា ។ បេ ។ អប្បណិហិតារម្ម-
ណាតិ ។ អាមន្តា ។ សត្តានំ ចុតូបបាតេ យថាភូតំ
ញាណំ តថាគតពលំ អរិយំ អប្បណិហិតារម្មណន្តិ ។

អើ ។ បុគ្គល ធ្វើទុកក្នុងចិត្ត នូវចុតិនិងបដិសន្ធិ របស់ពួកសត្វផង ធ្វើទុកក្នុងចិត្ត នូវសុញ្ញតៈផងឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ បុគ្គល ធ្វើទុកក្នុងចិត្ត នូវចុតិនិងបដិសន្ធិ របស់ពួកសត្វផង ធ្វើទុកក្នុងចិត្ត នូវសុញ្ញតៈផងឬ ។ អើ ។ ការប្រជុំចុះ នៃផស្សៈទាំង ២ នៃចិត្តទាំង ២ មានឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ កម្លាំងរបស់ព្រះតថាគត គឺការជ្រាបតាមពិត ក្នុងចុតិនិងបដិសន្ធិ របស់ពួកសត្វ ជាអរិយៈឬ ។ អើ ។ ជាអនិមិត្តារម្មណ៍ ។ បេ ។ ជាអប្បណិហិតារម្មណ៍ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ ជាអប្បណិហិតារម្មណ៍ឬ ។ អើ ។ បុគ្គល ធ្វើទុកក្នុងចិត្ត នូវចុតិនិងបដិសន្ធិ របស់ពួកសត្វផង ធ្វើទុកក្នុងចិត្ត នូវអប្បណិហិតៈផងឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ បុគ្គល ធ្វើទុកក្នុងចិត្ត នូវចុតិនិងបដិសន្ធិ របស់ពួកសត្វផង ធ្វើទុកក្នុងចិត្ត នូវអប្បណិហិតៈផងឬ ។ អើ ។ ការប្រជុំចុះ នៃផស្សៈទាំង ២ នៃចិត្តទាំង ២ មានឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[២៨២] សតិប្បដ្ឋាន ជាអរិយៈ ជាសុញ្ញតារម្មណ៍ ។ បេ ។ ជាអនិមិត្តារម្មណ៍ ។ បេ ។ ជាអប្បណិហិតារម្មណ៍ឬ ។ អើ ។ កម្លាំងរបស់ព្រះតថាគត គឺការជ្រាបតាមពិត ក្នុងចុតិនិងបដិសន្ធិ របស់ពួកសត្វ ជាអរិយៈ ជាអប្បណិហិតារម្មណ៍ឬ ។

ន ហេវំ វត្តព្វេ ។ បេ ។ សម្មប្បជានា[១] ។ បេ ។ ពោជ្ឈង្គា អរិយា សុញ្ញតារម្មណា ។ បេ ។ អនិមិត្តារម្មណា ។ បេ ។ អប្បណិហិតារម្មណាតិ ។ អាមន្តា ។ សត្តានំ ចុតូបបាតេ យថាកម្មូបគេ ញាណំ តថាគតពលំ អរិយំ អប្បណិហិតារម្មណន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[២៨៣] សត្តានំ ចុតូបបាតេ យថាកម្មូបគេ ញាណំ តថាគតពលំ អរិយំ ន វត្តព្វំ សុញ្ញតារម្មណំ ។ បេ ។ អនិមិត្តារម្មណំ ។ បេ ។ អប្បណិហិតារម្មណន្តិ ។ អាមន្តា ។ សតិប្បដ្ឋានា អរិយា ន វត្តព្វា អប្បណិហិតារម្មណាតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[២៨៤] សត្តានំ ចុតូបបាតេ យថាកម្មូបគេ ញាណំ តថាគតពលំ អរិយំ ន វត្តព្វំ សុញ្ញតារម្មណំ ។ បេ ។ អនិមិត្តារម្មណំ ។ បេ ។ អប្បណិហិតារម្មណន្តិ ។ អាមន្តា ។ សម្មប្បជានា ។ បេ ។ ពោជ្ឈង្គា អរិយា ន វត្តព្វា អប្បណិហិតារម្មណាតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

១ ម. សម្មប្បធានន្តិ ទិស្សតិ ។

អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ សម្មប្បធាន ។ បេ ។ ពោជ្ឈង្គៈ ជាអរិយៈ ជាសុញ្ញតារម្មណ៍ ។ បេ ។ ជាអនិមិត្តារម្មណ៍ ។ បេ ។ ជាអប្បណិហិតារម្មណ៍ឬ ។ អើ ។ កម្លាំងរបស់ព្រះតថាគត គឺការជ្រាបតាមពិត ក្នុងចុតិនិងបដិសន្ធិ របស់ពួកសត្វ ជាអរិយៈ ជាអប្បណិហិតារម្មណ៍ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[២៨៣] កម្លាំងរបស់ព្រះតថាគត គឺការជ្រាបតាមពិត ក្នុងចុតិនិងបដិសន្ធិ របស់ពួកសត្វ ជាអរិយៈ មិនគួរនិយាយថា ជាសុញ្ញតារម្មណ៍ ។ បេ ។ ជាអនិមិត្តារម្មណ៍ ។ បេ ។ ជាអប្បណិហិតារម្មណ៍ទេឬ ។ អើ ។ សតិប្បដ្ឋាន ជាអរិយៈ មិនគួរពោលថា ជាអប្បណិហិតារម្មណ៍ទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[២៨៤] កម្លាំងរបស់ព្រះតថាគត គឺការជ្រាបតាមពិត ក្នុងចុតិនិងបដិសន្ធិ របស់ពួកសត្វ ជាអរិយៈ មិនគួរពោលថា ជាសុញ្ញតារម្មណ៍ ។ បេ ។ ជាអនិមិត្តារម្មណ៍ ។ បេ ។ ជាអប្បណិហិតារម្មណ៍ទេឬ ។ អើ ។ សម្មប្បធាន ។ បេ ។ ពោជ្ឈង្គៈ ជាអរិយៈ មិនគួរពោលថា ជាអប្បណិហិតារម្មណ៍ទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[២៨៥] អាសវានំ ខយេ យថាភូតំ ញាណំ តថាគតពលំ អរិយន្តិ ។ អាមន្តា ។ ឋានាឋានេ យថាភូតំ ញាណំ តថាគតពលំ អរិយន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[២៨៦] អាសវានំ ខយេ យថាភូតំ ញាណំ តថាគតពលំ អរិយន្តិ ។ អាមន្តា ។ សត្តានំ ចុតូបបាតេ យថាភូតំ ញាណំ តថាគតពលំ អរិយន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[២៨៧] ឋានាឋានេ យថាភូតំ ញាណំ តថាគតពលំ ន វត្តព្វំ អរិយន្តិ ។ អាមន្តា ។ អាសវានំ ខយេ យថាភូតំ ញាណំ តថាគតពលំ ន វត្តព្វំ អរិយន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[២៨៨] សត្តានំ ចុតូបបាតេ យថាភូតំ ញាណំ តថាគតពលំ ន វត្តព្វំ អរិយន្តិ ។ អាមន្តា ។ អាសវានំ ខយេ យថាភូតំ ញាណំ តថាគតពលំ ន វត្តព្វំ អរិយន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[២៨៥] កម្លាំងរបស់ព្រះតថាគត គឺការជ្រាបតាមពិត ក្នុងការអស់ទៅ នៃអាសវៈទាំងឡាយ ជាអរិយៈឬ ។ អើ ។ កម្លាំងរបស់ព្រះតថាគត គឺការជ្រាបតាមពិត ក្នុងហេតុនិងមិនមែនហេតុ ជាអរិយៈឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[២៨៦] កម្លាំងរបស់ព្រះតថាគត គឺការជ្រាបតាមពិត ក្នុងការអស់ទៅ នៃអាសវៈទាំងឡាយ ជាអរិយៈឬ ។ អើ ។ កម្លាំងរបស់ព្រះតថាគត គឺការជ្រាបតាមពិត ក្នុងចុតិនិងបដិសន្ធិ របស់ពួកសត្វ ជាអរិយៈឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[២៨៧] កម្លាំងរបស់ព្រះតថាគត គឺការជ្រាបតាមពិត ក្នុងហេតុនិងមិនមែនហេតុ មិនគួរពោលថា ជាអរិយៈទេឬ ។ អើ ។ កម្លាំងរបស់ព្រះតថាគត គឺការជ្រាបតាមពិត ក្នុងការអស់ទៅ នៃអាសវៈទាំងឡាយ មិនគួរពោលថា ជាអរិយៈទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[២៨៨] កម្លាំងរបស់ព្រះតថាគត គឺការជ្រាបតាមពិត ក្នុងចុតិនិងបដិសន្ធិ របស់ពួកសត្វ មិនគួរពោលថា ជាអរិយៈទេឬ ។ អើ ។ កម្លាំងរបស់ព្រះតថាគត គឺការជ្រាបតាមពិត ក្នុងការអស់ទៅ នៃអាសវៈទាំងឡាយ មិនគួរពោលថា ជាអរិយៈទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

អរិយន្ទិកថា

[២៨៩] អាសវានំ ខយេ យថាភូតំ ញាណំ តថាគតពលំ អរិយំ សុញ្ញតារម្មណន្តិ ។ អាមន្តា ។ ហាដាហាដេ យថាភូតំ ញាណំ តថាគតពលំ អរិយំ សុញ្ញតារម្មណន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។ អាសវានំ ខយេ យថាភូតំ ញាណំ តថាគតពលំ អរិយំ អនិមិត្តារម្មណំ ។ បេ ។ អប្បណិហិតារម្មណន្តិ ។ អាមន្តា ។ ហាដាហាដេ យថាភូតំ ញាណំ តថាគតពលំ អរិយំ អប្បណិហិតារម្មណន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[២៩០] អាសវានំ ខយេ យថាភូតំ ញាណំ តថាគតពលំ អរិយំ សុញ្ញតារម្មណំ ។ បេ ។ អនិមិត្តារម្មណំ ។ បេ ។ អប្បណិហិតារម្មណន្តិ ។ អាមន្តា ។ សត្តានំ ចុតូបបាតេ យថាភូតំ ញាណំ តថាគតពលំ អរិយំ អប្បណិហិតារម្មណន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[២៩១] ហាដាហាដេ យថាភូតំ ញាណំ តថាគតពលំ អរិយំ ន វត្តព្វំ សុញ្ញតារម្មណន្តិ ។

អរិយន្តិកថា

[២៨៩] *កម្លាំងរបស់ព្រះតថាគត គឺការជ្រាបតាមពិត ក្នុងការអស់ទៅ នៃអាសវៈទាំងឡាយ ជាអរិយៈ ជាសុញ្ញតារម្មណ៍ឬ ។ អើ ។ កម្លាំងរបស់ព្រះតថាគត គឺការជ្រាបតាមពិត ក្នុងហេតុនិងមិនមែនហេតុ ជាអរិយៈ ជាសុញ្ញតារម្មណ៍ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ កម្លាំងរបស់ព្រះតថាគត គឺការជ្រាបតាមពិត ក្នុងការអស់ទៅ នៃអាសវៈទាំងឡាយ ជាអរិយៈ ជាអនិមិត្តារម្មណ៍ ។ បេ ។ ជាអប្បណិហិតារម្មណ៍ឬ ។ អើ ។ កម្លាំងរបស់ព្រះតថាគត គឺការជ្រាបតាមពិត ក្នុងហេតុនិងមិនមែនហេតុ ជាអរិយៈ ជាអប្បណិហិតារម្មណ៍ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។*

[២៩០] *កម្លាំងរបស់ព្រះតថាគត គឺការជ្រាបតាមពិត ក្នុងការអស់ទៅ នៃអាសវៈទាំងឡាយ ជាអរិយៈ ជាសុញ្ញតារម្មណ៍ ។ បេ ។ ជាអនិមិត្តារម្មណ៍ ។ បេ ។ ជាអប្បណិហិតារម្មណ៍ឬ ។ អើ ។ កម្លាំងរបស់ព្រះតថាគត គឺការជ្រាបតាមពិត ក្នុងចុតិនិងបដិសន្ធិ របស់ពួកសត្វ ជាអរិយៈ ជាអប្បណិហិតារម្មណ៍ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។*

[២៩១] *កម្លាំងរបស់ព្រះតថាគត គឺការជ្រាបតាមពិត ក្នុងហេតុនិងមិនមែនហេតុ ជាអរិយៈ មិនគួរពោលថា ជាសុញ្ញតារម្មណ៍ទេឬ ។*

អាមន្តា ។ អាសវានំ ខយេ យថាភូតំ ញាណំ តថាគតពលំ អរិយំ ន វត្តព្វំ សុញ្ញតារម្មណន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។ ឋានាឋានេ យថាភូតំ ញាណំ តថាគតពលំ អរិយំ ន វត្តព្វំ អនិមិត្តារម្មណំ ។ បេ ។ អប្បណិហិតារម្មណន្តិ ។ អាមន្តា ។ អាសវានំ ខយេ យថាភូតំ ញាណំ តថាគតពលំ អរិយំ ន វត្តព្វំ អប្បណិហិតារម្មណន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[២៩២] សត្តានំ ចុតូបបាតេ យថាភូតំ ញាណំ តថាគតពលំ អរិយំ ន វត្តព្វំ សុញ្ញតារម្មណំ ។ បេ ។ អនិមិត្តារម្មណំ ។ បេ ។ អប្បណិហិតារម្មណន្តិ ។ អាមន្តា ។ អាសវានំ ខយេ យថាភូតំ ញាណំ តថាគតពលំ អរិយំ ន វត្តព្វំ អប្បណិហិតារម្មណន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។

អរិយន្តិកថា ។

អើ ។ កម្លាំងរបស់ព្រះតថាគត គឺការជ្រាបតាមពិត ក្នុងការអស់ទៅ នៃអាសវៈទាំងឡាយ ជាអរិយៈ មិនគួរពោលថា ជាសុញ្ញតារម្មណ៍ទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ កម្លាំងរបស់ព្រះតថាគត គឺការជ្រាបតាមពិត ក្នុងហេតុនិងមិនមែនហេតុ ជាអរិយៈ មិនគួរពោលថា ជាអនិមិត្តារម្មណ៍ ។ បេ ។ ជាអប្បណិហិតារម្មណ៍ទេឬ ។ អើ ។ កម្លាំងរបស់ព្រះតថាគត គឺការជ្រាបតាមពិត ក្នុងការអស់ទៅ នៃអាសវៈទាំងឡាយ ជាអរិយៈ មិនគួរពោលថា ជាអប្បណិហិតារម្មណ៍ទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[២៩២] កម្លាំងរបស់ព្រះតថាគត គឺការជ្រាបតាមពិត ក្នុងចុតិនិងបដិសន្ធិ របស់ពួកសត្វ ជាអរិយៈមិនគួរពោលថា ជាសុញ្ញតារម្មណ៍ ។ បេ ។ ជាអនិមិត្តារម្មណ៍ ។ បេ ។ ជាអប្បណិហិតារម្មណ៍ទេឬ ។ អើ ។ កម្លាំងរបស់ព្រះតថាគត គឺការជ្រាបតាមពិត ក្នុងការអស់ទៅ នៃអាសវៈទាំងឡាយ ជាអរិយៈ មិនគួរពោលថា ជាអប្បណិហិតារម្មណ៍ទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

ចប់ អរិយន្តិកថា ។

១១៩

# វិមុច្ចិកថា

[២៩៣] សរាគំ ចិត្តំ វិមុច្ចតីតិ ។ អាមន្តា ។ រាគសហគតំ រាគសហជាតំ រាគសំសដ្ឋំ រាគសម្បយុត្តំ រាគសហភុ រាគានុបរិវត្តិ អកុសលំ លោកិយំ សាសវំ សញ្ញោជនិយំ គន្ថនិយំ ឱឃនិយំ យោគនិយំ នីវរណិយំ បរាមដ្ឋំ ឧបាទានិយំ សង្កិលេសិកំ ចិត្តំ វិមុច្ចតីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[២៩៤] សទោសំ ចិត្តំ វិមុច្ចតិ ទោសោ ច ចិត្តញ្ច ឧភោ វិមុច្ចន្តីតិ ។ អាមន្តា ។ សរាគំ ចិត្តំ វិមុច្ចតិ រាគោ ច ចិត្តញ្ច ឧភោ វិមុច្ចន្តីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[២៩៥] សវេទនំ ។ បេ ។ សសញ្ញំ ។ បេ ។ សចេតនំ ។ បេ ។ សបញ្ញំ ចិត្តំ វិមុច្ចតិ បញ្ញា ច ចិត្តញ្ច[១] ឧភោ វិមុច្ចន្តីតិ ។ អាមន្តា ។ សរាគំ ចិត្តំ វិមុច្ចតិ រាគោ ច ចិត្តញ្ច ឧភោ វិមុច្ចន្តីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

---

១ ម. សសញ្ញំ ចិត្តំ វិមុច្ចតិ សញ្ញា ច ចិត្តញ្ចាតិ ទិស្សតិយេវ ។ ឯវំ សព្វត្ថ ។

# វិមុច្ចតិកថា

[២៩៣] ចិត្តដែលប្រកបដោយរាគៈ រួចស្រឡះ (ចាកអាសវៈ) ឬ ។ អើ ។ ចិត្ត ដែលប្រព្រឹត្តទៅជាមួយនឹងរាគៈ មានកំណើតជាមួយនឹងរាគៈ ច្រឡូកច្រឡំដោយរាគៈ ប្រកបដោយរាគៈ កើតជាមួយនឹងរាគៈ ប្រព្រឹត្តទៅតាមរាគៈ ជាអកុសល ជាលោកិយៈ ប្រកបដោយអាសវៈ ជាប្រយោជន៍ដល់សញ្ញោជនៈ ដែលគន្ថៈគប្បីដោតក្រង ដែលឱឃៈគប្បីប្រព្រឹត្តកន្លង ដែលយោគៈគប្បីប្រព្រឹត្តកន្លង ជាប្រយោជន៍ដល់នីវរណៈ ដែលបរាមាសៈស្ទាបអង្អែលហើយ ជាប្រយោជន៍ដល់ឧបាទាន ប្រកបដោយសេចក្តីសៅហ្មង រួចស្រឡះឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[២៩៤] ចិត្តប្រកបដោយផស្សៈ រួចស្រឡះ ចុះផស្សៈនិងចិត្តទាំងពីរ រួចស្រឡះឬ ។ អើ ។ ចិត្ត ដែលប្រកបដោយរាគៈ រួចស្រឡះ ចុះរាគៈនិងចិត្ត ទាំងពីរ រួចស្រឡះឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[២៩៥] ចិត្ត ដែលប្រកបដោយវេទនា ។ បេ ។ ប្រកបដោយសញ្ញា ។ បេ ។ ប្រកបដោយចេតនា ។ បេ ។ ប្រកបដោយបញ្ញា រួចស្រឡះ ចុះបញ្ញានិងចិត្ត ទាំងពីរ រួចស្រឡះដែរឬ ។ អើ ។ ចិត្ត ដែលប្រកបដោយរាគៈ រួចស្រឡះ ចុះរាគៈនិងចិត្ត ទាំងពីរ រួចស្រឡះដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[២៩៦] សជស្សំ សរាគំ ចិត្តំ វិមុច្ចតិ ជស្សោ ច ចិត្តញ្ច ឧភោ វិមុច្ចន្តីតិ ។ អាមន្តា ។ រាគោ ច ចិត្តញ្ច ឧភោ វិមុច្ចន្តីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[២៩៧] សវេទនំ សរាគំ ។ បេ ។ សសញ្ញំ សរាគំ ។ បេ ។ សចេតនំ សរាគំ ។ បេ ។ សបញ្ញំ សរាគំ ចិត្តំ វិមុច្ចតិ បញ្ញា ច ចិត្តញ្ច ឧភោ វិមុច្ចន្តីតិ ។ អាមន្តា ។ រាគោ ច ចិត្តញ្ច ឧភោ វិមុច្ចន្តីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[២៩៨] សទោសំ ចិត្តំ វិមុច្ចតីតិ ។ អាមន្តា ។ ទោសសហគតំ ទោសសហជាតំ ទោសសំសដ្ឋំ ទោសសម្បយុត្តំ ទោសសហភុ ទោសានុបរិវត្តិ អកុសលំ លោកិយំ សាសវំ ។ បេ ។ សង្កិលេសិកំ ចិត្តំ វិមុច្ចតីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[២៩៩] សជស្សំ ចិត្តំ វិមុច្ចតិ ជស្សោ ច ចិត្តញ្ច ឧភោ វិមុច្ចន្តីតិ ។ អាមន្តា ។ សទោសំ ចិត្តំ វិមុច្ចតិ ទោសោ ច ចិត្តញ្ច ឧភោ វិមុច្ចន្តីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[២៩៦] ចិត្ត ដែលប្រកបដោយផស្សៈ ប្រកបដោយរាគៈ រួចស្រឡះ ចុះផស្សៈនិងចិត្ត ទាំងពីរ រួចស្រឡះដែរឬ ។ អើ ។ រាគៈនិងចិត្ត ទាំងពីរ រួចស្រឡះឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[២៩៧] ចិត្ត ប្រកបដោយវេទនា ប្រកបដោយរាគៈ ។ បេ ។ ប្រកបដោយសញ្ញា ប្រកបដោយរាគៈ ។ បេ ។ ប្រកបដោយចេតនា ប្រកបដោយរាគៈ ។ បេ ។ ប្រកបដោយបញ្ញា ប្រកបដោយរាគៈ រួចស្រឡះ ចុះបញ្ញានិងចិត្ត ទាំងពីរ រួចស្រឡះដែរឬ ។ អើ ។ រាគៈនិងចិត្ត ទាំងពីរ រួចស្រឡះឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[២៩៨] ចិត្ត ដែលប្រកបដោយទោសៈ រួចស្រឡះឬ ។ អើ ។ ចិត្ត ដែលប្រព្រឹត្តទៅជាមួយនឹងទោសៈ មានកំណើតជាមួយនឹងទោសៈ ប្រឡូកប្រឡំដោយទោសៈ ប្រកបដោយទោសៈ កើតជាមួយនឹងទោសៈ ប្រព្រឹត្តទៅតាមទោសៈ ជាអកុសល ជាលោកិយៈ ប្រកបដោយអាសវៈ ។ បេ ។ ប្រកបដោយសេចក្តីសៅហ្មង រួចស្រឡះឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[២៩៩] ចិត្តដែលប្រកបដោយផស្សៈ រួចស្រឡះ ចុះផស្សៈនិងចិត្ត ទាំងពីរ រួចស្រឡះដែរឬ ។ អើ ។ ចិត្ត ដែលប្រកបដោយទោសៈ រួចស្រឡះ ចុះទោសៈនិងចិត្ត ទាំងពីរ រួចស្រឡះដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

វិមុច្ចតិកថា

[៣០០] សវេទនំ ។ បេ ។ សសញ្ញំ ។ បេ ។ សចេតនំ ។ បេ ។ សបញ្ញំ ចិត្តំ វិមុច្ចតិ បញ្ញា ច ចិត្តញ្ច ឧភោ វិមុច្ចន្តីតិ ។ អាមន្តា ។ សទោសំ ចិត្តំ វិមុច្ចតិ ទោសោ ច ចិត្តញ្ច ឧភោ វិមុច្ចន្តីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[៣០១] សជស្សំ សទោសំ ចិត្តំ វិមុច្ចតិ ផស្សោ ច ចិត្តញ្ច ឧភោ វិមុច្ចន្តីតិ ។ អាមន្តា ។ សទោសំ ចិត្តំ វិមុច្ចតិ ទោសោ ច ចិត្តញ្ច ឧភោ វិមុច្ចន្តីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[៣០២] សវេទនំ សទោសំ ។ បេ ។ សសញ្ញំ សទោសំ ។ បេ ។ សចេតនំ សទោសំ ។ បេ ។ សបញ្ញំ សទោសំ ចិត្តំ វិមុច្ចតិ បញ្ញា ច ចិត្តញ្ច ឧភោ វិមុច្ចន្តីតិ ។ អាមន្តា ។ ទោសោ ច ចិត្តញ្ច ឧភោ វិមុច្ចន្តីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[៣០៣] សមោហំ ចិត្តំ វិមុច្ចតីតិ ។ អាមន្តា ។

វិមុច្ចតិកថា

[៣០០] ចិត្តដែលប្រកបដោយវេទនា ។ បេ ។ ប្រកបដោយសញ្ញា ។ បេ ។ ប្រកបដោយចេតនា ។ បេ ។ ប្រកបដោយបញ្ញា រួចស្រឡះ ចុះបញ្ញានិងចិត្ត ទាំងពីរ រួចស្រឡះដែរឬ ។ អើ ។ ចិត្តដែលប្រកបដោយទោសៈ រួចស្រឡះ ចុះទោសៈនិងចិត្ត ទាំងពីរ រួចស្រឡះដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[៣០១] ចិត្ត ដែលប្រកបដោយផស្សៈ ប្រកបដោយទោសៈ រួចស្រឡះ ចុះផស្សៈនិងចិត្ត ទាំងពីរ រួចស្រឡះដែរឬ ។ អើ ។ ចិត្តដែលប្រកបដោយទោសៈ រួចស្រឡះ ចុះទោសៈនិងចិត្ត ទាំងពីរ រួចស្រឡះដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[៣០២] ចិត្ត ដែលប្រកបដោយវេទនា ប្រកបដោយទោសៈ ។ បេ ។ ប្រកបដោយសញ្ញា ប្រកបដោយទោសៈ ។ បេ ។ ប្រកបដោយចេតនា ប្រកបដោយទោសៈ ។ បេ ។ ប្រកបដោយបញ្ញា ប្រកបដោយទោសៈ រួចស្រឡះ ចុះបញ្ញានិងចិត្ត ទាំងពីរ រួចស្រឡះដែរឬ ។ អើ ។ ទោសៈនិងចិត្ត ទាំងពីរ រួចស្រឡះដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[៣០៣] ចិត្ត ដែលប្រកបដោយមោហៈ រួចស្រឡះឬ ។ អើ ។

មោហសហគតំ មោហសហជាតំ មោហសំសដ្ឋំ មោ-
ហសម្បយុត្តំ មោហសហភុ មោហានុបរិវត្តិ អកុសលំ
លោកិយំ សាសវំ ។ បេ ។ សង្កិលេសិកំ ចិត្តំ
វិមុច្ចតីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[៣០៤] សជស្សំ ចិត្តំ វិមុច្ចតិ ជស្សោ ច
ចិត្តញ្ច ឧភោ វិមុច្ចន្តីតិ ។ អាមន្តា ។ សមោហំ
ចិត្តំ វិមុច្ចតិ មោហោ ច ចិត្តញ្ច ឧភោ វិមុច្ចន្តីតិ ។
ន ហេវំ វត្តព្វេ ។ បេ ។

[៣០៥] សវេទនំ ។ បេ ។ សសញ្ញំ ។ បេ ។
សចេតនំ ។ បេ ។ សបញ្ញំ ចិត្តំ វិមុច្ចតិ បញ្ញា ច
ចិត្តញ្ច ឧភោ វិមុច្ចន្តីតិ ។ អាមន្តា ។ សមោហំ
ចិត្តំ វិមុច្ចតិ មោហោ ច ចិត្តញ្ច ឧភោ វិមុច្ចន្តីតិ ។
ន ហេវំ វត្តព្វេ ។ បេ ។

[៣០៦] សជស្សំ សមោហំ ចិត្តំ វិមុច្ចតិ
ជស្សោ ច ចិត្តញ្ច ឧភោ វិមុច្ចន្តីតិ ។ អាមន្តា ។
មោហោ ច ចិត្តញ្ច ឧភោ វិមុច្ចន្តីតិ ។ ន ហេវំ
វត្តព្វេ ។ បេ ។

ចិត្ត ដែលប្រព្រឹត្តទៅជាមួយនឹងមោហៈ មានកំណើតជាមួយនឹងមោហៈ ប្រឡូកប្រឡំដោយមោហៈ ប្រកបដោយមោហៈ កើតជាមួយនឹងមោហៈ ប្រព្រឹត្តទៅតាមមោហៈ ជាអកុសល ជាលោកិយៈ ប្រកបដោយអាសវៈ ។ បេ ។ ប្រកបដោយសេចក្ដីសៅហ្មង រូបស្រឡះដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[៣០៤] ចិត្ត ដែលប្រកបដោយផស្សៈ រូបស្រឡះ ចុះផស្សៈនិងចិត្ត ទាំងពីរ រូបស្រឡះដែរឬ ។ អើ ។ ចិត្ត ដែលប្រកបដោយមោហៈ រូបស្រឡះ ចុះមោហៈនិងចិត្ត ទាំងពីរ រូបស្រឡះដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[៣០៥] ចិត្ត ដែលប្រកបដោយវេទនា ។ បេ ។ ប្រកបដោយសញ្ញា ។ បេ ។ ប្រកបដោយចេតនា ។ បេ ។ ប្រកបដោយបញ្ញា រូបស្រឡះ ចុះបញ្ញានិងចិត្ត ទាំងពីរ រូបស្រឡះដែរឬ ។ អើ ។ ចិត្ត ដែលប្រកបដោយមោហៈ រូបស្រឡះ ចុះមោហៈនិងចិត្ត ទាំងពីរ រូបស្រឡះដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[៣០៦] ចិត្ត ដែលប្រកបដោយផស្សៈ ប្រកបដោយមោហៈ រូបស្រឡះ ចុះផស្សៈនិងចិត្ត ទាំងពីរ រូបស្រឡះដែរឬ ។ អើ ។ មោហៈនិងចិត្ត ទាំងពីរ រូបស្រឡះដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[៣០៧] សវេទនំ សមោហំ ។ បេ ។ សសញ្ញំ សមោហំ ។ បេ ។ សចេតនំ សមោហំ ។ បេ ។ សបញ្ញំ សមោហំ ចិត្តំ វិមុច្ចតិ បញ្ញា ច ចិត្តញ្ច ឧភោ វិមុច្ចន្តីតិ ។ អាមន្តា ។ មោហោ ច ចិត្តញ្ច ឧភោ វិមុច្ចន្តីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[៣០៨] ន វត្តព្វំ[១] សរាគំ សទោសំ សមោហំ ចិត្តំ វិមុច្ចតីតិ ។ អាមន្តា ។ វីតរាគំ វីតទោសំ វីតមោហំ និក្កិលេសំ ចិត្តំ វិមុច្ចតីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ តេន ហិ[២] សរាគំ សទោសំ សមោហំ ចិត្តំ វិមុច្ចតីតិ ។

វិមុច្ចតិកថា ។

# វិមុច្ចមានកថា

[៣០៩] វិមុត្តំ វិមុច្ចមានន្តិ ។ អាមន្តា ។ ឯកទេសំ វិមុត្តំ ឯកទេសំ អវិមុត្តន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។

១ ម. ន វត្តព្វន្តិ អយមេវ បាឋោ ន វិជ្ជតិ ។ ២ ម. ឯត្ថន្តរេ ន វត្តព្វន្តិ ទិស្សតិ ។

*[៣០៧] ចិត្ត ដែលប្រកបដោយវេទនា ប្រកបដោយមោហៈ ។ បេ ។ ប្រកបដោយសញ្ញា ប្រកបដោយមោហៈ ។ បេ ។ ប្រកបដោយចេតនា ប្រកបដោយមោហៈ ។ បេ ។ ប្រកបដោយបញ្ញា ប្រកបដោយមោហៈ រួចស្រឡះ ចុះបញ្ញានិងចិត្ត ទាំងពីរ រួចស្រឡះដែរឬ ។ អើ ។ មោហៈនិងចិត្ត ទាំងពីរ រួចស្រឡះដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។*

*[៣០៨] បុគ្គលមិនគួរនិយាយថា ចិត្ត ដែលប្រកបដោយរាគៈ ប្រកបដោយទោសៈ ប្រកបដោយមោហៈ រួចស្រឡះទេឬ ។ អើ ។ ចិត្ត ដែលប្រាសចាករាគៈ ប្រាសចាកទោសៈ ប្រាសចាកមោហៈ មិនមានកិលេស រួចស្រឡះឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ ព្រោះហេតុនោះ ចិត្ត ដែលប្រកបដោយរាគៈ ប្រកបដោយទោសៈ ប្រកបដោយមោហៈ រមែងរួចស្រឡះ (ចាកអាសវៈ) ។*

ចប់ វិមុច្ចតិកថា ។

# វិមុច្ចមានកថា

*[៣០៩] ចិត្តរួចស្រឡះហើយ ចិត្តកំពុងរួចស្រឡះ មែនឬ ។ អើ ។ ចិត្តរួចស្រឡះហើយ មួយផ្នែក ចិត្តមិនទាន់រួចស្រឡះហើយ មួយផ្នែក មែនឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។*

[៣១០] ឯកទេសំ វិមុត្តំ ឯកទេសំ អវិមុត្តន្តិ ។ អាមន្តា ។ ឯកទេសំ សោតាបន្នោ ឯកទេសំ ន សោតាបន្នោ ឯកទេសំ សោតាបត្តិផលប្បត្តោ បដិលទ្ធោ អធិគតោ សច្ឆិកតោ ឧបសម្បជ្ជ វិហរតិ កាយេន ផុសិត្វា វិហរតិ ឯកទេសំ ន កាយេន ផុសិត្វា វិហរតិ ឯកទេសំ សត្តក្ខត្តុំ[១]បរមោ កោលំកោលោ ឯកពីជី ពុទ្ធេ អវេច្ចប្បសាទេន សមន្នាគតោ ធម្មេ ។ បេ ។ សង្ឃេ ។ បេ ។ អរិយកន្តេហិ សីលេហិ សមន្នាគតោ ឯកទេសំ អរិយកន្តេហិ សីលេហិ ន សមន្នាគតោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[៣១១] ឯកទេសំ វិមុត្តំ ឯកទេសំ អវិមុត្តន្តិ ។ អាមន្តា ។ ឯកទេសំ សកទាគាមី ឯកទេសំ ន សកទាគាមី ឯកទេសំ សកទាគាមិផលប្បត្តោ បដិលទ្ធោ អធិគតោ សច្ឆិកតោ ឧបសម្បជ្ជ វិហរតិ កាយេន ផុសិត្វា វិហរតិ ឯកទេសំ ន កាយេន ផុសិត្វា វិហរតីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

---
១ ម. សត្តក្ខត្តុបរមោ ។

[៣១០] ចិត្តរួចស្រឡះហើយ មួយផ្នែក ចិត្តមិនទាន់រួចស្រឡះហើយ មួយផ្នែក មែនឬ ។ អើ ។ បុគ្គល ជាសោតាបន្នៈ មួយផ្នែក មិនមែនជាសោតាបន្នៈ មួយផ្នែក បុគ្គលដល់នូវសោតាបត្តិផល ដែលបានចំពោះ ត្រាស់ដឹង ធ្វើឲ្យជាក់ច្បាស់ សម្រេច ពាល់ត្រូវដោយនាមកាយ មួយផ្នែក មិនពាល់ត្រូវដោយនាមកាយ មួយផ្នែក សត្តក្ខត្តុំបរមបុគ្គល កោលំកោលបុគ្គល ឯកពីជិបុគ្គល ប្រកបដោយសេចក្តីជ្រះថ្លាមិនកម្រើកក្នុងព្រះពុទ្ធ ក្នុងព្រះធម៌ ។ បេ ។ ក្នុងព្រះសង្ឃ ។ បេ ។ ប្រកបដោយសីលជាទីត្រេកអរនៃព្រះអរិយៈទាំងឡាយ មួយផ្នែក មិនប្រកបដោយសីលជាទីត្រេកអរនៃព្រះអរិយៈទាំងឡាយ មួយផ្នែក មែនឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[៤០៧] នេវសញ្ញានាសញ្ញាយតនេ ន វត្តព្វំ សញ្ញា អត្ថីតិ ។ អាមន្តា ។ អសញ្ញភវោ អសញ្ញគតិ អសញ្ញសត្តាវាសោ អសញ្ញសំសារោ អសញ្ញយោនិ អសញ្ញត្តភាវប្បដិលាភោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

សញ្ញភព ក្នុងកាលខ្លះ មាន អសញ្ញភព ក្នុងកាលខ្លះ មាន បញ្ចវោ-ការភព ក្នុងកាលខ្លះ មាន ឯកវោការភព ក្នុងកាលខ្លះ មាន ដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[៤០៦] សញ្ញា ក្នុងពួកអសញ្ញសត្វ ក្នុងកាលខ្លះ មាន ក្នុងកាលខ្លះ មិនមាន ឬ ។ អើ ។ កាលដូចម្ដេច សញ្ញា មាន កាលដូចម្ដេច សញ្ញា មិនមាន ។ សញ្ញា ក្នុងចុតិកាល (កាលច្យុត) និងឧបបត្តិកាល (កាលដែលកើត) មាន តែក្នុងឋិតិកាល (កាលដែលតាំងនៅ) មិនមានទេ ។ ពួកសញ្ញសត្វ ក្នុងចុតិកាលនិងឧបបត្តិកាល មាន ពួកអសញ្ញសត្វ ក្នុងឋិតិកាល មាន សញ្ញភព ក្នុងចុតិកាល និងឧបបត្តិកាល មាន អសញ្ញភព ក្នុងឋិតិកាល មាន បញ្ចវោការភព ក្នុងចុតិកាល និងឧបបត្តិកាល មាន ឯកវោការភព ក្នុងឋិតិកាល មានឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

ចប់ អសញ្ញកថា ។

# នេវសញ្ញានាសញ្ញាយតនកថា

[៤០៧] បុគ្គលមិនគួរនិយាយថា សញ្ញា ក្នុងនេវសញ្ញានាសញ្ញា-យតនភព មានទេឬ ។ អើ ។ អសញ្ញភព អសញ្ញគតិ អសញ្ញ-សត្តាវាសៈ អសញ្ញសំសារ អសញ្ញយោនិ អសញ្ញត្តភាវប្បដិលាភ មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[៤០៨] ននុ សញ្ញភវោ សញ្ញគតិ សញ្ញសត្តាវាសោ សញ្ញសំសារោ សញ្ញយោនិ សញ្ញត្តភាវប្បដិលាភោតិ ។ អាមន្តា ។ ហញ្ចិ សញ្ញភវោ សញ្ញគតិ ។ បេ ។ សញ្ញត្តភាវប្បដិលាភោតិ នោ វត រេ វត្តព្វេ នេវសញ្ញានាសញ្ញាយតនេ ន វត្តព្វំ សញ្ញា អត្ថីតិ ។

[៤០៩] នេវសញ្ញានាសញ្ញាយតនេ ន វត្តព្វំ សញ្ញា អត្ថីតិ ។ អាមន្តា ។ ឯកវោការភវោ គតិ ។ បេ ។ អត្តភាវប្បដិលាភោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ ននុ ចតុវោការភវោ គតិ ។ បេ ។ អត្តភាវប្បដិលាភោតិ ។ អាមន្តា ។ ហញ្ចិ ចតុវោការភវោ គតិ ។ បេ ។ អត្តភាវប្បដិលាភោ នោ វត រេ វត្តព្វេ នេវសញ្ញានាសញ្ញាយតនេ ន វត្តព្វំ សញ្ញា អត្ថីតិ ។

[៤១០] អសញ្ញសត្តេសុ ន វត្តព្វំ សញ្ញា អត្ថិ សោ ច អសញ្ញភវោ អសញ្ញគតិ អសញ្ញសត្តាវាសោ អសញ្ញសំសារោ អសញ្ញយោនិ អសញ្ញត្តភាវប្បដិលាភោតិ ។ អាមន្តា ។

[៤០៨] ក្រែង សញ្ញភព សញ្ញគតិ សញ្ញសត្តាវាសៈ សញ្ញ-សំសារ សញ្ញយោនិ សញ្ញត្តភាវប្បដិលាភ មានដែរឬ ។ អើ ។ ប្រសិនបើ សញ្ញភព សញ្ញគតិ ។ បេ ។ សញ្ញត្តភាវប្បដិលាភ មានដែរ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា បុគ្គលមិនគួរនិយាយថា សញ្ញា ក្នុងនេវសញ្ញានាសញ្ញាយតនភព មានទេ ។

[៤០៩] បុគ្គលមិនគួរនិយាយថា សញ្ញា ក្នុងនេវសញ្ញានាសញ្ញា-យតនភព មានទេឬ ។ អើ ។ ឯកវោការភព គតិ ។ បេ ។ ការបានអត្តភាព មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ ក្រែង ចតុវោការភព គតិ ។ បេ ។ ការបានអត្តភាព មានដែរឬ ។ អើ ។ ប្រសិនបើ ចតុវោការភព គតិ ។ បេ ។ ការបានអត្តភាព មានដែរ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា បុគ្គលមិនគួរនិយាយថា សញ្ញា ក្នុងនេវសញ្ញានាសញ្ញាយតនភព មានទេ ។

[៤១០] បុគ្គលមិនគួរនិយាយថា សញ្ញា ក្នុងពួកអសញ្ញសត្វ មានទេ ចុះចំណែកខាង អសញ្ញភពនោះ អសញ្ញគតិ អសញ្ញសត្តាវាសៈ អសញ្ញសំសារ អសញ្ញយោនិ អសញ្ញត្តភាវប្បដិលាភ មានដែរឬ ។ អើ ។

១៨៩

## នេវសញ្ញានាសញ្ញាយតនកថា

នេវសញ្ញានាសញ្ញាយតនេ ន វត្តព្វំ សញ្ញា អត្ថិ សោ ច អសញ្ញភវោ អសញ្ញគតិ អសញ្ញសត្តាវាសោ អសញ្ញសំសារោ អសញ្ញយោនិ អសញ្ញត្តភាវប្បដិលាភោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ អសញ្ញសត្តេសុ ន វត្តព្វំ សញ្ញា អត្ថិ សោ ច ឯកវោការភវោ គតិ ។ បេ ។ អត្តភាវប្បដិលាភោតិ ។ អាមន្តា ។ នេវសញ្ញានាសញ្ញាយតនេ ន វត្តព្វំ សញ្ញា អត្ថិ សោ ច ឯកវោការភវោ គតិ សត្តាវាសោ សំសារោ យោនិ អត្តភាវប្បដិលាភោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[៤១១] នេវសញ្ញានាសញ្ញាយតនេ ន វត្តព្វំ សញ្ញា អត្ថិ សោ ច សញ្ញភវោ សញ្ញគតិ ។ បេ ។ សញ្ញត្តភាវប្បដិលាភោតិ ។ អាមន្តា ។ អសញ្ញសត្តេសុ ន វត្តព្វំ សញ្ញា អត្ថិ សោ ច សញ្ញភវោ សញ្ញគតិ ។ បេ ។ សញ្ញត្តភាវប្បដិលាភោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[៤១២] នេវសញ្ញានាសញ្ញាយតនេ ន វត្តព្វំ សញ្ញា អត្ថិ សោ ច ចតុវោការភវោ គតិ ។ បេ ។

នេវសញ្ញានាសញ្ញាយតនកថា

បុគ្គលមិនគួរនិយាយថា សញ្ញា ក្នុងនេវសញ្ញានាសញ្ញាយតនភព មាន ទេ ចុះចំណែកខាង អសញ្ញភពនោះ អសញ្ញគតិ អសញ្ញសត្តាវាសៈ អសញ្ញសំសារ អសញ្ញយោនិ អសញ្ញត្តភាវប្បដិលាភ មាន ដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ មិនគួរនិយាយថា សញ្ញា ក្នុងពួកអសញ្ញសត្វ មានទេ ចុះចំណែកខាង ឯកវោការភព នោះ គតិ ។ បេ ។ ការបានអត្តភាព មានដែរឬ ។ អើ ។ មិនគួរនិយាយថា សញ្ញា ក្នុងនេវសញ្ញានាសញ្ញាយតនភព មានទេ ចុះចំណែកខាង ឯកវោការភពនោះ គតិ លំនៅរបស់សត្វ សំសារ កំណើត ការបានអត្តភាព មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះ ទេ ។ បេ ។

[៤១១] បុគ្គលមិនគួរនិយាយថា សញ្ញា ក្នុងនេវសញ្ញានាសញ្ញាយតនភព មានទេ ចុះចំណែកខាង សញ្ញភពនោះ សញ្ញគតិ ។ បេ ។ សញ្ញត្តភាវប្បដិលាភ មានដែរឬ ។ អើ ។ មិនគួរនិយាយថា សញ្ញា ក្នុងពួកអសញ្ញសត្វ មានទេ ចុះចំណែកខាង សញ្ញភពនោះ សញ្ញគតិ ។ បេ ។ សញ្ញត្តភាវប្បដិលាភ មានដែរឬ ។ អ្នកមិនគួរពោល យ៉ាងនេះទេ ។ បេ ។

[៤១២] បុគ្គលមិនគួរនិយាយថា សញ្ញា ក្នុងនេវសញ្ញានាសញ្ញាយតនភព មានទេ ចុះចំណែកខាង ចតុវោការភពនោះ គតិ ។ បេ ។

អត្ថភាវប្បដិលាភោតិ ។ អាមន្តា ។ អសញ្ញសត្តេសុ ន វត្តព្វំ សញ្ញា អត្ថិ សោ ច ចតុវោការភវោ ។ បេ ។ អត្ថភាវប្បដិលាភោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[៤១៣] នេវសញ្ញានាសញ្ញាយតនេ ន វត្តព្វំ សញ្ញា អត្ថីតិ ។ អាមន្តា ។ ននុ នេវសញ្ញានា-សញ្ញាយតនំ ចតុវោការភវោតិ ។ អាមន្តា ។ ហញ្ចិ នេវសញ្ញានាសញ្ញាយតនំ ចតុវោការភវោ នោ វត វេ វត្តព្វេ នេវសញ្ញានាសញ្ញាយតនេ ន វត្តព្វំ សញ្ញា អត្ថីតិ ។

[៤១៤] នេវសញ្ញានាសញ្ញាយតនំ ចតុវោកា-រភវោ នេវសញ្ញានាសញ្ញាយតនេ ន វត្តព្វំ សញ្ញា អត្ថីតិ ។ អាមន្តា ។ អាកាសានញ្ចាយតនំ ចតុវោ-ការភវោ អាកាសានញ្ចាយតនេ ន វត្តព្វំ សញ្ញា អត្ថីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[៤១៥] នេវសញ្ញានាសញ្ញាយតនំ ចតុវោការភវោ នេវសញ្ញានាសញ្ញាយតនេ ន វត្តព្វំ សញ្ញា អត្ថីតិ ។

ការបានអត្តភាព មានដែរឬ ។ អើ ។ បុគ្គលមិនគួរនិយាយថា សញ្ញា ក្នុងពួកអសញ្ញសត្វ មានទេ ចុះចំណែកខាង ចតុវោការភព នោះ ។ បេ ។ ការបានអត្តភាព មានដែរឬ ។ អ្នកមិនគួរពោលយ៉ាង នេះទេ ។ បេ ។

[៤១៣] បុគ្គលមិនគួរនិយាយថា សញ្ញា ក្នុងនេវសញ្ញានាសញ្ញា-យតនភព មានទេឬ ។ អើ ។ ក្រែងនេវសញ្ញានាសញ្ញាយតនភព ជាចតុវោការភពឬ ។ អើ ។ ប្រសិនបើ នេវសញ្ញានាសញ្ញាយតនភព ជាចតុវោការភពមែន ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា បុគ្គលមិន គួរនិយាយថា សញ្ញា ក្នុងនេវសញ្ញានាសញ្ញាយតនភព មានទេ ។

[៤១៤] នេវសញ្ញានាសញ្ញាយតនភព ជាចតុវោការភព បុគ្គល មិនគួរនិយាយថា សញ្ញា ក្នុងនេវសញ្ញានាសញ្ញាយតនភព មានទេឬ ។ អើ ។ អាកាសានញ្ចាយតនភព ជាចតុវោការភព បុគ្គលមិនគួរនិយាយ ថា សញ្ញា ក្នុងអាកាសានញ្ចាយតនភព មានទេឬ ។ អ្នកមិនគួរពោល យ៉ាងនេះទេ ។ បេ ។

[៤១៥] នេវសញ្ញានាសញ្ញាយតនភព ជាចតុវោការភព បុគ្គល មិនគួរនិយាយថា សញ្ញា ក្នុងនេវសញ្ញានាសញ្ញាយតនភព មានទេឬ ។

អាមន្តា ។ វិញ្ញាណញ្ចាយតនំ ។ បេ ។ អាកិញ្ចញ្ញាយតនំ ចតុវោការភវោ អាកិញ្ចញ្ញាយតនេ ន វត្តព្វំ សញ្ញា អត្ថីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[៤១៦] អាកាសានញ្ចាយតនំ ចតុវោការភវោ អត្ថិ តត្ថ សញ្ញាតិ ។ អាមន្តា ។ នេវសញ្ញានាសញ្ញាយតនំ ចតុវោការភវោ អត្ថិ តត្ថ សញ្ញាតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ វិញ្ញាណញ្ចាយតនំ ។ បេ ។ អាកិញ្ចញ្ញាយតនំ ចតុវោការភវោ អត្ថិ តត្ថ សញ្ញាតិ ។ អាមន្តា ។ នេវសញ្ញានាសញ្ញាយតនំ ចតុវោការភវោ អត្ថិ តត្ថ សញ្ញាតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[៤១៧] នេវសញ្ញានាសញ្ញាយតនេ ន វត្តព្វំ សញ្ញា អត្ថីតិ វា នត្ថីតិ វាតិ ។ អាមន្តា ។ ននុ នេវសញ្ញានាសញ្ញាយតនំ ចតុវោការភវោតិ ។ អាមន្តា ។ ហញ្ចិ នេវសញ្ញានាសញ្ញាយតនំ ចតុវោការភវោ តេន វត វេ វត្តព្វេ នេវសញ្ញានាសញ្ញាយតនេ ន វត្តព្វំ សញ្ញា អត្ថីតិ វា នត្ថីតិ វាតិ ។

នេវសញ្ញានាសញ្ញាយតនកថា

អើ ។ វិញ្ញាណញ្ចាយតនភព ។ បេ ។ អាកិញ្ចញ្ញាយតនភព ជាចតុ-វោការភព បុគ្គលមិនគួរនិយាយថា សញ្ញា ក្នុងអាកិញ្ចញ្ញាយតនភព មានទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[៤១៦] អាកាសានញ្ចាយតនភព ជាចតុវោការភព សញ្ញា ក្នុងអាកាសានញ្ចាយតនភពនោះ មានដែរឬ ។ អើ ។ នេវសញ្ញានា-សញ្ញាយតនភព ជាចតុវោការភព សញ្ញា ក្នុងនេវសញ្ញានាសញ្ញាយ-តនភពនោះ មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ វិញ្ញាណញ្ចាយតនភព ។ បេ ។ អាកិញ្ចញ្ញាយតនភព ជាចតុវោការភព សញ្ញា ក្នុងអាកិញ្ចញ្ញាយតនភពនោះ មានដែរឬ ។ អើ ។ នេវ-សញ្ញានាសញ្ញាយតនភព ជាចតុវោការភព សញ្ញា ក្នុងនេវសញ្ញានា-សញ្ញាយតនភពនោះ មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[៤១៧] បុគ្គលមិនគួរនិយាយថា សញ្ញា ក្នុងនេវសញ្ញានាសញ្ញា-យតនភព មានឬមិនមានទេឬ ។ អើ ។ ក្រែង នេវសញ្ញានាសញ្ញា-យតនភព ជាចតុវោការភពឬ ។ អើ ។ ប្រសិនបើ នេវសញ្ញានា-សញ្ញាយតនភព ជាចតុវោការភពមែន ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរ ពោលថា បុគ្គលមិនគួរនិយាយថា សញ្ញា ក្នុងនេវសញ្ញានាសញ្ញាយ-តនភព មានឬមិនមានទេ ។

[៤១៨] នេវសញ្ញានាសញ្ញាយតនំ ចតុវោការភវោ នេវសញ្ញានាសញ្ញាយតនេ ន វត្តព្វំ សញ្ញា អត្ថីតិ វា នត្ថីតិ វាតិ ។ អាមន្តា ។ អាកាសានញ្ចាយតនំ ។ បេ ។ វិញ្ញាណញ្ចាយតនំ ។ បេ ។ អាកិញ្ចញ្ញាយតនំ ចតុវោការភវោ អាកិញ្ចញ្ញាយតនេ ន វត្តព្វំ សញ្ញា អត្ថីតិ វា នត្ថីតិ វាតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[៤១៩] អាកាសានញ្ចាយតនំ ចតុវោការភវោ អត្ថិ តត្ថ សញ្ញាតិ ។ អាមន្តា ។ នេវសញ្ញានាសញ្ញាយតនំ ចតុវោការភវោ អត្ថិ តត្ថ សញ្ញាតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ វិញ្ញាណញ្ចាយតនំ ។ បេ ។ អាកិញ្ចញ្ញាយតនំ ចតុវោការភវោ អត្ថិ តត្ថ សញ្ញាតិ ។ អាមន្តា ។ នេវសញ្ញានាសញ្ញាយតនំ ចតុវោការភវោ អត្ថិ តត្ថ សញ្ញាតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[៦១៨] នេវសញ្ញានាសញ្ញាយតនភព ជាចតុវោការភព បុគ្គលមិនគួរនិយាយថា សញ្ញា ក្នុងនេវសញ្ញានាសញ្ញាយតនភព មានឬមិនមានទេឬ ។ អើ ។ អាកាសានញ្ចាយតនភព ។ បេ ។ វិញ្ញាណញ្ចាយ-តនភព ។ បេ ។ អាកិញ្ចញ្ញាយតនភព ជាចតុវោការភព បុគ្គលមិនគួរនិយាយថា សញ្ញា ក្នុងអាកិញ្ចញ្ញាយតនភព មានឬមិនមានទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[៦១៩] អាកាសានញ្ចាយតនភព ជាចតុវោការភព សញ្ញា ក្នុងអាកាសានញ្ចាយតនភពនោះ មានដែរឬ ។ អើ ។ នេវសញ្ញា-នាសញ្ញាយតនភព ជាចតុវោការភព សញ្ញា ក្នុងនេវសញ្ញានាសញ្ញា-យតនភពនោះ មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ វិញ្ញាណញ្ចាយតនភព ។ បេ ។ អាកិញ្ចញ្ញាយតនភព ជាចតុវោការភព សញ្ញា ក្នុងអាកិញ្ចញ្ញាយតនភពនោះ មានដែរឬ ។ អើ ។ នេវសញ្ញា-នាសញ្ញាយតនភព ជាចតុវោការភព សញ្ញា ក្នុងនេវសញ្ញានាសញ្ញា-យតនភពនោះ មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

១៦៣

នេវសញ្ញានាសញ្ញាយតនកថា

[៤២០] នេវសញ្ញានាសញ្ញាយតនេ ន វត្តព្វំ សញ្ញា អត្ថីតិ វា នត្ថីតិ វាតិ ។ អាមន្តា ។ ននុ នេវសញ្ញានាសញ្ញាយតនន្តិ ។ អាមន្តា ។ ហញ្ចិ នេវសញ្ញានាសញ្ញាយតនំ តេន វត រេ វត្តព្វេ នេវសញ្ញានាសញ្ញាយតនេ ន វត្តព្វំ សញ្ញា អត្ថីតិ វា នត្ថីតិ វាតិ ។

[៤២១] នេវសញ្ញានាសញ្ញាយតនន្តិ កត្វា នេវសញ្ញានាសញ្ញាយតនេ ន វត្តព្វំ សញ្ញា អត្ថីតិ វា នត្ថីតិ វាតិ ។ អាមន្តា ។ អទុក្ខមសុខា វេទនាតិ កត្វា អទុក្ខមសុខាយ វេទនាយ ន វត្តព្វំ វេទនាតិ វា អវេទនាតិ វាតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

នេវសញ្ញានាសញ្ញាយតនកថា ។

តតិយោ វគ្គោ ។

## នេវសញ្ញានាសញ្ញាយតនកថា

[៤២០] បុគ្គលមិនគួរនិយាយថា សញ្ញា ក្នុងនេវសញ្ញានាសញ្ញាយតនភព មានឬមិនមានទេឬ ។ អើ ។ ក្រែង នេវសញ្ញានាសញ្ញាយតនភព មានឬ ។ អើ ។ ប្រសិនបើ នេវសញ្ញានាសញ្ញាយតនភព មានមែន ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគួរពោលថា បុគ្គលគួរនិយាយថា សញ្ញា ក្នុងនេវសញ្ញានាសញ្ញាយតនភព មានឬមិនមានទេ ។

[៤២១] បុគ្គលធ្វើសេចក្តីចូលចិត្តថា នេវសញ្ញានាសញ្ញាយតនភព ដូច្នេះហើយ មិនគួរនិយាយថា សញ្ញា ក្នុងនេវសញ្ញានាសញ្ញាយតនភព មានឬមិនមានទេឬ ។ អើ ។ បុគ្គលធ្វើសេចក្តីចូលចិត្តថា អទុក្ខមសុខវេទនា ដូច្នេះហើយ មិនគួរនិយាយថា វេទនា ឬមិនមែនវេទនា ក្នុងអទុក្ខមសុខវេទនាទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

ចប់ នេវសញ្ញានាសញ្ញាយតនកថា ។

ចប់ តតិយវគ្គ ។

១៦៤

## តស្ស ឧទ្ទានំ

ពលំ សាធារណំ អរិយំ សភាគំ ចិត្តំ វិមុច្ចតិ
វិមុត្តំ វិមុច្ចមានំ អត្ថិ ចិត្តំ វិមុច្ចមានំ
អដ្ឋមកស្ស បុគ្គលស្ស ទិដ្ឋិបរិយុដ្ឋានំ បហីនំ
អដ្ឋមកស្ស បុគ្គលស្ស នត្ថិ បញ្ចិន្ទ្រិយានិ ចក្ខុំ
សោតំ ធម្មុបត្ថទ្ធំ យថាកម្មុបគតញ្ញាណំ ទេវេសុ
សំវរោ អសញ្ញសត្តេសុ សញ្ញា ឯវមេវ ភវគ្គន្តិ ។

---

## គិហិស្ស អរហាតិកថា

[៤២២] គិហិស្ស អរហាតិ ។ អាមន្តា ។ អត្ថិ អរហតោ គិហិសញ្ញោជនន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។ នត្ថិ អរហតោ គិហិសញ្ញោជនន្តិ ។ អាមន្តា ។ ហញ្ចិ នត្ថិ អរហតោ គិហិសញ្ញោជនំ នោ វត រេ វត្តព្វេ គិហិស្ស អរហាតិ ។

[៤២៣] គិហិស្ស អរហាតិ ។ អាមន្តា ។ ននុ អរហតោ គិហិសញ្ញោជនំ បហីនំ ឧច្ឆិន្នមូលំ

# ឧទ្ទាននៃតតិយវគ្គនោះ គឺ

និយាយ អំពីកម្លាំងព្រះតថាគត សាធារណៈដល់សាវ័ក ១ កម្លាំងព្រះតថាគត ជាអរិយៈ ១ ចិត្ត ប្រកបដោយរាគៈ រួចស្រឡះ ១ ចិត្ត រួចស្រឡះហើយ កំពុងរួចស្រឡះ និងចិត្តកំពុងរួចស្រឡះ ១ បុគ្គលទី ៨ លះបង់ទិដ្ឋិបរិយុដ្ឋានៈ ១ បុគ្គលទី ៨ មិនមានឥន្ទ្រិយ៥យ៉ាង ១ មំសចក្ខុ ដែលធម៌ទំនុកបម្រុង ១ មំសសោតដែលធម៌ទំនុកបម្រុង ១ យថាកម្មូបគតញ្ញាណ ១ ការសង្រួម ក្នុងពួកទេវតា ១ សញ្ញា ក្នុងពួកអសញ្ញសត្វ ១ ក្នុងនេវសញ្ញានាសញ្ញាយតនភព ១ ។

---

# គិហិអរហាតិកថា

[៤២២] គ្រហស្ថ បានជាព្រះអរហន្តដែរឬ ។ អើ ។ សញ្ញោជនៈនៃគ្រហស្ថ របស់ព្រះអរហន្ត មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ សញ្ញោជនៈនៃគ្រហស្ថ របស់ព្រះអរហន្ត មិនមានទេឬ ។ អើ ។ បើសញ្ញោជនៈនៃគ្រហស្ថ របស់ព្រះអរហន្ត មិនមានទេ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា គ្រហស្ថ បានជាព្រះអរហន្តទេ ។

[៤២៣] គ្រហស្ថ បានជាព្រះអរហន្តដែរឬ ។ អើ ។ ក្រែងសញ្ញោជនៈនៃគ្រហស្ថ ព្រះអរហន្ត បានលះបង់ហើយ មានឫសគល់

### គិហិស្ស អរហាតិកថា

តាលាវត្ថុកតំ អនភាវង្កតំ អាយតឹអនុប្បាទធម្មន្តិ ។ អាមន្តា ។ ហញ្ចិ អរហតោ គិហិសញ្ញោជនំ បហីនំ ឧច្ឆិន្នមូលំ តាលាវត្ថុកតំ អនភាវង្កតំ អាយតឹអនុប្បា-ទធម្មំ នោ វត រេ វត្តព្វេ គិហិស្ស អរហាតិ ។

[៤២៤] គិហិស្ស អរហាតិ ។ អាមន្តា ។ អត្ថិ កោចិ គិហី គិហិសញ្ញោជនំ អប្បហាយ ទិដ្ឋេវ ធម្មេ ទុក្ខស្សន្តករោតិ ។ នត្ថិ ។ ហញ្ចិ នត្ថិ កោចិ គិហី គិហិសញ្ញោជនំ អប្បហាយ ទិដ្ឋេវ ធម្មេ ទុក្ខស្សន្តករោ នោ វត រេ វត្តព្វេ គិហិស្ស អរហាតិ ។

[៤២៥] គិហិស្ស អរហាតិ ។ អាមន្តា ។ ននុ វច្ឆគោត្តោ បរិព្វាជកោ ភគវន្តំ ឯតទវោច អត្ថិ នុ ខោ ភោ គោតម កោចិ គិហី គិហិសញ្ញោជនំ អប្បហាយ កាយស្ស ភេទា ទុក្ខស្សន្តករោតិ នត្ថិ ខោ វច្ឆ កោចិ គិហី គិហិសញ្ញោជនំ អប្បហាយ កាយស្ស ភេទា ទុក្ខស្សន្តករោតិ អត្ថេវ សុត្តន្តោតិ ។

ផ្តាច់ហើយ ធ្វើឲ្យសល់តែទីនៅដូចជាទីនៅនៃដើមត្នោត ធ្វើមិនឲ្យមានបែបភាព ឲ្យជាធម៌លែងកើតតទៅទៀតឬ ។ អើ ។ បើសញ្ញោជនៈនៃគ្រហស្ថ ព្រះអរហន្ត បានលះបង់ហើយ មានឫសគល់ផ្តាច់ហើយ ធ្វើឲ្យសល់តែទីនៅដូចជាទីនៅនៃដើមត្នោត ធ្វើមិនឲ្យមានបែបភាព ឲ្យជាធម៌លែងកើតតទៅទៀត ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា គ្រហស្ថ បានជាព្រះអរហន្តទេ ។

[៤២៤] គ្រហស្ថ បានជាព្រះអរហន្តដែរឬ ។ អើ ។ គ្រហស្ថណាមួយ មិនទាន់លះសញ្ញោជនៈនៃគ្រហស្ថ ហើយធ្វើនូវទីបំផុតនៃទុក្ខក្នុងបច្ចុប្បន្ន មានដែរឬ ។ មិនមានទេ ។ បើគ្រហស្ថណាមួយ មិនទាន់លះសញ្ញោជនៈនៃគ្រហស្ថ ហើយធ្វើនូវទីបំផុតនៃទុក្ខក្នុងបច្ចុប្បន្ន មិនមានទេ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា គ្រហស្ថ បានជាព្រះអរហន្តទេ ។

[៤២៥] គ្រហស្ថ បានជាព្រះអរហន្តដែរឬ ។ អើ ។ ក្រែងវច្ឆគោត្តបរិព្វាជក បានក្រាបបង្គំទូលសួរព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះគោតមដ៏ចម្រើន គ្រហស្ថណាមួយ មិនទាន់លះសញ្ញោជនៈរបស់គ្រហស្ថ លុះបែកធ្លាយរាងកាយ ហើយធ្វើនូវទីបំផុតនៃទុក្ខ មានដែរឬ (ព្រះមានព្រះភាគ ទ្រង់ត្រាស់ថា) ម្នាលវច្ឆៈ គ្រហស្ថណាមួយ មិនទាន់លះសញ្ញោជនៈរបស់គ្រហស្ថ លុះបែកធ្លាយរាងកាយ ហើយធ្វើនូវទីបំផុតនៃទុក្ខ មិនមានទេ ពាក្យដូច្នេះ មានក្នុងព្រះសូត្រឬ ។

អាមន្តា ។ តេន ហិ ន វត្តព្វំ គិហិស្ស អរហាតិ ។

[៤២៦] គិហិស្ស អរហាតិ ។ អាមន្តា ។ អរហា មេថុនំ ធម្មំ បដិសេវេយ្យ មេថុនំ ធម្មំ ឧប្បាទេយ្យ បុត្តសម្ពាធសយនំ អជ្ឈាវសេយ្យ កាសិកចន្ទនំ បច្ចនុភវេយ្យ មាលាគន្ធវិលេបនំ ធារេយ្យ ជាតរូបរជតំ សាទិយេយ្យ អជេឡកំ បដិគ្គណ្ហេយ្យ កុក្កុដសូករំ បដិគ្គណ្ហេយ្យ ហត្ថិគវាស្សវឡវំ បដិគ្គណ្ហេយ្យ តិត្តិរវដ្ដកមោរកបិញ្ជលំ បដិគ្គណ្ហេយ្យ បីតវណ្ណវាលមោលិកំ ធារេយ្យ ឱទាតានិ វត្ថានិ ទីឃទសានិ ធារេយ្យ យាវជីវំ អគារិយភូតោ អស្សាតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[៤២៧] ន វត្តព្វំ គិហិស្ស អរហាតិ ។ អាមន្តា ។ ននុ យសោ កុលបុត្តោ ឧត្តិយោ គហបតិ សេតុ មាណវោ គិហិស្ស ព្យញ្ជនេន អរហត្តំ បត្តាតិ ។ អាមន្តា ។ ហញ្ចិ យសោ កុលបុត្តោ ឧត្តិយោ គហបតិ សេតុ មាណវោ គិហិស្ស ព្យញ្ជនេន អរហត្តំ បត្តា តេន វត រេ វត្តព្វេ គិហិស្ស អរហាតិ ។

គិហិស្ស អរហាតិកថា ។

អើ ។ ព្រោះហេតុនោះ អ្នកមិនគួរពោលថា គ្រហស្ថ បានជាព្រះអរហន្តទេ ។

[៤២៦] គ្រហស្ថ បានជាព្រះអរហន្តដែរឬ ។ អើ ។ ព្រះអរហន្ត សេពមេថុនធម្ម ញុំាងមេថុនធម្មឲ្យកើតឡើង នៅគ្រប់គ្រងដំណេកដែលចង្អៀតដោយកូន លាបពព្រោះព្រំខ្លឹមចន្ទន៍ដ៏ឧត្តម ទ្រទ្រង់ផ្កាកម្រង គ្រឿងក្រអូប និងគ្រឿងលាប ត្រេកអរចំពោះមាសនិងប្រាក់ ទទួលពពែនិងចៀម ទទួលមាន់និងជ្រូក ទទួលដំរី គោ សេះឈ្មោល សេះញី ទទួលទទា ក្រួច ក្ងោក ចចាត ទ្រទ្រង់ផ្នួងសក់ដែលមានទង មានពណ៌លឿង ទ្រទ្រង់សំពត់សមានជាយវែង នៅជាគ្រហស្ថ ដរាបអស់មួយជីវិតដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[៤២៧] បុគ្គលមិនគួរនិយាយថា គ្រហស្ថ បានជាព្រះអរហន្តទេឬ ។ អើ ។ ក្រែងយសកុលបុត្រ ឧត្តិយគហបតី និងសេតុមាណពដល់នូវព្រះអរហត្ត ដោយភេទនៃគ្រហស្ថឬ ។ អើ ។ បើ យស-កុលបុត្រ ឧត្តិយគហបតិ និងសេតុមាណព ដល់នូវព្រះអរហត្ត ដោយភេទនៃគ្រហស្ថមែន ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគួរពោលថា គ្រហស្ថ បានជាព្រះអរហន្តដែរ ។

ចប់ គិហិអរហាតិកថា ។

១៦៧

# ឧបបត្តិកថា

[៤២៨] សហ ឧបបត្តិយា អរហាតិ ។ អា-
មន្តា ។ សហ ឧបបត្តិយា សោតាបន្នោ ហោតីតិ ។
ន ហេវំ វត្តព្វេ ។ បេ ។

[៤២៩] សហ ឧបបត្តិយា អរហាតិ ។ អា-
មន្តា ។ សហ ឧបបត្តិយា សកទាគាមី ហោតីតិ ។
ន ហេវំ វត្តព្វេ ។ បេ ។

[៤៣០] សហ ឧបបត្តិយា អរហាតិ ។ អា-
មន្តា ។ សហ ឧបបត្តិយា អនាគាមី ហោតីតិ ។
ន ហេវំ វត្តព្វេ ។ បេ ។

[៤៣១] សហ ឧបបត្តិយា សោតាបន្នោ ន
ហោតីតិ ។ អាមន្តា ។ ហញ្ចិ សហ ឧបបត្តិយា
សោតាបន្នោ ន ហោតិ នោ វត រេ វត្តព្វេ សហ
ឧបបត្តិយា អរហាតិ ។

# ឧបបត្តិកថា

[៤២៨] បុគ្គល បានជាព្រះអរហន្ត ជាមួយគ្នានឹងការកើតឡើង[១]ឬ ។ អើ ។ បុគ្គល បានជាសោតាបន្ន: ជាមួយគ្នានឹងការកើតឡើង[២]ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[៤២៩] បុគ្គល បានជាព្រះអរហន្ត ជាមួយគ្នានឹងការកើតឡើងឬ ។ អើ ។ បុគ្គល បានជាសកទាគាមី ជាមួយគ្នានឹងការកើតឡើងឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[៤៣០] បុគ្គល បានជាព្រះអរហន្ត ជាមួយគ្នានឹងការកើតឡើងឬ ។ អើ ។ បុគ្គល បានជាអនាគាមី ជាមួយគ្នានឹងការកើតឡើងឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[៤៣១] បុគ្គល បានជាសោតាបន្ន: មិនមានជាមួយគ្នានឹងការកើតឡើងទេឬ ។ អើ ។ បើបុគ្គល បានជាសោតាបន្ន: មិនមានជាមួយគ្នានឹងការកើតឡើងទេ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា បុគ្គល បានជាព្រះអរហន្ត ជាមួយគ្នានឹងការកើតឡើងទេ ។

---

១ សំដៅយកបុគ្គល ដែលកើតក្នុងសុទ្ធាវាស បានសម្រេចជាអរហន្ត ដំណាលគ្នា នឹងការកើតឡើងឬ ?

២ សំដៅយក ឧបបត្តិចិត្ត (ចិត្តកើតឡើងជាលោកិយៈ) ។

[៤៣២] សហ ឧបបត្តិយា សកទាគាមី ន ហោតីតិ ។ អាមន្តា ។ ហញ្ចិ សហ ឧបបត្តិយា សកទាគាមី ន ហោតិ នោ វត រេ វត្តព្វេ សហ ឧបបត្តិយា អរហាតិ ។

[៤៣៣] សហ ឧបបត្តិយា អនាគាមី ន ហោតីតិ ។ អាមន្តា ។ ហញ្ចិ សហ ឧបបត្តិយា អនាគាមី ន ហោតិ នោ វត រេ វត្តព្វេ សហ ឧបបត្តិយា អរហាតិ ។

[៤៣៤] សហ ឧបបត្តិយា អរហាតិ ។ អាមន្តា ។ សារីបុត្តោ ថេរោ សហ ឧបបត្តិយា អរហាតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ មហាមោគ្គល្លានោ ថេរោ ។ បេ ។ មហាកស្សបោ ថេរោ ។ បេ ។ មហាកច្ចាយនោ ថេរោ ។ បេ ។ មហាកោដ្ឋិកោ ថេរោ ។ បេ ។ មហាបណ្ឌកោ ថេរោ សហ ឧបបត្តិយា អរហាតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[៤៣៥] សារីបុត្តោ ថេរោ ន សហ ឧបបត្តិយា អរហាតិ ។ អាមន្តា ។ ហញ្ចិ សារីបុត្តោ ថេរោ ន សហ ឧបបត្តិយា អរហា នោ វត រេ

[៤៣២] បុគ្គល បានជាសកទាគាមី មិនមានជាមួយគ្នានឹងការកើតឡើងទេឬ ។ អើ ។ បើបុគ្គល បានជាសកទាគាមី មិនមានជាមួយគ្នានឹងការកើតឡើងទេ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា បុគ្គល បានជាព្រះអរហន្ត ជាមួយគ្នានឹងការកើតឡើងទេ ។

[៤៣៣] បុគ្គល បានជាអនាគាមី មិនមានជាមួយគ្នានឹងការកើតឡើងទេឬ ។ អើ ។ បើបុគ្គល បានជាអនាគាមី មិនមានជាមួយគ្នានឹងការកើតឡើងទេ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា បុគ្គល បានជាព្រះអរហន្ត ជាមួយគ្នានឹងការកើតឡើងទេ ។

[៤៣៤] បុគ្គល បានជាព្រះអរហន្ត ជាមួយគ្នានឹងការកើតឡើងឬ ។ អើ ។ ព្រះសារីបុត្តត្ថេរ បានជាព្រះអរហន្ត ជាមួយគ្នានឹងការកើតឡើងឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ ព្រះមោគ្គ-ល្លានត្ថេរ ។ បេ ។ ព្រះមហាកស្សបត្ថេរ ។ បេ ។ ព្រះមហាកច្ចា-យនត្ថេរ ។ បេ ។ ព្រះមហាកោដ្ឋិកត្ថេរ ។ បេ ។ ព្រះមហាបណ្ឌ-កត្ថេរ បានជាព្រះអរហន្ត ជាមួយគ្នានឹងការកើតឡើងឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[៤៣៥] ព្រះសារីបុត្តត្ថេរ មិនមែនបានជាព្រះអរហន្ត ជាមួយគ្នានឹងការកើតឡើងទេឬ ។ អើ ។ បើព្រះសារីបុត្តត្ថេរ មិនមែនបានជាព្រះអរហន្ត ជាមួយគ្នានឹងការកើតឡើងទេ ម្នាលអ្នកដ៏ចម្រើន

វត្តព្វំ សហ ឧបបត្តិយា អរហាតិ ។

[៤៣៦] មហាមោគ្គល្លានោ ថេរោ ។ បេ ។ មហាកស្សបោ ថេរោ មហាកច្ចាយនោ ថេរោ មហាកោដ្ឋិកោ ថេរោ ។ បេ ។

[៤៣៧] មហាបណ្ឌកោ ថេរោ ន សហ ឧបបត្តិយា អរហាតិ ។ អាមន្តា ។ ហញ្ចិ មហា-បណ្ឌកោ ថេរោ ន សហ ឧបបត្តិយា អរហា នោ វត រេ វត្តព្វំ សហ ឧបបត្តិយា អរហាតិ ។

[៤៣៨] សហ ឧបបត្តិយា អរហាតិ ។ អា-មន្តា ។ ឧបបត្តេសិយេន ចិត្តេន អរហត្តំ សច្ឆិក-រោតិ លោកិយេន សាសវេន ។ បេ ។ សង្កិលេ-សិកេនាតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[៤៣៩] សហ ឧបបត្តិយា អរហាតិ ។ អា-មន្តា ។ ឧបបត្តេសិយំ ចិត្តំ និយ្យានិកំ ខយគាមិ ពោធគាមិ អបចយគាមិ អនាសវំ ។ បេ ។ អសង្កិ-លេសិកន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។

*អ្នកមិនគួរពោលថា បុគ្គល បានជាព្រះអរហន្ត ជាមួយគ្នានឹងការកើតឡើងទេ ។*

[៤៣៦] *ព្រះមហាមោគ្គល្លានត្ថេរ ។ បេ ។ ព្រះមហាកស្សបត្ថេរ ព្រះមហាកច្ចាយនត្ថេរ ព្រះមហាកោដ្ឋិកត្ថេរ ។ បេ ។*

[៤៣៧] *ព្រះមហាបណ្ឌកត្ថេរ មិនមែនបានជាព្រះអរហន្ត ជាមួយគ្នានឹងការកើតឡើងទេឬ ។ អើ ។ បើព្រះមហាបណ្ឌកត្ថេរ មិនមែនបានជាព្រះអរហន្ត ជាមួយគ្នានឹងការកើតឡើងទេ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា បុគ្គល បានជាព្រះអរហន្ត ជាមួយគ្នានឹងការកើតឡើងទេ ។*

[៤៣៨] *បុគ្គល បានជាព្រះអរហន្ត ជាមួយគ្នានឹងការកើតឡើងឬ ។ អើ ។ បុគ្គលធ្វើឲ្យជាក់ច្បាស់ នូវព្រះអរហត្ត ដោយចិត្ត ដែលកំពុងស្វែងរកនូវការកើតឡើង* (បដិសន្ធិចិត្ត) *ជាលោកិយៈ ប្រកបដោយអាសវៈ ។ បេ ។ ប្រកបដោយសេចក្តីសៅហ្មងឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។*

[៤៣៩] *បុគ្គល បានជាព្រះអរហន្ត ជាមួយគ្នានឹងការកើតឡើងឬ ។ អើ ។ ចិត្ត ដែលកំពុងស្វែងរកនូវការកើតឡើង ជានិយ្យានិកៈ ដល់នូវការអស់ទៅ ដល់នូវការត្រាស់ដឹង ដល់នូវការមិនសន្សំ មិនមានអាសវៈ ។ បេ ។ មិនប្រកបដោយសេចក្តីសៅហ្មងទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។*

[៤៤០] ននុ ឧបបត្តេសិយំ ចិត្តំ អនិយ្យានិកំ ន ខយគាមិ ន ពោធគាមិ ន អបចយគាមិ សាសវំ ។ បេ ។ សង្កិលេសិកន្តិ ។ អាមន្តា ។ ហញ្ចិ ឧបបត្តេសិយំ ចិត្តំ អនិយ្យានិកំ ន ខយគាមិ ន ពោធគាមិ ន អបចយគាមិ សាសវំ ។ បេ ។ សង្កិលេសិកំ នោ វត រេ វត្តព្វេ សហ ឧបបត្តិយា អរហាតិ ។

[៤៤១] សហ ឧបបត្តិយា អរហាតិ ។ អាមន្តា ។ ឧបបត្តេសិយេន ចិត្តេន រាគំ បជហាតិ ទោសំ បជហាតិ មោហំ បជហាតិ ។ បេ ។ អនោត្តប្បំ បជហាតីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[៤៤២] សហ ឧបបត្តិយា អរហាតិ ។ អាមន្តា ។ ឧបបត្តេសិយំ ចិត្តំ មគ្គោ ។ បេ ។ សតិប្បដ្ឋានំ សម្មប្បធានំ ឥទ្ធិបាទោ ឥន្ទ្រិយំ ពលំ ។ បេ ។ ពោជ្ឈង្គោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[៤៤៣] សហ ឧបបត្តិយា អរហាតិ ។

[៤៤០] ក្រែងចិត្ត ដែលកំពុងស្វែងរកនូវការកើតឡើង មិនមែនជានិយ្យានិកៈ មិនដល់នូវការអស់ទៅ មិនដល់នូវការត្រាស់ដឹង មិនដល់នូវការមិនសន្សំ ប្រកបដោយអាសវៈ ។ បេ ។ ប្រកបដោយសេចក្តីសៅហ្មងឬ ។ អើ ។ បើចិត្ត ដែលកំពុងស្វែងរកនូវការកើតឡើង មិនមែនជានិយ្យានិកៈ មិនដល់នូវការអស់ទៅ មិនដល់នូវការត្រាស់ដឹង មិនដល់នូវការមិនសន្សំ ប្រកបដោយអាសវៈ ។ បេ ។ ប្រកបដោយសេចក្តីសៅហ្មង ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា បុគ្គល បានជាព្រះអរហន្ត ជាមួយគ្នានឹងការកើតឡើងទេ ។

[៤៤១] បុគ្គល បានជាព្រះអរហន្ត ជាមួយគ្នានឹងការកើតឡើងឬ ។ អើ ។ បុគ្គល លះរាគៈ លះទោសៈ លះមោហៈ ។ បេ ។ លះអនោត្តប្បៈ ដោយចិត្ត ដែលកំពុងស្វែងរកនូវការកើតឡើងឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[៤៤២] បុគ្គល បានជាព្រះអរហន្ត ជាមួយគ្នានឹងការកើតឡើងឬ ។ អើ ។ ចិត្ត ដែលកំពុងស្វែងរកនូវការកើតឡើង ជាមគ្គ ។ បេ ។ ជាសតិប្បដ្ឋាន ជាសម្មប្បធាន ជាឥទ្ធិបាទ ជាឥន្ទ្រិយ ជាពលៈ ។ បេ ។ ជាពោជ្ឈង្គៈឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[៤៤៣] បុគ្គល បានជាព្រះអរហន្ត ជាមួយគ្នានឹងការកើតឡើងឬ ។

អាមន្តា ។ ឧបបត្តេសិយេន ចិត្តេន ទុក្ខំ បរិជានាតិ សមុទយំ បជហាតិ និរោធំ សច្ឆិករោតិ មគ្គំ ភាវេ-
តីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[៤៤៤] សហ ឧបបត្តិយា អរហាតិ ។ អាម-
ន្តា ។ ចុតិចិត្តំ មគ្គចិត្តំ ឧបបត្តេសិយំ ចិត្តំ ផល-
ចិត្តន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។

ឧបបត្តិកថា ។

# អនាសវកថា

[៤៤៥] អរហតោ សព្វេ ធម្មា អនាសវាតិ ។ អាមន្តា ។ មគ្គោ ផលំ និព្វានំ សោតាបត្តិមគ្គោ សោតាបត្តិផលំ សកទាគាមិមគ្គោ សកទាគាមិផលំ អនាគាមិមគ្គោ អនាគាមិផលំ អរហត្តមគ្គោ អរហត្ត-
ផលំ សតិបដ្ឋានំ សម្មប្បធានំ ឥទ្ធិបាទោ ឥន្ទ្រិយំ ពលំ ពោជ្ឈង្គោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[៤៤៦] អរហតោ សព្វេ ធម្មា អនាសវាតិ ។ អាមន្តា ។ អរហតោ ចក្ខុំ អនាសវន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។ អរហតោ ចក្ខុំ អនាសវន្តិ ។

*អើ ។ បុគ្គល កំណត់ដឹងនូវទុក្ខសច្ច លះនូវសមុទយសច្ច ធ្វើឲ្យជាក់ច្បាស់នូវនិរោធសច្ច ចម្រើននូវមគ្គសច្ច ដោយចិត្ត ដែលកំពុងស្វែងរកនូវការកើតឡើងឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។*

*[៤៤៤] បុគ្គល បានជាព្រះអរហន្ត ជាមួយគ្នានឹងការកើតឡើងឬ ។ អើ ។ ចុតិចិត្ត មគ្គចិត្ត ចិត្តដែលកំពុងស្វែងរកនូវការកើតឡើងជាផលចិត្តឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។*

ចប់ ឧបបត្តិកថា ។

# អនាសវកថា

*[៤៤៥] ពួកធម៌ទាំងអស់ របស់ព្រះអរហន្ត មិនមានអាសវៈទេឬ ។ អើ ។ មគ្គ ផល និព្វាន សោតាបត្តិមគ្គ សោតាបត្តិផល សកទាគាមិមគ្គ សកទាគាមិផល អនាគាមិមគ្គ អនាគាមិផល អរហត្តមគ្គ អរហត្តផល សតិប្បដ្ឋាន សម្មប្បធាន ឥទ្ធិបាទ ឥន្ទ្រិយ ពលៈ ពោជ្ឈង្គៈ (របស់ព្រះអរហន្ត ជាធម៌មិនមានអាសវៈ) ទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។*

*[៤៤៦] ពួកធម៌ទាំងអស់ របស់ព្រះអរហន្ត មិនមានអាសវៈទេឬ ។ អើ ។ ចក្ខុ របស់ព្រះអរហន្ត មិនមានអាសវៈទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ចក្ខុ របស់ព្រះអរហន្ត មិនមានអាសវៈទេឬ ។*

អាមន្តា ។ មគ្គោ ផលំ និព្វានំ សោតាបត្តិមគ្គោ សោតាបត្តិផលំ ។ បេ ។ ពោជ្ឈង្គោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ អរហតោ សោតំ ។ បេ ។ អរហតោ ឃានំ ។ បេ ។ អរហតោ ជិវ្ហា ។ បេ ។ អរហតោ កាយោ អនាសវោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[៤៤៧] អរហតោ កាយោ អនាសវោតិ ។ អាមន្តា ។ មគ្គោ ផលំ និព្វានំ សោតាបត្តិមគ្គោ សោតាបត្តិផលំ ។ បេ ។ ពោជ្ឈង្គោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[៤៤៨] អរហតោ កាយោ អនាសវោតិ ។ អាមន្តា ។ អរហតោ កាយោ បគ្គហនិគ្គហុបគោ ឆេទនភេទនូបគោ កាកេហិ គិជ្ឈេហិ កុលលេហិ សាធារណោតិ ។ អាមន្តា ។ អនាសវោ ធម្មោ បគ្គហនិគ្គហុបគោ ឆេទនភេទនូបគោ កាកេហិ គិជ្ឈេហិ កុលលេហិ សាធារណោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[៤៤៩] អរហតោ កាយេ វិសំ កមេយ្យ សត្ថំ កមេយ្យ អគ្គិ កមេយ្យាតិ ។ អាមន្តា ។

អើ ។ មគ្គ ផល និព្វាន សោតាបត្តិមគ្គ សោតាបត្តិផល ។ បេ ។ ពោជ្ឈង្គៈ (របស់ព្រះអរហន្ត ជាធម៌មិនមានអាសវៈ)ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ ត្រចៀក របស់ព្រះអរហន្ត ។ បេ ។ ច្រមុះ របស់ព្រះអរហន្ត ។ បេ ។ អណ្តាត របស់ព្រះអរហន្ត ។ បេ ។ កាយ របស់ព្រះអរហន្ត មិនមានអាសវៈទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[៤៤៧] កាយ របស់ព្រះអរហន្ត មិនមានអាសវៈទេឬ ។ អើ ។ មគ្គ ផល និព្វាន សោតាបត្តិមគ្គ សោតាបត្តិផល ។ បេ ។ ពោជ្ឈង្គៈ (របស់ព្រះអរហន្ត ជាធម៌មិនមានអាសវៈ) ទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[៤៤៨] កាយ របស់ព្រះអរហន្ត មិនមានអាសវៈទេឬ ។ អើ ។ កាយ របស់ព្រះអរហន្ត គួរដល់នូវការផ្គងឡើងនិងការសង្កត់សង្កិន គួរដល់នូវការដាច់និងការបែកធ្លាយ ជាសាធារណៈ ដល់ពួកក្អែក ត្មាត ខ្វែងដែរឬ ។ អើ ។ ធម៌ មិនមានអាសវៈ គួរដល់នូវការផ្គងឡើងនិងការសង្កត់សង្កិន គួរដល់នូវការដាច់និងការបែកធ្លាយ ជាសាធារណៈ ដល់ពួកក្អែក ត្មាត ខ្វែងដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[៤៤៩] ថ្នាំពិស គួរចូលទៅ គ្រឿងសស្ត្រា គួរមុត ភ្លើង គួរឆេះ ចំពោះកាយ របស់ព្រះអរហន្តដែរឬ ។ អើ ។

១៧៣

## អនាសវកថា

អនាសវេ ធម្មេ វិសំ កាមេយ្យ សត្ថំ កាមេយ្យ អគ្គិ កាមេយ្យាតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[៦៨០] លព្ភា អរហតោ កាយោ អន្ទុពន្ធនេន ពន្ធិតុំ រជ្ជុពន្ធនេន ពន្ធិតុំ សង្ខលិកពន្ធនេន ពន្ធិតុំ គាមពន្ធនេន ពន្ធិតុំ និគមពន្ធនេន ពន្ធិតុំ នគរពន្ធនេន ពន្ធិតុំ ជនបទពន្ធនេន ពន្ធិតុំ កណ្ឋបញ្ចមេហិ ពន្ធនេហិ ពន្ធិតុន្តិ ។ អាមន្តា ។ លព្ភា អនាសវោ ធម្មោ អន្ទុពន្ធនេន ពន្ធិតុំ រជ្ជុពន្ធនេន ពន្ធិតុំ សង្ខលិកពន្ធនេន ពន្ធិតុំ គាមពន្ធនេន និគមពន្ធនេន នគរពន្ធនេន ជនបទពន្ធនេន កណ្ឋបញ្ចមេហិ ពន្ធនេហិ ពន្ធិតុន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[៦៨១] យទិ អរហា បុថុជ្ជនស្ស ចីវរំ ទេតិ អនាសវំ ហុត្វា សាសវំ ហោតីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ អនាសវំ ហុត្វា សាសវំ ហោតីតិ ។ អាមន្តា ។ តញ្ញេវ អនាសវំ តំ សាសវន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។ តញ្ញេវ អនាសវំ តំ សាសវន្តិ ។ អាមន្តា ។ មគ្គោ អនាសវោ ហុត្វា

ថ្នាំពិស គួរចូលទៅ គ្រឿងសស្ត្រា គួរមុត ភ្លើង គួរឆេះ ចំពោះធម៌ដែលមិនមានអាសវៈដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[៤៩០] កាយ របស់ព្រះអរហន្ត គួរដើម្បីជាប់ដោយចំណងគឺខ្នោះ ដើម្បីជាប់ដោយចំណងគឺខ្សែ ដើម្បីជាប់ដោយចំណងគឺច្រវាក់ ដើម្បីជាប់ដោយចំណងគឺស្រុក ដើម្បីជាប់ដោយចំណងគឺនិគម ដើម្បីជាប់ដោយចំណងគឺនគរ ដើម្បីជាប់ដោយចំណងគឺជនបទ ដើម្បីជាប់ដោយចំណងមានកជាគម្រប់ ៥ ដែរឬ ។ អើ ។ ធម៌ មិនមានអាសវៈ គួរដើម្បីជាប់ដោយចំណងគឺខ្នោះ ដើម្បីជាប់ដោយចំណងគឺខ្សែ ដើម្បីជាប់ដោយចំណងគឺច្រវាក់ ដោយចំណងគឺស្រុក ដោយចំណងគឺនិគម ដោយចំណងគឺនគរ ដោយចំណងគឺជនបទ ដើម្បីជាប់ដោយចំណងមានកជាគម្រប់ ៥ ដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[៤៩១] បើព្រះអរហន្ត ឲ្យចីវរដល់បុថុជ្ជន (ចីវរនោះ) ជាវត្ថុមិនមានអាសវៈ តែប្រកបដោយអាសវៈ មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ (ចីវរ) ជាវត្ថុមិនមានអាសវៈ តែប្រកបដោយអាសវៈ មានដែរឬ ។ អើ ។ ចីវរនោះឯង មិនមានអាសវៈទេ តែចីវរនោះ ប្រកបដោយអាសវៈ មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ ចីវរនោះ មិនមានអាសវៈទេ តែចីវរនោះ ប្រកបដោយអាសវៈ មានដែរឬ ។ អើ ។ មគ្គ ជាធម៌មិនមានអាសវៈ

សាសវោ ហោតីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ ផលំ សតិប្បដ្ឋានំ សម្មប្បធានំ ឥទ្ធិបាទោ ឥន្ទ្រិយំ ពលំ ពោជ្ឈង្គោ អនាសវោ ហុត្វា សាសវោ ហោតីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[៤៨២] យទិ អរហា បុថុជ្ជនស្ស បិណ្ឌបាតំ ទេតិ សេនាសនំ ទេតិ គិលានប្បច្ចយភេសជ្ជបរិក្ខារំ ទេតិ អនាសវោ ហុត្វា សាសវោ ហោតីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ អនាសវោ ហុត្វា សាសវោ ហោតីតិ ។ អាមន្តា ។ តញ្ញេវ អនាសវំ តំ សាសវន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។ តញ្ញេវ អនាសវំ តំ សាសវន្តិ ។ អាមន្តា ។ មគ្គោ អនាសវោ ហុត្វា សាសវោ ហោតីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ ផលំ សតិប្បដ្ឋានំ សម្មប្បធានំ ឥទ្ធិបាទោ ឥន្ទ្រិយំ ពលំ ពោជ្ឈង្គោ អនាសវោ ហុត្វា សាសវោ ហោតីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

តែប្រកបដោយអាសវៈ មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ ផល សតិប្បដ្ឋាន សម្មប្បធាន ឥទ្ធិបាទ ឥន្ទ្រិយ ពលៈ ពោជ្ឈង្គៈ ជាធម៌មិនមានអាសវៈ តែប្រកបដោយអាសវៈ មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[៤៥២] បើព្រះអរហន្ត ឲ្យបិណ្ឌបាត ឲ្យទីសេនាសនៈ ឲ្យគិលានប្បច្ចយភេសជ្ជបរិក្ខារ ដល់បុថុជ្ជន (បច្ច័យមានបិណ្ឌបាតជាដើមនោះ) ជាសភាពមិនមានអាសវៈ តែប្រកបដោយអាសវៈ មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ (បច្ច័យមានបិណ្ឌបាតជាដើមនោះ) ជាសភាពមិនមានអាសវៈ តែប្រកបដោយអាសវៈ មានដែរឬ ។ អើ ។ បច្ច័យមានបិណ្ឌបាតជាដើមនោះឯង មិនមានអាសវៈទេ តែបច្ច័យមានបិណ្ឌបាតជាដើមនោះ ប្រកបដោយអាសវៈ មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ បច្ច័យមានបិណ្ឌបាតជាដើមនោះឯង មិនមានអាសវៈទេ តែបច្ច័យមានបិណ្ឌបាតជាដើមនោះ ប្រកបដោយអាសវៈ មានដែរឬ ។ អើ ។ មគ្គ ជាធម៌មិនមានអាសវៈ តែប្រកបដោយអាសវៈ មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ ផល សតិប្បដ្ឋាន សម្មប្បធាន ឥទ្ធិបាទ ឥន្ទ្រិយ ពលៈ ពោជ្ឈង្គៈ ជាធម៌មិនមានអាសវៈ តែប្រកបដោយអាសវៈ មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

អនាសវកថា

[៤៩៣] យទិ បុថុជ្ជនោ អរហតោ ចីវរំ ទេតិ សា-សវំ ហុត្វា អនាសវំ ហោតីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[៤៩៤] សាសវំ ហុត្វា អនាសវំ ហោតីតិ ។ អាមន្តា ។ តញ្ញេវ សាសវំ តំ អនាសវន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។ តញ្ញេវ សាសវំ តំ អនាស-វន្តិ ។ អាមន្តា ។ រាគោ សាសវោ ហុត្វា អនាសវោ ហោតីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ ទោសោ មោ-ហោ ។ បេ ។ អនោត្តប្បំ សាសវំ ហុត្វា អនាសវំ ហោតីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[៤៩៥] យទិ បុថុជ្ជនោ អរហតោ បិណ្ឌបាតំ ទេតិ សេនាសនំ ទេតិ គិលានប្បច្ចយភេសជ្ជបរិក្ខារំ ទេតិ សាសវោ ហុត្វា អនាសវោ ហោតីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[៤៩៦] សាសវោ ហុត្វា អនាសវោ ហោតីតិ ។

អនាសវកថា

[៤៥៣] បើបុថុជ្ជន ឲ្យចីវរដល់ព្រះអរហន្ត (ចីវរនោះ) ជាវត្ថុប្រកបដោយអាសវៈ តែមិនមានអាសវៈ មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[៤៥៤] (ចីវរ) ជាវត្ថុប្រកបដោយអាសវៈ តែមិនមានអាសវៈ មានដែរឬ ។ អើ ។ ចីវរនោះឯង ប្រកបដោយអាសវៈ តែចីវរនោះមិនមានអាសវៈ មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ ចីវរនោះឯង ប្រកបដោយអាសវៈ តែចីវរនោះ មិនមានអាសវៈ មានដែរឬ ។ អើ ។ រាគៈ ជាធម៌ប្រកបដោយអាសវៈ តែមិនមានអាសវៈ មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ ទោសៈ មោហៈ ។ បេ ។ អនោត្តប្បៈ ជាធម៌ប្រកបដោយអាសវៈ តែមិនមានអាសវៈ មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[៤៥៥] បើបុថុជ្ជន ឲ្យបិណ្ឌបាត ឲ្យសេនាសនៈ ឲ្យគិលានប្បច្ចយភេសជ្ជបរិក្ខារ ដល់ព្រះអរហន្ត (បច្ច័យមានបិណ្ឌបាតជាដើមនោះ) ជាសភាពប្រកបដោយអាសវៈ តែមិនមានអាសវៈ មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[៤៥៦] (បច្ច័យមានបិណ្ឌបាតជាដើមនោះ) ជាសភាពប្រកបដោយអាសវៈ តែមិនមានអាសវៈ មានដែរឬ ។

អាមន្តា ។ តញ្ញេវ សាសវំ តំ អនាសវន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។ តញ្ញេវ សាសវំ តំ អនាសវន្តិ ។ អាមន្តា ។ រាគោ សាសវោ ហុត្វា អនាសវោ ហោតីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ ទោសោ ។ បេ ។ មោហោ ។ បេ ។ អនោត្តប្បំ សាសវំ ហុត្វា អនាសវំ ហោតីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[៤៩៧] ន វត្តព្វំ អរហតោ សព្វេ ធម្មា អនាសវាតិ ។ អាមន្តា ។ ននុ អរហា អនាសវោតិ ។ អាមន្តា ។ ហញ្ចិ អរហា អនាសវោ តេន វត រេ វត្តព្វេ អរហតោ សព្វេ ធម្មា អនាសវាតិ ។

អនាសវកថា ។

# សមន្នាគតកថា

[៤៩៨] អរហា ចតូហិ ផលេហិ សមន្នាគតោតិ ។ អាមន្តា ។ អរហា ចតូហិ ផស្សេហិ ចតូហិ វេទនាហិ ចតូហិ សញ្ញាហិ ចតូហិ ចេតនាហិ ចតូហិ ចិត្តេហិ ចតូហិ សទ្ធាហិ ចតូហិ វីរិយេហិ

អើ ។ បច្ច័យមានបិណ្ឌបាតជាដើមនោះ ប្រកបដោយអាសវៈ តែបច្ច័យមានបិណ្ឌបាតជាដើមនោះ មិនមានអាសវៈ មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ បច្ច័យមានបិណ្ឌបាតជាដើមនោះឯង ប្រកបដោយអាសវៈ តែបច្ច័យមានបិណ្ឌបាតជាដើមនោះ មិនមានអាសវៈ មានដែរឬ ។ អើ ។ រាគៈ ប្រកបដោយអាសវៈ តែមិនមានអាសវៈ មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ ទោសៈ ។ បេ ។ មោហៈ ។ បេ ។ អនោត្តប្បៈ ប្រកបដោយអាសវៈ តែមិនមានអាសវៈ មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[៤៥៧] បុគ្គលមិនគួរនិយាយថា ពួកធម៌ទាំងអស់ របស់ព្រះអរហន្ត មិនមានអាសវៈទេឬ ។ អើ ។ ក្រែងព្រះអរហន្ត មិនមានអាសវៈទេឬ ។ អើ ។ បើព្រះអរហន្ត មិនមានអាសវៈទេ ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគួរពោលថា ពួកធម៌ទាំងអស់ របស់ព្រះអរហន្ត មិនមានអាសវៈទេ ។

ចប់ អនាសវកថា ។

# សមន្នាគតកថា

[៤៥៨] ព្រះអរហន្ត ប្រកបដោយផល ៤ ឬ ។ អើ ។ ព្រះអរហន្ត ប្រកបដោយផស្សៈ ៤ ដោយវេទនា ៤ ដោយសញ្ញា ៤ ដោយចេតនា ៤ ដោយចិត្ត ៤ ដោយសទ្ធា ៤ ដោយវីរិយៈ ៤

ចតូហិ សតីហិ ចតូហិ សមាធីហិ ចតូហិ បញ្ញាហិ សមន្នាគតោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[៤៥៩] អនាគាមី តីហិ ផលេហិ សមន្នាគតោតិ ។ អាមន្តា ។ អនាគាមី តីហិ ផស្សេហិ ។ បេ ។ តីហិ បញ្ញាហិ សមន្នាគតោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[៤៦០] សកទាគាមី ទ្វីហិ ផលេហិ សមន្នាគតោតិ ។ អាមន្តា ។ សកទាគាមី ទ្វីហិ ផស្សេហិ ។ បេ ។ ទ្វីហិ បញ្ញាហិ សមន្នាគតោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[៤៦១] អរហា សោតាបត្តិផលេន សមន្នាគតោតិ ។ អាមន្តា ។ អរហា សោតាបន្នោ សត្តក្ខត្តុំបរមោ កោលំកោលោ ឯកពីជីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ អរហា សកទាគាមិផលេន សមន្នាគតោតិ ។ អាមន្តា ។ អរហា សកទាគាមីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ អរហា អនាគាមិផលេន សមន្នាគតោតិ ។ អាមន្តា ។ អរហា អនាគាមី អន្តរាបរិនិព្វាយី ឧបហច្ចបរិនិព្វាយី អសង្ខារបរិនិព្វាយី សសង្ខារបរិនិព្វាយី ឧទ្ធំសោតោ អកនិដ្ឋគាមីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

ដោយសតិ ៤ ដោយសមាធិ ៤ ដោយបញ្ញា ៤ ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[៤៥៩] អនាគាមិបុគ្គល ប្រកបដោយផល ៣ ឬ ។ អើ ។ អនាគាមិបុគ្គល ប្រកបដោយផស្សៈ ៣ ។ បេ ។ ដោយបញ្ញា ៣ ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[៤៦០] សកទាគាមិបុគ្គល ប្រកបដោយផល ២ ឬ ។ អើ ។ សកទាគាមិបុគ្គល ប្រកបដោយផស្សៈ ២ ។ បេ ។ ដោយបញ្ញា ២ ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[៤៦១] ព្រះអរហន្ត ប្រកបដោយសោតាបត្តិផលឬ ។ អើ ។ ព្រះអរហន្ត ជាសោតាបន្នបុគ្គល គឺសត្តក្ខត្តុំបរមៈ កោលំកោលៈ ឯកពីជីឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ ព្រះអរហន្ត ប្រកបដោយសកទាគាមិផលឬ ។ អើ ។ ព្រះអរហន្ត ជាសកទាគាមិបុគ្គលឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ ព្រះអរហន្ត ប្រកបដោយអនាគាមិផលឬ ។ អើ ។ ព្រះអរហន្ត ជាអនាគាមិបុគ្គល គឺអន្តរាបរិនិព្វាយី ឧបហច្ចបរិនិព្វាយី អសង្ខារបរិនិព្វាយី សសង្ខារបរិនិព្វាយី ឧទ្ធំសោតៈ អកនិដ្ឋគាមីឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[៤៦២] អជាតាមី សោតាបត្តិផលេន សមន្នាគតោតិ ។ អាមន្តា ។ អជាតាមី សោតាបន្នោ សត្តក្ខត្តុំបរមោ កោលំកោលោ ឯកពីជីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ អជាតាមី សកទាគាមិផលេន សមន្នាគតោតិ ។ អាមន្តា ។ អជាតាមី សកទាគាមីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[៤៦៣] សកទាគាមី សោតាបត្តិផលេន សមន្នាគតោតិ ។ អាមន្តា ។ សកទាគាមី សោតាបន្នោ សត្តក្ខត្តុំបរមោ កោលំកោលោ ឯកពីជីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[៤៦៤] សោតាបត្តិផលេន សមន្នាគតោ សោតាបន្នោតិ វត្តព្វោតិ ។ អាមន្តា ។ អរហា សោតាបត្តិផលេន សមន្នាគតោតិ ។ អាមន្តា ។ ស្វេវ អរហា សោ សោតាបន្នោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[៤៦៥] សកទាគាមិផលេន សមន្នាគតោ សកទាគាមីតិ វត្តព្វោតិ ។ អាមន្តា ។ អរហា សកទាគាមិផលេន សមន្នាគតោតិ ។ អាមន្តា ។ ស្វេវ អរហា សោ សកទាគាមីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[៤៦២] អនាគាមិបុគ្គល ប្រកបដោយសោតាបត្តិផលឬ ។ អើ ។ អនាគាមិបុគ្គល ជាសោតាបន្នបុគ្គល គឺសត្តក្ខត្តុំបរមៈ កោលំកោលៈ ឯកពីជីឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ អនាគាមិបុគ្គល ប្រកបដោយសកទាគាមិផលឬ ។ អើ ។ អនាគាមិបុគ្គល ជាសកទាគាមិបុគ្គលឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[៤៦៣] សកទាគាមិបុគ្គល ប្រកបដោយសោតាបត្តិផលឬ ។ អើ ។ សកទាគាមិបុគ្គល ជាសោតាបន្នបុគ្គល គឺសត្តក្ខត្តុំបរមៈ កោលំកោលៈ ឯកពីជីឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[៤៦៤] បុគ្គល ប្រកបដោយសោតាបត្តិផល គួរនិយាយថា សោតាបន្នបុគ្គលឬ ។ អើ ។ ព្រះអរហន្ត ប្រកបដោយសោតាបត្តិផល ឬ ។ អើ ។ ព្រះអរហន្តនោះឯង គឺសោតាបន្នបុគ្គលនោះឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[៤៦៥] បុគ្គល ប្រកបដោយសកទាគាមិផល គួរនិយាយថា សកទាគាមិបុគ្គលឬ ។ អើ ។ ព្រះអរហន្ត ប្រកបដោយសកទាគាមិផលឬ ។ អើ ។ ព្រះអរហន្តនោះឯង គឺសកទាគាមិបុគ្គលនោះឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[៤៦៦] អជាតាមិផលេន សមន្នាគតោ អជា-
តាមីតិ ។ វត្តព្វោតិ ។ អាមន្តា ។ អរហា អជាតាមិ-
ផលេន សមន្នាគតោតិ ។ អាមន្តា ។ ស្វេវ អរហា
សោ អជាតាមីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[៤៦៧] សោតាបត្តិផលេន សមន្នាគតោ សោ-
តាបន្នោតិ វត្តព្វោតិ ។ អាមន្តា ។ អជាតាមី សោតា-
បត្តិផលេន សមន្នាគតោតិ ។ អាមន្តា ។ ស្វេវ អជា-
តាមី សោ សោតាបន្នោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[៤៦៨] សកទាគាមិផលេន សមន្នាគតោ ស-
កទាគាមីតិ វត្តព្វោតិ ។ អាមន្តា ។ អជាតាមី
សកទាគាមិផលេន សមន្នាគតោតិ ។ អាមន្តា ។
ស្វេវ អជាតាមី សោ សកទាគាមីតិ ។ ន ហេវំ
វត្តព្វេ ។ បេ ។

[៤៦៩] សោតាបត្តិផលេន សមន្នាគតោ សោ-
តាបន្នោតិ វត្តព្វោតិ ។ អាមន្តា ។ សកទាគាមី
សោតាបត្តិផលេន សមន្នាគតោតិ ។ អាមន្តា ។
ស្វេវ សកទាគាមី សោ សោតាបន្នោតិ ។ ន ហេវំ
វត្តព្វេ ។ បេ ។

សមន្នាគតកថា

[៤៦៦] បុគ្គល ប្រកបដោយអនាគាមិផល គួរនិយាយថា អនាគាមិបុគ្គលឬ ។ អើ ។ ព្រះអរហន្ត ប្រកបដោយអនាគាមិផល ឬ ។ អើ ។ ព្រះអរហន្តនោះឯង គឺអនាគាមិបុគ្គលនោះឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[៤៦៧] បុគ្គល ប្រកបដោយសោតាបត្តិផល គួរនិយាយថា សោតាបន្នបុគ្គលឬ ។ អើ ។ អនាគាមិបុគ្គល ប្រកបដោយសោ-តាបត្តិផលឬ ។ អើ ។ អនាគាមិបុគ្គលនោះឯង គឺសោតាបន្ន-បុគ្គលនោះឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[៤៦៨] បុគ្គល ប្រកបដោយសកទាគាមិផល គួរនិយាយថា សកទាគាមិបុគ្គលឬ ។ អើ ។ អនាគាមិបុគ្គល ប្រកបដោយសកទាគា-មិផលឬ ។ អើ ។ អនាគាមិបុគ្គលនោះឯង គឺសកទាគាមិបុគ្គលនោះ ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[៤៦៩] បុគ្គល ប្រកបដោយសោតាបត្តិផល គួរនិយាយថា សោតាបន្នបុគ្គលឬ ។ អើ ។ សកទាគាមិបុគ្គល ប្រកបដោយសោតា-បត្តិផលឬ ។ អើ ។ សកទាគាមិបុគ្គលនោះឯង គឺសោតាបន្នបុគ្គល នោះឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[៤៧០] អរហា សោតាបត្តិផលេន សមន្នាគតោតិ ។ អាមន្តា ។ ននុ អរហា សោតាបត្តិផលំ វីតិវត្តោតិ ។ អាមន្តា ។ ហញ្ចិ អរហា សោតាបត្តិផលំ វីតិវត្តោ នោ វត រេ វត្តព្វេ អរហា សោតាបត្តិផលេន សមន្នាគតោតិ ។

[៤៧១] អរហា សោតាបត្តិផលំ វីតិវត្តោ តេន សមន្នាគតោតិ ។ អាមន្តា ។ អរហា សោតាបត្តិមគ្គំ វីតិវត្តោ សក្កាយទិដ្ឋឹ វិចិកិច្ឆំ សីលព្វតបរាមាសំ អបាយគមនិយំ រាគំ អបាយគមនិយំ ទោសំ អបាយគមនិយំ មោហំ វីតិវត្តោ តេន សមន្នាគតោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[៤៧២] អរហា សកទាគាមិផលេន សមន្នាគតោតិ ។ អាមន្តា ។ ននុ អរហា សកទាគាមិផលំ វីតិវត្តោតិ ។ អាមន្តា ។ ហញ្ចិ អរហា សកទាគាមិផលំ វីតិវត្តោ នោ វត រេ វត្តព្វេ អរហា សកទាគាមិផលេន សមន្នាគតោតិ ។

[៤៧០] ព្រះអរហន្ត ប្រកបដោយសោតាបត្តិផលឬ ។ អើ ។ ក្រែងព្រះអរហន្ត ប្រព្រឹត្តកន្លងនូវសោតាបត្តិផលហើយឬ ។ អើ ។ បើព្រះអរហន្ត ប្រព្រឹត្តកន្លងនូវសោតាបត្តិផលហើយ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា ព្រះអរហន្ត ប្រកបដោយសោតាបត្តិផលទេ ។

[៤៧១] ព្រះអរហន្ត ប្រព្រឹត្តកន្លងនូវសោតាបត្តិផលហើយ ប្រកបដោយសោតាបត្តិផលនោះឬ ។ អើ ។ ព្រះអរហន្ត ប្រព្រឹត្តកន្លងនូវសោតាបត្តិមគ្គ ប្រព្រឹត្តកន្លងនូវសក្កាយទិដ្ឋិ វិចិកិច្ឆា សីលព្វតបរាមាសៈ រាគៈ ដែលជាដំណើរទៅកាន់អបាយ ទោសៈ ដែលជាដំណើរទៅកាន់អបាយ និងមោហៈ ដែលជាដំណើរទៅកាន់អបាយ ហើយ ប្រកបដោយសោតាបត្តិមគ្គនោះឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[៤៧២] ព្រះអរហន្ត ប្រកបដោយសកទាគាមិផលឬ ។ អើ ។ ក្រែងព្រះអរហន្ត ប្រព្រឹត្តកន្លងនូវសកទាគាមិផលហើយឬ ។ អើ ។ បើព្រះអរហន្ត ប្រព្រឹត្តកន្លងនូវសកទាគាមិផលហើយ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា ព្រះអរហន្ត ប្រកបដោយសកទាគាមិផលទេ ។

១៨១

សមន្នាគតកថា

[៤៧៣] អរហា សកទាគាមិផលំ វីតិវត្តោ តេន សមន្នាគតោតិ ។ អាមន្តា ។ អរហា សកទាគាមិមគ្គំ វីតិវត្តោ ឱឡារិកំ កាមរាគំ ឱឡារិកំ ព្យាបាទំ វីតិ-វត្តោ តេន សមន្នាគតោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[៤៧៤] អរហា អនាគាមិផលេន សមន្នាគតោ-តិ ។ អាមន្តា ។ ននុ អរហា អនាគាមិផលំ វីតិវត្តោតិ ។ អាមន្តា ។ ហញ្ចិ អរហា អនាគាមិផលំ វីតិវត្តោ នោ វត រេ វត្តព្វេ អរហា អនាគាមិផលេន សមន្នាគតោតិ ។

[៤៧៥] អរហា អនាគាមិផលំ វីតិវត្តោ តេន សមន្នាគតោតិ ។ អាមន្តា ។ អរហា អនាគាមិមគ្គំ វីតិវត្តោ អណុសហគតំ កាមរាគំ អណុសហគតំ ព្យាបាទំ វីតិវត្តោ តេន សមន្នាគតោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[៤៧៦] អនាគាមី សោតាបត្តិផលេន សមន្នា-គតោតិ ។ អាមន្តា ។ ននុ អនាគាមី សោតាបត្តិផលំ វីតិវត្តោតិ ។ អាមន្តា ។ ហញ្ចិ អនាគាមី សោតាបត្តិ-ផលំ វីតិវត្តោ នោ វត រេ វត្តព្វេ អនាគាមី សោតា-បត្តិផលេន សមន្នាគតោតិ ។

[៤៧៣] ព្រះអរហន្ត ប្រព្រឹត្តកន្លងនូវសកទាគាមិផល ហើយប្រកបដោយសកទាគាមិផលនោះឬ ។ អើ ។ ព្រះអរហន្ត ប្រព្រឹត្តកន្លងនូវសកទាគាមិមគ្គ ប្រព្រឹត្តកន្លងនូវកាមរាគៈដ៏គ្រោតគ្រាត ព្យាបាទដ៏គ្រោតគ្រាត ហើយប្រកបដោយសកទាគាមិមគ្គនោះឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[៤៧៤] ព្រះអរហន្ត ប្រកបដោយអនាគាមិផលឬ ។ អើ ។ ក្រែងព្រះអរហន្ត ប្រព្រឹត្តកន្លងនូវអនាគាមិផលហើយឬ ។ អើ ។ បើព្រះអរហន្ត ប្រព្រឹត្តកន្លងនូវអនាគាមិផលហើយ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា ព្រះអរហន្ត ប្រកបដោយអនាគាមិផលទេ ។

[៤៧៥] ព្រះអរហន្ត ប្រព្រឹត្តកន្លងនូវអនាគាមិផល ហើយប្រកបដោយអនាគាមិផលនោះឬ ។ អើ ។ ព្រះអរហន្ត ប្រព្រឹត្តកន្លងនូវអនាគាមិមគ្គ ប្រព្រឹត្តកន្លងនូវកាមរាគៈដ៏ស្រាលស្ដើង ព្យាបាទដ៏ស្រាលស្ដើង ហើយប្រកបដោយអនាគាមិមគ្គនោះឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[៤៧៦] អនាគាមិបុគ្គល ប្រកបដោយសោតាបត្តិផលឬ ។ អើ ។ ក្រែងអនាគាមិបុគ្គល ប្រព្រឹត្តកន្លងនូវសោតាបត្តិផលហើយឬ ។ អើ ។ បើអនាគាមិបុគ្គល ប្រព្រឹត្តកន្លងនូវសោតាបត្តិផលហើយ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា អនាគាមិបុគ្គល ប្រកបដោយសោតាបត្តិផលទេ ។

[៤៧៧] អនាគាមី សោតាបត្តិផលំ វីតិវត្តោ តេន សមន្នាគតោតិ ។ អាមន្តា ។ អនាគាមី សោតាបត្តិមគ្គំ វីតិវត្តោ សក្កាយទិដ្ឋឹ ។ បេ ។ អបាយគមនិយំ មោហំ វីតិវត្តោ តេន សមន្នាគតោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[៤៧៨] អនាគាមី សកទាគាមិផលេន សមន្នាគតោតិ ។ អាមន្តា ។ ននុ អនាគាមី សកទាគាមិផលំ វីតិវត្តោតិ ។ អាមន្តា ។ ហញ្ចិ អនាគាមី សកទាគាមិផលំ វីតិវត្តោ នោ វត រេ វត្តព្វេ អនាគាមី សកទាគាមិផលេន សមន្នាគតោតិ ។

[៤៧៩] អនាគាមី សកទាគាមិផលំ វីតិវត្តោ តេន សមន្នាគតោតិ ។ អាមន្តា ។ អនាគាមី សកទាគាមិមគ្គំ វីតិវត្តោ ឱឡារិកំ កាមរាគំ ឱឡារិកំ ព្យាបាទំ វីតិវត្តោ តេន សមន្នាគតោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[៤៧៧] អនាគាមិបុគ្គល ប្រព្រឹត្តកន្លងនូវសោតាបត្តិផល ហើយប្រកបដោយសោតាបត្តិផលនោះឬ ។ អើ ។ អនាគាមិបុគ្គល ប្រព្រឹត្តកន្លងនូវសោតាបត្តិមគ្គ ប្រព្រឹត្តកន្លងនូវសក្កាយទិដ្ឋិ ។ បេ ។ មោហៈដែលជាដំណើរទៅកាន់អបាយ ហើយប្រកបដោយសោតាបត្តិមគ្គនោះឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[៤៧៨] អនាគាមិបុគ្គល ប្រកបដោយសកទាគាមិផលឬ ។ អើ ។ ក្រែងអនាគាមិបុគ្គល ប្រព្រឹត្តកន្លងនូវសកទាគាមិផលហើយឬ ។ អើ ។ បើអនាគាមិបុគ្គល ប្រព្រឹត្តកន្លងនូវសកទាគាមិផលហើយ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា អនាគាមិបុគ្គល ប្រកបដោយសកទាគាមិផលទេ ។

[៤៧៩] អនាគាមិបុគ្គល ប្រព្រឹត្តកន្លងនូវសកទាគាមិផល ហើយប្រកបដោយសកទាគាមិផលនោះឬ ។ អើ ។ អនាគាមិបុគ្គល ប្រព្រឹត្តកន្លងនូវសកទាគាមិមគ្គ ប្រព្រឹត្តកន្លងនូវកាមរាគៈដ៏គ្រោតគ្រាត ព្យាបាទដ៏គ្រោតគ្រាត ហើយប្រកបដោយសកទាគាមិមគ្គនោះឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

១៨៣

សមន្នាគតកថា

[៤៨០] សកទាគាមី សោតាបត្តិផលេន ស-
មន្នាគតោតិ ។ អាមន្តា ។ ននុ សកទាគាមី សោតា-
បត្តិផលំ វីតិវត្តោតិ ។ អាមន្តា ។ ហញ្ចិ សកទាគាមី
សោតាបត្តិផលំ វីតិវត្តោ នោ វត រេ វត្តព្វេ សក-
ទាគាមី សោតាបត្តិផលេន សមន្នាគតោតិ ។

[៤៨១] សកទាគាមី សោតាបត្តិផលំ វីតិវត្តោ
តេន សមន្នាគតោតិ ។ អាមន្តា ។ សកទាគាមី
សោតាបត្តិមគ្គំ វីតិវត្តោ សក្កាយទិដ្ឋឹ ។ បេ ។ អបា-
យគមនិយំ មោហំ វីតិវត្តោ តេន សមន្នាគតោតិ ។
ន ហេវំ វត្តព្វេ ។ បេ ។

[៤៨២] ន វត្តព្វំ អរហា ចតូហិ ផលេហិ
សមន្នាគតោតិ ។ អាមន្តា ។ ននុ អរហតា ចត្តារិ
ផលានិ បដិលទ្ធានិ តេហិ ច អបរិហីនោតិ ។ អា-
មន្តា ។ ហញ្ចិ អរហតា ចត្តារិ ផលានិ បដិលទ្ធានិ
តេហិ ច អបរិហីនោ តេន វត រេ វត្តព្វេ អរហា
ចតូហិ ផលេហិ សមន្នាគតោតិ ។

សមន្នាគតកថា

[៤៨០] សកទាគាមិបុគ្គល ប្រកបដោយសោតាបត្តិផលឬ ។ អើ ។ ក្រែងសកទាគាមិបុគ្គល ប្រព្រឹត្តកន្លងនូវសោតាបត្តិផលហើយឬ ។ អើ ។ បើសកទាគាមិបុគ្គល ប្រព្រឹត្តកន្លងនូវសោតាបត្តិផលហើយ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា សកទាគាមិបុគ្គលប្រកបដោយសោតាបត្តិផលទេ ។

[៤៨១] សកទាគាមិបុគ្គល ប្រព្រឹត្តកន្លងនូវសោតាបត្តិផលហើយប្រកបដោយសោតាបត្តិផលនោះឬ ។ អើ ។ សកទាគាមិបុគ្គលប្រព្រឹត្តកន្លងនូវសោតាបត្តិមគ្គ ប្រព្រឹត្តកន្លងនូវសក្កាយទិដ្ឋិ ។ បេ ។ និងមោហៈ ដែលជាដំណើរទៅកាន់អបាយ ហើយប្រកបដោយសោតាបត្តិ-មគ្គនោះឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[៤៨២] បុគ្គលមិនគួរនិយាយថា ព្រះអរហន្ត ប្រកបដោយផល ៤ ទេឬ ។ អើ ។ ក្រែងព្រះអរហន្ត បានចំពោះនូវផល ៤ ហើយមិនសាបសូន្យចាកផល ៤ នោះទេឬ ។ អើ ។ បើព្រះអរហន្ត បានចំពោះនូវផល ៤ មិនសាបសូន្យចាកផល ៤ នោះទេ ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគួរពោលថា ព្រះអរហន្ត ប្រកបដោយផល៤ដែរ ។

[៤៨៣] ន វត្តព្វំ អនាគាមី តីហិ ផលេហិ សមន្នាគតោតិ ។ អាមន្តា ។ ននុ អនាគាមិនា តីណិ ផលានិ បដិលទ្ធានិ តេហិ ច អបរិហីនោតិ ។ អាមន្តា ។ ហញ្ចិ អនាគាមិនា តីណិ ផលានិ បដិលទ្ធានិ តេហិ ច អបរិហីនោ តេន វត រេ វត្តព្វេ អនាគាមី តីហិ ផលេហិ សមន្នាគតោតិ ។

[៤៨៤] ន វត្តព្វំ សកទាគាមី ទ្វីហិ ផលេហិ សមន្នាគតោតិ ។ អាមន្តា ។ ននុ សកទាគាមិនា ទ្វេ ផលានិ បដិលទ្ធានិ តេហិ ច អបរិហីនោតិ ។ អាមន្តា ។ ហញ្ចិ សកទាគាមិនា ទ្វេ ផលានិ បដិលទ្ធានិ តេហិ ច អបរិហីនោ តេន វត រេ វត្តព្វេ សកទាគាមី ទ្វីហិ ផលេហិ សមន្នាគតោតិ ។

[៤៨៥] អរហតា ចត្តារិ ផលានិ បដិលទ្ធានិ តេហិ ច អបរិហីនោតិ ។ អរហា ចតូហិ ផលេហិ សមន្នាគតោតិ ។ អាមន្តា ។ អរហតា ចត្តារោ មគ្គា បដិលទ្ធា តេហិ ច អបរិហីនោតិ ។ អរហា ចតូហិ មគ្គេហិ សមន្នាគតោតិ ។ ន ហេវំ វត្តព្វេ ។បេ។

[៤៨៣] បុគ្គលមិនគួរនិយាយថា អនាគាមិបុគ្គល ប្រកបដោយផល ៣ ទេឬ ។ អើ ។ ក្រែងអនាគាមិបុគ្គល បានចំពោះនូវផល ៣ ហើយមិនសាបសូន្យចាកផលនោះទេឬ ។ អើ ។ បើអនាគាមិបុគ្គល បានចំពោះនូវផល ៣ ហើយមិនសាបសូន្យចាកផល ៣ នោះទេ ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគួរពោលថា អនាគាមិបុគ្គល ប្រកបដោយផល ៣ ដែរ ។

[៤៨៤] បុគ្គលមិនគួរនិយាយថា សកទាគាមិបុគ្គល ប្រកបដោយផល ២ ទេឬ ។ អើ ។ ក្រែងសកទាគាមិបុគ្គល បានចំពោះនូវផល ២ ហើយមិនសាបសូន្យចាកផល ២ នោះទេឬ ។ អើ ។ បើសកទាគាមិបុគ្គល បានចំពោះនូវផល ២ ហើយមិនសាបសូន្យចាកផល ២ នោះទេ ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគួរពោលថា សកទាគាមិបុគ្គល ប្រកបដោយផល ២ ដែរ ។

[៤៨៥] ព្រះអរហន្ត បានចំពោះនូវផល ៤ ហើយមិនសាបសូន្យចាកផល ៤ នោះទេឬ ។ ព្រះអរហន្ត ប្រកបដោយផល ៤ ឬ ។ អើ ។ ព្រះអរហន្ត បានចំពោះនូវមគ្គ ៤ ហើយមិនសាបសូន្យចាកមគ្គ ៤ នោះទេឬ ។ ព្រះអរហន្ត ប្រកបដោយមគ្គ ៤ ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[៤៨៦] អនាគាមិនា តីណិ ផលានិ បដិលទ្ធានិ តេហិ ច អបរិហីនោតិ ។ អនាគាមី តីហិ ផលេហិ សមន្នាគតោតិ ។ អាមន្តា ។ អនាគាមិនា តយោ មគ្គា បដិលទ្ធា តេហិ ច អបរិហីនោតិ ។ អនាគាមី តីហិ មគ្គេហិ សមន្នាគតោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[៤៨៧] សកទាគាមិនា ទ្វេ ផលានិ បដិលទ្ធានិ តេហិ ច អបរិហីនោតិ ។ សកទាគាមី ទ្វីហិ ផលេហិ សមន្នាគតោតិ ។ អាមន្តា ។ សកទាគាមិនា ទ្វេ មគ្គា បដិលទ្ធា តេហិ ច អបរិហីនោតិ ។ សកទាគាមី ទ្វីហិ មគ្គេហិ សមន្នាគតោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

សមន្នាគតកថា ។

# ឧបេក្ខាសមន្នាគតកថា

[៤៨៨] អរហា ឆហិ ឧបេក្ខាហិ សមន្នាគតោតិ ។ អាមន្តា ។ អរហា ឆហិ ផស្សេហិ ឆហិ វេទនាហិ ឆហិ សញ្ញាហិ ។ បេ ។ ឆហិ បញ្ញាហិ សមន្នាគតោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

សមន្នាគតកថា

[៤៨៦] *អនាគាមិបុគ្គល បានចំពោះនូវផល ៣ ហើយមិនសាបសូន្យចាកផល ៣ នោះទេឬ ។ អនាគាមិបុគ្គល ប្រកបដោយផល ៣ ឬ ។ អើ ។ អនាគាមិបុគ្គល បានចំពោះនូវមគ្គ ៣ ហើយមិនសាបសូន្យចាកមគ្គ ៣ នោះទេឬ ។ អនាគាមិបុគ្គល ប្រកបដោយមគ្គ ៣ ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។*

[៤៨៧] *សកទាគាមិបុគ្គល បានចំពោះនូវផល ២ ហើយមិនសាបសូន្យចាកផល ២ នោះទេឬ ។ សកទាគាមិបុគ្គល ប្រកបដោយផល ២ ឬ ។ អើ ។ សកទាគាមិបុគ្គល បានចំពោះនូវមគ្គ ២ ហើយមិនសាបសូន្យចាកមគ្គ ២ នោះទេឬ ។ សកទាគាមិបុគ្គល ប្រកបដោយមគ្គ ២ ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។*

ចប់ សមន្នាគតកថា ។

# ឧបេក្ខាសមន្នាគតកថា

[៤៨៨] *ព្រះអរហន្ត ប្រកបដោយឧបេក្ខា ៦ ឬ ។ អើ ។ ព្រះអរហន្ត ប្រកបដោយផស្សៈ ៦ ដោយវេទនា ៦ ដោយសញ្ញា ៦ ។ បេ ។ ដោយបញ្ញា ៦ ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។*

[៤៨៩] អរហា ធហិ ឧបេក្ខាហិ សមន្នាគតោ-តិ ។ អាមន្តា ។ អរហា ចក្ខុនា រូបំ បស្សន្តោ សោតេន សទ្ទំ សុណាតិ ឃានេន គន្ធំ ឃាយតិ ជិវ្ហាយ រសំ សាយតិ កាយេន ផោដ្ឋព្វំ ផុសតិ មនសា ធម្មំ វិជានាតិ ។ បេ ។ មនសា ធម្មំ វិជានន្តោ ចក្ខុនា រូបំ បស្សតិ សោតេន សទ្ទំ សុណាតិ ឃានេន គន្ធំ ឃាយតិ ជិវ្ហាយ រសំ សាយតិ កាយេន ផោដ្ឋព្វំ ផុសតីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[៤៩០] អរហា ធហិ ឧបេក្ខាហិ សមន្នាគតោតិ ។ អាមន្តា ។ សតតំ សមិតំ អព្វោកិណ្ណំ ធហិ ឧបេក្ខាហិ សមន្នាគតោ សមាហិតោ ធ ឧបេក្ខាយោ បច្ចុបដ្ឋិតាតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[៤៩១] ន វត្តព្វំ អរហា ធហិ ឧបេក្ខាហិ សមន្នាគតោតិ ។ អាមន្តា ។ ននុ អរហា ធឡុបេក្ខោតិ ។ អាមន្តា ។ ហញ្ចិ អរហា ធឡុបេក្ខោ តេន វត រេ វត្តព្វេ អរហា ធហិ ឧបេក្ខាហិ សមន្នាគតោតិ ។

ឧបេក្ខាសមន្នាគតកថា ។

[៤៨៩] ព្រះអរហន្ត ប្រកបដោយឧបេក្ខា ៦ ឬ ។ អើ ។ ព្រះអរហន្ត កាលឃើញរូបដោយចក្ខុ រមែងឮសំឡេងដោយត្រចៀក ធុំក្លិនដោយច្រមុះ លិទ្ធភ្លក្សរសដោយអណ្តាត ពាល់ត្រូវផ្សព្វដោយកាយ ដឹងច្បាស់នូវធម្មារម្មណ៍ដោយចិត្ត ។ បេ ។ កាលដឹងច្បាស់នូវធម្មារម្មណ៍ដោយចិត្ត រមែងឃើញរូបដោយចក្ខុ ឮសំឡេងដោយត្រ-ចៀក ធុំក្លិនដោយច្រមុះ លិទ្ធភ្លក្សរសដោយអណ្តាត ពាល់ត្រូវផ្សព្វដោយកាយឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[៤៩០] ព្រះអរហន្ត ប្រកបដោយឧបេក្ខា ៦ ឬ ។ អើ ។ (ព្រះអរហន្ត) ប្រកបដោយឧបេក្ខា ៦ មានចិត្តខ្ជាប់ខ្ជួន ទៀងទាត់ មិនរាយមាយ ចុះឧបេក្ខាទាំង ៦ តាំងឡើងប្រាកដឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[៤៩១] បុគ្គលមិនគួរនិយាយថា ព្រះអរហន្ត ប្រកបដោយឧបេក្ខា ៦ ទេឬ ។ អើ ។ ក្រែងព្រះអរហន្ត មានឧបេក្ខា ៦ ឬ ។ អើ ។ បើព្រះអរហន្ត មានឧបេក្ខា ៦ ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគួរពោលថា ព្រះអរហន្ត ប្រកបដោយឧបេក្ខា ៦ ។

ចប់ ឧបេក្ខាសមន្នាគតកថា ។

១៨៧

# ពោធិយា ពុទ្ធោតិកថា

[៤៩២] ពោជ្ឈិយា ពុជ្ឈោតិ ។ អាមន្តា ។ ពោ-
ជ្ឈិយា និរុទ្ធាយ វិគតាយ បដិប្បស្សទ្ធាយ អពុទ្ធោ
ហោតីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[៤៩៣] ពោជ្ឈិយា ពុជ្ឈោតិ ។ អាមន្តា ។ អតី-
តាយ ពោជ្ឈិយា ពុជ្ឈោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[៤៩៤] អតីតាយ ពោជ្ឈិយា ពុជ្ឈោតិ ។ អា-
មន្តា ។ តាយ ពោជ្ឈិយា ពោជ្ឈិករណីយំ ករោតីតិ ។
ន ហេវំ វត្តព្វេ ។ បេ ។

[៤៩៥] តាយ ពោជ្ឈិយា ពោជ្ឈិករណីយំ ក-
រោតីតិ ។ អាមន្តា ។ តាយ ពោជ្ឈិយា ទុក្ខំ បរិជា-
នាតិ សមុទយំ បជហាតិ និរោធំ សច្ឆិករោតិ មគ្គំ
ភាវេតីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[៤៩៦] ពោជ្ឈិយា ពុជ្ឈោតិ ។ អាមន្តា ។ អនាគ-
តាយ ពោជ្ឈិយា ពុជ្ឈោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

# ពោធិយា ពុទ្ធោតិកថា

[៤៩២] បុគ្គលជាព្រះពុទ្ធ ដោយពោធិញ្ញាណ (ចតុមគ្គញ្ញាណនិងសព្វញ្ញុតញ្ញាណឬ) ។ អើ ។ បុគ្គល កាលបើពោធិញ្ញាណ រលត់ហើយ ទៅប្រាសហើយ ស្ងប់រម្ងាប់ហើយ មិនឈ្មោះថាព្រះពុទ្ធទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[៤៩៣] បុគ្គល ជាព្រះពុទ្ធ ដោយពោធិញ្ញាណឬ ។ អើ ។ បុគ្គល ជាព្រះពុទ្ធ ដោយពោធិញ្ញាណជាអតីតឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[៤៩៤] បុគ្គល ជាព្រះពុទ្ធ ដោយពោធិញ្ញាណជាអតីតឬ ។ អើ ។ ព្រះពុទ្ធ ធ្វើនូវពោធិករណីយកិច្ច ដោយពោធិញ្ញាណនោះឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[៤៩៥] ព្រះពុទ្ធ ធ្វើនូវពោធិករណីយកិច្ច ដោយពោធិញ្ញាណនោះឬ ។ អើ ។ ព្រះពុទ្ធ កំណត់ដឹងនូវទុក្ខសច្ច លះបង់នូវសមុទយសច្ច ធ្វើឲ្យជាក់ច្បាស់នូវនិរោធសច្ច ចម្រើននូវមគ្គសច្ច ដោយពោធិញ្ញាណនោះឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[៤៩៦] បុគ្គល ជាព្រះពុទ្ធ ដោយពោធិញ្ញាណឬ ។ អើ ។ បុគ្គល ជាព្រះពុទ្ធ ដោយពោធិញ្ញាណជាអនាគតឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[៤៩៧] អនាគតាយ ពោធិយា ពុទ្ធោតិ ។ អាមន្តា ។ តាយ ពោធិយា ពោធិករណីយំ ករោតីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[៤៩៨] តាយ ពោធិយា ពោធិករណីយំ ករោតីតិ ។ អាមន្តា ។ តាយ ពោធិយា ទុក្ខំ បរិជានាតិ ។ បេ ។ មគ្គំ ភាវេតីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[៤៩៩] បច្ចុប្បន្នាយ ពោធិយា ពុទ្ធោ តាយ ពោធិយា ពោធិករណីយំ ករោតីតិ ។ អាមន្តា ។ អតីតាយ ពោធិយា ពុទ្ធោ តាយ ពោធិយា ពោធិករណីយំ ករោតីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[៥០០] បច្ចុប្បន្នាយ ពោធិយា ពុទ្ធោ តាយ ពោធិយា ទុក្ខំ បរិជានាតិ សមុទយំ បជហាតិ និរោធំ សច្ឆិករោតិ មគ្គំ ភាវេតីតិ ។ អាមន្តា ។ អតីតាយ ពោធិយា ពុទ្ធោ តាយ ពោធិយា ទុក្ខំ បរិជានាតិ ។ បេ ។ មគ្គំ ភាវេតីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[៤៩៧] បុគ្គល ជាព្រះពុទ្ធ ដោយពោធិញ្ញាណជាអនាគត ឬ ។ អើ ។ ព្រះពុទ្ធ ធ្វើនូវពោធិករណីយកិច្ច ដោយពោធិញ្ញាណនោះឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[៤៩៨] ព្រះពុទ្ធ ធ្វើនូវពោធិករណីយកិច្ច ដោយពោធិញ្ញាណនោះឬ ។ អើ ។ ព្រះពុទ្ធ កំណត់ដឹងនូវទុក្ខសច្ច ។ បេ ។ ចម្រើននូវមគ្គសច្ច ដោយពោធិញ្ញាណនោះឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[៤៩៩] បុគ្គល ជាព្រះពុទ្ធ ដោយពោធិញ្ញាណជាបច្ចុប្បន្ន ធ្វើនូវពោធិករណីយកិច្ច ដោយពោធិញ្ញាណនោះឬ ។ អើ ។ បុគ្គល ជាព្រះពុទ្ធ ដោយពោធិញ្ញាណជាអតីត ធ្វើនូវពោធិករណីយកិច្ច ដោយពោធិញ្ញាណនោះឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[៥០០] បុគ្គល ជាព្រះពុទ្ធ ដោយពោធិញ្ញាណជាបច្ចុប្បន្ន កំណត់ដឹងនូវទុក្ខសច្ច លះបង់នូវសមុទយសច្ច ធ្វើឲ្យជាក់ច្បាស់នូវនិរោធ-សច្ច ចម្រើននូវមគ្គសច្ច ដោយពោធិញ្ញាណនោះឬ ។ អើ ។ បុគ្គល ជាព្រះពុទ្ធ ដោយពោធិញ្ញាណជាអតីត កំណត់ដឹងនូវទុក្ខសច្ច ។ បេ ។ ចម្រើននូវមគ្គសច្ច ដោយពោធិញ្ញាណនោះឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

១៨៩

ពោធិយា ពុទ្ធោតិកថា

[៨០១] បច្ចុប្បន្នាយ ពោធិយា ពុទ្ធោ តាយ ពោធិយា ពោធិករណីយំ ករោតីតិ ។ អាមន្តា ។ អនាគតាយ ពោធិយា ពុទ្ធោ តាយ ពោធិយា ពោធិករណីយំ ករោតីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[៨០២] បច្ចុប្បន្នាយ ពោធិយា ពុទ្ធោ តាយ ពោធិយា ទុក្ខំ បរិជានាតិ ។ បេ ។ មគ្គំ ភាវេតីតិ ។ អាមន្តា ។ អនាគតាយ ពោធិយា ពុទ្ធោ តាយ ពោធិយា ទុក្ខំ បរិជានាតិ ។ បេ ។ មគ្គំ ភាវេតីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[៨០៣] អតីតាយ ពោធិយា ពុទ្ធោ ន ច តាយ ពោធិយា ពោធិករណីយំ ករោតីតិ ។ អាមន្តា ។ បច្ចុប្បន្នាយ ពោធិយា ពុទ្ធោ ន ច តាយ ពោធិយា ពោធិករណីយំ ករោតីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[៨០៤] អតីតាយ ពោធិយា ពុទ្ធោ ន ច តាយ ពោធិយា ទុក្ខំ បរិជានាតិ ។ បេ ។ មគ្គំ ភាវេតីតិ ។ អាមន្តា ។ បច្ចុប្បន្នាយ ពោធិយា ពុទ្ធោ ន ច តាយ ពោធិយា ទុក្ខំ បរិជានាតិ ។ បេ ។ មគ្គំ ភាវេតីតិ ។ ន ហេវំ វត្តព្វំ ។ បេ ។

ពោធិយា ពុទ្ធោតិកថា

[៥០១] បុគ្គល ជាព្រះពុទ្ធ ដោយពោធិញ្ញាណជាបច្ចុប្បន្ន ធ្វើនូវពោធិករណីយកិច្ច ដោយពោធិញ្ញាណនោះឬ ។ អើ ។ បុគ្គល ជាព្រះពុទ្ធ ដោយពោធិញ្ញាណជាអនាគត ធ្វើនូវពោធិករណីយកិច្ចដោយពោធិញ្ញាណនោះឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[៥០២] បុគ្គល ជាព្រះពុទ្ធ ដោយពោធិញ្ញាណជាបច្ចុប្បន្ន កំណត់ដឹងនូវទុក្ខសច្ច ។ បេ ។ ចម្រើននូវមគ្គសច្ច ដោយពោធិញ្ញាណនោះឬ ។ អើ ។ បុគ្គល ជាព្រះពុទ្ធ ដោយពោធិញ្ញាណជាអនាគត កំណត់ដឹងនូវទុក្ខសច្ច ។ បេ ។ ចម្រើននូវមគ្គសច្ច ដោយពោធិញ្ញាណនោះឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[៥០៣] បុគ្គល ជាព្រះពុទ្ធ ដោយពោធិញ្ញាណជាអតីត តែមិនធ្វើនូវពោធិករណីយកិច្ច ដោយពោធិញ្ញាណនោះទេឬ ។ អើ ។ បុគ្គល ជាព្រះពុទ្ធ ដោយពោធិញ្ញាណជាបច្ចុប្បន្ន តែមិនធ្វើនូវពោធិករណីយកិច្ច ដោយពោធិញ្ញាណនោះទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[៥០៤] បុគ្គល ជាព្រះពុទ្ធ ដោយពោធិញ្ញាណជាអតីត តែមិនកំណត់ដឹងនូវទុក្ខសច្ច ។ បេ ។ មិនចម្រើននូវមគ្គសច្ច ដោយពោធិញ្ញាណនោះទេឬ ។ អើ ។ បុគ្គល ជាព្រះពុទ្ធ ដោយពោធិញ្ញាណជាបច្ចុប្បន្ន តែមិនកំណត់ដឹងនូវទុក្ខសច្ច ។ បេ ។ មិនចម្រើននូវមគ្គសច្ច ដោយពោធិញ្ញាណនោះទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[៤០៥] អនាគតាយ ពោធិយា ពុទ្ធោ ន ច តាយ ពោធិយា ពោធិករណីយំ ករោតីតិ ។ អាមន្តា ។ បច្ចុប្បន្នាយ ពោធិយា ពុទ្ធោ ន ច តាយ ពោធិយា ពោធិករណីយំ ករោតីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[៤០៦] អនាគតាយ ពោធិយា ពុទ្ធោ ន ច តាយ ពោធិយា ទុក្ខំ បរិជានាតិ ។ បេ ។ មគ្គំ ភាវេតីតិ ។ អាមន្តា ។ បច្ចុប្បន្នាយ ពោធិយា ពុទ្ធោ ន ច តាយ ពោធិយា ទុក្ខំ បរិជានាតិ ។ បេ ។ មគ្គំ ភាវេតីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[៤០៧] អតីតាយ ពោធិយា ពុទ្ធោ អនាគតាយ ពោធិយា ពុទ្ធោ បច្ចុប្បន្នាយ ពោធិយា ពុទ្ធោតិ ។ អាមន្តា ។ តីហិ ពោធីហិ ពុទ្ធោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[៤០៨] តីហិ ពោធីហិ ពុទ្ធោតិ ។ អាមន្តា ។ សតតំ សមិតំ អព្វោកិណ្ណំ តីហិ ពោធីហិ សមន្នាគតោ សមាហិតោ តិស្សោ ពោធិយោ បច្ចុបដ្ឋិតាតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

[៥០៥] បុគ្គល ជាព្រះពុទ្ធ ដោយពោធិញ្ញាណជាអនាគត តែមិនធ្វើនូវពោធិករណីយកិច្ច ដោយពោធិញ្ញាណនោះទេឬ ។ អើ ។ បុគ្គល ជាព្រះពុទ្ធ ដោយពោធិញ្ញាណជាបច្ចុប្បន្ន តែមិនធ្វើនូវពោធិ-ករណីយកិច្ច ដោយពោធិញ្ញាណនោះទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[៥០៦] បុគ្គល ជាព្រះពុទ្ធ ដោយពោធិញ្ញាណជាអនាគត តែមិនកំណត់ដឹងនូវទុក្ខសច្ច ។ បេ ។ មិនចម្រើននូវមគ្គសច្ច ដោយពោ-ធិញ្ញាណនោះទេឬ ។ អើ ។ បុគ្គល ជាព្រះពុទ្ធ ដោយពោធិញ្ញាណជាបច្ចុប្បន្ន តែមិនកំណត់ដឹងនូវទុក្ខសច្ច ។ បេ ។ មិនចម្រើននូវមគ្គសច្ច ដោយពោធិញ្ញាណនោះទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[៥០៧] បុគ្គល ជាព្រះពុទ្ធ ដោយពោធិញ្ញាណជាអតីត ជាព្រះពុទ្ធ ដោយពោធិញ្ញាណជាអនាគត ជាព្រះពុទ្ធ ដោយពោធិញ្ញាណជាបច្ចុប្បន្នឬ ។ អើ ។ បុគ្គល ជាព្រះពុទ្ធ ដោយពោធិញ្ញាណ ៣ ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[៥០៨] បុគ្គលជាព្រះពុទ្ធ ដោយពោធិញ្ញាណ ៣ ឬ ។ អើ ។ បុគ្គល ជាព្រះពុទ្ធ ប្រកបដោយពោធិញ្ញាណទាំង ៣ មានចិត្តខ្ជាប់ខ្ជួនទៀងទាត់ មិនរាយមាយ ចុះពោធិញ្ញាណទាំង ៣ តាំងនៅប្រាកដឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

[៤០៩] ន វត្តព្វំ ពោធិយា ពុទ្ធោតិ ។ អាមន្តា ។ ននុ ពោធិប្បដិលាភា ពុទ្ធោតិ ។ អាមន្តា ។ ហញ្ចិ ពោធិប្បដិលាភា ពុទ្ធោ តេន វត រេ វត្តព្វេ ពោធិយា ពុទ្ធោតិ ។

[៤១០] ពោធិប្បដិលាភា ពុទ្ធោតិ ។ ពោធិយា ពុទ្ធោតិ ។ អាមន្តា ។ ពោធិប្បដិលាភា ពោធីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

ពោធិយា ពុទ្ធោតិកថា ។

# លក្ខណកថា

[៤១១] លក្ខណសមន្នាគតោ ពោធិសត្តោតិ ។ អាមន្តា ។ បទេសលក្ខណេហិ សមន្នាគតោ បទេសពោធិសត្តោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

